ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

របាយការណ៍ស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការនៅកម្ពុជា ឆ្នាំ២០០៨

រៀបចំដោយ

គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

សម្រាប់វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី២

ថ្ងៃទី០៤-០៥ ខែធ្នូ ឆ្នាំ២០០៨

ខែវិច្ឆិកា ឆ្នាំ២០០៨

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

របាយការណ៍ស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការនៅកម្ពុជា ឆ្នាំ២០០៨

រៀបចំដោយ

គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

សម្រាប់វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី២

ថ្ងៃទី០៤-០៥ ខែធ្នូ ឆ្នាំ២០០៨

ខែវិច្ឆិកា ឆ្នាំ២០០៨

សេចក្តីថ្លែងអំណរគុណ

ប្រភពព័ត៌មានសំខាន់សម្រាប់រៀបចំរបាយការណ៍ស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការនេះ គឺជាព័ត៌មាននៃរបាយការណ៍ ដែលក្រុមការងារបច្ចេកទេសចម្រុះបានផ្តល់ឱ្យគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ។ រាជរដ្ឋាភិបាលសូមថ្លែងអំណរគុណចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ប្រធានក្រុមការងារបច្ចេកទេសចម្រុះទាំងអស់ មន្ត្រីបង្គោលរបស់ក្រុមការងារ និងប្រធានសម្របសម្រួលរបស់ដៃគូអភិវឌ្ឍន៍ ហើយសង្ឃឹមថា របាយការណ៍នេះនឹងផ្តល់សារៈប្រយោជន៍សម្រាប់កិច្ចការរបស់យើងទាំងអស់គ្នា នាពេលអនាគត ។

ទន្ទឹមនេះដែរ រាជរដ្ឋាភិបាលក៏ថ្លែងអំណរគុណចំពោះដៃគូអភិវឌ្ឍន៍ទាំងអស់ ដែលបានបញ្ចូលទិន្នន័យស្តីពីគម្រោងនិងកម្មវិធីរបស់ខ្លួន ទៅក្នុងប្រព័ន្ធទិន្នន័យកម្ពុជា ។ ប្រសិនបើគ្មានការអំណត់ និងកិច្ចសហការល្អពីសំណាក់ដៃគូអភិវឌ្ឍន៍ទេនោះ រាជរដ្ឋាភិបាលនឹងជួបការលំបាកក្នុងការវិភាគព័ត៌មានស្តីពីបរិមាណធនធានទាំងឡាយរបស់ដៃគូអភិវឌ្ឍន៍ជាមិនខាន ។

របបគំហើញក្នុងរបាយការណ៍នេះបានផ្អែកលើសក្ខីភាពជាក់ស្តែង ដែលគណៈកម្មាធិការនិតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាប្រមូលបានសម្រាប់ធ្វើការវិភាគ ។ នៅក្នុងគ្រប់ករណីទាំងអស់ គណៈកម្មាធិការនិតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានធ្វើសុពលភាពទិន្នន័យទាំងឡាយជាមួយនឹងដៃគូអភិវឌ្ឍន៍ទាំងអស់ មុននឹងធ្វើការវិភាគលើទិន្នន័យទាំងនេះ ។

មាតិការឿង

អារម្ភកថា

ខ្លឹមសារសង្ខេបប្រតិបត្តិ .... i-vii

ជំពូក ១ - សេចក្តីផ្តើម 1

ភាពជាម្ចាស់មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងកិច្ចអភិវឌ្ឍន៍ដោយផ្តោតលើលទ្ធផល 1

គោលដៅចំបងនៃរបាយការណ៍ស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហត្រិបត្តិការឆ្នាំ២០០៨ 3

សារគន្លឹះ 4

ជំពូក ២ - ស្ថានភាពទូទៅនៃភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍន៍ ឆ្នាំ២០០៧-២០០៨ 6

តម្រូវការសម្រាប់ពន្លឿនការអនុវត្តន៍ 6

ការពង្រឹងក្របខ័ណ្ឌខាងស្ថាប័នដោយផ្តោតលើភាពជាដៃគូ 7

ការបំពាក់មធ្យោបាយជាមូលដ្ឋានដល់ក្រុមការងារបច្ចេកទេសចម្រុះ 7

ការអភិវឌ្ឍន៍សមត្ថភាព- មូលដ្ឋានគ្រឹះសម្រាប់ភាពជាដៃគូប្រកបដោយប្រសិទ្ធភាព 8

ភាពជាដៃគូសកល និងគំនិតផ្តួចផ្តើមស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ 10

ការត្រិះរិះពិចារណាអំពីភាពជាដៃគូ ដោយផ្អែកលើការវាយតំលៃប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ 12

សេចក្តីសន្និដ្ឋាន 13

ជំពូក ៣ - និន្នាការនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ 15

យុទ្ធសាស្រ្តចតុកោណ- ដំណាក់កាលទី២ 15

ការត្រួតពិនិត្យពាក់កណ្តាលអាណត្តិនៃការអនុវត្តន៍ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ 15

និន្នាការសរុបនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ 17

និន្នាការរយៈពេលវែងនៃហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ 21

និន្នាការនៃការផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការតាមវិស័យ 22

ការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការនៅតាមខេត្ត- ក្រុង 24

ការគាំទ្ររបស់អង្គការក្រៅរដ្ឋាភិបាលក្នុងកិច្ចអភិវឌ្ឍន៍ប្រទេស 25

ការពិនិត្យសក្ខីភាពជាក់ស្តែងនៃការអនុវត្តន៍ផែនការសកម្មភាពស្តីពីសុខដុមនីយកម្ម ការតម្រឹម និង លទ្ធផល ឆ្នាំ២០០៧-២០០៨ 26

ភាពជាម្ចាស់ 27

ការតម្រឹម 29

ទម្រង់ការនានានៃហិរញ្ញប្បទានសហប្រតិបត្តិការ 33

ភាពអាចទស្សន៍ទាយជាមុន 35

សុខដុមនីយកម្ម និងភាពជាដៃគូ 37

ការគ្រប់គ្រងដោយផ្តោតលើលទ្ធផល 42

គណនេយ្យភាពទ្វេទិស 43

ផែនការសកម្មភាពស្តីពីសុខដុមនីយកម្ម ការតម្រឹម និងលទ្ធផល- ក្របខ័ណ្ឌការងារសម្រាប់ប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ.......... 44

ជំពូក ៤ - ការអនុវត្តន៍សូចនាករតាមដានរួមគ្នា.......... 47

គោលការណ៍នៃសូចនាករតាមដានរួមគ្នា.......... 47
វឌ្ឍនភាពក្នុងការអនុវត្តន៍.......... 47
អាទិភាពក្នុងវិស័យសង្គមកិច្ច.......... 48
អាទិភាពក្នុងវិស័យសេដ្ឋកិច្ច.......... 48
អាទិភាពក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ.......... 50
វិស័យអភិបាលកិច្ច និងអាទិភាពពហុវិស័យ អាទិភាពក្នុងវិស័យសង្គមកិច្ច.......... 50
សង្ខេបអំពីវឌ្ឍនភាពក្នុងការអនុវត្តន៍សូចនាករតាមដានរួមគ្នា.......... 51

ជំពូក ៥ - ទិសដៅកម្រិតគោលនយោបាយក្នុងការគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ.......... 54

អនុសាសន៍កម្រិតគោលនយោបាយចំពោះរាជរដ្ឋាភិបាល..........55
អនុសាសន៍កម្រិតគោលនយោបាយសម្រាប់ដៃគូអភិវឌ្ឍន៍..........58
ភារកិច្ចទទួលខុសត្រូវរួមគ្នា និងគណនេយ្យភាពទ្វេទិស..........59
ការរួមគ្នាត្រួតពិនិត្យការអនុវត្តន៍គោលនយោបាយ.......... 61

ជំពូក ៦ - សន្និដ្ឋាន.......... 63

បញ្ជីតារាង

តារាងទី១: ធនធានសរុបឆ្នាំ២០០៣-២០០៨ 2
តារាងទី២: សូចនាករសម្រាប់តាមដានការអនុវត្តន៍សេចក្តីថ្លែងការណ៍ទីក្រុងប៉ារីសនៅកម្ពុជា 11
តារាងទី៣: ការបែងចែកធនធានក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០០៦-២០១០ 16
តារាងទី៤: ការព្យាករណ៍និងការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការរបស់ដៃគូអភិវឌ្ឍន៍២០០២-២០១០ 19
តារាងទី៥: ការផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការនៅតាមវិស័យ ២០០៦-២០០៧ 23
តារាងទី៦: ការគាំទ្រតាមខេត្ត-ក្រុង 24
តារាងទី៧: ការគាំទ្រតាមវិស័យរបស់អង្គការក្រៅរដ្ឋាភិបាល ឆ្នាំ២០០៦ - ២០០៧ 25
តារាងទី៨: ការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការតាមដៃគូអភិវឌ្ឍន៍និងតាមប្រភេទហិរញ្ញប្បទាន 34
តារាងទី៩: ភាពអាចទស្សន៍ទាយជាមុននៃហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ឆ្នាំ ២០០៧-២០០៨ 36
តារាងទី១០: ទម្រង់ការនៃភាពជាដៃគូ ឆ្នាំ២០០៧ 38
តារាងទី១១: សង្ខេបអំពីវឌ្ឍនភាពនៃការអនុវត្តន៍សូចនាករតាមដានរួមគ្នា.......... 51
តារាងទី១២: ការបែងចែកការគាំទ្រហិរញ្ញប្បទានសហប្រតិបត្តិការផ្តល់ដោយដៃគូអភិវឌ្ឍន៍ធំៗ ៥ ទៅលើវិស័យធំៗ ១០ ក្នុងឆ្នាំ២០០៧ 57

រូបភាព

រូបភាពទី១: ការប្រើប្រាស់ និងការប៉ាន់ស្មានហិរញ្ញប្បទានសហប្រតិបត្តិការឆ្នាំ២០០១-២០១០ 17
រូបភាពទី២: ការប្រែប្រួលប្រចាំឆ្នាំនៃការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការឆ្នាំ២០០៦-២០០៧ 20
រូបភាពទី៣: ហិរញ្ញប្បទានសហប្រតិបត្តិការបែងចែកតាមវិស័យ ឆ្នាំ២០០៦-២០០៧ 22
រូបភាពទី៤: ការគាំទ្រតាមខេត្ត-ក្រុង 24
រូបភាពទី៥ : ការតម្រឹមកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ទៅនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦ 31
រូបភាពទី៦ : ការតម្រឹមកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ទៅនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០០៧ 32
រូបភាពទី៧ : ការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការតាមប្រភេទឆ្នាំ២០០២-២០០៨ 33
រូបភាពទី៨ : ភាពបែកខ្ញែកនៃហិរញ្ញប្បទានសហប្រតិបត្តិការ ឆ្នាំ២០០៧ 39

ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី ១ : សុក្រិត្យភាពនៃទិន្នន័យ
ឧបសម្ព័ន្ធទី ២ : តារាងទិន្នន័យបន្ថែម
ឧបសម្ព័នទី ៣ : ចំណាត់ថ្នាក់តាមវិស័យ និងអនុវិស័យ
ឧបសម្ព័ន្ធទី ៤ : ស្ថានភាពនៃការអនុវត្តន៍សូចនាករតាមដានរួមគ្នា
ឧបសម្ព័ន្ធទី ៥ : វាក្យស័ព្ទប្រើប្រាស់ក្នុងការគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍

អារម្ភកថា

គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (ក.អ.ក/គ.ជ.នា) បានរៀបចំបាយការណ៍ស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការឆ្នាំ២០០៨ សម្រាប់ **វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី២** ។ ផ្អែកលើរបាយការណ៍លើកទី១ ស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ ដែលបានរៀបចំសម្រាប់វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី១ នាខែមិថុនា ឆ្នាំ២០០៧ របាយការណ៍លើកទី២នេះបានផ្តល់ធាតុចូលបន្ថែមទៀត សម្រាប់ជម្រុញអនុវត្ត «**យុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាពនៅកម្ពុជា-ដំណាក់កាលទី២**» ដែល **សម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានប្រកាសនៅក្នុងកិច្ចប្រជុំលើកទី១នៃគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី២៦ ខែកញ្ញាកន្លងមក និង «**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ**» តាមរយៈការរំលេចឱ្យឃើញនូវស្ថានភាពនៃភាពជាដៃគូរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ និងតួនាទីនៃហិរញ្ញប្បទានសហប្រតិបត្តិការ ក្នុងការគាំទ្រដល់កិច្ចប្រឹងប្រែងរួមសម្រាប់ជម្រុញកិច្ចអភិវឌ្ឍន៍ប្រទេស ។

របាយការណ៍នេះត្រូវបានរៀបចំស្របពេលនឹងបរិការណ៍ប្រែប្រួលរបស់សកលលោកផងដែរ ។ ការថយចុះនៃហិរញ្ញប្បទានអភិវឌ្ឍន៍ផ្លូវការឆ្នាំ២០០៧ និងការប្តេជ្ញាបង្កើនហិរញ្ញប្បទានសម្រាប់គាំទ្រដល់ការអនុវត្តន៍គោលដៅសហសវត្សរ៍ និងគោលដៅផ្តល់ហិរញ្ញប្បទានអភិវឌ្ឍន៍ផ្លូវការ ឱ្យបាន ០,៧ភាគរយនៃចំណូលជាតិសរុប តម្រូវឱ្យយកចិត្តទុកដាក់ទៅលើគុណភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ ទោះបីជាមិនទាន់មានភាពច្បាស់លាស់អំពីបរិមាណរបស់វាក៏ដោយ ។ នេះជាសារឯកភាពគ្នារបស់កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីនៅក្នុងវេទិកាកំពូល នាខែកញ្ញា ឆ្នាំ២០០៨ ស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ ។ ការព្រួយបារម្ភអំពីសន្តិសុខស្បៀងនិងការថយចុះខាងសេដ្ឋកិច្ច បានក្រើនរំលឹកយើងទាំងអស់គ្នា អំពីកាតព្វកិច្ចនៃការប្រើប្រាស់ធនធានទាំងអស់ ទាំងធនធានក្នុងស្រុក ទាំងធនធានក្រៅប្រទេស ប្រកបដោយការប្រុងប្រយ័ត្ន និងមានគណនេយ្យភាព ។

ផ្អែកលើបញ្ហាប្រឈមទាំងនេះ និងស្ថិតក្នុងបរិការណ៍នៃអាណត្តិរបស់រាជរដ្ឋាភិបាលនីតិកាលទី៤នៃរដ្ឋសភា ខ្ញុំសូមបញ្ជាក់ថា របាយការណ៍ស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការឆ្នាំ២០០៨ បានធ្វើការវិភាគ ដោយផ្តោតជាសំខាន់ទៅពេលអនាគត ។ របាយការណ៍លើកនេះមានគុណភាពខ្ពស់ជាងរបាយការណ៍ឆ្នាំ២០០៧ ពីព្រោះបានរៀបចំដោយផ្អែកតាមអភិក្រមនៃសក្ខីភាពជាក់ស្តែងសម្រាប់គ្រប់គ្រងកិច្ចអភិវឌ្ឍន៍ ។ លើសពីនេះ ការវិភាគក្នុងរបាយការណ៍ស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការឆ្នាំ២០០៨នេះ ក៏បានប្រើប្រាស់ព័ត៌មានប្រាកដប្រជា និងសក្ខីភាពជាច្រើនទៀត ក្នុងនោះ ក៏មានរបាយការណ៍ពាក់កណ្តាលអាណត្តិនៃការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងការវាយតម្លៃនូវប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការនៅកម្ពុជា និងផ្អែកលើអភិក្រមសហការគ្នា ដែលបានប្រើជាព័ត៌មានវិភាគ សម្រាប់អនុវត្តក្នុងអំឡុងពេលចាប់ពីវេទិកាសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី១ នាខែមិថុនា ឆ្នាំ២០០៧ ។

ប្រការសំខាន់ជាងនេះគឺ របាយការណ៍ស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការនេះអាចផ្សព្វផ្សាយបានជាសាធារណៈ ហើយខ្ញុំមានជំនឿជឿជាក់ថា របាយការណ៍នេះនឹងអាចជម្រុញឱ្យមានការពិភាក្សា ទាំងនៅក្នុងប្រទេស ទាំងនៅលើឆាកអន្តរជាតិ ។ ស្ថិតក្នុងស្មារតីនេះ របាយការណ៍មិនត្រឹមតែពិនិត្យ និងឆ្លុះបញ្ចាំងអំពីទិដ្ឋភាពខាងបច្ចេកទេសនៃ «ទំនាក់ទំនងរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍» ប៉ុណ្ណោះទេ ប៉ុន្តែ របាយការណ៍នេះក៏ជម្រុញឱ្យពិនិត្យឡើងវិញ អំពីការអនុវត្តន៍ការប្តេជ្ញា និងការសន្យារវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ក៏ដូចជាភាគីពាក់ព័ន្ធដទៃទៀត ដែលតំណាងឱ្យរាជរដ្ឋាភិបាល ឬតំណាងឱ្យដៃគូអភិវឌ្ឍន៍ ។

ខ្ញុំឆ្លៀតឱកាសនេះ ដើម្បីសំដែងនូវការសរសើរដ៏ស្មោះស្ម័គ្រចំពោះកិច្ចប្រឹងប្រែងរបស់ឯកឧត្តម **ឈឿង យ៉ាណារ៉ា** អគ្គលេខាធិការ ក.អ.ក/គ.ជ.នា និងជាអគ្គលេខាធិការនៃវេទិកាសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា ព្រមទាំងសហការី ដែលបានរៀបចំរបាយការណ៍ស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការដ៏សំខាន់នេះ ។ ដោយទទួលស្គាល់អំពីគុណភាពនៃខ្លឹមសារ និងការវិភាគរបស់របាយការណ៍នេះ ខ្ញុំសូមថ្លែងអំណរគុណ ចំពោះសហការីនៅក្នុងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ដែលបានចូលរួមក្នុងកិច្ចការនានាជាមួយនឹង ក.អ.ក/គ.ជ.នា សម្រាប់រៀបចំរបាយការណ៍នេះ ។

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

គាត ឈន់

ខ្លឹមសារសង្ខេបប្រតិបត្តិ

បុព្វកថានៃរបាយការណ៍នេះបានគូសបញ្ជាក់ថា ប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍មិនមែន សំដៅត្រឹមការកែលំអអភិក្រមការងារផែនកានីយកម្មនិងថវិកានីយកម្ម ការអនុវត្តន៍សកម្មភាពនិងលទ្ធផលដែលសម្រេច បានក្នុងការគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ ឬតម្រូវការ នៃការសិក្សាស្រាវជ្រាវបន្ថែមទៀតប៉ុណ្ណោះទេ ។ ប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ គឺជា គណនេយ្យភាពទ្វេទិសរវាងភាគីពាក់ព័ន្ធ និងគណនេយ្យភាព ចំពោះសហគមន៍ទាំងមូល សម្រាប់ឈានទៅ សម្រេចកិច្ចអភិវឌ្ឍន៍ដោយផ្តោតលើលទ្ធផល ។ ក្នុងន័យនេះ របាយការណ៍ ស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការឆ្នាំ២០០៨ នឹងប្រមូលផ្តុំនូវសក្ខីភាពជាក់ស្តែងពីប្រភពនានានៅថ្នាក់ជាតិសម្រាប់ពិនិត្យវឌ្ឍនភាពនៃការអនុវត្តន៍ការប្តេជ្ញាក្នុងការលើកកំពស់ប្រសិទ្ធភាពនៃទម្រង់ការភាពជាដៃគូ ។ ការប្តេជ្ញាទាំងនេះដែលត្រូវបានបញ្ជាក់ច្បាស់ក្នុងសេចក្តីថ្លែងការណ៍កម្ពុជាស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ អភិវឌ្ឍន៍នាឆ្នាំ២០០៦ ត្រូវបានរំលេចឱ្យចេញជាសកម្មភាពអាទិភាពនៅក្នុងផែនការសកម្មភាពស្តីពីសុខដុមនីយកម្ម ការតម្រឹម និងលទ្ធផល ។

របាយការណ៍ស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការឆ្នាំ២០០៨ ក៏បានប្រើប្រាស់ការវិភាគកម្រិតសកល ដែលផ្តល់ការត្រិះរិះពិចារណាមួយស្តីពីវឌ្ឍនភាពនៃការអនុវត្តន៍ពាក់កណ្តាលអាណត្តិនូវសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស ស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ សម្រាប់វេទិកាកំពូលនៅទីក្រុងអាក្រា កាលពីខែកញ្ញា ឆ្នាំ២០០៨ និង ដែលជាមូលដ្ឋាននៃការរៀបចំ «ផែនការសកម្មភាពទីក្រុងអាក្រា» ។ សក្ខីភាពជាក់ស្តែង ទាំងខាងបរិមាណ ទាំងខាង គុណភាព បានក្លាយជាមូលដ្ឋានដើម្បីរៀបចំអនុសាសន៍កម្រិតគោលនយោបាយមួយចំនួន សម្រាប់ពិភាក្សានៅវេទិកា សម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី២ ដែលនឹងប្រារព្ធធ្វើនៅខែធ្នូ ឆ្នាំ២០០៨នេះ ។ អនុសាសន៍ដែលបាន ស្នើឡើងបានផ្អែកលើសារចម្បងទាំង៥ ដែលជាលទ្ធផលនៃការវិភាគក្នុងរបាយការណ៍នេះ គឺ៖

១- សក្ខីភាពនៃដំណើរការមួយដែលមានភាពនឿយណាយ និងអូសបន្លាយ ហើយតម្រូវឱ្យមានកិច្ចអន្តរាគមន៍ កម្រិតនយោបាយ ។

២- ភាពចាំបាច់ក្នុងការផ្តោតការយកចិត្តទុកដាក់លើការធ្វើឱ្យសាមញ្ញ នូវគំនិតផ្តួចផ្តើមនៃការលើកកំពស់ប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ ការធ្វើអាទិភាវូបនីយកម្ម និងការធ្វើឱ្យគំនិតផ្តួចផ្តើមទាំងនេះ បានចាក់គ្រឹះរឹងមាំ និងជាក់ស្តែងសម្រាប់បង្កើនប្រសិទ្ធភាពនៃហិរញ្ញប្បទាន ។

៣- ការប្រឹងប្រែងជម្រុញឱ្យមានវឌ្ឍនភាពក្នុងការអនុវត្តន៍ត្រូវពឹងអាស្រ័យលើប្រសិទ្ធភាពនៃជវភាពរបស់ភាព ជាដៃគូ ។

៤- ភាពចាំបាច់តម្រូវឱ្យមានការចូលរួមទូលំទូលាយបន្ថែមទៀត ប៉ុន្តែ ទាមទារឱ្យមានសមត្ថភាព និងជំនាញ សមស្រប ។

៥- ការអភិវឌ្ឍន៍សមត្ថភាពបានក្លាយជាអាទិភាពចម្បងនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ។

សារទាំងនេះគឺជាមូលដ្ឋាននៃអនុសាសន៍សម្រាប់ទាំងខាងរាជរដ្ឋាភិបាល ទាំងខាងដៃគូអភិវឌ្ឍន៍ ដែលបាន បញ្ជាក់អំពីភាពចាំបាច់ក្នុងការកំណត់ចង្អៀមការងារអាទិភាពដែលសមល្មម និងអាចសម្រេចបាន ដោយផ្អែកលើបណ្តា អាទិភាពដែលមានក្នុងផែនការសកម្មភាពស្តីពីសុខដុមនីយកម្ម ការតម្រឹម និងលទ្ធផល ដើម្បីរំលេចកិច្ចប្រឹងប្រែង ទាំងនេះទៅក្នុងដំណើរការកំណែទម្រង់នៅកម្រិតថ្នាក់ជាតិ និងកម្រិតវិស័យ ។ ទន្ទឹមនេះ ក៏ត្រូវអភិវឌ្ឍសមត្ថភាព សម្រាប់រៀបចំលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីចូលរួមពិភាក្សាកិច្ចសហប្រតិបត្តិការ អភិវឌ្ឍន៍ ក្នុងស្មារតីនៃភាពជាដៃគូ ។ អនុសាសន៍ចុងក្រោយនៃរបាយការណ៍បានបញ្ជាក់ថា រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ គួរចាប់ផ្តើមរៀបចំដំណើរការ មួយ ដែលផ្តល់លទ្ធភាពឱ្យវិស័យនិមួយៗ ក្រសួងនិងដៃគូអភិវឌ្ឍន៍ អាចកំណត់សកម្មភាពអាទិភាពដោយផ្អែកលើ មូលដ្ឋានជាក់ស្តែង ហើយចាប់ផ្តើមអនុវត្តសកម្មភាពអាទិភាព ទាំងនេះ ព្រមទាំងត្រួតពិនិត្យរួមគ្នា តាមរយៈការរៀបចំ សូចនាករតាមដានរួមគ្នាខាងក្រោម ÷

ផ្អែកតាម «**យុទ្ធសាស្ត្រចតុកោណ - ដំណាក់កាលទី២**» ការត្រួតពិនិត្យពាក់កណ្តាលអាណត្តិនៃការ អនុវត្តន៍ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ផែនការសកម្មភាពស្តីពីសុខដុមនីយកម្ម ការតម្រឹម និងលទ្ធផល សេចក្តី ថ្លែងការណ៍កម្ពុជាស្តីពីការបង្កើនប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ ការវាយតម្លៃប្រសិទ្ធភាពនៃ ហិរញ្ញប្បទានសហប្រតិបត្តិការ ដែលរួមមានការស្វ័យវាយតម្លៃ និងរបាយការណ៍ត្រួតពិនិត្យឯករាជ្យ អនុសាសន៍ក្នុងរបាយការណ៍ស្តីពីការបង្កើនប្រសិទ្ធភាពនៃហិរញ្ញប្បទាន សហប្រតិបត្តិការឆ្នាំ២០០៨ និងការ ពិភាក្សាក្នុងវេទិកាសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា ព្រមទាំងផែនការសកម្មភាពទីក្រុងអាក្រា រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ បានសន្យារួមគ្នាដូចតទៅ ÷

ក- រាជរដ្ឋាភិបាលនឹងពិភាក្សាផ្ទៃក្នុង កម្រិតខ្ពស់ ដើម្បីកំណត់សកម្មភាពជាក់ស្តែង ដែលអាចសម្រេចបាន និងអាចត្រួតពិនិត្យបាន ទាំងនៅកម្រិតជាតិ ទាំងនៅកម្រិតវិស័យ ដើម្បីជម្រុញឱ្យមានវឌ្ឍនភាពក្នុងការ អនុវត្តន៍អាទិភាព និងការប្តេជ្ញាបង្កើនប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ ។

ខ- ដៃគូអភិវឌ្ឍន៍ត្រូវពិភាក្សាផ្ទៃក្នុង និងត្រូវពិភាក្សាជាមួយនឹងទីស្នាក់ការកណ្តាលរៀងៗខ្លួន (ឈរលើស្មារតីនៃវេទិកាកំពូលស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ)
និងជាមួយដៃគូអភិវឌ្ឍន៍ផ្សេង ទៀត ដើម្បីកំណត់សកម្មភាពជាក់ស្តែងដែលអាចសម្រេចបាន និងអាចត្រួតពិនិត្យបាន ដើម្បីជម្រុញឱ្យ មានវឌ្ឍនភាពក្នុងការអនុវត្តន៍អាទិភាព និងការប្តេជ្ញាស្តីពីការបង្កើនប្រសិទ្ធភាពនៃហិរញ្ញប្បទានសហ- ប្រតិបត្តិការ ។

គ- រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ត្រូវចូលប្រជុំរួមគ្នានាត្រីមាសទី១ឆ្នាំ២០០៩ ដើម្បីពិភាក្សានិងកំណត់សកម្មភាពមួយចំនួនសម្រាប់អនុវត្ត ។ សកម្មភាពជាក់ស្តែងទាំងនេះត្រូវមានភាពជាក់ស្តែង និងអាចតាមដានបាន ដោយផ្អែកតាមផែនការសកម្មភាពស្តីពីសុខដុមនីយកម្ម ការតម្រឹម និងលទ្ធផល ព្រមទាំង ការប្តេជ្ញានានាដែលបានឯកភាពក្នុងសេចក្តីថ្លែងការណ៍កម្ពុជា ។

គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (គ.ជ.ទា/ក.អ.ក) ក្នុងតួនាទី ជាចំណុចប្រមូលផ្តុំរបស់រាជរដ្ឋាភិបាល នឹងសម្របសម្រួលដំណើរការនេះ ដោយសហការជាមួយនឹងក្រុម ការងារបច្ចេកទេសចម្រុះស្តីពីភាពជាដៃគូនិងសុខដុមនីយកម្ម ។ សកម្មភាពអាទិភាព ដែលបានឯកភាពគ្នានេះ ត្រូវលើកបង្ហាញក្នុងកិច្ចប្រជុំនៃគណៈកម្មាធិការសម្របសម្រួលរវាង

រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ហើយ សកម្មភាពដែលបានឯកភាពទាំងនេះ នឹងត្រូវបញ្ចូលទៅក្នុងតារាងសូចនាករសម្រាប់តាមដានរួមគ្នាឆ្នាំ២០០៩- ២០១០ ដោយចាត់ទុកសកម្មភាពទាំងនេះ គឺជាការប្តេជ្ញារួមគ្នាសម្រាប់អនុវត្តផែនការសកម្មភាពស្តីពីសុខដុម- នីយកម្ម ការតម្រឹម និងលទ្ធផល និងការប្តេជ្ញាដែលបានចែងក្នុងសេចក្តីថ្លែងការណ៍កម្ពុជាស្តីពីការបង្កើន ប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ ។

សកម្មភាពសំខាន់ៗមួយចំនួន សម្រាប់លើកកំពស់ប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ និងសម្រាប់ ជម្រុញឱ្យដំណើរការនេះបានជឿនលឿនទៅមុខ ត្រូវបានអនុវត្តបន្ទាប់ពីកិច្ចប្រជុំនៃវេទិកាសម្រាប់កិច្ចសហប្រតិបត្តិការ អភិវឌ្ឍន៍កម្ពុជាលើកទី១ ។ កិច្ចការចម្បងៗទាំងនោះរួមមាន ÷ ការធ្វើអង្កេតលើកទី២ ស្តីពីការតាមដានការអនុវត្តន៍ សេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស ។ លទ្ធផលនៃការធ្វើអង្កេតបានបង្ហាញអំពីការរីកចម្រើនអំពីសមត្ថភាព ទាំងខាងរាជ រដ្ឋាភិបាល ទាំងខាងដៃគូអភិវឌ្ឍន៍ ក្នុងការប្រមូលនិងវិភាគព័ត៌មានដែលពាក់ព័ន្ធនឹងការផ្តល់ហិរញ្ញប្បទាន និងការ ប្រើប្រាស់ប្រព័ន្ធទិន្នន័យស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការនៅកម្ពុជា សម្រាប់គាំទ្រដល់ដំណើរការផែនកានីយកម្ម និង ថវិកានីយកម្ម ។ លទ្ធផលនៃការធ្វើអង្កេតក៏បានបង្ហាញបន្ថែមទៀត អំពីវឌ្ឍនភាពមានកម្រិតស្តីពីការប្រើប្រាស់ ប្រព័ន្ធជាតិ និងប្រព័ន្ធព័ត៌មានជាតិ សម្រាប់ជាមូលដ្ឋានក្នុងការផ្តល់ការគាំទ្រតាមអភិក្រមគ្រប់គ្រងតាមកម្មវិធី និង ការផ្សារភ្ជាប់ផែនការនិងថវិកាទៅនឹងប្រព័ន្ធតាមដានដោយផ្តោតលើលទ្ធផល ។ ជារួម លទ្ធផលដែលទទួលបានពីការ ធ្វើអង្កេតនេះបានឆ្លុះបញ្ចាំងអំពីភាពចាំបាច់ដែលត្រូវប្រឹងប្រែងបន្ថែមទៀត សម្រាប់បង្កើនល្បឿននៃវឌ្ឍនភាព ។

លើសពីនេះ ក៏បានសិក្សាអំពីការប្រើប្រាស់កិច្ចសហប្រតិបត្តិការបច្ចេកទេសនៅកម្ពុជា និងគណនេយ្យភាពទ្វេទិសក្នុងកម្រិតអនុតំបន់ ព្រមទាំងវាយតម្លៃពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការនៅកម្ពុជាផងដែរ ។ ការ សិក្សាវិភាគទាំងនេះបានគូសបញ្ជាក់ពីភាពចាំបាច់នៃការបង្កើតភាពជាដៃគូ ដែលផ្អែកលើការយោគយល់គ្នាទៅវិញ ទៅមក និងផែនការសកម្មភាពរួមគ្នា ដើម្បីធានាឱ្យបានជាអតិបរមានូវប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ។ ការផ្តួចផ្តើមឱ្យមានការបណ្តុះបណ្តាល ជាអាទិ៍ ការបណ្តុះបណ្តាលដល់មន្ត្រីរបស់រាជរដ្ឋាភិបាលអំពីបច្ចេកទេសដែល ពាក់ព័ន្ធនឹងប្រធានបទប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ និងការបង្ហាញពីការរៀបចំខាងស្ថាប័នគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ជូនដល់ដៃគូអភិវឌ្ឍន៍ សុទ្ធតែជាកិច្ចប្រឹងប្រែងនៃការអភិវឌ្ឍន៍សមត្ថភាព ការពង្រឹងភាពជា ម្ចាស់ និងការជម្រុញឱ្យមានប្រសិទ្ធភាពនូវជវភាពនៃភាពជាដៃគូ ។

តាមទិន្នន័យស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា ធនធានដែលដៃគូអភិវឌ្ឍន៍ និងអង្គការក្រៅ រដ្ឋាភិបាលបានផ្តល់មកកម្ពុជាក្នុងឆ្នាំ២០០៧ បានបន្តកើនឡើងរហូតដល់៧៩០លានដុល្លាអាមេរិក ពោលគឺបានកើនឡើង ប្រមាណ១១% បើប្រៀបធៀបនឹងឆ្នាំ២០០៦ ដែលមានប្រមាណ៧១៣លានដុល្លាអាមេរិក ។ ធនធានហិរញ្ញប្បទាននេះ បន្តកើនឡើងថែមទៀតក្នុងឆ្នាំ២០០៨ (ធនធានប៉ាន់ស្មានរបស់ដៃគូអភិវឌ្ឍន៍មាន ៨៤៨លានដុល្លាអាមេរិក) ។ ការធ្លាក់ចុះ នៃតម្លៃប្រាក់ដុល្លាអាមេរិកធៀបនឹងរូបិយប័ណ្ណដទៃទៀត នៅក្នុងឆ្នាំ២០០៧និង២០០៨ គឺជាមូលហេតុមួយនៃកំណើន ហិរញ្ញប្បទាននេះ ។ ទន្ទឹមនឹងនេះ លទ្ធភាពទទួលហិរញ្ញប្បទានពីបណ្តាដៃគូអភិវឌ្ឍន៍ដទៃៗទៀត ដូចជាប្រទេសគូវ៉ែត ប្រទេសកាតា

និងសាធារណរដ្ឋប្រជាមានិតចិន រួមជាមួយនឹងមូលនិធិសកល និងហិរញ្ញប្បទានតាមខ្សែបណ្តោយ ដែលមានចំនួនច្រើនឡើងៗ បានផ្តល់កាលានុវត្តភាពក្នុងការបង្កើនហិរញ្ញប្បទានសម្រាប់គាំទ្រដល់ការអនុវត្តន៍បណ្តាគោលដៅអាទិភាពរបស់រាជរដ្ឋាភិបាល ។ ទន្ទឹមនេះ ក៏ជាបញ្ហាប្រឈមផងដែរ ដោយសារការកើនឡើងនៃតម្រូវការក្នុង កិច្ចការសម្របសម្រួល ។

និន្នាការនៃការផ្តល់ហិរញ្ញប្បទាន

និន្នាការនៃការផ្តល់ហិរញ្ញប្បទាន (គិតជាលានដុល្លា)



វិភាជន៍តាមវិស័យ ឆ្នាំ២០០៧ (គិតជាលានដុល្លា)



	2004	2005	2006	2007 (តួលេខបឋម) USD	%	2008 (ប៉ាន់ស្មាន)
ធនាគារអភិវឌ្ឍន៍អាស៊ី	76,7	89,4	67,5	69,4	8,8	114
អង្គការសហប្រជាជាតិ (ធនធានផ្ទាល់)	36,3	41,1	54,0	52,4	6,6	94,1
ធនាគារពិភពលោក	49,5	37,8	24,5	47,6	6,0	57,1
មូលនិធិរូបិយវត្ថុអន្តរជាតិ	2,4	0,3	83,5	0,9	0,1	---
មូលនិធិសកល		18,8	21,9	21,1	2,7	32,3
អង្គការសហប្រជាជាតិ និងពហុភាគី	164,8	187,5	251,2	191,4	24,2	297,5
បែលហ្ស៊ិក	5,2	11,7	7,3	8,0	1,0	3,3
ដាណឺម៉ាក	5,8	4,8	4,1	9,8	1,2	10,1
ហ្វាំងឡង់	3,3	3,3	4,5	5,2	0,7	6,8
បារាំង	23,0	24,4	21,8	21,8	2,8	33,3
អាល្លឺម៉ង់	14,1	27,3	32,4	36,5	4,6	33
ហុល្លង់	1,6	1,1	0,1	0,1		
អេស្ប៉ាញ			2,8	4,1	0,5	7,4
ស៊ុយអែត	22,0	13,6	16,0	17,3	2,2	17,9
ចក្រភពអង់គ្លេស	17,0	20,6	20,7	23,7	3,0	37,8
សហភាពអឺរ៉ុប	15,0	23,7	46,5	44,9	5,7	52,1
ដៃគូសហភាពអឺរ៉ុប	107,1	130,6	156,1	171,4	21,7	201,7
អូស្ត្រាលី	24,3	16,8	22,5	29,6	3,7	23
កាណាដា	1,5	9,1	7,9	8,7	1,1	19,2
ចិន	32,5	46,6	53,2	92,4	11,7	127,9
ជប៉ុន	101,8	111,7	103,7	122,1	15,4	144,6
ណូវែលហ្សេឡង់	2,4	2,1	1,7	3,8	0,5	3,3
ន័រវែស	3,4					
សាធារណរដ្ឋកូរ៉េ	24,1	14,9	13,3	31,4	4,0	12,1
ស្វីស	3,2	2,8	2,4	3,6	0,5	3,8
សហរដ្ឋអាមេរិក	40,6	43,3	51,0	58,1	7,4	54,9
ដៃគូអភិវឌ្ឍន៍ទ្វេភាគីដទៃទៀត	234,1	247,2	255,7	349,8	44,3	44,3
អង្គការក្រៅរដ្ឋាភិបាល (ធនធានផ្ទាល់)	49,4	44,7	50,2	77,7	9,8	
សរុប	555,4	610,0	713,2	790,4	100	887,9

ការពិនិត្យពីការតម្រឹមបង្ហាញថា ហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍មានប្រមាណ៩៥%នៃតម្រូវការធនធានដែល បានកែសម្រួល បានគាំទ្រដល់ការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិក្នុងឆ្នាំ២០០៧ ។

វិស័យដែលទទួលការ គាំទ្រច្រើនជាងគេមាន ÷ វិស័យសុខាភិបាល និងការប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍ (ច្រើនជាង១៥០លានដុល្លាអាមេរិក) វិស័យអប់រំ (៨៨លានដុល្លាអាមេរិក) និងការអភិវឌ្ឍន៍ជនបទនិងកសិកម្ម (ប្រមាណ១១៤លានដុល្លាអាមេរិក) ។ ការគាំទ្រសរុបសម្រាប់វិស័យអភិបាលកិច្ចមានប្រមាណ ១១០លានដុល្លាអាមេរិក ដែលប្រមាណពាក់កណ្តាលនៃធនធាន សម្រាប់គាំទ្រកំណែទម្រង់វិមជ្ឈការនិង វិសហមជ្ឈការ ។ ជារួម លទ្ធផលនៃការវិភាគបានបង្ហាញថា ជាទូទៅ ដៃគូ អភិវឌ្ឍន៍បានតម្រឹមការផ្តល់ ហិរញ្ញប្បទានរបស់ខ្លួនជាមួយនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បើទោះជាចាំបាច់ត្រូវ ពិនិត្យការវិភាជន៍ឡើងវិញសម្រាប់គាំទ្រវិស័យកសិកម្មនិងអភិវឌ្ឍន៍ជនបទ ដើម្បីធានាធនធានគ្រប់គ្រាន់សម្រាប់គាំទ្រ វិស័យអាទិភាព ដូចដែលបានកំណត់ក្នុង «**យុទ្ធសាស្ត្រចតុកោណ - ដំណាក់កាលទី២**» ។ នៅពេលដែលយុទ្ធសាស្ត្រតាមវិស័យត្រូវបានរៀបចំ និងបន្តពង្រឹងការផ្សារភ្ជាប់ទៅនឹងថវិការដ្ឋនិងផែនការប្រតិបត្តិការ យើងត្រូវរៀបចំយន្តការ សម្រាប់ធានាការតម្រឹមតាមវិស័យទាំងនេះ ។

បើទោះបីជាទូទៅ ការផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការត្រូវបានតម្រឹមជាមួយនឹងអាទិភាពអភិវឌ្ឍន៍ក៏ដោយ ក៏ទម្រង់ការនៃការផ្តល់ហិរញ្ញប្បទាននៅតែជាបញ្ហាប្រឈមខ្លាំងជាងមុន ។ ការកើនឡើងនៃហិរញ្ញប្បទានជាកម្មីដែល និន្នាការមានការប្រែប្រួល ទាមទារឱ្យមានការតាមដានយកចិត្តទុកដាក់សម្រាប់ធានាចីរភាពនៃបំណុល ។ លើសពីនេះ ចំនួនច្រើនលើសលុបនៃគម្រោងតូចៗបានបង្កើនបន្ទុកចំណាយប្រតិបត្តិការកាន់តែច្រើនឡើងៗដល់រាជរដ្ឋាភិបាល ។ កិច្ចសហប្រតិបត្តិការបច្ចេកទេសមានប្រមាណជាង៣០%នៃទំហំហិរញ្ញប្បទានសរុប និងការរៀបចំគោលការណ៍ណែនាំ មួយ ដែលផ្សារភ្ជាប់នឹងគោលនយោបាយអភិវឌ្ឍន៍សមត្ថភាពរបស់ប្រទេស នឹងជួយបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ ធនធានកិច្ចសហប្រតិបត្តិការបច្ចេកទេសទាំងនេះ ។ ក្នុងឆ្នាំ២០០៧នេះ ការផ្តល់ហិរញ្ញប្បទានសម្រាប់គាំទ្រថវិកាបាន ចាប់ផ្តើម ហើយបានប្រើប្រាស់ធនធានប្រមាណ៣៥លានដុល្លាអាមេរិក ។ នេះជាសញ្ញាបង្ហាញពីការជឿនលឿននៃភាព ជាដៃគូសម្រាប់កិច្ចអភិវឌ្ឍន៍ ។

គម្រោងវិនិយោគគឺជាសមាសធាតុធំជាងគេនៃហិរញ្ញប្បទានដែលផ្តល់ក្នុងឆ្នាំ២០០៧ ប្រមាណ ៤៥% នៃធនធាន សរុប ។ ប៉ុន្តែ គម្រោងដែលដំណើរការមានចំនួនច្រើនលើសលុប រហូតដល់៧៥៩គម្រោង និងការប្រើប្រាស់ធនធាន មានកម្រិតទាបនៅតាមគម្រោងនីមួយៗ (មាន៦២២គម្រោងដែលបានប្រើប្រាស់ធនធានតិចជាង១លានដុល្លាសម្រាប់ គម្រោងនីមួយៗ) ។ នេះមានន័យថា ចំណាយនៃការគ្រប់គ្រងគម្រោងទាំងនេះ សម្រាប់ស្ថាប័នជាតិមានកម្រិតខ្ពស់ (ការកើនឡើងនូវចំនួនអង្គភាពអនុវត្តគម្រោងដែលកត់ត្រាបានក្នុងពេលធ្វើអង្កេតសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីសអាច ឆ្លើយតបនឹងកំណត់សំគាល់ខាងលើ) ។ ជាមួយគ្នានេះដែររបាយការណ៍ស្តីពីលទ្ធផលនៃការធ្វើអង្កេតក៏បានពិនិត្យអំពី ការអនុវត្តន៍ប្រតិភូកម្មភាពជាដៃគូក្នុងឆ្នាំ២០០៧ ។ តាមទិន្នន័យដែលបានរាយកាណ៍ មាន៤១ករណី ដែលដៃគូអភិវឌ្ឍន៍ បានប្រតិភូកម្មធនធានឱ្យដៃគូអភិវឌ្ឍន៍ផ្សេងទៀត ។ ដោយទទួលស្គាល់ពីភាពចាំបាច់នៃការបង្កើនប្រសិទ្ធភាពនៃ ហិរញ្ញប្បទានសហប្រតិបត្តិការ ភាគីទាំង២នឹងបង្កើនការប្រើប្រាស់ «អភិក្រមគ្រប់គ្រងទូទាំងវិស័យ» ឱ្យកាន់តែច្រើន ព្រមទាំងអនុវត្ត «លក្ខខ័ណ្ឌនៃការបែងចែកពលកម្ម» ។ ផ្អែកតាមវេទយិតភាពនៃគំនិតផ្តួចផ្តើមដែលបំពេញឱ្យគ្នាទៅវិញ ទៅមក រាជរដ្ឋាភិបាលបានគូសបញ្ជាក់ពីការត្រៀមខ្លួនរួចជាស្រេចក្នុងការសម្របសម្រួល ប្រសិនបើដៃគូអភិវឌ្ឍន៍បង្ហាញពីឆន្ទៈពិតប្រាកដចង់ឱ្យមានដំណើរការនេះ ។

ទន្ទឹមនេះ ក៏មានវឌ្ឍនភាពផងដែរ ក្នុងការអនុវត្តន៍យន្តការគណនេយ្យភាពទ្វេទិសក្នុងឆ្នាំ២០០៧ និង២០០៨ ។ វិធានសម្រាប់ពង្រឹងក្រុមការងារបច្ចេកទេសចម្រុះ និងកែលំអដំណើរការពិភាក្សានៃគណៈកម្មាធិការសម្របសម្រួល រវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ត្រូវបានដាក់ឱ្យអនុវត្ត ។ យើងរំពឹងថានឹងចូលរួមចំណែកជាវិជ្ជមានដល់ភាពជា ដៃគូសម្រាប់កិច្ចអភិវឌ្ឍន៍ក្នុងរយៈពេលដ៏ខ្លីខាងមុខ ។ ការអនុវត្តន៍សូចនាករតាមដានរួមគ្នាបានបង្ហាញអំពីវឌ្ឍនភាព ស្ទើរគ្រប់មុខព្រួញ ទោះបីជាការដ្ឋានខ្លះតម្រូវឱ្យមានកិច្ចប្រឹងប្រែង និងពន្លឿនវឌ្ឍនភាពបន្ថែមទៀតក៏ដោយ ។ ការ វាយតម្លៃពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការនៅកម្ពុជា ដែលរួមមានការត្រួតពិនិត្យឯករាជ្យស្តីពីវឌ្ឍនភាព ដែលសម្រេចបាន គឺជាជំហានដ៏សំខាន់មួយសម្រាប់ពង្រឹងគណនេយ្យភាពទ្វេទិស ។ លទ្ធផលនៃការវាយតម្លៃត្រូវបាន រំលេចនៅក្នុងរបាយការណ៍នេះ ។

ភាពជាម្ចាស់	«**យុទ្ធសាស្ត្រចតុកោណ - ដំណាក់កាលទី២**» កំណត់ការអភិវឌ្ឍន៍ជនបទ ជាវិស័យអាទិភាព ។ បញ្ហាប្រឈមគន្លឹះពាក់ព័ន្ធនឹងទំនាក់ទំនងរវាងយុទ្ធសាស្ត្រ ផែនការ និងថវិកានៅថ្នាក់ជាតិ និងការពង្រីកដំណើរការនេះ នៅកម្រិតវិស័យ ។
ការតម្រឹម	សក្ខីភាពជាក់ស្តែងបានបង្ហាញពីការតម្រឹមហិរញ្ញប្បទានទៅនឹងតម្រូវការធនធានដែលមានចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ ការរៀបចំផែនការតាមវិស័យ រួមជាមួយកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែលកំពុងអនុវត្ត នឹងជួយបង្កើនការប្រើប្រាស់ប្រព័ន្ធរបស់ជាតិឱ្យបានកាន់តែច្រើន ។
សុខដុមនីយកម្ម	ការផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការនៅមានភាពបែកខ្ញែកនៅឡើយ ដោយចំនួនគម្រោងដែលមានថវិកាតូចមានចំនួនច្រើនលើសលុប ។ ការកំណត់ពីគោលការណ៍សម្រាប់ការបែងចែកពលកម្មអាចពន្លឿនការប្រើប្រាស់ប្រតិភូកម្មភាពជាដៃគូ និងសហហិរញ្ញប្បទាន ទន្ទឹមនឹងការរៀបចំកម្មវិធីអភិវឌ្ឍន៍តាមវិស័យ ។
គ្រប់គ្រងដោយផ្តោតលើលទ្ធផល	ការពង្រឹងប្រព័ន្ធតាមដានការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិនៅតែជាបញ្ហាប្រឈម ក្នុងបរិបទនៃភាពជាដៃគូមិនអំណោយផល ។ នៅកម្រិតវិស័យ ក៏មានវឌ្ឍនភាពផងដែរ ទោះបីជាដៃគូអភិវឌ្ឍន៍ចាំបាច់ត្រូវប្រឹងប្រែងបន្ថែមជាច្រើនសម្រាប់ពង្រឹងប្រព័ន្ធទាំងនេះ និងត្រូវត្រៀមលក្ខណៈប្រើប្រាស់ប្រព័ន្ធទាំងនេះផងដែរ ។
គណនេយ្យភាពទ្វេទិស	ការវាយតម្លៃអំពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការបានគូសបញ្ជាក់អំពីសារៈសំខាន់នៃជីវភាពនៃភាពជាដៃគូ ទន្ទឹមនឹងពេលដែលការអនុវត្តន៍សូចនាករតាមដានរួមគ្នាមានវឌ្ឍនភាពស្ទើរគ្រប់វិស័យ ពិសេសវិស័យសង្គមកិច្ច ។ សូចនាករតាមដានរួមគ្នាត្រូវតែមានតុល្យភាព និងមានភាពជាក់ស្តែងនៅតាមវិស័យ ។

ការត្រួតពិនិត្យស្តីពីការអនុវត្តន៍ផែនការសកម្មភាពស្តីពីសុខដុមនីយកម្ម ការតម្រឹម និងលទ្ធផលបានបង្ហាញពី វឌ្ឍនភាពក្នុងកិច្ចប្រឹងប្រែងរៀបចំក្របខ័ណ្ឌស្ថាប័នច្បាស់លាស់ សម្រាប់គ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការឱ្យមាន ប្រសិទ្ធភាព ។ បញ្ហាប្រឈមចំពោះមុខទាមទារឱ្យមានការផ្សារភ្ជាប់រវាងដំណើរការនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ កម្មវិធីវិនិយោគសាធារណៈ ថវិការដ្ឋ ការគ្រប់គ្រងហិរញ្ញប្បទានសហ

ប្រតិបត្តិការ និងដំណើរការពាក់ព័ន្ធផ្សេងៗទៀត នៅកម្រិតវិស័យ ។ បន្ទាប់មក ត្រូវបង្កើតប្រព័ន្ធរឹងមាំសម្រាប់តាមដានលទ្ធផលនៃការប្រើប្រាស់ធនធានទាំងនេះ ។

របាយការណ៍បានបញ្ចប់
ដោយធ្វើការសន្និដ្ឋានអំពីបញ្ហាប្រឈមក្នុងទំនាក់ទំនងរវាងប្រសិទ្ធភាពនៃហិរញ្ញប្បទាន សហប្រតិបត្តិការនិងកិច្ចអភិវឌ្ឍន៍ដោយផ្តោតលើលទ្ធផល ដែលតម្រូវឱ្យមានការយល់ដឹងឯកភាពគ្នាមួយអំពីសារជាតិ នៃទំនាក់ទំនងនេះ ។ បន្ទាប់មក ត្រូវកំណត់ពីសកម្មភាពដែលពាក់ព័ន្ធនឹងគោលនយោបាយ និងដែលអាចសម្រេច លទ្ធផលបាន ។ ការសិក្សា និងការវិភាគជាច្រើននៅកម្ពុជាក៏បានបង្ហាញពីបរិស្ថានអំណោយផល សម្រាប់ពន្លឿនការអនុវត្តន៍ឱ្យបានស៊ីជម្រៅ និងពីការប្រតិបត្តិល្អៗដែលពាក់ព័ន្ធនឹងការលើកកំពស់ប្រសិទ្ធភាពនៃហិរញ្ញប្បទានសហ-ប្រតិបត្តិការ ។ ទន្ទឹមនឹងទទួលស្គាល់ពីបរិការណ៍របស់កម្ពុជា អនុសាសន៍ដែលបានស្នើឡើងក្នុងរបាយការណ៍នេះបាន ទទូចឱ្យពន្លឿនល្បឿននៃការអនុវត្តន៍បន្ថែមទៀត ។

\- - - - - - - -

ជំពូក ១
សេចក្តីផ្តើម

«របាយការណ៍ស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការឆ្នាំ២០០៨» ដែលគណៈកម្មាធិការនីតិ-សម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (គ. ជ. នា/ ក. អ. ក) បានរៀបចំសម្រាប់ «វេទិកាសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី២» នឹងរួមចំណែកយ៉ាងសំខាន់ក្នុងការពិភាក្សាស្តីពីការអភិវឌ្ឍន៍របស់ប្រទេស ។ ដោយផ្អែកតាម «យុទ្ធសាស្ត្រចតុកោណ- ដំណាក់កាលទី២» ដែល **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានប្រកាសក្នុងសម័យប្រជុំលើកទី១នៃគណៈរដ្ឋមន្ត្រីសម្រាប់នីតិកាលទី៤នៃរដ្ឋសភា នាថ្ងៃទី២៦ខែកញ្ញាឆ្នាំ២០០៨ កន្លងមក និង «របាយការណ៍ពាក់កណ្តាលអាណត្តិនៃការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ» គោលដៅចម្បងនៃ«របាយការណ៍ស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការឆ្នាំ២០០៨» នេះ គឺពិនិត្យអំពីតួនាទីនៃហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ និងគូសបញ្ជាក់អំពីជីវភាពនៃភាពជាដៃគូរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ក្នុងការគាំទ្រការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដើម្បីឈានទៅសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជា ។

ភាពជាម្ចាស់មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងកិច្ចអភិវឌ្ឍន៍ដោយផ្តោតលើលទ្ធផល

ដោយមានសង្គតិភាពជាមួយនឹងការផ្ទេរពីយន្តការកិច្ចប្រជុំពិគ្រោះយោបល់ មកជាវេទិកាកិច្ចសហប្រតិ-បត្តិការអភិវឌ្ឍន៍កម្ពុជា «របាយការណ៍ស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ» នេះបានផ្តោតជាសំខាន់ទៅលើភាពជាម្ចាស់របស់រាជរដ្ឋាភិបាល ក្នុងការប្រែក្លាយការប្តេជ្ញាខាងនយោបាយ ឱ្យទៅជាការបង្កើនសមត្ថភាពការផ្តល់សេវាសាធារណៈឱ្យកាន់តែប្រសើរឡើង និងការអនុវត្តន៍ឱ្យបានសម្រេចនូវបណ្តាអាទិភាពសម្រាប់កិច្ចអភិវឌ្ឍន៍ ដូចមានចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ ដូចនេះ របាយការណ៍នេះបានចាប់ផ្តើមពីការបង្ហាញឱ្យឃើញនូវទំនាក់ទំនងរវាងប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ និងកិច្ចអភិវឌ្ឍន៍ដោយផ្តោតលើលទ្ធផល ÷

- *ភាពជាម្ចាស់និងភាពដឹកនាំ* : សក្ខីភាព ទាំងនៅកម្រិតជាតិ ទាំងនៅកម្រិតសកល បានបង្ហាញយ៉ាងច្បាស់ថា ទំនាក់ទំនងដោយផ្ទាល់រវាងការផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការ និងការអភិវឌ្ឍន៍ដោយផ្តោតលើលទ្ធផល បានស្តែងចេញតាមរយៈការបង្កើតភាពជាដៃគូប្រកបដោយជីវភាព ដែលគោរព និងលើកតម្កើងភាពជាម្ចាស់របស់កម្ពុជា ។

- *ការអភិវឌ្ឍន៍សមត្ថភាព* : ហិរញ្ញប្បទានសហប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព គឺជាហិរញ្ញប្បទានដែលគាំទ្រដល់កិច្ចអភិវឌ្ឍន៍ប្រទេស ។ ក្នុងករណីនេះ យើងអាចសន្និដ្ឋានបានថា តួនាទីរបស់ហិរញ្ញប្បទានសហ-ប្រតិបត្តិការ គឺការគាំទ្រដល់ការអភិវឌ្ឍន៍សមត្ថភាព ដែលជាសមាសភាគសំខាន់មួយនៃកិច្ចអភិវឌ្ឍន៍ប្រទេស ។

- *គោលនយោបាយ ការងារផែនការកម្ម និងការគ្រប់គ្រងធនធាន* : ភាពជាដៃគូដ៏រឹងមាំ កម្មវិធីអភិវឌ្ឍន៍ដែលបានឯកភាពរួមគ្នា និងការគ្រប់គ្រងល្អប្រសើរនូវព័ត៌មានហិរញ្ញប្បទានសហប្រតិបត្តិការ បានផ្តល់លទ្ធភាពនិងសមត្ថភាពដោយផ្ទាល់ ក្នុងការពង្រឹងទំនាក់ទំនងរវាងគោលនយោបាយ ផែនការ និងថវិកា ។ សំខាន់ជាងនេះ

ទៀត ក៏អាចជួយឱ្យរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍មានឱកាសបានស្វែងយល់រួមគ្នា និងបង្កើតគំនិតច្នៃប្រឌិតថ្មីៗបន្ថែមទៀត ។

- *<u>ការផ្តល់សេវាកម្ម</u>*៖ ហិរញ្ញប្បទានសហប្រតិបត្តិការបាននិងកំពុងផ្តល់ការគាំទ្រសម្រាប់សេវាសាធារណៈសំខាន់ៗរបស់រាជរដ្ឋាភិបាល ។ ការបង្កើនប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការនឹងជម្រុញឱ្យមានកិច្ចសម្របសម្រួលក្នុងការផ្តល់សេវាសាធារណៈ ក្នុងបរិបទនៃទស្សនទានរយៈពេលវែងសម្រាប់កិច្ចអភិវឌ្ឍន៍សមត្ថភាពប្រកបដោយចីរភាព ។

- *<u>ប្រព័ន្ធតាមដានប្រកបដោយប្រសិទ្ធភាព</u>*៖ ការពង្រឹងប្រព័ន្ធគ្រប់គ្រងព័ត៌មានឱ្យកាន់តែប្រសើរ ពិសេសព័ត៌មានស្តីពីការផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការ គឺជាឧបករណ៍ដ៏សំខាន់សម្រាប់តាមដាននិងត្រួតពិនិត្យរួមគ្នា ព្រមទាំងសម្រាប់ដកស្រង់បទពិសោធន៍រួមគ្នា ដើម្បីឈានទៅបង្កើនទំនុកចិត្តរវាងភាគីពាក់ព័ន្ធទាំងអស់ ។

- *<u>គណនេយ្យភាព</u>*៖ តម្រូវការក្នុងការកត់ត្រាឱ្យបានច្បាស់លាស់ និងការផ្សព្វផ្សាយជាសាធារណៈ នូវព័ត៌មានពាក់ព័ន្ធនឹងបរិមាណហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ រួមទាំងការវិភាជន៍ និងប្រសិទ្ធភាពនៃការប្រើប្រាស់ធនធានទាំងនោះ គឺជាវិធីសាស្ត្រប្រកបដោយចីរភាពក្នុងការធានាទំនាក់ទំនងរវាងធាតុចូល និងលទ្ធផល ។

ការបញ្ជាក់ឱ្យច្បាស់បន្ថែមទៀតអំពីទំនាក់ទំនងនៅកម្រិតថ្នាក់ជាតិ រវាងប្រសិទ្ធភាពហិរញ្ញប្បទានសហ-ប្រតិបត្តិការ និងកិច្ចអភិវឌ្ឍន៍ដោយផ្តោតលើលទ្ធផល តម្រូវឱ្យប្រកាន់យកនូវអភិក្រមគ្រប់ជ្រុងជ្រោយមួយសម្រាប់វាយតម្លៃអំពីទំនាក់ទំនងរវាងបរិមាណហិរញ្ញប្បទានសហប្រតិបត្តិការ និងប្រសិទ្ធភាពរបស់វា ។ តារាងទី១ ខាងក្រោមបានបង្ហាញអំពីស្ថានភាពទូទៅនៃធនធានសរុប ក្នុងរយៈពេលឆ្នាំ២០០៣-២០០៨ រួមមានធនធានក្នុងប្រទេស និងហិរញ្ញប្បទានសហប្រតិបត្តិការរបស់ដៃគូអភិវឌ្ឍន៍ ៖

តារាងទី១ ៖ ធនធានសរុបឆ្នាំ២០០៣-២០០៨ (លានដុល្លារអាមេរិក)

	២០០៣	២០០៤	២០០៥	២០០៦	២០០៧	២០០៨
មូលនិធិចំណាយរបស់រាជរដ្ឋាភិបាល			៧៨,៨	៩៥,២	១១០,៣	១៣៣,៣
ហិរញ្ញប្បទានសហប្រតិបត្តិការ	៥៣៩,៥	៥៥៥,៤	៦១០	៧១៣,២	៧៩០,៤	៨៨៧,៩
ធនធានសរុប			៦៨៨,៨	៨០៨,៤	៩០០,៧	១.០២១,២
ហិរញ្ញប្បទានសហប្រតិបត្តិការ (គិតជាភាគរយនៃធនធានសរុប)			៨៩%	៨៨%	៨៨%	៨៧%

ប្រភព ៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកា)

ដោយមិនរៀបរាប់អំពីគំរូនៃកំណើន ហិរញ្ញប្បទានសហប្រតិបត្តិការគឺជាធនធានសាធារណៈបន្ថែមសម្រាប់គាំទ្រដល់ការផ្តល់សេវាសាធារណៈ និងជាកាតាលីករសម្រាប់ជម្រុញការវិនិយោគឯកជន តាមរយៈការផ្តល់សេវាសេដ្ឋកិច្ច និងហេដ្ឋារចនាសម្ព័ន្ធ ។ ទោះបីជាគំរូកម្រិតសកលបានលើកឡើងជាទូទៅ នូវភាពមិនប្រាកដប្រជាខ្លះៗ ក្នុងទំនាក់ទំនងរវាងហិរញ្ញប្បទានសហប្រតិបត្តិការនិងកំណើនក៏ដោយ ក៏ទំនាក់ទំនងនេះមានភាពច្បាស់លាស់ និងរឹងមាំសម្រាប់កម្ពុជា ។

គោលដៅចម្បងនៃរបាយការណ៍ស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការឆ្នាំ២០០៨

របាយការណ៍នេះគឺជារបាយការណ៍គ្រប់ជ្រុងជ្រោយ ដែលបានធ្វើសំយោគនូវការវិភាគជាច្រើនក្នុងរយៈពេល១៨ខែកន្លងមក ។ ឯកសារនេះបានពិនិត្យឡើងវិញអំពីសក្តិភាពជាក់ស្តែងជាច្រើន ដើម្បីកំណត់បណ្តាសកម្មភាពអាទិភាពនានាដែលត្រូវប្រកាន់យក ដើម្បីធានាប្រសិទ្ធភាពនៃការប្រើប្រាស់ធនធានរបស់ដៃគូអភិវឌ្ឍន៍សម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ បន្ថែមលើរបាយការណ៍ដែលក្រុមការងារបច្ចេកទេសចម្រុះបានផ្តល់មក គ.ជ.ទា/ក.អ.ក ក៏ដូចជារបាយការណ៍ស្តីពីសកម្មភាពនានាដែលដៃគូអភិវឌ្ឍន៍បានផ្តល់ ហើយដែលត្រូវបានបញ្ចូលក្នុងប្រព័ន្ធទិន្នន័យហិរញ្ញប្បទានសហប្រតិបត្តិការកម្ពុជា យើងបានអនុវត្តសកម្មភាពរួមគ្នាជាច្រើនបន្ទាប់ពីវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី១ ។ សកម្មភាពទាំងនេះរួមមាន ÷

១- ការពិនិត្យវាយតម្លៃអំពីការគ្រប់គ្រង និងប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការបច្ចេកទេស

២- ការធ្វើអង្កេតស្តីពីការតាមដានការអនុវត្តន៍សេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស និងការចូលរួមនិងការផ្តល់ធាតុចូលរបស់កម្ពុជានៅក្នុងវេទិកាអន្តរជាតិសំខាន់ៗដែលពាក់ព័ន្ធនឹងប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ និង

៣- ការវាយតម្លៃអំពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការនៅកម្ពុជា ក្នុងនោះមានការវាយតម្លៃវឌ្ឍនភាពនៃការអនុវត្តន៍សេចក្តីថ្លែងការណ៍កម្ពុជាស្តីពីការពង្រឹងប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ និងការវាយតម្លៃអំពីវឌ្ឍនភាពពាក់កណ្តាលអាណត្តិនៃការអនុវត្តន៍ផែនការសកម្មភាពស្តីពីសុខដុមនីយកម្ម ការតម្រឹម និងលទ្ធផល ។

ក្នុងក្របខ័ណ្ឌនៃរបាយការណ៍ពាក់កណ្តាលអាណត្តិនៃការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងយុទ្ធសាស្ត្រចតុកោណ- ដំណាក់កាលទី២ របាយការណ៍ស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការបានផ្តល់កាលានុវត្តភាពសម្រាប់ឆ្លុះបញ្ចាំងអំពីវឌ្ឍនភាពការងារ សមិទ្ធផល និងបណ្តាបញ្ហាប្រឈមក្នុងការអនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាល ដែលមានចែងក្នុងឯកសារយុទ្ធសាស្ត្រដ៏សំខាន់ទាំងពីរនេះ ។ លើសពីនេះ របាយការណ៍ស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការបានរំលេចរបកគំហើញគន្លឹះមួយចំនួន ដែលទទួលបានពីរបាយការណ៍នៃការវាយតម្លៃឯករាជ្យស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការនៅកម្ពុជា ដែលទើបបានបញ្ចប់នាពេលថ្មីៗកន្លងមកនេះ ដើម្បីលើកវិធានការមួយចំនួនសម្រាប់ពន្លឿនការអនុវត្តន៍ផែនការសកម្មភាពស្តីពីសុខដុមនីយកម្ម ការតម្រឹម និងលទ្ធផល ។ ជាមួយគ្នានេះដែរ គួរកត់សំគាល់ថា យោងតាមរបាយការណ៍ស្តីពីការវាយតម្លៃប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការនៅកម្ពុជា រាជរដ្ឋាភិបាលពុំមានបំណងកែសម្រួលផែនការសកម្មភាពស្តីពីសុខដុមនីយកម្ម ការតម្រឹម និងលទ្ធផលរបស់ខ្លួនឡើយ ទោះបីជាសកម្មភាពកម្រិតគោលនយោបាយមួយចំនួនត្រូវពិនិត្យ និងធ្វើអាទិភាវូបនីយកម្មឡើងវិញឱ្យស្របតាមតម្រូវការរបស់ក្រសួង និងស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល និងក្រុមការងារបច្ចេកទេសចម្រុះ ក៏ដូចជាដៃគូអភិវឌ្ឍន៍ក៏ដោយ ។

របាយការណ៍ស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការនេះបានចាប់ផ្តើម ដោយឆ្លុះបញ្ចាំងអំពីគំនិតផ្តួចផ្តើមនានាស្តីពីភាពជាដៃគូដែលបានអនុវត្តចាប់តាំងពីពាក់កណ្តាលឆ្នាំ២០០៧មក ។ របាយការណ៍បាន

លើកឡើងថា ទោះបីជាការប្តេជ្ញាមានភាពរឹងមាំក៏ដោយ ក៏ការប្តេជ្ញាទាំងនេះពុំទាន់ត្រូវបានប្រែក្លាយឱ្យទៅជាការអនុវត្តន៍ជាក់ស្តែងនៅឡើយ ។ ដោយផ្អែកលើសកម្មភាពមួយចំនួនស្តីពីភាពជាដៃគូដែលបានរំលេចនៅក្នុងរបាយការណ៍ស្តីពីកិច្ចសហប្រតិបត្តិការបច្ចេកទេស និងការវាយតម្លៃឯករាជ្យស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការកន្លងមក យើងត្រូវបន្តពង្រឹងភាពជាដៃគូបន្ថែមទៀត ដើម្បីបង្កើនទំនុកចិត្តរវាងភាគីទាំងសងខាង និងសំខាន់ជាងនេះទៀត បង្កើនប្រព័ន្ធទំនាក់ទំនងឱ្យកាន់តែប្រសើរឡើងសម្រាប់បណ្តាសកម្មភាពជាក់លាក់ដែលភាគីទាំពីរត្រូវប្រកាន់យក ដើម្បីកាត់បន្ថយនូវភាពនឿយណាយក្នុងការអនុវត្តន៍ភាពជាដៃគូសម្រាប់កិច្ចអភិវឌ្ឍន៍ ។ ការពិនិត្យ និងការវិភាគអំពីបរិមាណនៃហិរញ្ញប្បទានសហប្រតិបត្តិការ គួបផ្សំជាមួយនឹងរបកគំហើញនៃរបាយការណ៍ស្តីពីការវាយតម្លៃប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការនៅកម្ពុជា និងរបាយការណ៍ពាក់កណ្តាលអាណត្តិនៃការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គឺជាមូលដ្ឋានសំខាន់បន្ថែមទៀតសម្រាប់វាយតម្លៃគុណភាពនៃការផ្តល់ និងការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការ ។

បន្ទាប់មក របាយការណ៍ស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការនេះ បានផ្តោតទៅលើវឌ្ឍនភាពនៃការអនុវត្តន៍សូចនាករតាមដានរួមគ្នាចាប់តាំងពីពាក់កណ្តាលឆ្នាំ២០០៧ ។ ពិនិត្យជារួម យើងមានវឌ្ឍនភាពគួរឱ្យលើកទឹកចិត្តក្នុងការអនុវត្តន៍សូចនាករតាមដានរួមគ្នាទាំងនេះ ។ ទន្ទឹមនេះដែរ ក៏បានឆ្លុះបញ្ចាំងអំពីទស្សនៈខ្វែងគ្នាមួយចំនួនរវាងកម្រិតបច្ចេកទេសនិងកម្រិតនយោបាយ ដែលពាក់ព័ន្ធនឹងទំនាក់ទំនងរវាងការផ្តល់និងការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការ ។ របាយការណ៍បានរៀបរាប់អំពីសក្ខីភាពជាច្រើន សម្រាប់ជាមូលដ្ឋាននៃការរៀបចំអនុសាសន៍កម្រិតគោលនយោបាយសម្រាប់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ក៏ដូចជាអនុសាសន៍ដែលបញ្ជាក់អំពីការទទួលខុសត្រូវរួមគ្នារបស់ភាគីទាំង២ រួមទាំងការទទួលខុសត្រូវរបស់ក្រុមការងារបច្ចេកទេសចម្រុះផងដែរ ។ របាយការណ៍នេះបានបញ្ចប់ដោយសេចក្តីសន្និដ្ឋានខ្លីថា ប្រសិនបើរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍មិនបានប្រើប្រាស់ឱ្យអស់នូវសក្តានុពលសកលនិងបរិស្ថានអំណោយផលរបស់កម្ពុជា សម្រាប់អនុវត្តការប្តេជ្ញារបស់ខ្លួនទេ នោះយើងមានសង្ឃឹមតិចតួចណាស់ក្នុងការអនុវត្តន៍ឱ្យបានសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្ស ។

សារគន្លឹះ

ស្របពេលនឹងបរិការណ៍នៃការធ្លាក់ចុះសេដ្ឋកិច្ចសកលលោក ការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការប្រកបដោយប្រសិទ្ធភាពកាន់តែមានអត្ថន័យសំខាន់បន្ថែមទៀត នៅក្នុងស្ថានភាពដែលធនធានក្នុងស្រុក ក៏ដូចជាធនធានពីក្រៅប្រទេសកាន់តែកម្រនិងស្ចួចស្តើងទៅ ។ លើសពីនេះ ហិរញ្ញប្បទានសហប្រតិបត្តិការរបស់ដៃគូអភិវឌ្ឍន៍នឹងត្រូវបំពេញតួនាទីបន្ថែមទៀតក្នុងការផ្តល់ការគាំទ្រដល់សុវត្ថិភាពសង្គម នៅក្នុងស្ថានភាពនៃអសន្តិសុខស្បៀង និងការធ្លាក់ចុះទូទៅនៃសេដ្ឋកិច្ចសកលលោក ។ ស្ថិតក្នុងទស្សនវិស័យនេះ និងផ្អែកតាមសក្ខីភាពជាក់ស្តែង បណ្តាចំណុចដូចខាងក្រោមនេះអាចចាត់ទុកបានថាជាចំណុចដ៏សំខាន់បំផុតក្នុងកិច្ចសហប្រតិបត្តិការ ÷

១- សក្ខីភាពនៃដំណើរការមួយដែលមានភាពនឿយណាយ និងអូសបន្លាយ តម្រូវឱ្យមានកិច្ចអន្តរាគមន៍កម្រិតនយោបាយ ។

២- ចាំបាច់ត្រូវការផ្តោតការយកចិត្តទុកដាក់លើការធ្វើឱ្យសាមញ្ញ នូវគំនិតផ្តួចផ្តើមនៃការលើកកម្ពស់ប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ ការធ្វើអាទិភាវូបនីយកម្ម និងការធ្វើឱ្យគំនិតផ្តួចផ្តើមទាំងនេះបានចាក់គ្រឹះរឹងមាំ និងជាក់ស្តែងសម្រាប់បង្កើនប្រសិទ្ធភាពហិរញ្ញប្បទាន ។

៣- ការប្រឹងប្រែងជម្រុញឱ្យមានការជឿនលឿនទៅមុខក្នុងការអនុវត្តន៍ត្រូវពឹងអាស្រ័យលើប្រសិទ្ធភាពនៃជវភាពរបស់ភាពជាដៃគូ ។

៤- ចាំបាច់ត្រូវជម្រុញឱ្យមានការចូលរួមទូលំទូលាយបន្ថែមទៀត ប៉ុន្តែ ក៏ទាមទារឱ្យមានសមត្ថភាព និងជំនាញសមស្រប ។

៥- ការអភិវឌ្ឍន៍សមត្ថភាពបានក្លាយជាកត្តាចំបងនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ។

របាយការណ៍ស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ បានបង្ហាញអំពីអភិក្រមគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ សម្រាប់ពង្រឹងការងារផែនការនីយកម្ម ថវិកានីយកម្ម ការអនុវត្តន៍ និងគុណភាពនៃកិច្ចប្រតិបត្តិការ ឬក៏តម្រូវការសម្រាប់សិក្សាស្រាវជ្រាវបន្ថែមទៀត ។ សរុបមក របាយការណ៍នេះបានផ្តោតទៅលើគណនេយ្យភាពរវាងភាគីពាក់ព័ន្ធ និងគណនេយ្យភាពចំពោះសហគមន៍ទាំងមូល ដើម្បីឈានទៅសម្រេចឱ្យបាននូវកិច្ចអភិវឌ្ឍន៍ដោយផ្តោតលើលទ្ធផល ។

\- - - - - - - -

ជំពូក ២

ស្ថានភាពទូទៅនៃភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍន៍

សេចក្តីថ្លែងការណ៍របស់កម្ពុជាស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការបានកំណត់ថា ទំនុកចិត្ត និងគណនេយ្យភាពទ្វេទិស គឺជាមូលដ្ឋានចម្បងសម្រាប់ភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធភាព ។ សក្ខីភាពជាក់ស្តែង ដែលរួមទាំងរបាយការណ៍វាយតំលៃក្រុមការងារបច្ចេកទេសចម្រុះឆ្នាំ២០០៦ និងរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តន៍សូចនាករតាមដានរួមគ្នាឆ្នាំ២០០៧បានបង្ហាញថា អន្តរកាលឆ្ពោះទៅការគាំទ្រកម្មវិធីដែលដឹកនាំដោយរាជរដ្ឋាភិបាល ទាមទារនូវសមត្ថភាពនិងមុខជំនាញ ដែលជាទូទៅ ខុសប្លែកពីការងារជំនាញបច្ចេកទេសសម្រាប់គ្រប់គ្រងគម្រោង ។ ដើម្បីគាំទ្រអន្តរកាលនេះ និងដើម្បីពង្រឹងប្រសិទ្ធភាពរបស់ក្រុមការងារបច្ចេកទេសចម្រុះ យើងបានខិតខំប្រឹងប្រែងជាច្រើន ដើម្បីបង្កើនសមត្ថភាពនិងមុខជំនាញខាងភាពជាដៃគូសម្រាប់រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ។ ក្នុងពេលថ្មីៗកន្លងមក យើងបានធ្វើការវាយតម្លៃរួមគ្នាអំពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ និងការត្រួតពិនិត្យឯករាជ្យសម្រាប់តាមដានវឌ្ឍនភាពផងដែរ ។ ជំពូកនេះនឹងបង្ហាញគំនិតផ្តួចផ្តើមនានាស្តីពីភាពជាដៃគូ ដែលបានអនុវត្តចាប់តាំងពីវេទិកាសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី១ នាខែមិថុនា ឆ្នាំ២០០៧ និងឆ្លុះបញ្ចាំងអំពីលទ្ធផល និងរបកគំហើញនានានៃរបាយការណ៍វាយតម្លៃឯករាជ្យ ។ ទន្ទឹមនេះ ក៏បានគូសបញ្ជាក់អំពីតម្រូវការក្នុងការបន្តកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត ពិសេសការបង្កើនទំនុកចិត្ត និងការយល់ដឹងពីគ្នាឱ្យកាន់តែប្រសើរឡើង ដើម្បីធានាប្រសិទ្ធភាពនៃការអភិវឌ្ឍន៍ ។

<u>តម្រូវការសម្រាប់ពន្លឿនការអនុវត្តន៍</u>

ឆមាសទី២នៃឆ្នាំ២០០៧ គឺជាដំណាក់កាលនៃការបញ្ជាក់សាជាថ្មីម្តងទៀត អំពីការប្តេជ្ញា និងការខិតខំប្រឹងប្រែងសម្រាប់ពន្លឿនដំណើរការនៃការអនុវត្តន៍ផែនការសកម្មភាពស្តីពីសុខដុមនីយកម្ម ការតម្រឹម និងលទ្ធផល ។ នៅក្នុងកិច្ចប្រជុំនៃវេទិកាសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី១ រាជរដ្ឋាភិបាលបានបញ្ជាក់ថា «ដល់ពេលវេលាដែលត្រូវអនុវត្តការប្តេជ្ញានានាដែលបានសន្យាកន្លងមក» ។ សារនេះត្រូវបានទទួលការឆ្លើយតបជាវិជ្ជមានពីសំណាក់ដៃគូអភិវឌ្ឍន៍របស់យើង ។ ជាលទ្ធផល យើងបានទទួលការឯកភាពលើចំណុចសំខាន់ៗដូចខាងក្រោម ÷

១- ការគោរពនូវរចនាសម្ព័ន្ធស្ថាប័នរបស់កម្ពុជា ការកែលំអប្រព័ន្ធព័ត៌មានស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការ និង" ភាពអាចទស្សន៍ទាយជាមុន" នៃហិរញ្ញប្បទានសហប្រតិបត្តិការ ។

២- ការពង្រឹងទំនាក់ទំនងរវាងថវិកា និងផែនការតាមវិស័យ ។

៣- តម្រូវការឱ្យកាត់បន្ថយ «ភាពបែកខ្ញែក» ក្នុងការផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការ តាមរយៈគំនិតផ្តួចផ្តើមនានាស្តីពីការបែងចែកពលកម្ម និងការធ្វើប្រតិភូកម្មហិរញ្ញប្បទាន ។

៤- ការបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងកិច្ចសហប្រតិបត្តិការបច្ចេកទេស និង

៥- ការបង្កើនគណនេយ្យភាពទ្វេទិស និងការពង្រឹងភាពជាដៃគូនៅតាមក្រុមការងារបច្ចេកទេសចម្រុះ និងគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ។

ប្រតិភូនានានៃវេទិកាសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាបានទទួលស្គាល់ថា ការឯកភាពគ្នានេះ គឺជាទស្សនទានត្រឹមត្រូវ សម្រាប់ពន្លឿនការអនុវត្តន៍សកម្មភាពនានាដែលជះឥទ្ធិពលជាវិជ្ជមានលើអាទិភាពនានានៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។

ការពង្រឹងក្របខ័ណ្ឌខាងស្ថាប័នដោយផ្តោតលើភាពជាដៃគូ

បញ្ហាប្រឈមមួយក្នុងចំណោមបញ្ហាប្រឈមនានាក្នុងការប្រើប្រាស់និងការអនុវត្តន៍ទម្រង់ការខាងស្ថាប័ន មានការពាក់ព័ន្ធយ៉ាងជិតស្និទ្ធទៅនឹងការផ្លាស់ប្តូរមន្ត្រីជាញឹកញាប់របស់ដៃគូអភិវឌ្ឍន៍ ។ ដើម្បីកែសម្រួលស្ថានភាពនេះ គ. ជ. នា/ ក. អ. ក បានរៀបចំសិក្ខាសាលាមួយសម្រាប់ដៃគូអភិវឌ្ឍន៍នាខែវិច្ឆិកា ឆ្នាំ២០០៧ ។ ក្នុងពេលបើកសិក្ខាសាលា និងយោងតាមការពិភាក្សាក្នុងវេទិកាសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា **ឯកឧត្តម ឈៀង យ៉ាណារ៉ា** អគ្គលេខាធិការនៃ គ. ជ. នា បានបញ្ជាក់ថា÷«យើងនៅមានកិច្ចការជាច្រើនទៀតដែលរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ត្រូវបន្តអនុវត្ត ។ រាជរដ្ឋាភិបាលនឹងបន្តពង្រឹងការគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ ដោយត្រូវប្រែក្លាយក្របខ័ណ្ឌគោលនយោបាយឱ្យទៅជាការអនុវត្តន៍ជាក់ស្តែង ។ ចំពោះដៃគូអភិវឌ្ឍន៍វិញ ក៏ត្រូវផ្លាស់ប្តូរផ្នត់គំនិតនិងឥរិយាបថមួយចំនួន ដោយកាត់បន្ថយការិយាល័យធិបតេយ្យក្នុងដំណើរការ នៃការគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ ការអនុវត្តន៍តាមរបៀបវារៈនយោបាយរៀងៗខ្លួន ការស្វែងយល់ពី បរិបទកម្ពុជា ការសិក្សាអំពីរបៀបធ្វើការរួមគ្នាប្រកបដោយប្រសិទ្ធភាព និងកំណែទម្រង់ក្នុងរបៀបរបបនៃការ អនុវត្តន៍ហិរញ្ញប្បទានសហប្រតិបត្តិការ ដែលបណ្តាលឱ្យមានភាពបែកខ្ញែកខាងសមត្ថភាព ហើយជះឥទ្ធិពល តិចតួចទៅលើកិច្ចអភិវឌ្ឍន៍ដោយផ្តោតលើលទ្ធផល» ។

បន្ទាប់មក សិក្ខាសាលាក៏បានផ្តោតទៅលើទម្រង់ការនានាខាងស្ថាប័ន និងរចនាសម្ព័ន្ធសម្រាប់គ្រប់គ្រងភាពជាដៃគូសម្រាប់កិច្ចអភិវឌ្ឍន៍ ព្រមទាំងឧបករណ៍ និងកិច្ចដំណើការពាក់ព័ន្ធនានា ដូចជា គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ក្រុមការងារបច្ចេកទេសចម្រុះ សូចនាករតាមដានរួមគ្នា និងប្រព័ន្ធទិន្នន័យស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការ ។ នាពេលអនាគត យើងនឹងផ្សព្វផ្សាយព័ត៌មានស្តីពីធនធានសម្រាប់សិក្ខាសាលាបែបនេះ នៅតាមប្រព័ន្ធ On-line ដើម្បីឱ្យបុគ្គលិកខាងដៃគូអភិវឌ្ឍន៍អាចទទួលព័ត៌មានបានជាប្រចាំ តាមទម្រង់នៃការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិកនេះ ។

ការបំពាក់មធ្យោបាយជាមូលដ្ឋានដល់ក្រុមការងារបច្ចេកទេសចម្រុះ

ការវាយតម្លៃផ្ទៃក្នុងស្តីពីសមត្ថភាពនៃក្រុមការងារបច្ចេកទេសចម្រុះ ដែលបានអនុវត្តនាខែមិថុនាឆ្នាំ២០០៧ បានបង្ហាញកត្តាមួយចំនួន ដែលរាំងស្ទះដល់ការគ្រប់គ្រងនិងការអនុវត្តន៍ការងារប្រកបដោយប្រសិទ្ធភាពរបស់ក្រុមការងារបច្ចេកទេសចម្រុះ ។ ទន្ទឹមនឹងភាពចាំបាច់ក្នុងការផ្តល់មុខជំនាញសម្រាប់ពង្រឹងភាពជាដៃគូ ពិសេសនៅកម្រិតគ្រប់គ្រង យើងពិនិត្យឃើញផងដែរអំពីភាពចាំបាច់ក្នុងការកសាងសមត្ថភាពរបស់លេខាធិការដ្ឋាននៃក្រុមការងារបច្ចេកទេសចម្រុះ ដើម្បីធានាភាពរលូនក្នុងដំណើរការ និងការគ្រប់គ្រងការងាររបស់ក្រុមការងារ ។ សមត្ថភាពទាំងនេះទាក់ទងនឹងតម្រូវការខាងបច្ចេកទេស ដូចជាតម្រូវការឧបករណ៍ និងដំណើរការនានាដែលជាមូលដ្ឋាននៃផែនការសកម្មភាពស្តីពីសុខដុមនីយកម្ម ការតម្រឹម និងលទ្ធផល ព្រមទាំងតម្រូវការខាងស្វែងយល់

វាក្យស័ព្ទបច្ចេកទេសនានា ដែលប្រើប្រាស់ក្នុងកិច្ចការដែលពាក់ព័ន្ធប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ ដូចជាអត្ថន័យនៃ«គណនេយ្យភាពទ្វេទិស» និងភាពខុសគ្នាខាងអត្ថន័យរវាង «ការតម្រឹម» និង«សុខដុមនីយកម្ម» ។

ដើម្បីឆ្លើយតបនឹងតម្រូវការខាងលើនេះ គ.ជ.ន/ក.អ.ក បានរៀបចំវគ្គបណ្តុះបណ្តាលរយៈពេលពីរសប្តាហ៍លើប្រធានបទ«គោលការណ៍នៃការគ្រប់គ្រងនិងប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការ» ដោយសហការជាមួយមហាវិទ្យាល័យជាតិរដ្ឋបាលនិងអភិបាលកិច្ចសាធារណៈនៃសាកលវិទ្យាល័យហ្វីលីពីន ។ វគ្គបណ្តុះបណ្តាលនេះបានបែងចែកជាពីរផ្នែក ហើយបានបណ្តុះបណ្តាលមន្ត្រីរាជការចំនួន៦០នាក់ មកពីក្រុមការងារបច្ចេកទេសចម្រុះទាំង១៩ ។ វគ្គបណ្តុះបណ្តាលបានផ្តោតលើសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស ការអនុវត្តន៍សេចក្តីថ្លែងការណ៍នេះក្នុងបរិបទកម្ពុជា បច្ចេកទេសសម្រាប់ជម្រុញប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ និងអភិក្រមនានាដែលពាក់ព័ន្ធនឹងកិច្ចការអន្តរវិស័យ ដូចជាយេនឌ័រ ព្រមទាំងវិធានការមួយចំនួនដែលជួយពង្រឹង «ភាពជាម្ចាស់របស់រាជរដ្ឋាភិបាល» និង «គណនេយ្យភាពទ្វេទិស» ផងដែរ ។

បញ្ហាប្រឈម និងការរាំងស្ទះសំខាន់ផ្សេងៗទៀត រួមមាន÷ បញ្ហាភាសា និងការបកស្រាយ គ្រឿងបរិក្ខា និងធនធានសម្រាប់រៀបចំ និងផ្សព្វផ្សាយឯកសារ តម្រូវការខាងឧបករណ៍និងការបណ្តុះបណ្តាលជាក់លាក់មួយចំនួន និងកាលានុវត្តភាពក្នុងការផ្លាស់ប្តូរ និងដកស្រង់បទពិសោធន៍ពីគ្នាទៅវិញទៅមក ។ អាស្រ័យហេតុនេះ គ.ជ.ន/ក.អ.ក បានបង្កើតបណ្តាញលេខាធិការដ្ឋានរបស់ក្រុមការងារបច្ចេកទេសចម្រុះ ហើយបានផ្តល់ការគាំទ្រថវិកាជាកញ្ចប់ទៀតផង ។

លេខាធិការដ្ឋានក្រុមការងារបច្ចេកទេសចម្រុះបានជួបជុំគ្នា ដើម្បីផ្លាស់ប្តូរយោបល់ និងបទពិសោធន៍ស្តីពីការគ្រប់គ្រង និងដំណើរការរបស់លេខាធិការដ្ឋាន និងរបៀបបំពេញការងារនៅក្នុងបរិស្ថានការងារមួយដែលមានសមាសភាពចម្រុះចូលរួម និងដើម្បីទទួលពុទ្ធិបន្ថែមស្តីពី«អភិក្រមគ្រប់គ្រងទូទាំងវិស័យ» ។ ដោយមានការឯកភាព និងយល់ព្រមពីប្រធាននៃក្រុមការងារបច្ចេកទេសចម្រុះ និងមន្ត្រីបង្គោលរបស់ដៃគូអភិវឌ្ឍន៍ដែលជាសមាជិកក្នុងក្រុមការងារបច្ចេកទេសទាំងនោះ ការគាំទ្រថវិកាជាកញ្ចប់ត្រូវបានផ្តល់ជូនក្រុមការងារបច្ចេកទេសចម្រុះចំនួន១០ សម្រាប់គាំទ្រចំណាយខាងផ្នែករដ្ឋបាល សំភារៈ សេវាបកប្រែ និងការផ្តល់លាភការផ្អែកលើលទ្ធផលការងារ ។ គំនិតផ្តួចផ្តើមក្នុងការគាំទ្រតាមរយៈការផ្តល់ថវិកាជាកញ្ចប់នេះគឺជាទម្រង់ការសាកល្បង ដើម្បីក្រុមការងារបច្ចេក-ទេសចម្រុះអាចកាត់បន្ថយបញ្ហាលំបាកខាងផ្នែករដ្ឋបាលដែលរាំងស្ទះដល់ដំណើរការរបស់ក្រុមការងារបច្ចេកទេសចម្រុះទាំងនោះ ។ ទោះជាយ៉ាងនេះក្តី ក៏ការផ្តល់ថវិកាជាកញ្ចប់នេះមិនមែនមានបំណងចង់ដោះស្រាយជំនួសបណ្តាក្រសួងនិងស្ថាប័នរបស់រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ដែលបានផ្តល់ហិរញ្ញប្បទានសម្រាប់គាំទ្រសកម្មភាពរបស់ក្រុមការងារបច្ចេកទេសចម្រុះនិងលេខាធិការដ្ឋាន នាពេលអនាគតនោះឡើយ ។

ការអភិវឌ្ឍន៍សមត្ថភាព- មូលដ្ឋានគ្រឹះសម្រាប់ភាពជាដៃគូប្រកបដោយប្រសិទ្ធភាព

តួនាទីនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍សម្រាប់ជម្រុញការអភិវឌ្ឍន៍សមត្ថភាព តាមរយៈការផ្តល់កិច្ចសហប្រតិបត្តិការបច្ចេកទេស គឺជាមូលដ្ឋានគ្រឹះដ៏សំខាន់នៃភាពជាដៃគូសម្រាប់កិច្ចអភិវឌ្ឍន៍ ។ ក្នុងស្មារតីដែល

កិច្ចសហប្រតិបត្តិការសម្រាប់កិច្ចអភិវឌ្ឍន៍ត្រូវបានផ្តល់ សម្រាប់គាំទ្រដល់ដំណើរការនៃការផ្លាស់ប្តូរពីស្ថានភាពសង្គមបច្ចុប្បន្ន ឱ្យបានប្រសើរនាពេលអនាគត លទ្ធភាពរបស់រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ក្នុងការរៀបចំទស្សនវិស័យរួមគ្នា ក៏ដូចជាការអនុវត្តន៍រួមគ្នា នូវសកម្មភាពដែលបានព្រមព្រៀង និងការត្រួតពិនិត្យព្រមទាំងការផ្លាស់ប្តូរបទពិសោធន៍ជាមួយគ្នា គឺជាមូលដ្ឋាន សំខាន់សម្រាប់កំណត់ប្រសិទ្ធភាពនៃការផ្តល់ និងការគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ នៅកម្ពុជា ។

ផ្អែកលើសក្ខីភាពជាក់ស្តែងនៃរបាយការណ៍ស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការឆ្នាំ២០០៧ និងការពិភាក្សាក្នុងវេទិកាសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា យើងបានឯកភាពអំពីសកម្មភាពសំខាន់និងបន្ទាន់មួយចំនួន ដើម្បីកែទម្រង់ការផ្តល់ និងការគ្រប់គ្រងកិច្ចសហប្រតិបត្តិការបច្ចេកទេស ។ ទោះបីនេះមិនមែនជាបញ្ហាថ្មីថ្មោងសម្រាប់កម្ពុជា និងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ដទៃទៀត ក៏រាជរដ្ឋាភិបាល ពិសេសក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលបានផ្តោតការយកចិត្តទុកដាក់ទៅលើការអភិវឌ្ឍន៍សមត្ថភាព ដោយបានធ្វើការសិក្សាឯករាជ្យចំនួន២លើក ។ ការសិក្សាទី១បានផ្តោតលើតួនាទី និងប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការបច្ចេកទេស សម្រាប់គាំទ្រការអភិវឌ្ឍន៍សមត្ថភាព ។ រីឯការសិក្សាទី២ បានរៀបរាប់សក្ខីភាពជាក់ស្តែងបន្ថែមទៀត នៅក្នុងវិស័យសុខាភិបាល ។

<u>កិច្ចសហប្រតិបត្តិការបច្ចេកទេស- របកគំហើញសំខាន់ៗចំនួន១០</u>

១- សក្ខីភាពចម្រុះជាច្រើនបានបង្ហាញថា កិច្ចសហប្រតិបត្តិការបច្ចេកទេសបានចូលរួមចំណែកជាច្រើន ក្នុងកិច្ចអភិវឌ្ឍន៍ដោយផ្តោតលើលទ្ធផល ។
២- ទស្សនទាននៃកិច្ចសហប្រតិបត្តិការបច្ចេកទេសច្រើនទទួលភាពបរាជ័យក្នុងការឆ្លើយតបទៅនឹងបរិបទសង្គមនិងវប្បធម៌ ដែលកិច្ចសហប្រតិបត្តិការបច្ចេកទេសកំពុងប្រតិបត្តិការ ។
៣- ការច្នៃប្រឌិតនិងបទពិសោធន៍នានាសម្រាប់ឱ្យស្ថាប័នរាជរដ្ឋាភិបាលកំណត់នូវអភិក្រមល្អ និងមានប្រសិទ្ធភាព ដូចជា «កិច្ចសហប្រតិបត្តិការត្បូង- ត្បូង» ជាដើម ។
៤- កិច្ចសហប្រតិបត្តិការបច្ចេកទេសច្រើនតែងទទួលបានជោគជ័យ ក្នុងការសម្រេចគោលដៅរបស់គម្រោង។ ប៉ុន្តែ លទ្ធផលនេះមិនផ្សារភ្ជាប់ទៅនឹងការវាយតំលៃអំពីតម្រូវការខាងសមត្ថភាព និងមិនបានជួយពង្រឹងរចនាសម្ព័ន្ធខាងស្ថាប័នឡើយ ។
៥- ការវាយតំលៃពិស្តារមួយចំនួនអំពីប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការបច្ចេកទេស ច្រើនផ្តោតទៅលើការចែករំលែកនិងអនុវត្តនូវចំណេះដឹង ។
៦- បញ្ហាប្រឈមក្នុងកំណែទម្រង់និងការកសាងសមត្ថភាពភាគច្រើនមានភាពស្មុគស្មាញ ហើយទាមទារឱ្យចាត់វិធានការដោយមានការសម្របសម្រួលគ្នា ។
៧- ឧទាហរណ៍ជាច្រើនស្តីពីការអភិវឌ្ឍន៍សមត្ថភាពប្រកបដោយប្រសិទ្ធភាព បានបញ្ជាក់ថា គំរូកិច្ចសហប្រតិបត្តិការបច្ចេកទេសចាស់គំរិលត្រូវបានប្រើប្រាស់ ក្នុងប្រទេសដែលទើបចាកផុតពីវិបត្តិ ។ កិច្ចសហប្រតិបត្តិការបច្ចេកទេសច្រើនប្រកាន់ទស្សនៈ «យល់ឃោគ» ក្នុងបណ្តាប្រទេសដែលពឹងផ្អែកខ្លាំងទៅលើហិរញ្ញប្បទានបរទេស ។
៨- ការទាញយកបុគ្គលិកដែលមានសមត្ថភាពពីវិស័យនានារបស់រាជរដ្ឋាភិបាលដោយដៃគូអភិវឌ្ឍន៍ បានបង្កើតទីផ្សារពលកម្ម២ស្របគ្នា និងក្លាយជាឧបសគ្គរាំងស្ទះដល់សកម្មភាពនៃការអភិវឌ្ឍន៍សមត្ថភាព ។
៩- ទស្សនទាននៃការផ្តល់កិច្ចសហប្រតិបត្តិការបច្ចេកទេសដោយមានការសម្របសម្រួល និងសុខដុមនីយកម្ម នឹងកាត់បន្ថយការប្រណាំងប្រជែងសម្រាប់កេងយកឥទ្ធិពល ព្រមទាំងជួយពង្រឹងភាពដឹកនាំរបស់ស្ថាប័ន ។
១០- ការកាត់បន្ថយឧបសគ្គរាំងស្ទះនានាទាមទារឱ្យមានអន្តរាគមន៍កម្រិតនយោបាយ ។

ការសិក្សាទាំងពីរនេះ គួបផ្សំជាមួយនឹងកិច្ចពិភាក្សារវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ បានកំណត់បញ្ហាសំខាន់មួយចំនួនស្តីពីភាពជាដៃគូសម្រាប់កិច្ចអភិវឌ្ឍន៍ ហើយបានតម្រូវឱ្យភាគីទាំង២ផ្លាស់ប្តូរអភិក្រមក្នុងកិច្ចសហប្រតិបត្តិការ ។ ការសិក្សានេះក៏បានបង្ហាញអំពីជវភាពនៃទំនាក់ទំនងយ៉ាងជិតស្និទ្ធ រវាងការផ្តល់លាភការក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ និងឥរិយាបថរបស់ភាគីទាំងពីរចំពោះភាពជាដៃគូសម្រាប់កិច្ចអភិវឌ្ឍន៍ ។ ភាពខុសគ្នាខាងវប្បធម៌ ទស្សនទានផ្ទុយគ្នាស្តីពីចរិតលក្ខណៈ នៃភាពជាដៃគូសម្រាប់កិច្ចអភិវឌ្ឍន៍ និងកាតព្វកិច្ចនៃភាគីទាំងពីរ គឺជាមូលហេតុចម្បងនៃការយល់ច្រឡំ ហើយនៅករណីខ្លះ បានធ្វើឱ្យប្រេះឆាដល់ទំនាក់ទំនងសហប្រតិបត្តិការ ដែលមិនអំណោយផលដល់ការអភិវឌ្ឍន៍សមត្ថភាព ។

ផ្អែកលើលទ្ធផលនៃការសិក្សាទាំងពីរខាងលើ និងបន្ទាប់ពីបានពិគ្រោះយោបល់បន្ថែម យើងបានព្រាងឯកសារជំហររបស់រាជរដ្ឋាភិបាលស្តីពីកិច្ចសហប្រតិបត្តិការបច្ចេកទេសសម្រាប់ពិភាក្សា ហើយផ្អែកលើមូលដ្ឋាននេះ ក៏បានរៀបចំឯកសារណែនាំមួយផងដែរ ។ ឯកសារនេះនឹងត្រូវក្លាយជាផ្នែកមួយនៃ «យុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍន៍សមត្ថភាព និងការគ្រប់គ្រងធនធានមនុស្ស» របស់ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល ដើម្បីធានាឱ្យការផ្តួចផ្តើមរបស់រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍អាចបំពេញឱ្យគ្នាទៅវិញទៅមក ទាំងនៅកម្រិតថ្នាក់ជាតិ ទាំងនៅកម្រិតវិស័យ ។

យើងទទួលស្គាល់អំពីសក្តានុពលនៃការបង្កើនការប្រើប្រាស់«កិច្ចសហប្រតិបត្តិការត្បូង-ត្បូង» សម្រាប់អភិវឌ្ឍសមត្ថភាព ។ ទន្ទឹមនេះ ក៏ត្រូវប្រឹងប្រែងបន្ថែមទៀត ដើម្បីពង្រឹងការអនុវត្តន៍គំនិតផ្តួចផ្តើមនានាស្តីពីភាពជាដៃគូ និងការផ្លាស់ប្តូរបទពិសោធន៍ជាមួយគ្នានៅក្នុងកម្រិតតំបន់ផងដែរ ។ ក្នុងស្មារតីនេះ យើងបានរៀបចំសិក្ខាសាលារយៈពេល២ថ្ងៃនៅរាជធានីភ្នំពេញ នាខែមិថុនាកន្លងមកនេះ សម្រាប់សមភាគីរបស់យើង ដែលអញ្ជើញមកពីប្រទេសប៉ាប៉ាញូហ្គីណេ វៀតណាម និងឥណ្ឌូណេស៊ី ។ លើសពីនេះ ក៏បានរៀបចំឱ្យមានការសិក្សារួមគ្នារវាង៣ប្រទេស- កម្ពុជា វៀតណាម និងឡាវ លើប្រធានបទស្តីពី«គណនេយ្យភាពទ្វេទិស» នាខែសីហាកន្លងមកដែរ ។ ភាគីទាំងអស់បានទទួលស្គាល់ថា គំនិតផ្តួចផ្តើមទាំងនេះត្រូវបានអនុវត្តប្រកបដោយជោគជ័យ ព្រោះម៉្យាង ដោយសារបានផ្លាស់ប្តូរបទពិសោធន៍ និងម៉្យាងទៀត ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការជាមួយគ្នា ដែលទាំងនេះគឺជាស្នូលនៃអភិក្រមនៃ«កិច្ចសហប្រតិបត្តិការត្បូង-ត្បូង» ។ ឯកសារណែនាំស្តីពីកិច្ចសហប្រតិបត្តិការបច្ចេកទេស ដែលសមស្របនឹងអភិក្រមនៃការងាររបស់ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលស្តីពីការអភិវឌ្ឍន៍សមត្ថភាព ក៏បានបញ្ជាក់អំពីតម្រូវការនៃការធ្វើកំណែទម្រង់ក្នុងការផ្តល់ និងគ្រប់គ្រងកិច្ចសហប្រតិបត្តិការបច្ចេកទេស សម្រាប់អភិវឌ្ឍសមត្ថភាពតាមរយៈការប្រើប្រាស់ជម្រើសថ្មីៗដទៃទៀតដែរ ។

ភាពជាដៃគូសកល និងគំនិតផ្តួចផ្តើមស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ

រាជរដ្ឋាភិបាលបានចូលរួមក្នុងសកម្មភាពជាច្រើន សម្រាប់ត្រៀមរៀបចំវេទិកាកំពូលស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ ដែលបានប្រារព្ធនៅទីក្រុងអាក្រានាខែកញ្ញា ឆ្នាំ២០០៨ ។ ការវិភាគជាសកលគួបផ្សំជាមួយនឹងសក្ខីភាពជាក់ស្តែង បានផ្តល់មេរៀនល្អជាច្រើនសម្រាប់វាយតម្លៃវឌ្ឍនភាពនៅកម្ពុជា និងកំណត់សកម្មភាពអាទិភាពសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ ។

កិច្ចការដ៏សំខាន់ដែលកម្ពុជាបានអនុវត្តក្នុងឆ្នាំ២០០៨នេះគឺការធ្វើអង្កេតស្តីពីការអនុវត្តន៍សេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស ។ យើងបានដំណើរការតាមរបៀបសាមញ្ញ ដោយប្រើប្រាស់ប្រព័ន្ធទិន្នន័យស្តីពីហិរញ្ញប្បទានសហ-ប្រតិបត្តិការ ដោយមានកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយនឹងដៃគូអភិវឌ្ឍន៍ទាំងអស់ ។ លទ្ធផលនៃការធ្វើអង្កេតត្រូវបានបង្ហាញនៅក្នុងតារាងទី២ខាងក្រោម ហើយនឹងត្រូវវិភាគលំអិតនៅក្នុងជំពូកក្រោយ ។ ប៉ុន្តែ ដូចបានបញ្ជាក់ក្នុងរបាយការណ៍ស្តីពីការវិភាគជាសកល យើងត្រូវបកស្រាយលទ្ធផលនៃការធ្វើអង្កេតនេះដោយប្រុងប្រយ័ត្ន ។ យើងមានពេលតិចតួចណាស់ក្នុងការធ្វើសុពលភាពទិន្នន័យទាំងនេះ ដោយសារការធ្វើអង្កេតនេះបានពឹងផ្អែកលើរបាយការណ៍របស់ដៃគូអភិវឌ្ឍន៍ ដែលពួកគេអាចប្រើប្រាស់វិធីសាស្ត្រ និងអភិក្រមខុសៗពីគ្នា ។ លើសពីនេះ

កង្វល់អំពីផលប្រយោជន៍របស់សូចនាករទាំងឡាយ និងភាពសមស្របរបស់វាចំពោះកម្ពុជា គឺជាប្រធានបទមួយ ដែលត្រូវយកចិត្តទុកដាក់សម្រាប់ការវាយតម្លៃឯករាជ្យ ដែលបានអនុវត្តក្នុងត្រីមាសទី៤ឆ្នាំ២០០៨ ។

តារាងទី២ : សូចនាករសម្រាប់តាមដានការអនុវត្តន៍សេចក្តីថ្លែងការណ៍ទីក្រុងប៉ារីសនៅកម្ពុជា

ល.រ	សូចនាករ	ទិន្នន័យមូលដ្ឋាន ឆ្នាំ២០០៥ (អង្កេតឆ្នាំ២០០៦)	ស្ថានភាពឆ្នាំ ២០០៧ (អង្កេតឆ្នាំ ២០០៨)	គោលដៅ ឆ្នាំ២០១០
១	ការអនុវត្តន៍ក្របខ័ណ្ឌនិងផែនការជាតិ	C	C	B ឬ A
២	គុណភាពនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ	2,5	3	3,5
៣	ហិរញ្ញប្បទានសហប្រតិបត្តិការកត់ត្រាក្នុងថវិកា	79%	85%	90%
៤	កិច្ចសហប្រតិបត្តិការបច្ចេកទេសដោយមានការសម្របសម្រួល	36%	35%	50%
៥a	ការប្រើប្រាស់ប្រព័ន្ធជាតិស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ	10%	12%	គ្មាន
៥b	ការប្រើប្រាស់ប្រព័ន្ធលទ្ធកម្មជាតិ	6%	16%	គ្មាន
៦	អង្គភាពអនុវត្តគម្រោង	49	121	16
៧	ភាពអាចទស្សទាយជាមុនប្រចាំឆ្នាំ	69%	96%	85%
៨	ហិរញ្ញប្បទានសហប្រតិបត្តិការគ្មានភ្ជាប់ចំណង	86%	99%	ច្រើនជាង 86%
៩	ការប្រើប្រាស់អភិក្រមគ្រប់គ្រងទូទាំងវិស័យ	24%	28%	66%
១០a	បេសកកម្មដោយមានការសម្របសម្រួល	26%	12%	50%
១០b	ការសិក្សាដោយមានការសម្របសម្រួល	58%	17%	70%
១១	ក្របខ័ណ្ឌវាយតម្លៃដែលអាចទទួលយកបាន	C	C	B ឬ A
១២	ការពិនិត្យអំពីគណនេយ្យភាពទ្វេទិស	បានអនុវត្ត	បានអនុវត្ត	គោលដៅសម្រេច

ការចូលរួមរបស់កម្ពុជាសម្រាប់រៀបចំគំនិតផ្តួចផ្តើមសកលនានា បានជួយកម្ពុជាឱ្យពង្រឹងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនបន្ថែមទៀត និងបានជម្រុញឱ្យដៃគូអភិវឌ្ឍន៍សម្រួលការផ្លាស់ប្តូរផ្ទៃក្នុងរបស់ពួកគេឱ្យស្របនឹងការប្រែប្រួលរបស់កម្ពុជា ។ ទន្ទឹមនេះ ក៏អាចចាត់ទុកថា សេចក្តីថ្លែងការណ៍ទីក្រុងប៉ារីសគឺជាអាវុធមុខពីរសម្រាប់បង្កើនប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការផងដែរ ។ ប្រការដែលគួរឱ្យកត់សំគាល់គឺដំណើរឆ្ពោះទៅកិច្ចប្រជុំនៅទីក្រុងអាក្រាក្នុងឆ្នាំ២០០៨បានជួបប្រទះការលំបាកនិងឧបសគ្គខ្លះៗ នៅពេលដែលការសិក្សាដក

ពិសោធន៍មួយចំនួនបានរៀបចំឡើងយ៉ាងឆាប់រហ័ស ដែលបង្កើនបន្ទុកបន្ថែមទៀតមកលើរាជរដ្ឋាភិបាល នៅពេលរាជរដ្ឋាភិបាលកំពុងរៀបចំចូលរួមយ៉ាងសកម្មក្នុងកិច្ចការនានាកម្រិតសកល និងទន្ទឹមនឹងពេលដែលរាជរដ្ឋាភិបាលប្រឹងប្រែងអនុវត្តកម្មវិធីការងាររបស់ខ្លួន ។ ទន្ទឹមនេះ សក្ខីភាពជាក់ស្តែងដែលបានពិភាក្សាក្នុងអំឡុងពេលនៃការវាយតម្លៃឯករាជ្យបានបញ្ជាក់ថា ដំណើរការនេះបានក្លាយជាបទដ្ឋានបច្ចេកវិទ្យាមួយ ដែលអ្នកឯកទេសខាងការគ្រប់គ្រងប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការមួយចំនួនបានរៀបចំ ហើយដែលមិនសូវផ្តល់តម្លៃលើគំនិតផ្តួចផ្តើម និងកិច្ចប្រឹងប្រែង និងការសម្រេចចិត្តរបស់ប្រទេសដៃគូនិមួយៗឡើយ ។ ចុងបញ្ចប់ ដូចបានពិភាក្សាពីខាងដើម ការធ្វើអង្កេតនេះបានផ្តោតទៅលើសូចនាករចង្អៀតមួយចំនួន ដែលមិនបានឆ្លុះបញ្ចាំងភាពជាក់ស្តែងរបស់កម្ពុជា ហើយក្នុងករណីនេះ បានធ្វើឱ្យបាក់ទឹកចិត្តក្នុងការរៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពឱ្យបានត្រឹមត្រូវ ។

តម្លៃនៃសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីសត្រូវបានចាត់ទុកថាជាកាលានុវត្តភាពសម្រាប់លើកកំពស់ និងពង្រឹងការប្តេជ្ញាជាសកល ហើយក៏ជាមូលដ្ឋានសម្រាប់កម្ពុជាអនុវត្តអាទិភាពនានាស្តីពីសុខដុមនីយកម្ម ការតម្រឹម និងលទ្ធផលផងដែរ ។ ក្នុងន័យនេះ «ផែនការសកម្មភាពទីក្រុងអាក្រា» បានបង្ហាញអំពីវឌ្ឍនភាពសំខាន់ៗជាច្រើន ហើយក៏បានបញ្ជាក់ពីតម្រូវការបន្ទាន់ ដើម្បីប្រែក្លាយការប្តេជ្ញាឱ្យទៅជាភាពអាចទស្សន៍ទាយបានជាមុននៃការផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការ ការប្រើប្រាស់ប្រព័ន្ធជាតិឱ្យកាន់តែច្រើនឡើង ការកាត់បន្ថយភាពបែកខ្ញែកនៃការផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការ និងការបញ្ជ្រាបបញ្ហាអន្តរវិស័យ ដូចជាយេនឌ័រនិងបរិស្ថាន ទៅក្នុងផែនការតាមវិស័យ ។ ការប្តេជ្ញាទាំងអស់នេះមានលក្ខណៈស្របជាមួយនឹងអាទិភាពរបស់កម្ពុជា ។ ក្នុងស្មារតីនេះ ការពិភាក្សាលើអនុសាសន៍កម្រិតគោលនយោបាយ និងសកម្មភាពចាំបាច់នានានឹងត្រូវបង្ហាញនៅក្នុងជំពូកទី៥ ។

ការត្រិះរិះពិចារណាអំពីភាពជាដៃគូ ដោយផ្អែកលើការវាយតម្លៃប្រសិទ្ធភាពនៃហិរញ្ញប្បទាន សហប្រតិបត្តិការនៅកម្ពុជា

ការវាយតម្លៃឯករាជ្យត្រូវបានអនុវត្ត បន្ទាប់ពីវេទិកាកំពូលនៅទីក្រុងអាក្រាស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ ។ ការវាយតម្លៃឯករាជ្យនេះបានផ្តល់កាលានុវត្តភាពសម្រាប់រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ពិនិត្យវឌ្ឍនភាព និងកំណត់ទិសដៅសម្រាប់អនុវត្តផែនការសកម្មភាពស្តីពីសុខដុមនីយកម្ម ការតម្រឹមនិងលទ្ធផលនាអនាគត ។ ផ្អែកលើរបាយការណ៍ស្វ័យវាយតម្លៃរបស់ដៃគូអភិវឌ្ឍន៍ និងក្រុមការងារបច្ចេកទេសចម្រុះ គួបផ្សំជាមួយនឹងការត្រួតពិនិត្យឯករាជ្យ ការវាយតម្លៃប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការបានបញ្ជាក់ពីតម្រូវការនៃការយកចិត្តទុកដាក់បន្ថែមទៀតទៅលើសកម្មភាពអាទិភាពមួយចំនួន ដោយមិនបាច់កែសម្រួលជាដុំកំភួនលើផែនការសកម្មភាពស្តីពីសុខដុមនីយកម្ម ការតម្រឹម និងលទ្ធផលនេះឡើយ ។ របាយការណ៍នេះបានបញ្ជាក់អំពីតម្រូវការនៃការបង្កើនប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ ដោយត្រូវធ្វើការដោយផ្ទាល់ជាមួយក្រសួងនិងស្ថាប័ននៅថ្នាក់ជាតិ ព្រមទាំងកាត់បន្ថយកិច្ចដំណើរការដែលមិនចាំបាច់ ដែលទាំងអស់នេះអាចជួយជម្រុញដល់កិច្ចអភិវឌ្ឍន៍របស់ប្រទេស ។ បញ្ហាសំខាន់ៗនានាដែលបានលើកឡើងក្នុងអំឡុងពេលនៃការវាយតម្លៃឯករាជ្យមានបង្ហាញនៅក្នុងតារាងខាងក្រោមនេះ ព្រមទាំងបានអត្ថាធិប្បាយលំអិតក្នុងជំពូកទី៣ ។ បញ្ហាសំខាន់ៗដែលតម្រូវឱ្យមានដំណោះស្រាយក្នុងកម្រិតគោលនយោបាយនោះគឺ ÷

- ***ភាពដឹកនាំ***: គំនិតផ្តួចផ្តើមសម្រាប់ពង្រឹងភាពជាម្ចាស់ លទ្ធភាពកសាងភាពជាដៃគូ និងការអភិវឌ្ឍន៍សមត្ថភាព គឺជាសញ្ញានៃភាពដឹកនាំ ។

- ***គណនេយ្យភាពទ្វេទិស*** : តម្រូវការសកម្មភាពក្នុងកម្រិតជាច្រើន : ទំនាក់ទំនងក្រសួងនិងស្ថាប័នថ្នាក់ជាតិ ទំនាក់ទំនងគ្រប់វិស័យ ការលើកទឹកចិត្តរបស់ដៃគូអភិវឌ្ឍន៍ និងវេទិកាសម្រាប់ពិភាក្សារួមគ្នា ។

- ***ការនឿយណាយ***: ចាប់ពីបានបង្កើតក្របខ័ណ្ឌគោលនយោបាយ និងរបៀបរបបដំណើរការមក អ្នកអនុវត្ត ទាំងខាងរាជរដ្ឋាភិបាល ទាំងខាងដៃគូអភិវឌ្ឍន៍ហាក់ដូចជាត្រូវជាប់គាំងក្នុងយន្តការ ហើយជួបប្រទះការលំបាកក្នុងការកៀរគរភាគីពាក់ព័ន្ធដទៃ ឱ្យចូលរួមអនុវត្តជាមួយគ្នា ។

សេចក្តីសន្និដ្ឋាន

កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ បានបង្ហាញអំពីការប្តេជ្ញាសម្រាប់ពង្រឹងភាពជាដៃគូ ។ ទោះជាយ៉ាងនេះក្តី ក៏មានការលំបាកក្នុងការសន្និដ្ឋានអំពីការប្រែក្លាយភាពជាដៃគូនេះឱ្យទៅជាការអនុវត្តន៍ឱ្យមានប្រសិទ្ធភាព នូវសកម្មភាពអាទិភាពដែលបានព្រមព្រៀងគ្នា ព្រោះថាអនុសាសន៍ដែលបានអនុមតិនៅវេទិកាសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាតម្រូវឱ្យមានការពិនិត្យពិចារណា និងការអនុវត្តន៍បន្ថែមទៀត ។

មុននឹងពិនិត្យការវិភាគអំពីបរិមាណនៃហិរញ្ញប្បទានសហប្រតិបត្តិការនៅក្នុងជំពូកបន្ទាប់នេះ សក្ខីភាពជាក់ស្តែងជាច្រើនដែលបានទទួលពីការពិនិត្យអំពីគុណភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ បានបញ្ជាក់ថាមានការនឿយណាយក្នុងកិច្ចប្រឹងប្រែងបង្កើនប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ ។ ការត្រួតពិនិត្យឯករាជ្យបានបញ្ជាក់ថា ប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការអាចប្រឈមនឹងហានិភ័យ ដោយសាររបៀបដំណើរការរបស់ខ្លួន ។ ប្រការនេះតម្រូវឱ្យរៀបចំអភិក្រមគ្រប់ជ្រុងជ្រោយ ដែលអាចប្រតិបត្តិការជាក់ស្តែងបាន ដោយត្រូវកំណត់ទិសដៅកម្រិតគោលនយោបាយ

> <u>ការវាយតម្លៃឯករាជ្យស្តីពីប្រសិទ្ធភាពនៃ</u>
> <u>ហិរញ្ញប្បទានសហប្រតិបត្តិការ</u>
>
> ១- ស្ថានភាពទូទៅមានលក្ខណៈចម្រុះ តាមរយៈសក្ខីភាពជាក់ស្តែង ដែលមានវឌ្ឍនភាពគួរឱ្យកត់សំគាល់នៅក្នុងវិស័យមួយចំនួន ហើយមានការលំបាកក្នុងវិស័យមួយចំនួនផ្សេងទៀត។
> ២- ភាពដឹកនាំនិងសមត្ថភាពរបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍គឺជាកត្តាសំខាន់បំផុតក្នុងការកំណត់ភាពជោគជ័យ ។
> ៣- ទំនាក់ទំនងរវាងបណ្តាស្ថាប័នរាជរដ្ឋាភិបាលនៅថ្នាក់ជាតិគឺជាបញ្ហាសំខាន់ក្នុងការបូកសរុបសមិទ្ធផលនៃការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។
> ៤- កម្មវិធីតាមវិស័យត្រូវផ្តោតលើសកម្មភាពជាក់លាក់ ដើម្បីរៀបចំផែនការ ធនធាន សកម្មភាព និងលទ្ធផលរំពឹងទុក ។
> ៥- អភិក្រមដែលមានលក្ខណៈស្មុគស្មាញ និងបច្ចេកទេសសុទ្ធសាធអាចបង្កឧបសគ្គសម្រាប់ការអនុវត្តន៍ ។ ការណែនាំកម្រិតគោលនយោបាយអាចជួយពន្លឿនឱ្យមានវឌ្ឍនភាព ។
> ៦- ជម្រុញឱ្យមានការចូលរួមឱ្យកាន់តែទូលំទូលាយថែមទៀតពីភាគីពាក់ព័ន្ធទាំងឡាយ ដូចជាសភាជាតិ និងសង្គមស៊ីវិលនៅពេលដែលកិច្ចដំណើរការមានលក្ខណៈរឹងមាំហើយ ។
> ៧- ការតម្រឹម និងកិច្ចអភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធភាព តម្រូវឱ្យវិភាជន៍ធនធានឡើងវិញដោយផ្តោតទៅលើវិស័យកសិកម្ម និងសេវាកម្មតាមបែបវិមជ្ឈការ ។
> ៨- ជវភាពនៃទំនាក់ទំនងរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ត្រូវពិចារណាឡើងវិញ ក្នុងស្មារតីលើកកំពស់សមត្ថភាពនៃភាពជាដៃគូ ។
> ៩- ការគួបផ្សំរវាងហិរញ្ញប្បទានសហប្រតិបត្តិការ ជាមួយនឹងការអភិវឌ្ឍន៍សមត្ថភាពក្នុងបរិបទកំណែទំរង់ នឹងក្លាយជាមូលដ្ឋាននៃការរៀបចំកម្មវិធីហិរញ្ញប្បទានសហប្រតិបត្តិការនាអនាគត ។
> ១០- ការជំនះភាពនឿយណាយតម្រូវឱ្យរៀបចំអាទិភាពមុតស្រួច ការចូលរួមឱ្យកាន់តែទូលាយថែមទៀត និងគណនេយ្យ-ភាពទ្វេទិសដោយផ្តោតលើលទ្ធផល ។

ច្បាស់លាស់ ភាពដឹកនាំដ៏រឹងមាំរបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ដើម្បីកាត់បន្ថយការវិភាគស្មុគស្មាញ ដំណោះស្រាយដែលមានលក្ខណៈបច្ចេកទេស និងផែនការលំអិតហួសហេតុ ដែលក្នុងករណីខ្លះ ធ្វើឱ្យការអនុវត្តន៍ត្រូវជាប់គាំង ។

អភិក្រមបែបនេះតម្រូវឱ្យបង្កើតកាលានុវត្តភាពថ្មីៗជាច្រើនបន្ថែមទៀតសម្រាប់បង្កើនជំនឿទុកចិត្តរវាងមន្ត្រីជាន់ខ្ពស់នៃរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ដែលជាសមភាគី ពិសេសនៅកម្រិតក្រុមការងារបច្ចេកទេសចម្រុះ និងដើម្បីកំណត់រួមគ្នានូវសកម្មភាពអាទិភាពមួយចំនួនដែលអាចអនុវត្តឱ្យសម្រេច ដោយត្រូវពិនិត្យអំពីធនធាន និងសមត្ថភាពរបស់ភាគីទាំងសងខាង ។ គោលជំហរនេះត្រូវបានបញ្ជាក់យ៉ាងច្បាស់លាស់នៅក្នុង «យុទ្ធសាស្ត្រចតុកោណ» និង «របាយការណ៍ពាក់កណ្តាលអាណត្តិនៃការអនុវត្តន៍ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ» ដែលបានរំលឹកឱ្យស្វែងរកដំណោះស្រាយត្រឹមត្រូវ សម្រាប់គាំទ្រដល់ការអនុវត្តន៍អាទិភាពនានានៃកិច្ចអភិវឌ្ឍន៍ ។

\- - - - - - - -

ជំពូក ៣
និន្នាការនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍

ដោយផ្អែកលើសក្ខីភាពជាក់ស្តែង ជំពូកនេះនឹងគូសបញ្ជាក់អំពីនិន្នាការសំខាន់ៗមួយចំនួនក្នុងការផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការនៅក្នុងចន្លោះឆ្នាំ២០០៦-២០០៨ និងការប៉ាន់ស្មានផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់ឆ្នាំ២០០៩-២០១០ផងដែរ (ទោះបីទិន្នន័យឆ្នាំ២០០៩ និងឆ្នាំ២០១០មានលក្ខណៈបណ្តោះអាសន្នសម្រាប់ការឆ្លុះបញ្ចាំងតែប៉ុណ្ណោះ) ។ ទិន្នន័យទាំងនេះ គួបផ្សំនឹងលទ្ធផលនៃការសិក្សាដទៃទៀត គឺជាមូលដ្ឋានសំខាន់សម្រាប់ពិនិត្យការជះឥទ្ធិពលក្នុងគោលនយោបាយគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ និងផែនការសកម្មភាពស្តីពីសុខដុមនីយកម្ម ការតម្រឹម និងលទ្ធផល ក្នុងបរិការណ៍នៃ «យុទ្ធសាស្ត្រចតុកោណ» និង«ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ» ។

ការធ្វើវិភាគហិរញ្ញប្បទានសហប្រតិបត្តិការក្នុងក្របខ័ណ្ឌនៃកិច្ចអភិវឌ្ឍន៍ជារួម គឺជាកិច្ចការចាំបាច់ ក្នុងពេលដែល «យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី២» បានកំណត់បណ្តាអាទិភាពរបស់ប្រទេស និងរបាយការណ៍ពាក់កណ្តាលអាណត្តិស្តីពីការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ បានឆ្លុះបញ្ចាំងពីវឌ្ឍនភាពរហូតមកដល់ពេលបច្ចុប្បន្ននេះ ។ របាយការណ៍នេះបានផ្តល់កាលានុវត្តភាពសម្រាប់រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ធ្វើការកែតម្រូវចាំបាច់មួយចំនួន ទាំងនៅកម្រិតគោលនយោបាយ ទាំងការវិភាជន៍និងគ្រប់គ្រងធនធាន ។

យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី២

«យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី២»បានបន្តផ្តោតទៅលើសន្តិភាព និងស្ថេរភាព ។ ទន្ទឹមនឹងនេះ ក៏ទទួលស្គាល់ផងដែរ អំពីតម្រូវការចាំបាច់ក្នុងការពង្រឹងមូលដ្ឋានសម្រាប់កំណើនប្រកបដោយចីរភាពក្នុងរយៈពេលវែងឱ្យបានដល់ ៧%ក្នុងមួយឆ្នាំ ក្នុងគោលដៅបន្តកាត់បន្ថយអត្រាភាពក្រីក្រឱ្យបាន១%ក្នុងមួយឆ្នាំ និងដើម្បីកែលំអវិស័យសង្គមកិច្ច ពិសេសវិស័យសុខាភិបាល អប់រំ និងសមភាពខាងយេនឌ័រ ។ អាទិភាពនៃ «យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី២» រួមមាន ÷

- *អភិបាលកិច្ចល្អ*: ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ កំណែទម្រង់ច្បាប់និងប្រព័ន្ធតុលាការ កំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ និងកំណែទម្រង់កងកម្លាំងប្រដាប់អាវុធ។
- *បរិស្ថានគ្របដណ្តប់* : សន្តិភាព ស្ថេរភាព និងសណ្តាប់ធ្នាប់សង្គម សមាហរណកម្មពិភពលោក ភាពជាដៃគូជាមួយនឹងវិស័យឯកជន អង្គការសង្គមស៊ីវិលនិងដៃគូអភិវឌ្ឍន៍ និងបរិស្ថានអំណោយផលខាងម៉ាក្រូសេដ្ឋកិច្ច ។
- *កំណើនសេដ្ឋកិច្ច* : ជំរុញការអភិវឌ្ឍន៍កសិកម្ម ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត វិស័យឯកជន និងការអភិវឌ្ឍន៍សមត្ថភាព ព្រមទាំងការគ្រប់គ្រងធនធានមនុស្ស ។

ការត្រួតពិនិត្យពាក់កណ្តាលអាណត្តិនៃការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ

វឌ្ឍនភាព និងបញ្ហាប្រឈមនានាដែលបានរំលេចចាប់តាំងពីដើមឆ្នាំ២០០៦ បានផ្តល់ជា «សំណៅឯកសារជាក់ស្តែង» សម្រាប់កំណត់ឱ្យបានល្អិតល្អន់បន្ថែមនូវបណ្តាអាទិភាពនៃយុទ្ធសាស្ត្រចតុកោណ ។ ការត្រួតពិនិត្យពាក់កណ្តាលអាណត្តិនៃការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបានធ្វើបច្ចុប្បន្នភាពពីតម្រូវការហិរញ្ញប្បទានដូចមានក្នុងតារាងខាងក្រោម ដើម្បីរំលេចអាទិភាពនៃសន្តិសុខស្បៀងនិងកំណើនជនបទ ។

តារាងទី៣ - ការវិភាជន៍ធនធានក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០០៦ - ២០១០ (គិតជាលានដុល្លា)

វិស័យ	2006 **ផយអជ**	2006 % **វិភាជន៍**	2008 MTR **កែប្រែ**	2008 % **វិភាជន៍**	2006 – 2008 % **ប្រែប្រួល**
វិស័យសង្គមកិច្ច					
អប់រំ (មូលដ្ឋាន = ៦០ភាគរយ)	550	15,71%	670	15,95%	22%
សុខាភិបាល	600	17,14%	720	17,14%	20%
សរុប	1.150	32,85%	1.390	33,10%	21%
វិស័យសេដ្ឋកិច្ច					
កសិកម្ម និង ការគ្រប់គ្រងដីធ្លីៈ ក្រៅពីធញ្ញជាតិ	150	4,29%	200	4,76%	33%
ធញ្ញជាតិតាមរដូវៈ ស្រូវ ។ល។	200	5,71%	370	8,81%	85%
អភិវឌ្ឍន៍ជនបទ	350	10,00%	420	10,00%	20%
កម្មន្តសាល រ៉ែ និងពាណិជ្ជកម្ម	80	2,29%	100	2,38%	25%
សរុប	780	22,29%	1.090	25,95%	40%
ហេដ្ឋារចនាសម្ព័ន្ធ					
ដឹកជញ្ជូន (ផ្លូវជាតិ និងផ្លូវខេត្ត- ក្រុង)	550	15,71%	690	16,43%	25%
ទឹកស្អាត និងអនាម័យ (មិនគិតជនបទ)	150	4,29%	180	4,29%	20%
ថាមពល និងអគ្គិសនី	120	3,43%	160	3,81%	33%
ប្រៃសណីយ៍ និងទូរគមនាគមន៍	60	1,71%	75	1,79%	25%
សរុប	880	25,14%	1.105	26,31%	26%
សេវាកម្ម និងកម្មវិធីអន្តរវិស័យ					
ការបញ្ជ្រាបយេនឌ័រ	30	0,86%	40	0,95%	33%
ទេសចរណ៍	30	0,86%	45	1,07%	50%
បរិស្ថាន និងអភិរក្ស	100	2,86%	120	2,86%	20%
សហគមន៍ និងសេវាកម្មសង្គម	80	2,29%	100	2,38%	25%
វប្បធម៌ និងវិចិត្រសិល្បៈ	30	0,86%	40	0,95%	33%
អភិបាលកិច្ច និងរដ្ឋបាល	220	6,29%	270	6,43%	23%
សរុប	490	14,00%	615	14,64%	26%
ធនធានមិនទាន់វិភាជន៍	200	5,71%			
សរុបៈ	3.500	100%	4.200	100%	20%

ប្រភព : ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០០៦- តារាងទី៥.២ និងរបាយការណ៍ពាក់កណ្តាលអាណត្តិស្តីពីការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០០៨- តារាងទី៤.៣

សកម្មភាពអាទិភាពដទៃទៀតដែលបានជម្រុញឱ្យសម្រេចគោលដៅនៃយុទ្ធសាស្ត្រចតុកោណ មានដូចខាងក្រោម ÷

- រក្សាឱ្យបាននូវស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច ស្របពេលដែលសកលលោកកំពុងជួបវិបត្តិកលយុគហិរញ្ញវត្ថុ និងផ្តល់ឱ្យគ្រប់គ្រាន់នូវបណ្តាញសុវត្ថិភាពសង្គមដល់ជនដែលទទួលឥទ្ធិពលពីអសន្តិសុខស្បៀង ។
- ពង្រឹងការងារផែនការនីយកម្មនិងថវិកានីយកម្ម ដើម្បីធានាការវិភាគន៍ធនធាននិងការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព រួមទាំងតម្រឹមធនធានក្រៅប្រទេស និងពង្រឹងទំនាក់ទំនងរវាងបណ្តាក្រសួងនិងស្ថាប័ននៅថ្នាក់ជាតិ ។
- យកចិត្តទុកដាក់បន្ថែមទៀតលើការអភិវឌ្ឍន៍វិស័យកសិកម្មនិងអភិវឌ្ឍន៍ជនបទ តាមរយៈការវិនិយោគដែលបំពេញឱ្យគ្នាទៅវិញទៅមក រវាងផ្នែកហេដ្ឋារចនាសម្ព័ន្ធជនបទ សេវាហិរញ្ញវត្ថុ ពិពិធកម្មកសិកម្ម បច្ចេកទេសកែច្នៃ និងបច្ចេកទេសរក្សាកសិផលក្រោយពេលប្រមូលផល ។

នៅពេលឆ្លុះបញ្ចាំងអំពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ យើងត្រូវប្រើប្រាស់គោលនយោបាយកម្រិតថ្នាក់ជាតិ ដើម្បីប្លុកសរុបសកម្មភាពជាក់ស្តែងនានាដែលពាក់ព័ន្ធនឹងវឌ្ឍនភាព សម្រាប់ឈានទៅសម្រេចលទ្ធផលដែលបានរំពឹងទុក ។

និន្នាការសរុបនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍

និន្នាការទូទៅនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍នៅចុងឆ្នាំ២០០៨មានលក្ខណៈវិជ្ជមាន (ទោះបីជាតួលេខហិរញ្ញប្បទាននៅឆ្នាំ២០០៨មានលក្ខណៈបណ្តោះអាសន្ននៅឡើយ) ហើយបានកើនឡើង១១% ប្រៀបធៀបនឹងឆ្នាំ២០០៧ ដែលមានប្រមាណ៧៩០,៤លានដុល្លាអាមេរិក[២] ។ រូបភាពទី១បានបង្ហាញថា កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍បានកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ។ នេះជាសមិទ្ធផលគួរឱ្យកត់សំគាល់សម្រាប់កម្ពុជា ក្នុងពេលដែលទំហំនៃហិរញ្ញប្បទានសហប្រតិបត្តិការទូទៅលើសកលលោកស្ថិតនៅទ្រឹង ឬក៏ធ្លាក់ចុះ ។

រូបភាពទី១ : ការប្រើប្រាស់ និងការប៉ាន់ស្មានហិរញ្ញប្បទានសហប្រតិបត្តិការឆ្នាំ២០០១-២០១០(លានដុល្លា)



<u>កំណត់សំគាល់</u>: តួលេខឆ្នាំ២០១០មិនបានកត់ត្រាធនធានរបស់អង្គការក្រៅរដ្ឋាភិបាល- ទិន្នន័យឆ្នាំ២០០៩-២០១០ កត់ត្រាតែធនធានដែលបានសន្យា

---

[២] <u>កំណត់សំគាល់</u> : ទិន្នន័យទាំងអស់នេះត្រូវបានដកស្រង់ពីប្រព័ន្ធគ្រប់គ្រងទិន្នន័យហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ផ្លូវការរបស់កម្ពុជា
ទិន្នន័យទាំងអស់នេះត្រូវបានធ្វើសុពលភាពត្រឹមថ្ងៃទី១៤ ខែតុលា ឆ្នាំ២០០៨

រូបភាពទី១ក៏បានឆ្លុះបញ្ចាំងអំពីចំណុចសំខាន់ៗដទៃទៀតផងដែរ ÷

ក- ការប្រើប្រាស់ហិរញ្ញប្បទានឆ្នាំ២០០៦ ដែលបានលើកឡើងក្នុងរបាយការណ៍ស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការនៅកម្ពុជាឆ្នាំ២០០៧ មានចំនួន៥៩០,៤លានដុល្លាអាមេរិក ។ ប៉ុន្តែ តួលេខនេះត្រូវបានធ្វើបច្ចុប្បន្នភាពឡើងវិញ ហើយបានកើនដល់៧១៣,២លានដុល្លាអាមេរិក ពោលគឺបានកើនឡើងប្រមាណ២០% ឬ ១២០លានដុល្លាអាមេរិក ក្នុងនោះបានកត់ត្រាបន្ថែមពីការលុបបំណុលរបស់អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិចំនួន៨២លានដុល្លាអាមេរិកផងដែរ ។

ខ- បន្ទាប់ពីកម្ចីបានធ្លាក់ចុះមួយរយៈ ធៀបនឹងហិរញ្ញប្បទានសរុប ការផ្តល់កម្ចីមានភាពល្អប្រសើរវិញដោយបានកើនឡើងពី១៩%ក្នុងឆ្នាំ២០០៦ ទៅ២៨%ក្នុងឆ្នាំ២០០៧ ដោយសារអ្នកផ្តល់កម្ចីទាំងនោះ (ដូចជាធនាគារអភិវឌ្ឍន៍អាស៊ី អង្គការមូលនិធិសម្រាប់អភិវឌ្ឍកសិកម្ម សាធារណរដ្ឋប្រជាមានិតចិន ជប៉ុន សាធារណរដ្ឋកូរ៉េ និងបារាំង) បានបង្កើនសកម្មភាពរៀងៗខ្លួន ។

គ- ទិន្នន័យសម្រាប់ឆ្នាំ២០០៨ ២០០៩ និង២០១០ គឺជាតួលេខប៉ាន់ស្មានហើយមិនទាន់ជាតួលេខផ្លូវការនៅឡើយ ។ នៅក្នុងអំឡុង៣ឆ្នាំនេះ ហិរញ្ញប្បទានផ្ទាល់របស់អង្គការក្រៅរដ្ឋាភិបាលមិនទាន់បានកត់ត្រាទេ ។ ទន្ទឹមនេះ ទិន្នន័យសម្រាប់ឆ្នាំ២០០៩ និង២០១០ ដែលជាតួលេខប៉ាន់ស្មាន បានកត់ត្រាតែហិរញ្ញប្បទានដែលបានសន្យាសម្រាប់បណ្តាគម្រោងកំពុងដំណើរការ និងគម្រោងអាទិភាពខ្ពស់តែប៉ុណ្ណោះ (ហិរញ្ញប្បទានដែលមិនទាន់បានសន្យា មិនបានកត់ត្រាបញ្ចូលនៅឡើយ) ។

<u>*ការកត់សំគាល់អំពីអត្រាប្តូរប្រាក់*</u>: របាយការណ៍ស្តីពីអត្រាប្តូរប្រាក់ឆ្នាំ២០០៧ បានបង្ហាញថាអត្រាប្តូរប្រាក់អាមេរិកបានធ្លាក់ចុះប្រមាណ៥-១០% បើធៀបនឹងឆ្នាំ២០០៦ (ទោះបីជាអត្រាប្តូរប្រាក់យេនជប៉ុនបានធ្លាក់ចុះតែ១%ប៉ុណ្ណោះ-ជប៉ុនជាដៃគូអភិវឌ្ឍន៍ដ៏ធំជាងគេបង្អស់របស់កម្ពុជា) ។ របាយការណ៍ស្តីពីអត្រាប្តូរប្រាក់ឆ្នាំ២០០៨ បានបង្ហាញថា រូបិយប័ណ្ណអាមេរិកបានបន្តចុះ១០% បើធៀបនឹងរូបិយប័ណ្ណដទៃទៀត ។ ក្នុងស្មារតីនេះ ការពិនិត្យទិន្នន័យស្តីពីការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការសរុប គិតជារូបិយប័ណ្ណដុល្លាអាមេរិក ក៏ត្រូវយកចិត្តទុកដាក់អំពីបរិការណ៍នេះ ។ ទន្ទឹមនេះប្រមាណ៤៥%នៃហិរញ្ញប្បទានសហប្រតិបត្តិការដែលផ្តល់មកកម្ពុជាជារូបិយប័ណ្ណដុល្លាអាមេរិក ក៏មិនទទួលរងឥទ្ធិពលពីការប្រែប្រួលអត្រាប្តូរប្រាក់នេះឡើយ ។

ការផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការតាមប្រភពត្រូវបានបង្ហាញក្នុងតារាងទី៤ខាងក្រោម ។ ដូចបណ្តាឆ្នាំកន្លងមក ជប៉ុនបានផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការច្រើនជាងគេបង្អស់មកកម្ពុជាក្នុងឆ្នាំ២០០៧នេះ ដែលមានទំហំ១២២,១លានដុល្លាអាមេរិក (ស្មើនឹង១៥%នៃហិរញ្ញប្បទានសរុប និងបានកើនឡើងប្រមាណ១៨%ក្នុងមួយឆ្នាំ) ។ ទន្ទឹមនឹងនេះ ក៏គួរកត់សំគាល់ផងដែរថា ហិរញ្ញប្បទានពីសាធារណរដ្ឋប្រជាមានិតចិន បានកើនឡើងយ៉ាងខ្លាំង ប្រមាណ ៧៥%ក្នុងមួយឆ្នាំ ហើយហិរញ្ញប្បទាននេះត្រូវបានប្រើប្រាស់សម្រាប់ស្តារហេដ្ឋារចនាសម្ព័ន្ធ ។ កំណត់សំគាល់ដទៃទៀតរួមមាន ÷

ក- ធនាគារពិភពលោក ដាណឺម៉ាក ណូវែលហ្សេឡង់ និងសាធារណរដ្ឋកូរ៉េ បានផ្តល់ហិរញ្ញប្បទានទ្វេដងដល់កម្ពុជា ។

តារាងទី៤ - ការព្យាករណ៍ និងការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការជាក់ស្តែងរបស់ដៃគូអភិវឌ្ឍន៍ ២០០២- ២០១០ (លានដុល្លា)

ដៃគូអភិវឌ្ឍន៍	2002	2003	2004	2005	2006	2007 (តួលេខបឋម) USD	%	2002-2007 សរុប USD	%	2008 (ប៉ាន់ស្មាន)	2009 (ព្យាករណ៍)	2010 (ព្យាករណ៍)
អង្គការសហប្រជាជាតិ និងស្ថាប័នពហុភាគី												
កម្មវិធីអង្គការសហប្រជាជាតិ (ធនធានសរុប)	81,8	88,3	73,8	91,8	96,3	96,4	12,2	528,4	---			
អង្គការសហប្រជាជាតិ (ធនធានផ្ទាល់)	42,2	44,2	36,3	41,1	54,0	52,4	6,6	270,2	7,2	94,1	58,4	40,2
ធនាគារពិភពលោក	47,2	63,7	49,5	37,8	24,5	47,6	6,0	270,3	7,2	57,1	27,6	7,9
មូលនិធិរូបិយវត្ថុអន្តរជាតិ	23,5	12,3	2,4	0,3	83,5	0,9	0,1	122,9	3,3			
ធនាគារអភិវឌ្ឍន៍អាស៊ី	78,5	73,3	76,7	89,4	67,5	69,4	8,8	454,7	12,2	114,0	99,5	90,8
មូលនិធិសកល				18,8	21,9	21,1	2,7	61,8	1,7	32,3	17,4	
សរុប	**191,4**	**193,4**	**164,8**	**187,5**	**251,2**	**191,4**	**24,2**	**1.179,8**	**31,6**	**297,4**	**202,9**	**138,9**
សហភាពអឺរ៉ុប												
សហគមន៍អឺរ៉ុប	25,8	32,7	15,0	23,7	46,5	44,9	5,7	188,6	5,0	52,1	40,4	18,0
បែលហ្ស៊ិក	2,2	3,7	5,2	11,7	7,3	8,0	1,0	38,2	1,0	3,3	4,0	
ដាណឺម៉ាក	4,8	4,3	5,8	4,8	4,1	9,8	1,2	33,5	0,9	10,1	12,9	10,4
ហ្វាំងឡង់	0,9		3,3	3,3	4,5	5,2	0,7	17,2	0,5	6,8	5,3	0,2
បារាំង	28,3	25,9	23,0	24,4	21,8	21,8	2,8	145,3	3,9	33,3	30,4	32,2
អាល្លឺម៉ង់	17,2	17,6	14,1	27,3	32,4	36,5	4,6	145,1	3,9	33,0	38,6	19,5
ហុល្លង់	3,7	2,8	1,6	1,1	0,1	0,1		9,4	0,3	0,0		
អេស្ប៉ាញ					2,8	4,1	0,5	7,0	0,2	7,4	3,5	
ស៊ុយអែត	13,6	12,4	22,0	13,6	16,0	17,3	2,2	94,9	2,5	17,9	21,0	10,1
ចក្រភពអង់គ្លេស	11,6	15,4	17,0	20,6	20,7	23,7	3,0	108,9	2,9	37,8	35,3	35,8
សរុប	**108,2**	**114,7**	**107,1**	**130,6**	**156,1**	**171,4**	**21,7**	**788,1**	**21,1**	**201,7**	**191,5**	**126,3**
ដៃគូអភិវឌ្ឍន៍ទ្វេភាគី												
អូស្ត្រាលី	17,8	22,7	24,3	16,8	22,5	29,6	3,7	133,6	3,6	23,0	19,3	17,3
កាណាដា	3,4	2,6	1,5	9,1	7,9	8,7	1,1	33,2	0,9	19,2	15,2	6,1
ចិន	5,7	5,6	32,5	46,6	53,2	92,4	11,7	236,1	6,3	127,9	67,1	47,5
ជប៉ុន	105,6	101,2	101,8	111,7	103,7	122,1	15,4	646,0	17,3	144,6	53,0	26,3
ណូវែលហ្សេឡង់	1,3	1,9	2,4	2,1	1,7	3,8	0,5	13,2	0,4	3,3	3,6	3,6
ន័រវេស	3,4	2,7	3,4					9,5	0,3			
សាធារណរដ្ឋកូរ៉េ	22,5	10,3	24,1	14,9	13,3	31,4	4,0	116,5	3,1	12,1	19,6	5,6
ស្វីស	2,9	2,5	3,2	2,8	2,4	3,6	0,5	17,5	0,5	3,8	2,8	
សហរដ្ឋអាមេរិក	22,1	34,3	40,6	43,3	51,0	58,1	7,4	249,3	6,7	54,9	52,7	
សរុប	**185,7**	**184,2**	**234,1**	**247,2**	**255,7**	**349,8**	**44,3**	**1.456,6**	**39,0**	**388,8**	**233,4**	**106,4**
អង្គការក្រៅរដ្ឋាភិបាល (ធនធានផ្ទាល់)	**45,6**	**47,2**	**49,4**	**44,7**	**50,2**	**77,7**	**9,8**	**314,9**	**8,4**			
សរុប	**530,9**	**539,5**	**555,4**	**610,0**	**713,2**	**790,4**	**100**	**3.739,4**	**100**	**888,9**	**628,8**	**371,6**

ខ- ការកើនឡើងនៃហិរញ្ញប្បទានសហប្រតិបត្តិការគួរឱ្យកត់សំគាល់ (គិតជា%) ពីប្រទេសស្វីស (៥០%) អេស្ប៉ាញ (៨៦%) អូស្ត្រាលី (៣២%) ហ្វាំងឡង់ (១៦%) ចក្រភពអង់គ្លេស (១៤%) សហរដ្ឋអាមេរិក (១៤%) អាល្លឺម៉ង់ (១៣%) និងកាណាដា (១០%) ។

គ- គួរកត់សំគាល់ថា ហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍បីប៉ុណ្ណោះ (អង្គការសហប្រជាជាតិ មូលនិធិសកលប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍ ជំងឺរបេងនិងជំងឺគ្រុនចាញ់ សហភាពអឺរ៉ុប) បានថយចុះតែបន្តិចបន្តួចប៉ុណ្ណោះ ។ នេះបញ្ជាក់អំពីស្ថេរភាពនៃកម្មវិធីសហប្រតិបត្តិការ (មិនរាប់បញ្ចូលការលុបបំណុលរបស់អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិក្នុងឆ្នាំ២០០៦) ។

រូបភាពទី២ខាងក្រោមនេះបានបង្ហាញលំអិតអំពីការប្រែប្រួលប្រចាំឆ្នាំនៃការប្រើប្រាស់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ ។ តារាងនេះបានរំលេចអំពីការកើនឡើងនៃការផ្តល់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ស្ទើរទាំងអស់ក្នុងឆ្នាំ២០០៧ ហើយនេះបានបង្ហាញសញ្ញាវិជ្ជមាននៃការគាំទ្ររបស់ដៃគូអភិវឌ្ឍន៍ក្នុងកិច្ចអភិវឌ្ឍន៍ជាតិ ។

រូបភាពទី២ : ការប្រែប្រួលប្រចាំឆ្នាំនៃការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការ (ឆ្នាំ២០០៦-២០០៧)



គំនិតផ្តួចផ្តើមដ៏សំខាន់មួយនៃកិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ គឺការព្យាករណ៍ធនធានសម្រាប់បណ្តាឆ្នាំខាងមុខ ដែលជាឧបករណ៍ចាំបាច់សម្រាប់រៀបចំថវិកា កម្មវិធីវិនិយោគសាធារណៈ និងក្របខ័ណ្ឌចំណាយសម្រាប់រយៈពេលមធ្យម ។ ការត្រួតពិនិត្យពាក់កណ្តាលអាណត្តិនៃការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងការវាយតម្លៃស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ (ស្វ័យវាយតម្លៃ និងការត្រួតពិនិត្យឯករាជ្យ) បានកត់សំគាល់នូវទំនាក់ទំនងយ៉ាងជិតស្និទ្ធ រវាងប្រព័ន្ធគ្រប់គ្រងទិន្នន័យស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ផ្លូវការរបស់ គ.ជ.ន/ក.អ.ក និងដំណើរការនៃការងារផែនការនីយកម្ម និងថវិកានីយកម្ម ។ ក្នុងស្មារតីនេះ របាយការណ៍ត្រួតពិនិត្យពាក់កណ្តាលអាណត្តិនៃការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបានផ្តល់អនុសាសន៍ឱ្យស្ថាប័នទាំងបួនថា ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឧត្តម-ក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ និងគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា ត្រូវបន្តពង្រឹងកិច្ចសហការបន្ថែមទៀត ។ ទោះបីជាទិន្នន័យរបស់ដៃគូអភិវឌ្ឍន៍នៅពុំទាន់បានពេញលេញ ហើយភាគច្រើននៃទិន្នន័យទាំងនេះបានផ្តោតទៅលើបណ្តាគម្រោងកំពុងដំណើរការ និងគម្រោងមានអាទិភាពខ្ពស់ក៏ដោយ ក៏ប្រព័ន្ធទិន្នន័យនេះមានភាពរឹងមាំជាងមុន ហើយដៃគូអភិវឌ្ឍន៍កំពុងចាប់ផ្តើមអនុវត្តនូវការប្តេជ្ញារបស់ពួកគេនៅក្នុងវេទិកាកំពូលនៅទីក្រុងអាក្រា[៣] ។ ការប្រឹងប្រែងបន្តឱ្យមានវឌ្ឍនភាពស្តីពីភាពអាចទស្សន៍ទាយបានជាមុន (សូមពិនិត្យអត្ថបទពិភាក្សាស្តីពីការតម្រឹម) នឹងនៅតែជាអាទិភាពសម្រាប់រយៈពេលមធ្យមរបស់យើងទាំងអស់គ្នា ។

---

[៣] ចាប់ផ្តើមពីពេលនេះតទៅ ដៃគូអភិវឌ្ឍន៍នឹងផ្តល់ព័ត៌មានពេញលេញនិងទាន់ពេលវេលា ស្តីពីការសន្យាផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការប្រចាំឆ្នាំ និងការប្រើប្រាស់ហិរញ្ញប្បទានជាក់ស្តែង ដើម្បីឱ្យប្រទេសដៃគូអាចកត់ត្រាហិរញ្ញប្បទានសហប្រតិបត្តិការទាំងអស់បានសុក្រឹតនៅក្នុងថវិកា និងប្រព័ន្ធគណនេយ្យរបស់ពួកគេ- " ផែនការសកម្មភាពទីក្រុងអាក្រា- កថាខណ្ឌទី២៦ b" ។

និន្នាការរយៈពេលវែងនៃហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍

ក្នុងចន្លោះឆ្នាំ១៩៩២-២០០៧ ដៃគូអភិវឌ្ឍន៍បានរាយការណ៍ថា ការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិ-ការអភិវឌ្ឍន៍នៅកម្ពុជា មានចំនួន ៧.៨៦០លានដុល្លាអាមេរិក ហើយត្រូវបានបែងចែកដូចខាងក្រោម ÷

- ៣.១០០លានដុល្លាអាមេរិក ផ្តល់ដោយប្រទេសមិនមែនសមាជិកនៃសហគមន៍អឺរ៉ុប (៣៩%នៃហិរញ្ញប្បទានសរុប) ។
- ២.២០០លានដុល្លាអាមេរិក (២៩%) ផ្តល់ដោយភ្នាក់ងារអង្គការសហប្រជាជាតិ ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ និងស្ថាប័នពហុភាគីដទៃទៀត ។
- ១.៩០០លានដុល្លាអាមេរិក (២៤%) ផ្តល់ដោយប្រទេសជាសមាជិកសហគមន៍អឺរ៉ុប និងសហគមន៍អឺរ៉ុប ។
- ១.៥៦០លានដុល្លាអាមេរិក (២០%) ផ្តល់ដោយជប៉ុន ។
- ៦៥០លានដុល្លាអាមេរិក (៨%) ផ្តល់ដោយអង្គការក្រៅរដ្ឋាភិបាល ។

ប្រទេសជប៉ុននៅតែជាដៃគូផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការធំជាងគេបំផុតសម្រាប់កម្ពុជា ដោយបានផ្តល់ប្រមាណ២០%នៃធនធានហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍សរុបក្នុងចន្លោះឆ្នាំ១៩៩២-២០០៧ ។ ដៃគូអភិវឌ្ឍន៍សំខាន់ៗដទៃទៀតរួមមាន ÷

- សហរដ្ឋអាមេរិកបានផ្តល់ប្រមាណ៥៥០លានដុល្លាអាមេរិក
- គណៈកម្មការអឺរ៉ុបបានផ្តល់ប្រមាណ៥០០លានដុល្លាអាមេរិក
- សាធារណរដ្ឋបារាំងបានផ្តល់ប្រមាណ៤៥០លានដុល្លាអាមេរិក
- អូស្ត្រាលីបានផ្តល់ប្រមាណ៣៣០លានដុល្លាអាមេរិក
- សាធារណរដ្ឋប្រជាមានិតចិនបានផ្តល់ជាង៣០០លានដុល្លាអាមេរិក ក្នុងនោះ៧៥%នៃហិរញ្ញប្បទាននេះត្រូវបានប្រើប្រាស់ចាប់ពីឆ្នាំ២០០៤មក ។

បើពិនិត្យមើលទៅអនាគត គួរកត់សំគាល់ដែរថា ប្រភពហិរញ្ញប្បទានថ្មីៗនាពេលខាងមុខនឹងមានផលប៉ះពាល់ទៅលើស្ថានភាពទូទៅនៃហិរញ្ញប្បទានសហប្រតិបត្តិការ ។ កំណើនយ៉ាងឆាប់រហ័សនៃហិរញ្ញប្បទានសហប្រតិបត្តិការរបស់សាធារណរដ្ឋប្រជាមានិតចិននិងសាធារណរដ្ឋកូរ៉េបានឆ្លុះបញ្ចាំងក្នុងតារាងទី៤ ។ លើសពីនេះ កិច្ចព្រមព្រៀងសហប្រតិបត្តិការអភិវឌ្ឍន៍រវាងកម្ពុជានិងប្រទេសកាតានិងគុយវ៉ែតកាលពីដើមឆ្នាំ២០០៨នេះនឹងត្រូវប្រែក្លាយទៅជាការសន្យាផ្តល់ហិរញ្ញប្បទានផ្លូវការ ហើយបន្ទាប់មក នឹងត្រូវប្រើប្រាស់ហិរញ្ញប្បទានសម្រាប់អភិវឌ្ឍវិស័យជនបទ ។ ការគាំទ្រនៅក្នុងវិស័យដទៃទៀតក៏អាចមានការប្រែប្រួលផងដែរ ។ មូលនិធិសកល និងកម្មវិធីគំនិតផ្តួចផ្តើមក្នុងការធ្វើឱ្យសម្រេចការអប់រំសម្រាប់ទាំងអស់គ្នាឱ្យបានឆាប់រហ័ស (Education For All Fast-Track Initiative) ដែលត្រូវបានបង្កើតឡើងក្នុងរយៈពេលដ៏ខ្លី គឺជាប្រភពហិរញ្ញប្បទានសំខាន់សម្រាប់គាំទ្រវិស័យសុខាភិបាលនិងអប់រំ ។ បញ្ហាប្រឈមនាពេលអនាគត គឺការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនូវធនធានហិរញ្ញប្បទានដែលបានមកពីប្រភពផ្សេងៗគ្នា (សូមពិនិត្យមើលការពិភាក្សាលំអិតខាងក្រោម) ។ នេះជាបញ្ហាប្រឈម ដែលបានឆ្លុះបញ្ចាំងពីស្ថានភាពក្នុងកម្រិតសកល ដោយសាររហូតមកដល់បច្ចុប្បន្ននេះ មានដៃគូ

អភិវឌ្ឍន៍ចំនួន៥៦ និងស្ថាប័នពហុភាគីនិងអង្គការមូលនិធិជាង២៣០ (ក្នុងនោះ ដៃគូជាង១០០កំពុងប្រតិបត្តិការក្នុងវិស័យសុខាភិបាល) ។ ចំនួនដៃគូមាននិន្នាការកើនឡើងបន្តទៀត ទោះបីជាការប្តេជ្ញាសម្រាប់អនុវត្តសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីសតម្រូវឱ្យយកចិត្តទុកដាក់ខ្ពស់លើប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការយ៉ាងណាក៏ដោយ [៤] ។

និន្នាការនៃការផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការតាមវិស័យ

ជាទូទៅ ហិរញ្ញប្បទានសហប្រតិបត្តិការត្រូវបានវិភាជន៍ សម្រាប់គាំទ្រដោយផ្ទាល់ដល់បណ្តាសកម្មភាពរបស់វិស័យ ដូចបានបង្ហាញក្នុងគំនូសខាងក្រោម សម្រាប់ឆ្នាំ២០០៦-២០០៧ ។ គំនូសទាំងនេះបានបញ្ជាក់អំពីការបន្តផ្តល់ហិរញ្ញប្បទានកម្រិតខ្ពស់នៅក្នុងវិស័យអប់រំ និងសុខាភិបាល (សរុបចំនួន ១៤៤លានដុល្លាអាមេរិកក្នុងឆ្នាំ២០០៦ និង១៥២លានដុល្លាអាមេរិកក្នុងឆ្នាំ២០០៧ ហើយការផ្តល់ហិរញ្ញប្បទានសម្រាប់ជម្ងឺអេដស៍ក៏ត្រូវបានគិតជាហិរញ្ញប្បទានសម្រាប់គាំទ្រវិស័យសុខាភិបាល) ។

រូបភាពទី៣ - ហិរញ្ញប្បទានសហប្រតិបត្តិការបែងចែកតាមវិស័យ ឆ្នាំ២០០៦-២០០៧ (លានដុល្លា)





គួរកត់សំគាល់ដែរអំពីការកើនឡើងគួរឱ្យកត់សំគាល់នៃហិរញ្ញប្បទានសហប្រតិបត្តិការក្នុងវិស័យអភិវឌ្ឍន៍ជនបទ និងវិស័យដឹកជញ្ជូន ក្នុងឆ្នាំ២០០៧ ។ ដូចនេះ យើងយល់អំពីសារៈប្រយោជន៍នៃការពិនិត្យមើលអំពីការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការតាមវិស័យធំៗទាំង៤នៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ ការវិភាគបានបង្ហាញនៅក្នុងតារាងទី៥ខាងក្រោម ។

ដោយផ្អែកតាមសកម្មភាពអាទិភាពនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បើប្រៀបធៀបឆ្នាំ២០០៧ និងឆ្នាំ២០០៥ (មួយឆ្នាំមុនចាប់ផ្តើមអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ) យើងពិនិត្យឃើញថា វិស័យយេនឌ័រ អភិបាលកិច្ច ការអភិវឌ្ឍន៍ជនបទ និងជម្ងឺអេដស៍បានទទួលហិរញ្ញប្បទានច្រើនជាងវិស័យដទៃទៀតដែលជាវិស័យអាទិភាពនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ ផ្ទុយទៅវិញ ហិរញ្ញប្បទានសម្រាប់វិស័យទឹកស្អាតនិងអនាម័យ វិស័យបរិស្ថាននិងអភិរក្សធនធានធម្មជាតិបែរជាថយចុះទៅវិញ ។ គួរឱ្យកត់សំគាល់អំពីការប្រែប្រួលសំខាន់ក្នុងឆ្នាំ

[៤] សូមពិនិត្យមើលឯកសាររបស់ធនាគារពិភពលោក- ខែឧសភា ឆ្នាំ២០០៨ ស្តីពីស្ថាបត្យកម្មនៃហិរញ្ញប្បទានសហប្រតិបត្តិការ- ការពិនិត្យទូទៅនៃនិន្នាការសំខាន់ៗនៃលំហូរហិរញ្ញប្បទានសហប្រតិបត្តិការ ។

២០០៧ បើប្រៀបធៀបនឹងឆ្នាំ២០០៦ អំពីការផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់គាំទ្រថវិកាសម្រាប់ចាប់ផ្តើមអនុវត្តកម្មវិធីប្រតិបត្តិការសម្រាប់កាត់បន្ថយភាពក្រីក្រនិងកំណើន ។ ទន្ទឹមនេះ ហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់ផ្គត់ផ្គង់ស្បៀងអាហារក៏បានកើនឡើងដែរសម្រាប់បង្កើនសុវត្ថិភាពស្បៀង ព្រមទាំងការបន្តកើនឡើងនៃការវិនិយោគសម្រាបវិស័យទេសចរណ៍ ដែលជាវិស័យមានសក្តានុពលសម្រាប់កំណើននិងការងារ ។

តារាងទី៥ - ការផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការនៅតាមវិស័យ ២០០៦-២០០៧ (លានដុល្លា)

វិស័យ	2005		2006		2007 (តួលេខបឋម)		2008 (ប៉ាន់ស្មាន)	
	ដុល្លា	%	ដុល្លា	%	ដុល្លា	%	ដុល្លា	%
វិស័យសង្គមកិច្ច								
អប់រំ	69,3	11,4	79,7	11,2	88,2	11,2	67,9	7,6
សុខាភិបាល	110,3	18,1	109,0	15,3	111,2	14,1	106,0	11,9
ហ៊ីវ/ អេដស៍	25,4	4,2	35,4	5,0	41,0	5,2	44,2	5,0
សរុប	**205,0**	**33,7**	**224,1**	**31,5**	**240,4**	**30,5**	**218,1**	**24,6**
វិស័យសេដ្ឋកិច្ច								
កសិកម្ម	33,8	5,5	123,5	17,3	43,3	5,5	53,6	6,0
អភិវឌ្ឍន៍ជនបទ	50,0	8,2	49,9	7,0	71,0	9,0	71,4	8,0
កម្មន្តសាល រ៉ែ ពាណិជ្ជកម្ម	10,0	1,6	24,2	3,4	15,7	2,0	29,2	3,3
នគរូបនីយកម្ម	3,9	0,6	0,9	0,1	2,0	0,2	4,2	0,5
សេវាកម្មធនាគារ និងធុរកិច្ច	12,7	2,1	9,7	1,4	15,6	2,0	11,5	1,3
សរុប	**110,4**	**18,0**	**208,2**	**29,2**	**147,6**	**18,7**	**169,9**	**19,1**
ហេដ្ឋារចនាសម្ព័ន្ធ								
ដឹកជញ្ជូន	73,9	12,1	54,8	7,7	99,2	12,5	170,5	19,2
ទឹកស្អាត និងអនាម័យ	24,5	4,0	18,2	2,6	17,4	2,2	26,6	3,0
ថាមពល និងអគ្គិសនី	15,6	2,6	13,7	1,9	12,6	1,6	31,0	3,5
ព័ត៌មាន និងទូរគមនាគមន៍	0,9	0,1	9,9	1,4	31,3	4,0	1,8	0,2
សរុប	**114,9**	**18,8**	**96,6**	**13,6**	**160,5**	**20,3**	**229,9**	**25,9**
សេវាកម្ម និងកម្មវិធីអន្តរវិស័យ								
យេនឌ័រ	2,6	0,4	3,8	0,5	6,4	0,8	7,0	0,8
ទេសចរណ៍	1,2	0,2	2,5	0,4	3,0	0,4	6,1	0,7
បរិស្ថាន និងអភិរក្ស	12,3	2,0	14,6	2,0	8,9	1,1	7,1	0,8
សហគមន៍	35,3	5,8	38,5	5,4	52,2	6,6	14,9	1,7
វប្បធម៌ និងសិល្បៈ	4,8	0,.8	14,1	2,0	7,2	0,9	5,8	0,7
អភិបាលកិច្ច និងរដ្ឋបាល	67,3	11,0	96,8	13,6	109,9	13,9	137,0	15,4
សេដ្ឋកិច្ច និងអភិវឌ្ឍន៍ផែនការ/ នយោបាយ			3,5		10,0			
ការបោះឆ្នោត			6,3		6,5			
សិទ្ធិមនុស្ស			5,1		9,7			
ច្បាប់ និងតុលាការ			14,1		11,6			
វិមជ្ឈការ និងវិសហមជ្ឈការ			39,9		45,9			
ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ			11,0		5,0			
កំណែទម្រង់សេវាសាធារណៈ			2,2		2,1			
សង្គមស៊ីវិល			4,1		8,2			
ផ្សេងៗ			10,6		10,8			
ហិរញ្ញប្បទានទ្រទ្រង់ថវិកា	11,1	1,8			29,1	3,7	22,3	2,5
សរុប	**134,6**	**22,0**	**170,3**	**23,9**	**216,7**	**27,4**	**200,2**	**22,5**
ស្បៀង និងសង្គ្រោះបន្ទាន់	3,0	0,5	0,4	0,1	2,1	0,3	10,4	1,2
ផ្សេងៗ	42,0	6,9	13,4	1,9	23,3	2,9	59,5	6,7
សរុប	**610,0**	**100**	**713,2**	**100**	**790,4**	**100**	**887,9**	**100**

ការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការនៅតាមខេត្ត - ក្រុង

តារាងទី៦ - ការគាំទ្រតាមខេត្ត- ក្រុង (លានដុល្លា)

ខេត្ត/ក្រុង	2005	2006	2007	2008
ភ្នំពេញ	78,9	68,2	70,7	49,7
កណ្ដាល	8,6	26,7	53,8	77,9
ក្រុងព្រះសីហនុ	9,9	278	44,2	31,9
សៀមរាប	43,5	37,2	44,1	31,3
កំពង់ចាម	12,4	16,0	24,1	28,0
បាត់ដំបង	15,9	21,7	22,2	27,1
ក្រចេះ	10,5	10,0	18,0	32,0
កំពង់ធំ	18,3	17,4	17,6	23,9
ព្រៃវែង	12,9	9,7	17,4	27,6
បន្ទាយមានជ័យ	15,2	15,2	16,7	20,2
ផ្សេងទៀត	102,2	88,1	106,1	490,7
ទូទាំងប្រទេស	281,7	375,3	355,5	397,2
សរុប	610,0	713,2	790,4	**887,9**

រូបភាពទី៤ : ការគាំទ្រខេត្ត- ក្រុង (ដុល្លាសម្រាប់ប្រជាជនម្នាក់ៗ)



ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមក ការវិភាគស្ដីពីការប្រើ ប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការនៅតាមខេត្ត- ក្រុង ឱ្យបានគ្រប់ជ្រុងជ្រោយ គឺជាការលំបាកដោយសារគុណភាពនៃទិន្នន័យ (គម្រោងកម្រិតជាតិជាច្រើនត្រូវបានចាត់ទុកថាផ្ដល់អត្ថប្រយោជន៍ចំពោះតែរាជធានីភ្នំពេញ ឬក៏គ្មានទិន្នន័យតែម្ដង) ។ ការខិតខំប្រឹងប្រែងធ្វើសុពលភាពទិន្នន័យហិរញ្ញប្បទានសហប្រតិបត្តិការ ក្នុងទស្សនៈផ្ដោតការយកចិត្តទុកដាក់ទៅលើវិស័យអភិវឌ្ឍន៍ជនបទ ក៏បានទទួលលទ្ធផលគាប់ប្រសើរផងដែរ ហើយព័ត៌មានទាំងនេះ គឺជាមូលដ្ឋានសំខាន់ សម្រាប់ធ្វើការវិភាគឱ្យបានប្រាកដប្រជា ។ តារាងទី៦បានបង្ហាញថា សរុបធនធានដែលខេត្ត- ក្រុងចំនួន ១០ បានទទួលហិរញ្ញប្បទានសហប្រតិបត្តិការច្រើនជាងគេ (ចំនួន៣២៩លានដុល្លាអាមេរិក) ពោលគឺច្រើនជាងបីដង ធៀបនឹងខេត្ត- ក្រុង១៤ទៀត ដែលទទួលបានត្រឹមតែ១១០ លានដុល្លាអាមេរិកតែប៉ុណ្ណោះ ។ សរុបមក ក្នុងឆ្នាំ២០០៧ ហិរញ្ញប្បទានប្រមាណ៥៥% ត្រូវបានផ្ដល់ឱ្យថ្នាក់ខេត្ត-ក្រុង ។ ជាទូទៅ ទំហំហិរញ្ញប្បទាននេះមានកម្រិតប្រហាក់ប្រហែលនឹងបណ្ដាឆ្នាំកន្លងមកដែរ ។

បើគិតចំនួនប្រជាជន ការផ្ដល់ហិរញ្ញប្បទានសហប្រតិបត្តិការតាមតំបន់ មានការប្រែប្រួលជាច្រើន ។ ក្រុងព្រះសីហនុបានទទួលកម្រិតខ្ពស់ជាងគេ សម្រាប់ប្រជាជនម្នាក់ គឺចំនួន២២១ដុល្លាអាមេរិក ដោយសារទំហំហិរញ្ញប្បទានសហប្រតិបត្តិការដែលក្រុងនេះបានទទួល ហើយបន្ទាប់មក គឺខេត្តមណ្ឌលគិរីដែលឈរក្នុងលំដាប់ទី២ ចំនួន ១៤០ដុល្លាអាមេរិក ដោយសារតែប្រជាជនក្នុងខេត្តនេះមានចំនួនតិច ។ ក្នុងឆ្នាំ២០០៧នេះ រាជធានីភ្នំពេញ បានទទួលហិរញ្ញប្បទានសហប្រតិបត្តិការ ត្រឹម៥៣ដុល្លាអាមេរិកសម្រាប់ប្រជាជនម្នាក់ ពោលគឺទាបជាងបន្តិចបន្តួច ធៀបនឹងមធ្យមភាគទូទាំងប្រទេស ដែលមានប្រមាណ៥៣ ដុល្លាអាមេរិកសម្រាប់ប្រជាជនម្នាក់ ។ ដោយឡែក ខេត្តតាកែវ កំពង់ចាម និងកំពង់ស្ពឺ បានទទួលក្នុងចន្លោះ ១០ - ១៥ដុល្លាអាមេរិកសម្រាប់ប្រជាជនម្នាក់ ក្នុងឆ្នាំ២០០៧កន្លងមក ។

ការគាំទ្ររបស់អង្គការក្រៅរដ្ឋាភិបាលក្នុងកិច្ចអភិវឌ្ឍន៍ប្រទេស

ប្រភពសំខាន់ដទៃទៀតនៃហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់ខេត្ត-ក្រុង គឺអង្គការក្រៅរដ្ឋាភិបាល ។ ក្នុងពេលដែលធនធានរបស់អង្គការក្រៅរដ្ឋាភិបាលមានប្រមាណ១០%នៃហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍សរុប ក្នុងឆ្នាំ២០០៧នេះហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ដែលអង្គការក្រៅរដ្ឋាភិបាលបានផ្តល់ឱ្យខេត្ត-ក្រុង មានចំនួន ១៨% ។ ទន្ទឹមនេះដែរ អង្គការក្រៅរដ្ឋាភិបាលបានផ្តល់ធនធានមួយភាគធំរបស់ខ្លួន សម្រាប់ចូលរួមអភិវឌ្ឍន៍ខេត្ត- ក្រុងមួយចំនួន ។ ជាក់ស្តែង ក្នុងឆ្នាំ២០០៧ ធនធានប្រមាណ៤៦%នៃហិរញ្ញប្បទានសហប្រតិ-បត្តិការអភិវឌ្ឍន៍សម្រាប់ខេត្តសៀមរាបត្រូវបានផ្តល់ដោយអង្គការក្រៅរដ្ឋាភិបាល ។ ដោយឡែក ខេត្តតាកែវ និងខេត្តកោះកុង ហិរញ្ញប្បទានចំនួន៣៦% បានផ្តល់ដោយអង្គការក្រៅរដ្ឋាភិបាល ។ ដូចគ្នានេះដែរ ហិរញ្ញប្បទានដែលខេត្តកំពង់ឆ្នាំង និងកំពង់ចាមបានទទួលពីអង្គការក្រៅរដ្ឋាភិបាល មានប្រមាណ២១% និង១៩%នៃធនធានសរុប ។

អង្គការក្រៅរដ្ឋាភិបាលបានបន្តធ្វើសកម្មភាពរបស់ខ្លួន នៅក្នុងវិស័យសង្គមកិច្ច ។ ក្នុងឆ្នាំ២០០៦និង២០០៧ ប្រមាណ២/ ៣ នៃធនធានផ្ទាល់របស់អង្គការក្រៅរដ្ឋាភិបាល ត្រូវបានប្រើប្រាស់នៅក្នុងវិស័យសុខាភិបាលនិងអប់រំ ដោយផ្តោតជាសំខាន់ទៅក្នុងផ្នែកសុខុមាលភាពសហគមន៍ និងអភិវឌ្ឍន៍ជនបទ ។ អង្គការក្រៅរដ្ឋាភិបាលបានរាយការណ៍ថា ពួកគេមានធនធានផ្ទាល់ប្រមាណ៧៨លានដុល្លាអាមេរិកក្នុងឆ្នាំ២០០៧ សម្រាប់ចូលរួមសកម្មភាពអភិវឌ្ឍន៍ប្រទេស ពោលគឺកើនឡើងប្រមាណ៥០%ធៀបនឹងឆ្នាំ២០០៦ ដែលមានត្រឹមតែ៥០លានដុល្លាអាមេរិកប៉ុណ្ណោះ (តារាង ទី៧) ។

តារាងទី៧ - ការគាំទ្រតាមវិស័យរបស់អង្គការក្រៅរដ្ឋាភិបាល ឆ្នាំ២០០៦ - ២០០៧ (គិតជាលានដុល្លា)

វិស័យ	២០០៦						២០០៧ (តួលេខបឋម)					
	គាំទ្រដោយដៃគូអភិវឌ្ឍន៍		ធនធានផ្ទាល់		សរុប		គាំទ្រដោយដៃគូអភិវឌ្ឍន៍		ធនធានផ្ទាល់		សរុប	
	ដុល្លា	%	ដុល្លា	%	ដុល្លា	%	ដុល្លា	%	ដុល្លា	%	ដុល្លា	%
សុខាភិបាល	14,3	12,6	28,3	56,5	42,6	26,1	9,5	9	36,7	47,2	46,2	25,2
អប់រំ	3,4	3	5,2	10,4	8,5	5,2	4,1	3,9	18,3	23,5	22,4	12,2
សុខុមាលភាពសហគមន៍	3	2,6	7,7	15,3	10,7	6,5	3,6	3,4	10,3	13,3	13,9	7,6
អភិវឌ្ឍន៍ជនបទ	5,8	5,1	6,7	13,4	12,5	7,7	7,9	7,5	8,5	10,9	16,4	8,9
កសិកម្ម	7,4	6,5	1,5	2,9	8,8	5,4	17,9	17	2,7	3,5	20,7	11,3
កម្មន្តសាល/ពាណិជ្ជកម្ម	1,5	1,4	0,2	0,3	1,7	1	6,7	6,3	0,6	0,8	7,3	4
អភិបាលកិច្ច	33	29,1	0	0	33	20,2	29,8	28,2	0	0	29,8	16,2
សេវាកម្មធនាគារ និងធុរកិច្ច	7,9	7	0	0	7,9	4,9	1,9	1,8	0	0	1,9	1
វប្បធម៌ និងសិល្បៈ	1,4	1,2	0	0	1,4	0,9	1,5	1,4	0	0	1,5	0,8
បញ្ហាបយេនឌ័រ	1,8	1,6	0	0	1,8	1,1	2,7	2,5	0	0	2,7	1,5
អន្តរវិស័យ	29,1	25,7	0	0	29,1	17,8	10,9	10,3	0	0	10,9	5,9
ផ្សេងៗ	4,7	4,2	0,6	1,2	5,3	3,3	9,4	8,9	0,6	0,8	10	5,5
សរុប	**113,3**	**100**	**50,2**	**100**	**163,5**	**100**	**105,8**	**100**	**77,7**	**100**	**183,5**	**100**

អង្គការក្រៅរដ្ឋាភិបាលកាន់តែមានតួនាទីសំខាន់បន្ថែមទៀត សម្រាប់សកម្មភាពនៃកិច្ចអភិវឌ្ឍន៍ប្រទេស នៅពេលដែលពួកគេបានក្លាយជាភ្នាក់ងារអនុវត្តសកម្មភាពរបស់ដៃគូអភិវឌ្ឍន៍មួយចំនួន បន្ថែមធនធានផ្ទាល់របស់ពួកគេ ។ ជាក់ស្តែង ក្នុងឆ្នាំ២០០៦ អង្គការក្រៅរដ្ឋាភិបាលបានគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការចំនួន១៣៣ លានដុល្លាអាមេរិក ជំនួសដៃគូអភិវឌ្ឍន៍ ដែលធនធាននេះមានរហូតដល់១០៦លានដុល្លាអាមេរិកក្នុងឆ្នាំ២០០៧ ។ វិស័យសំខាន់ៗដែលអង្គការក្រៅរដ្ឋាភិបាលធ្វើសកម្មភាពគឺ÷ អភិបាលកិច្ច វិស័យកសិកម្មនិងអភិវឌ្ឍន៍ជនបទ និង អន្តរវិស័យដែលរួមបញ្ចូលវិស័យកសិកម្ម អភិវឌ្ឍន៍ជនបទ និងទឹកស្អាតនិងអនាម័យ ។ ទន្ទឹមនេះ ក៏មានដៃគូអភិវឌ្ឍន៍ផ្តល់ការគាំទ្រក្នុងផ្នែកយេនឌ័រ និងវប្បធម៌តាមរយៈអង្គការក្រៅរដ្ឋាភិបាលផងដែរ ។ ប៉ុន្តែ ក៏គ្មានអង្គការក្រៅរដ្ឋាភិបាលណាមួយប្រើប្រាស់ធនធានផ្ទាល់ខ្លួនសម្រាប់ធ្វើសកម្មភាពក្នុងផ្នែកអភិបាលកិច្ចឡើយ ។

អង្គការក្រៅរដ្ឋាភិបាលបានផ្តល់សេវាកម្មដោយផ្ទាល់ និងបានគាំទ្រដល់អភិបាលកិច្ច និងការតស៊ូមតិខាងនយោបាយផងដែរ ។ ការចែកចាយព័ត៌មានបានបង្កើនការយល់ដឹងរបស់ភាគីពាក់ព័ន្ធទៅលើសកម្មភាពរបស់ពួកគេ ។ ក្នុងឆ្នាំ២០០៧-២០០៨ ការប្រាស្រ័យទាក់ទងរវាងអង្គការសង្គមស៊ីវិលនិងរាជរដ្ឋាភិបាល ដំណើរការបានប្រសើរឡើង ដែលអាចចាត់ទុកថានេះជាវឌ្ឍនភាពល្អ ហើយតួនាទីរបស់អង្គការសង្គមស៊ីវិលត្រូវបានរំលេចនៅក្នុងដំណើរការត្រួតពិនិត្យពាក់កណ្តាលអាណត្តិនៃការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ ការវាយតម្លៃអំពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការដែលបានដំណើរការក្នុងពេលថ្មីៗកន្លងមកនេះ ក៏បានបង្ហាញឱ្យឃើញថា សង្គមស៊ីវិលបានបង្កើនតួនាទីរបស់ខ្លួន ដើម្បីក្លាយជាដៃគូពិភាក្សាកិច្ចការសមស្របនានា ក៏ដូចជាការអនុវត្តន៍ និងការគ្រប់គ្រងសកម្មភាពផ្ទាល់របស់ខ្លួនឱ្យមានប្រសិទ្ធភាពនិងមានបទដ្ឋានដូចគ្នានឹងទម្រង់ការនៃហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ដទៃទៀតដែរ (វឌ្ឍនភាពថ្មីៗក្នុងការរៀបចំក្រមស្តីពីគោលការណ៍សីលធម៌ និងបទដ្ឋានអប្បបរមា) ។ ទន្ទឹមនេះ ក៏គួរកត់សំគាល់ដែរថា ក្នុងឆ្នាំ២០០៧ អង្គការក្រៅរដ្ឋាភិបាលបានបង្កើនធនធានរបស់ខ្លួនសម្រាប់គាំទ្រវិស័យកសិកម្មនិងអភិវឌ្ឍន៍ជនបទ ព្រមទាំងគ្រប់គ្រងធនធានដែលដៃគូអភិវឌ្ឍន៍មួយចំនួនបានផ្តល់កាន់តែច្រើនឡើងសម្រាប់វិស័យទាំងនេះ ។ ដូចនេះ យើងពិនិត្យឃើញកាន់តែច្បាស់ឡើង នូវតួនាទីរបស់អង្គការក្រៅរដ្ឋាភិបាលក្នុងការចូលរួមអនុវត្តបណ្តាអាទិភាពនៃយុទ្ធសាស្ត្រចតុកោណ ។

ការពិនិត្យសក្ខីភាពជាក់ស្តែងនៃការអនុវត្តន៍ផែនការសកម្មភាពស្តីពីសុខដុមនីយកម្ម ការតម្រឹម និង លទ្ធផល ឆ្នាំ២០០៧-២០០៨

ទិន្នន័យដែលបានបង្ហាញខាងលើនឹងត្រូវបានប្រើប្រាស់ សម្រាប់ឆ្លុះបញ្ចាំងអំពីបទពិសោធន៍នៃការអនុវត្តន៍ផែនការសកម្មភាពស្តីពីសុខដុមនីយកម្ម ការតម្រឹម និងលទ្ធផល ពិសេសសម្រាប់ពិនិត្យឡើងវិញនូវអនុសាសន៍នានានៃរបាយការណ៍ស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការឆ្នាំ២០០៧ ការអង្កេតស្តីពីការតាមដានការអនុវត្តន៍សេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស និងការវាយតម្លៃដែលទើបបញ្ចប់នាពេលថ្មីៗកន្លងមក ។ ទិន្នន័យខាងលើបង្ហាញអំពីកំណើននៃលំហូរហិរញ្ញប្បទានសហប្រតិបត្តិការ ហើយទាំងដៃគូអភិវឌ្ឍន៍ ទាំងអង្គការក្រៅរដ្ឋាភិបាលបានបង្វែរការយកចិត្តទុកដាក់លើវិស័យអភិវឌ្ឍន៍ជនបទ ដែលជាអាទិភាពរបស់រាជរដ្ឋាភិបាល ។ ការវាយតម្លៃឯករាជ្យបានគូសបញ្ជាក់ថា ដូចគ្នានឹងប្រទេសដៃគូជាច្រើនដទៃទៀត កម្ពុជាបានប្រឈមនឹងបញ្ហានៃការផ្ទេរការអនុវត្តន៍ «របៀបវារៈនៃប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការពីស្ថាប័នថ្នាក់ជាតិទៅស្ថាប័នគន្លឹះ

ដទៃទៀតរបស់រាជរដ្ឋាភិបាល» ព្រោះនេះជាមូលដ្ឋាននៃការអនុវត្តន៍ជាក់ស្តែងនូវបណ្តាសកម្មភាពសម្រាប់បង្កើន ប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ ។ សក្ខីភាពជាក់ស្តែង គួបផ្សំនឹងទិន្នន័យបង្ហាញខាងលើ អាចបញ្ជាក់ ពីប្រសិទ្ធភាពនៃការគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ និងតម្រូវការនៃការផ្លាស់ប្តូរការគ្រប់គ្រងហិរញ្ញប្ប-ទានទាំងនេះ ដើម្បីពង្រឹងកិច្ចអភិវឌ្ឍន៍ដោយផ្តោតលើលទ្ធផល ។

ភាពជាម្ចាស់

> *«រាជរដ្ឋាភិបាលបានប្រឹងប្រែងជាច្រើន ក្នុងការរៀបចំគោលនយោបាយ និងកិច្ចដំណើរការនានា... ក្នុងគ្រប់ករណីទាំងអស់ វឌ្ឍនភាពនេះបានជួយពង្រឹងភាពដឹកនាំ និងសមត្ថភាព»*
>
> *របាយការណ៍ស្តីពីការវាយតម្លៃឯករាជ្យអំពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការនៅកម្ពុជា ឆ្នាំ ២០០៨*

ជាទស្សនទាន ភាពជាម្ចាស់មានការពិបាកយល់បន្តិច ។ ទោះយ៉ាងនេះក្តី ក៏អាចរាប់បញ្ចូលទាំង «ផ្នែករឹងនិងផ្នែកទន់» ។«ផ្នែករឹង» នៃភាពជាម្ចាស់ពាក់ព័ន្ធនឹងក្របខ័ណ្ឌគោលនយោបាយ ឧបករណ៍សម្រាប់ការងារផែនការនីយកម្មនិងថវិកានីយកម្ម ព្រមទាំងគុណភាពនៃកិច្ចដំណើរការគ្រប់គ្រង ។«ផ្នែកទន់»នៃភាពជាម្ចាស់ពាក់ព័ន្ធនឹងភាពដឹកនាំនៅកម្រិតនយោបាយ និងតម្រូវការខាងសមត្ថភាពបច្ចេកទេសសម្រាប់អនុវត្តគោលនយោបាយប្រព័ន្ធផែនការនិងថវិកាប្រកបដោយប្រសិទ្ធភាព ។ ការវិភាគមួយចំនួនដែលបានអនុវត្តក្នុងឆ្នាំ២០០៧-២០០៨ បានបង្ហាញអំពីវឌ្ឍនភាពក្នុងការពង្រឹងក្របខ័ណ្ឌគោលនយោបាយ និងការពង្រឹងខាងស្ថាប័ន ។

រីឯវឌ្ឍនភាពនៃការងារផែនការនីយកម្មនិងថវិកានីយកម្ម ព្រមទាំងការអនុវត្តន៍នៅថ្នាក់ជាតិ របាយការណ៍ពាក់កណ្តាលអាណត្តិនៃការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងការវាយតម្លៃប្រសិទ្ធភាពនៃហិរញ្ញ-ប្បទានសហប្រតិបត្តិការនាពេលថ្មីៗនេះ បានឆ្លុះបញ្ចាំងអំពីស្ថានភាពចម្រុះ ។ ការរៀបចំយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី២ ការរៀបចំរបាយការណ៍ពាក់កណ្តាលអាណត្តិស្តីពីការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ស្ថានភាពរឹងមាំខាងម៉ាក្រូសេដ្ឋកិច្ច និងការរៀបចំថវិកាក្នុងក្របខ័ណ្ឌកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការពង្រឹងការគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ គឺជាលទ្ធផលនៃកិច្ចសហការរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ។ ទន្ទឹមនឹងវឌ្ឍនភាពគួរឱ្យមោទនភាពនេះ ក៏នៅមានបញ្ហាប្រឈមក្នុងកិច្ចសម្របសម្រួល ដើម្បីឱ្យបណ្តាផ្នែកនានានៃសមាសភាគទាំងនេះអាចដំណើរការប្រកបដោយសង្គតិភាព ។ ការវាយតម្លៃឯករាជ្យបានសង្កេតឃើញថា «ស្ថាប័នសម្រាប់អនុវត្តភារកិច្ចនានាដូចមានចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិពុំទាន់មានទំនាក់ទំនងគ្នាបានល្អឡើយ» ។ ការសង្កេតនេះក៏បានទទួលការគាំទ្រពីក្រសួងផែនការ ដែលបានបញ្ជាក់ក្នុងរបាយការណ៍ពាក់កណ្តាលអាណត្តិស្តីពីការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិថា «យើងត្រូវអនុវត្តជាបន្ទាន់នូវសកម្មភាពរួមគ្នាជាច្រើនដើម្បីបង្កើតវឌ្ឍនភាពបន្ថែមទៀត»។

របកគំហើញនេះក៏បានរំលេចនៅក្នុងរបាយការណ៍នៃការធ្វើអង្កេតស្តីពីការតាមដានការអនុវត្តន៍សេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស ដែលរបាយការណ៍នេះបានគូសបញ្ជាក់អំពីវឌ្ឍនភាពដែលសម្រេចបាន ព្រមទាំងបានលើកអនុសាសន៍ថា «ចាំបាច់ត្រូវបង្កើនការផ្តោតការយកចិត្តទុកដាក់ទៅលើការរៀបចំ និងការពង្រឹងប្រព័ន្ធជាតិនៅគ្រប់កម្រិតទាំងអស់ (ប្រព័ន្ធរៀបចំផែនការ ថវិកា និងការអនុវត្តន៍ ប្រព័ន្ធរបាយការណ៍ និងការតាមដាននិង

វាយតម្លៃ)» ។ ជាលទ្ធផល កម្ពុជាត្រូវបានចាត់ថ្នាក់ក្នុងក្រុមប្រទេសប្រភេទ C ។ នេះមានន័យថា កម្ពុជាបានបង្កើតប្រព័ន្ធសំខាន់ៗរួចហើយ ប៉ុន្តែត្រូវបន្តពង្រឹងទំនាក់ទំនងខាងស្ថាប័នបន្ថែមទៀត ។ បញ្ហានេះជាឧបសគ្គចម្បងនៃការរៀបចំផែនការនិងថវិកាចំណាយនៅតាមបណ្តាក្រសួង ដូចដែលក្រុមការងារបច្ចេកទេសមួយចំនួនបានលើកឡើងក្នុងរបាយការណ៍ស្វ័យវាយតម្លៃស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ ។

បញ្ហាប្រឈមទី២នៃ «ភាពជាម្ចាស់» គឺការពង្រឹងភាពដឹកនាំ និងការបង្កើនសមត្ថភាពសម្រាប់គ្រប់គ្រងធនធានប្រកបដោយប្រសិទ្ធភាព ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលបានសម្រេចវឌ្ឍនភាពជាដុំកំភួនជាច្រើន ហើយការវាយតម្លៃឯករាជ្យក៏បានបញ្ជាក់ថា «មានសក្ខីភាពជាក់ស្តែងជាច្រើនដែលបង្ហាញថា រាជរដ្ឋាភិបាលនិងស្ថាប័នមួយចំនួនបានពង្រឹងភាពដឹកនាំ តាមរយៈការស្តែងចេញយ៉ាងច្បាស់លាស់អំពីតម្រូវការអាទិភាពរបស់ខ្លួន» ។ យើងបានប្រឹងប្រែងរួមគ្នាជាច្រើន ដើម្បីពង្រឹងសមត្ថភាព ទាំងនៅកម្រិតបច្ចេកទេស ទាំងនៅកម្រិតគ្រប់គ្រង ដូចជាការបណ្តុះបណ្តាល និងការគាំទ្រជាកញ្ចប់ថវិកា សម្រាប់ពង្រឹងសមត្ថភាពបច្ចេកទេស និងសមត្ថភាពខាងរដ្ឋបាលរបស់ក្រុមការងារបច្ចេកទេសចម្រុះ ។ ទន្ទឹមនេះដែរ រាជរដ្ឋាភិបាលបាននិងកំពុងពិភាក្សាជាមួយនឹងដៃគូអភិវឌ្ឍន៍ ដើម្បីបង្កើនប្រសិទ្ធភាពនៃយន្តការពិគ្រោះយោបល់នានា រួមទាំងយន្តការនៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ផងដែរ ។

ជាទីបញ្ចប់ យើងក៏ត្រូវពិនិត្យ និងពិចារណាអំពីខ្លឹមសារនៃគោលការណ៍ «ភាពជាម្ចាស់» និងមូលដ្ឋានគ្រឹះនៃទំនាក់ទំនងរបស់វា ព្រមទាំងការអនុវត្តន៍ជាក់ស្តែងក្នុងបរិការណ៍កម្ពុជា ។ ក្នុងបរិការណ៍នៃអតុល្យភាពខាងធនធានហិរញ្ញវត្ថុ និងសមត្ថភាពបច្ចេកទេស រវាងស្ថាប័ននានារបស់រដ្ឋ (ដូចជារាជរដ្ឋាភិបាល និងបណ្តាក្រសួងជំនាញព្រមទាំងរដ្ឋសភា) និងសង្គមស៊ីវិល និងរវាងស្ថាប័នទាំងនេះជាមួយនឹងដៃគូអភិវឌ្ឍន៍ ការពង្រឹងភាពជាម្ចាស់ដោយខ្លួនឯង ឬដោយគាំទ្រពីដៃគូអភិវឌ្ឍន៍គឺជាបញ្ហាសំខាន់បំផុត ។ ការវិភាគសកលនានាក្នុងក្របខ័ណ្ឌនៃសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស បានលើកឡើងថា ដៃគូអភិវឌ្ឍន៍ខ្លះមិនបានបំពេញការងារក្នុងបរិបទកម្ពុជា ហើយមិនទាន់បានយល់ច្បាស់អំពីជវភាពនៅកម្ពុជាឡើយ ។ ផ្ទុយទៅវិញ ពួកគេបានដាក់កំហិតឱ្យភាគីកម្ពុជាធ្វើការផ្លាស់ប្តូរទៅតាមតម្រូវការរបស់ពួកគេ ដើម្បីធានាឱ្យកម្មវិធីហិរញ្ញប្បទានអាចឆ្លើយតបនឹងនិយាមរបស់ពួកគេជាជាងសម្របទៅនឹងបរិបទកម្ពុជា ។ ការយល់ដឹងឱ្យបានច្បាស់លាស់ខាងវប្បធម៌ និងខាងនយោបាយ ព្រមទាំងខាងការគ្រប់គ្រងរដ្ឋបាល នឹងជួយបង្កើនប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ ។ ការសិក្សាស្តីពីកិច្ចសហប្រតិបត្តិការបច្ចេកទេសនៅកម្ពុជាក៏បានបញ្ជាក់ថា បញ្ហានេះត្រូវយកចិត្តទុកដាក់អនុវត្តនៅកម្ពុជាផងដែរ [៥] ។

តាមស្ថានភាពដូចរៀបរាប់ខាងលើ តើយើងត្រូវដំណើរការយ៉ាងដូចម្តេច? យើងបានបង្កើតមូលដ្ឋានគ្រឹះជាច្រើន ។ ផែនការយុទ្ធសាស្រ្តសម្រាប់គាំទ្រក្រសួងផែនការ បានផ្តល់កាលានុវត្តភាពសំខាន់បន្ថែមទៀតសម្រាប់បន្តពង្រឹងតួនាទីសម្របសម្រួលរវាងស្ថាប័ននៅថ្នាក់ជាតិ ។ ការពង្រឹងទំនាក់ទំនងរវាងស្ថាប័ននៅថ្នាក់ជាតិ រួមមានក្រសួងផែនការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគ.ជ.ន/ក.អ.ក ត្រូវដំណើរការជាពាកម្រិត តាមរយៈការពង្រឹងភាពដឹកនាំកម្រិតនយោបាយដូចបានបញ្ជាក់ក្នុងយុទ្ធសាស្រ្តចតុកោណ តាមរយៈការរៀបចំនិងការ

[៥] សូមមើល «កិច្ចសហប្រតិបត្តិការបច្ចេកទេសសម្រាប់ការអភិវឌ្ឍន៍សមត្ថភាពនៅកម្ពុជា- ការធ្វើឱ្យប្រព័ន្ធមានលក្ខណៈកាន់តែប្រសើរឡើង» (ឆ្នាំ២០០៨) និង «របាយការណ៍សំយោគស្តីពីការវាយតម្លៃទៅលើការអនុវត្តន៍សេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស» (ឆ្នាំ២០០៨)

អនុវត្តន៍ប្រព័ន្ធលាភការសម្រាប់ពង្រឹងការចែករំលែកព័ត៌មាន និងការគ្រប់គ្រង និងតាមរយៈការអភិវឌ្ឍន៍សមត្ថភាពសម្រាប់រៀបចំផែនការនិងថវិកា និងត្រួតពិនិត្យការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ ការវាយតម្លៃឯករាជ្យបានផ្តល់អនុសាសន៍ថា ការកាត់បន្ថយភាពស្មុគស្មាញក្នុងការរៀបចំផែនការអាចជួយបង្កើនការទទួលខុសត្រូវ និងការអនុវត្តន៍ តាមរយៈ÷

១- ការបង្កើតឱ្យមានទំនាក់ទំនងដោយផ្ទាល់រវាងគោលដៅរួមដែលបានព្រមព្រៀងនៅកម្រិតកំពូល និងយុទ្ធសាស្ត្រសម្រាប់អនុវត្តគោលដៅទាំងនេះ និង

២- ការលុបបំបាត់របាំងបច្ចេកទេស ដែលបច្ចុប្បន្ន បានផ្តល់ឱកាសតិចតួចដល់ក្រសួងនិងស្ថាប័ននៃរាជរដ្ឋាភិបាលសម្រាប់ចូលរួមក្នុងកិច្ចការជំនាញបច្ចេកទេសស្នូលមួយចំនួនប៉ុណ្ណោះ ។

ការតម្រឹម

> *«ការប្រើប្រាស់ប្រព័ន្ធជាតិដោយដៃគូអភិវឌ្ឍន៍ គឺជាជម្រើសទីមួយ»*
>
> *ផែនការសកម្មភាពទីក្រុងអាក្រា ឆ្នាំ២០០៨*

ការតម្រឹមបានផ្តែកលើៈ ១- កម្រិតនៃភាពស្របគ្នារវាងអាទិភាពអភិវឌ្ឍន៍ជាតិ និងការគាំទ្ររបស់ដៃគូអភិវឌ្ឍន៍ និង២- ការពង្រឹង និងការប្រើប្រាស់ប្រព័ន្ធជាតិសម្រាប់ការរៀបចំកម្មវិធី ការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការ និងការធ្វើរបាយការណ៍ស្តីពីសកម្មភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ ។ ដូច្នេះ ការធ្វើអង្កេតស្តីពីការអនុវត្តន៍សេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស បានឆ្លុះបញ្ចាំងអំពីវឌ្ឍនភាពនៃការប្រើប្រាស់ប្រព័ន្ធជាតិក្នុងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ដែលបានកើនឡើងពី៧៩% ក្នុងឆ្នាំ២០០៥ មកដល់៨៥% ក្នុងឆ្នាំ២០០៧ (សូមពិនិត្យតារាងទី២) និងវឌ្ឍនភាពយ៉ាងធំធេងក្នុងភាពទស្សន៍ទាយបានជាមុន (អត្រានៃការប្រើប្រាស់ហិរញ្ញប្បទានសហ-ប្រតិបត្តិការជាក់ស្តែង ធៀបនឹងផែនការផ្តល់ធនធានគឺ៩៦%)។

កត្តាចម្បងនៃជោគជ័យ ដែលជាមូលដ្ឋានសំខាន់សម្រាប់ពង្រឹងដំណើរការរៀបចំផែនការនិងថវិកា គឺការពង្រឹងប្រព័ន្ធជាតិ និងការអនុវត្តន៍ការងាររវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ។ ប្រព័ន្ធគ្រប់គ្រងទិន្នន័យហិរញ្ញប្បទានសហប្រតិបត្តិការ ដែល គ.ជ.នា គ្រប់គ្រងបណ្តាព័ត៌មានដែលដៃគូអភិវឌ្ឍន៍បានផ្តល់ ហើយធ្វើសុពលភាពដោយស្ថាប័នរបស់រាជរដ្ឋាភិបាល គឺជាឧបករណ៍ដែលអាចកត់ត្រាការសន្យាផ្តល់ធនធាន និងការប្រើប្រាស់ធនធានជាក់ស្តែង សម្រាប់រៀបចំថវិកា ។ លើសពីនេះ ក៏ជាឧបករណ៍សម្រាប់រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ កាត់បន្ថយភាពខុសគ្នាក្នុងការកត់ត្រាការប្រើប្រាស់ហិរញ្ញប្បទានរវាងដៃគូអភិវឌ្ឍន៍ និងរាជរដ្ឋាភិបាលផងដែរ ។ ទន្ទឹមនេះ វិស័យជលផលក៏បានរាយការណ៍អំពីវឌ្ឍនភាពក្នុងការបង្កើតប្រព័ន្ធជាច្រើនក្នុងកម្រិតវិស័យ បើទោះបីជាដៃគូអភិវឌ្ឍន៍មានឆន្ទៈតិចតួចស្ទួចស្តើងក្នុងការប្រើប្រាស់ប្រព័ន្ធទាំងនេះក៏ដោយ ។ គំនិតផ្តួចផ្តើមទាំងនេះបានបង្ហាញឱ្យឃើញពីវឌ្ឍនភាពយ៉ាងលឿនក្នុងការពង្រឹង និងប្រើប្រាស់ប្រព័ន្ធជាតិ ប្រសិនបើភាគីទាំងសងខាងបានត្រៀមខ្លួនរួចជាស្រេចសម្រាប់អនុវត្តតាមការប្តេជ្ញារបស់ខ្លួន ។

ទន្ទឹមនេះ យើងមានវឌ្ឍនភាពតិចតួចក្នុងការអនុវត្តន៍សូចនាករដទៃទៀតនៃសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស ។ ចំនួនអង្គភាពអនុវត្តគម្រោងបានកើនឡើងពី៤៩ ទៅ១២១ ហើយពុំទាន់មានសក្ខីភាពជាក់ស្តែង ដែល

អាចបញ្ជាក់ពីការកើនឡើងនៃការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ និងលទ្ធកម្មរបស់រាជរដ្ឋាភិបាលនៅឡើយ[៦] ។ វឌ្ឍនភាពនៃការអនុវត្តន៍សូចនាករទាំងនេះនៅក្នុងបរិការណ៍កម្ពុជា ពុំទាន់មានភាពប្រាកដប្រជានៅឡើយ ព្រោះទាមទាររយៈពេលវែង ដើម្បីរកឱ្យឃើញនូវឫសគល់នៃបញ្ហា ។ ការវិភាគស្តីពីការអភិវឌ្ឍន៍សមត្ថភាព គួបផ្សំជាមួយនឹងការប្រើប្រាស់កិច្ចសហប្រតិបត្តិការបច្ចេកទេសបានបង្ហាញឱ្យឃើញថា ការប្រើប្រាស់អង្គភាពអនុវត្តគម្រោងបានបង្ហាញអំពីភាពទន់ខ្សោយនៃប្រព័ន្ធជាតិ ។ ភាគីជាច្រើនបានទទួលយកអង្គភាពអនុវត្តគម្រោង និងភាពចាំបាច់របស់វា ។ ការបន្តពង្រឹងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលកន្លងមក បានបង្កើតវឌ្ឍនភាពសំខាន់ៗជាច្រើន គឺជាឧទាហរណ៍ជាក់ស្តែងមួយទៀត សម្រាប់ពិនិត្យពិចារណាការប្រើប្រាស់ប្រព័ន្ធរបស់រាជរដ្ឋាភិបាល នៅក្នុងបរិការណ៍នៃការអភិវឌ្ឍន៍សមត្ថភាពរយៈពេលវែង ។

បញ្ហាប្រឈមដ៏ចម្បងសម្រាប់ការតម្រឹម គឺការគ្រប់គ្រងសកម្មភាពអន្តរវិស័យ ដូចជាផ្នែកយេនឌ័រ អេដស៍ សុខមាលភាពកុមារ សន្តិសុខស្បៀង និងការគ្រប់គ្រងដីធ្លី ។ ក្រុមការងារបច្ចេកទេសចម្រុះខាងយេនឌ័របានរាយការណ៍អំពីជោគជ័យរបស់ខ្លួនក្នុងការសម្របសម្រួលជាមួយនឹងបណ្តាភាគីពាក់ព័ន្ធ សម្រាប់វាយតម្លៃស្ថានភាពយេនឌ័រនៅកម្ពុជាឆ្នាំ២០០៨ ។ ក្រុមការងារបច្ចេកទេសយេនឌ័រនេះក៏បានរាយការណ៍អំពីការចូលរួមរបស់ខ្លួនប្រកបដោយប្រសិទ្ធភាពក្នុងការរៀបចំច្បាប់ស្តីពីការប្រឆាំងនឹងការជួញដូរមនុស្ស និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត- ក្រុង ស្រុក- ខណ្ឌផងដែរ ។ ទន្ទឹមនេះ ក៏បានប្រឈមនឹងបញ្ហាមួយចំនួនផងដែរ ។ វឌ្ឍនភាពរបស់ក្រុមការងារយេនឌ័រនេះ អាចមានលក្ខណៈប្លែកពីក្រុមការងារបច្ចេកទេសចម្រុះដទៃទៀត ដែលបានរាយការណ៍ក្នុងដំណើរការនៃស្វ័យវាយតម្លៃរបស់ខ្លួន សម្រាប់ជាធាតុចូលនៃការវាយតម្លៃឯករាជ្យស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការថា បានជួបប្រទះការលំបាកក្នុងការពង្រឹងទំនាក់ទំនងខាងស្ថាប័នសម្រាប់ការងារអន្តរវិស័យ ។ នេះគឺជាបញ្ហាប្រឈមខាងប្រព័ន្ធការងារក្នុងកម្រិតគោលនយោបាយ ដែលទាមទារឱ្យមានសកម្មភាពរួមគ្នារវាងប្រធានក្រុមការងារបច្ចេកទេសចម្រុះ អ្នកសម្របសម្រួលខាងដៃគូអភិវឌ្ឍន៍ និងគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ។

ការវាយតម្លៃអំពីការរៀបចំកម្មវិធីនីយកម្ម និងការផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ គឺជាមូលដ្ឋាន សម្រាប់ពិនិត្យកម្រិតតម្រឹមនៃការផ្តល់ហិរញ្ញប្បទាន ។ ការវិភាគនៃការធ្វើអង្កេតការអនុវត្តន៍សេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស និងរបាយការណ៍ត្រួតពិនិត្យពាក់កណ្តាលអាណត្តិនៃការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បានសន្និដ្ឋានដូចគ្នាថា ត្រូវខិតខំប្រឹងប្រែងបន្ថែមទៀតដើម្បីតម្រឹមធនធានរបស់ដៃគូអភិវឌ្ឍន៍ជាមួយនឹងបណ្តាអាទិភាពរបស់រាជរដ្ឋាភិបាល ។ ក្នុងស្មារតីនេះ ការតម្រឹមគឺជាការសាកល្បងសម្រាប់ការយល់ដឹងអំពីប្រសិទ្ធភាពនៃការវិភាជន៍ធនធាន ។ នេះមានន័យថា ប្រសិនយើងវិភាជន៍ធនធានមិនបានត្រឹមត្រូវតាមសកម្មភាពអាទិភាពទេនោះ យើងមិនអាចសម្រេចលទ្ធផលដែលរំពឹងទុកនោះបានឡើយ ។ យើងអាចពិនិត្យបញ្ហានេះតាម២របៀប ÷ ទី១- ការតម្រឹមជាក់ស្តែង និងទី២- ការតម្រឹមការផ្តល់ហិរញ្ញប្បទានតាមវិស័យនិមួយៗ ។

[៦] កត់សម្គាល់អំពីមន្ទិលសង្ស័យចំពោះការកត់ត្រាចំនួនអង្គភាពអនុវត្តគម្រោង ។ តួលេខឆ្នាំ២០០៥ និង២០០៧ក៏នៅតែជាបញ្ហាដដែល ។ ដូច្នេះ ការវិភាគត្រូវធ្វើឡើងដោយប្រុងប្រយ័ត្ន ។

យោងតាមការប៉ាន់ស្មានអំពីតម្រូវការចំណាយដែលមានចែងក្នុងតារាងទី ៤.៣ នៃរបាយការណ៍ត្រួតពិនិត្យពាក់កណ្ដាលអាណត្តិនៃការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ តម្រូវការសរុបប្រចាំឆ្នាំសម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ គឺ៨៤០លានដុល្លាអាមេរិក ក្នុងនោះ ហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍សរុបមានទំហំ៨៥% ក្នុងឆ្នាំ២០០៦ និង៩៥% ក្នុងឆ្នាំ២០០៧ នៃតម្រូវការធនធានសរុប ។ ពិនិត្យជារួមក្នុងការអនុវត្តន៍ជាក់ស្ដែង ធនធានរបស់ដៃគូអភិវឌ្ឍន៍បានតម្រឹមល្អជាមួយនឹងតម្រូវការ ។ រូបភាពទី៥ បានបង្ហាញអំពីការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការនៅតាមវិស័យ ធៀបនឹងតម្រូវការធនធានប្រចាំឆ្នាំនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ លើសពីនេះ យើងក៏អាចសន្និដ្ឋានបានដែរថា វិស័យមួយចំនួន ដូចជាអភិបាលកិច្ច សុខាភិបាល កសិកម្ម និងស្បៀងអាហារ និងសហគមន៍និងសេវាសុខុមាលភាពសង្គម បានទទួលធនធានគ្រប់គ្រាន់ ក្នុងពេលដែលវិស័យមួយចំនួនទៀត ដូចជាវិស័យអភិវឌ្ឍន៍ជនបទ ដឹកជញ្ជូន និងអប់រំ បែរជាមិនទាន់បានទទួលធនធានគ្រប់គ្រាន់ទេវិញ ។

រូបភាពទី៥ : ការតម្រឹមកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ទៅនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦





ស្ថិតក្នុងស្មារតីនេះ យើងគួរបញ្ជាក់អំពីសារៈសំខាន់នៃធនធានក្នុងស្រុក និងដំណើរការរៀបចំថវិកា ដែលជាឧបករណ៍ក្នុងការធានាឱ្យមានធនធានគ្រប់គ្រាន់សម្រាប់អនុវត្តបណ្ដាអាទិភាពរបស់រាជរដ្ឋាភិបាល ក៏ដូចជា

ធានាឱ្យបាននូវការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាពសម្រាប់គាំទ្រថវិកា តាមរយៈកម្មវិធីប្រតិបត្តិការកាត់បន្ថយភាពក្រីក្រនិងកំណើន ដែលនៅមានកម្រិតហើយកំពុងកើនឡើងជារៀងរាល់ឆ្នាំ ។ ការប្រៀបធៀបរវាងតម្រូវការហិរញ្ញប្បទាននិងការសន្យាផ្តល់ហិរញ្ញប្បទាន គឺជាចំណុចចាប់ផ្តើមដ៏សំខាន់សម្រាប់ជាមូលដ្ឋានក្នុងការវិភាគអំពីការតម្រឹម ។ លើសពីនេះ ការវិភាជន៍ធនធានក៏មានសារៈសំខាន់ផងដែរ នៅពេលដែលទំហំតម្រូវការធនធាននិងការប្រើប្រាស់ធនធានពុំទាន់មានតុល្យភាពជាមួយគ្នា ។ ស្ថានភាពនេះនឹងនាំឱ្យវិស័យមួយចំនួនបានទទួលធនធានច្រើនលើសពីតម្រូវការ រីឯវិស័យមួយចំនួនទៀតបែរជាទទួលធនធានមិនគ្រប់គ្រាន់ទៅវិញ ។

រូបភាពទី៥ខាងក្រោមនេះបានបង្ហាញថា នៅក្នុងឆ្នាំ២០០៦ ទំនាក់ទំនងរវាងតម្រូវការ និងការផ្តល់ធនធាន (ការតម្រឹមធនធាន) មានកម្រិតខ្ពស់ ។ នេះបញ្ជាក់បានថា មានភាពល្អប្រសើរជាងមុនអំពីការតម្រឹមធនធានបរទេសជាមួយនឹងអាទិភាពរបស់ប្រទេស ទោះជាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបានស្នើឱ្យមានការខិតខំបន្ថែមទៀតក៏ដោយ ដោយសារតែនៅមានគម្លាតរវាងតម្រូវការធនធាននិងការផ្តល់ហិរញ្ញប្បទានជាក់ស្តែង សម្រាប់វិស័យអភិបាលកិច្ច អភិវឌ្ឍន៍ជនបទ និងដឹកជញ្ជូន ។

រូបភាពទី៦ : ការតម្រឹមកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ទៅនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៧





ទម្រង់ការទានានៃហិរញ្ញប្បទានសហប្រតិបត្តិការ

ការវិភាគបានបង្ហាញថា ហិរញ្ញប្បទានក្នុងឆ្នាំ២០០៧សម្រាប់គាំទ្រវិស័យកសិកម្មមានការធ្លាក់ចុះ ទោះបីជាមានការលុបចោលបំណុលរបស់អង្គការមូលនិធិរូបិយប័ណ្ណអន្តរជាតិក្នុងឆ្នាំ២០០៦ ហើយដែលធនធាននេះនឹងត្រូវប្រើប្រាស់សម្រាប់វិស័យកសិកម្ម ធារាសាស្ត្រ និងការផ្គត់ផ្គង់ទឹកស្អាតនៅជនបទក្នុងឆ្នាំ២០០៧ និងឆ្នាំបន្ទាប់ទៀតក៏ដោយ ។ ការផ្តល់ហិរញ្ញប្បទានសម្រាប់វិស័យហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនបានកើនឡើងយ៉ាងច្រើន ដោយសារមួយផ្នែកនៃកំណើននេះបានមកពីហិរញ្ញប្បទានរបស់សាធារណរដ្ឋប្រជាមានិតចិន
ទោះបីវិស័យនេះនៅមិនទាន់ បានទទួលធនធានគ្រប់គ្រាន់ក៏ដោយ ។

ការតម្រឹមទម្រង់ការទានាក៏ជាចំណុចសំខាន់មួយសម្រាប់ពិចារណាដែរ ។រាជរដ្ឋាភិបាលធ្លាប់បានបញ្ជាក់ទំនោររបស់ខ្លួនទៅលើទម្រង់ការផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការតាមរយៈកម្មវិធី ឬការគាំទ្រថវិកាឱ្យកាន់តែច្រើនឡើងថែមទៀត (នឹងពិភាក្សានៅក្នុងផ្នែក«សុខដុមនីយកម្ម»ខាងក្រោម) ។ រាជរដ្ឋាភិបាលសូមស្វាគមន៍ចំពោះកម្មវិធីប្រតិបត្តិការសម្រាប់កាត់បន្ថយភាពក្រីក្រនិងកំណើន ដែលផ្តល់ហិរញ្ញប្បទានដោយធនាគារពិភពលោក និងជប៉ុន ក្នុងឆ្នាំ២០០៧ ហើយបន្ទាប់មក ចក្រភពអង់គ្លេសបានចូលរួមផ្តល់ហិរញ្ញប្បទានក្នុងឆ្នាំ២០០៨ ដែលធនធាននេះមាន៣០លានដុល្លាអាមេរិកសម្រាប់ឆ្នាំ២០០៧ និង២២លានដុល្លាអាមេរិកសម្រាប់ឆ្នាំ២០០៨ [៧]។ ទន្ទឹមនឹងនេះ យោងតាមលទ្ធផលនៃការធ្វើអង្កេតស្តីពីការអនុវត្តន៍សេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស ការបង្កើនហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់គាំទ្រទម្រង់ការគ្រប់គ្រងទូទាំងវិស័យ និងការប្រើប្រាស់ប្រព័ន្ធជាតិមិនទាន់មានវឌ្ឍនភាពជាដុំកំភួននៅឡើយ ។ ស្ថានភាពនេះពុំមែនកើតឡើងនៅកម្ពុជាតែម្នាក់ឯងទេ ពីព្រោះនៅកម្រិតសកល ក៏បានកត់សំគាល់ថា «ការផ្តល់ហិរញ្ញប្បទានរួមគ្នា និងរបៀបចាត់ចែងការអនុវត្តន៍ភាគច្រើនត្រូវបានកំណត់ដោយដៃគូអភិវឌ្ឍន៍ ដោយមិនប្រើប្រាស់នីតិវិធី និងរចនាសម្ព័ន្ធរបស់ប្រទេសដៃគូ ។ នេះគឺជាការធ្វើសុខដុមនីយកម្មដោយគ្មានការតម្រឹម» [៨] ។

រូបភាពទី៧ : ការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការតាមប្រភេទឆ្នាំ២០០២-២០០៨



	2002	2003	2004	2005	2006	2007
មិនបានរាយការណ៍	0,0	0,0	4,6	8,5	1.4	7,0
ជំនួយម្ហូបអាហារ/ សង្គ្រោះបន្ទាន់	25,0	27,5	20,2	17,1	20,7	19,9
ហិរញ្ញប្បទានទ្រទ្រង់ថវិកា	39,4	32,1	6,4	6,9	91,2	35,2
កិច្ចសហប្រតិបត្តិការបច្ចេកទេស	275,4	247,1	263,5	287,3	248,0	306,3
ហិរញ្ញប្បទានសហប្រតិបត្តិការមូលធន	191,1	232,9	260,8	290,1	351,9	422,0

[៧] កម្មវិធីប្រតិបត្តិការលុបចោលបំណុលរបស់អង្គការរូបិយប័ណ្ណអន្តរជាតិ ក្នុងករណីខ្លះគឺជាការគាំទ្រថវិកា ត្រូវបានចាត់ទុកជាការគាំទ្រសម្រាប់វិស័យកសិកម្មសម្រាប់ការវិភាគក្នុងរបាយការណ៍នេះ ដូចបានបញ្ជាក់ក្នុងកិច្ចព្រមព្រៀងផ្តល់ហិរញ្ញប្បទានសម្រាប់វិស័យនេះ ។

[៨] «ការពង្រឹងនូវលទ្ធផលតាមរយៈការប្រើប្រាស់សេចក្តីថ្លែងការណ៍ទីក្រុងប៉ារីសនៅកម្រិតវិស័យ» ឆ្នាំ២០០៨ : ឯកសារនៃកិច្ចប្រជុំតុមូលទី៨បង្ហាញក្នុងវេទិកាកំពូលនាទីក្រុងអាក្រាស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ ។

តារាងទី៨: ការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការតាមដៃគូអភិវឌ្ឍន៍និងតាមប្រភេទហិរញ្ញប្បទាន (លានដុល្លា)

	FTC	ITC	IPA	GBS	Food aid	other	Total	FTC	ITC	IPA	GBS	Food aid	other	Total	FTC	ITC	IPA	GBS	Food aid	Total
ភ្នាក់ងារអង្គការសហប្រជាជាតិ																				
FAO		0,2					0,2	0,2	0,1					0,3	0,5				0,2	0,7
IFAD			4,1				4,1			5,5				5,5			5,4			5,4
ILO	3,8		0,1				3,9	3,4		0,1				3,6	1,4		0,2			1,6
UNAIDS	0,4						0,4	0,4						0,4						
UNDP	7,8						7,8	9,2						9,2	35,0					35,0
UNESCO	2,1						2,1	1,9						1,9	2,3					2,3
UNFPA	2,1						2,1	2,9						2,9	5,0					5,0
UNICEF		12,1					12,1		12,1					12,1		9,7				9,7
WFP					19		19					15,9		15,9					28,0	28,0
WHO	2,2						2,2	0,6						0,6	3,9	2,4				6,3
ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ																				
World Bank	0,7	7,2	16,5				24,5	0,6	5,1	26,5	15,5			47,6	1,4	41,8	14,0			57,1
IMF	1,4			82,1			83,5	0,9						0,9						
ADB	3,2	4	60,2				67,5	3,2	4,1	62,1				69,4	3,6	4,1	106,3			114,0
ផ្សេងៗ																				
Global Fund			21,9				21,9			21,1				21,1			32,3			32,3
សរុប	23,7	23,5	102,8	82,1	19		251,3	23,3	21,4	115,3	15,5	15,9		191,4	53,2	57,9	158,1		28,2	297,4
សហភាពអឺរ៉ុប																				
Belgium	6,9		0,1			0,4	7,3	7		0,5			0,4	8	3,3					3,3
Denmark	2,8		1,3				4,1			9,8				9,8			10,1			10,1
Finland	4,5						4,5	5,2						5,2	6,8					6,8
France	2,6	1,6	17,6				21,8	2,8	0,9	18				21,8	9,2	1,6	22,4			33,3
Germany	13,2	8,1	9,3		0,8	1	32,4	16,3	0,2	12,6		0,9	6,5	36,5	18,0		14,1		1,0	33,0
Netherlands	0,1						0,1	0,1						0,1						0,0
Spain	1,1		1,7				2,8	2,7				1,4		4,1	6,2				1,1	7,4
Sweden	2,1	7,5	6,3				16	0,9	16,4					17,3	0,9	17,0				17,9
UK	8,1	0,2	12,2	0,1			20,7	12,8	0,1	10,3	0,5			23,7	27,6		7,2	3,1		37,8
EC	37,5			9			46,5	39,3			5,6			44,9	36,1	0,2		15,8		52,1
សរុប	41,4	17,4	48,5	0,1	0,8	1,4	109,7	47,8	17,6	51,2	0,5	2,3	6,9	126,5	108,1	18,9	53,7	18,9	2,1	201,7
ដៃគូអភិវឌ្ឍន៍ទ្វេភាគីសំខាន់ៗ																				
Australia	18,3	3,9			0,3		22,5	26,4	3,2					29,6	20,9	2,2				23,0
Canada	7,9						7,9	8,7						8,7	19,2					19,2
China	0,4		52,8				53,2			92,4				92,4		22,0	105,9			127,9
Japan	37,9		65,7				103,7	37,2	0,1	71,2	13,6			122,1	40,5	13,5	85,0	5,6		144,6
New Zealand	1,2	0,5					1,7	1,3	2,5					3,8	1,6	1,8				3,3
Rep of Korea	8,1		5,1				13,3	31,4						31,4	3,0	3,7	5,3			12,1
Switzerland	0,1	0,3	2				2,4	0,5	0,4	2,7				3,6	0,9		2,8			3,8
USA			51				51			58,1				58,1			54,9			54,9
សរុប	73,9	4,7	176,6	0	0,3	0	255,7	105,5	6,2	224,4	13,6	0	0	349,7	86,1	43,2	253,9	5,6		388,8
អង្គការក្រៅរដ្ឋាភិបាល	18,4	7,2	24		0,6		50,2	32,1	12,8	31		1,8	0,1	77,7						
សរុប	**195,1**	**52,9**	**351,9**	**91,2**	**20,7**	**1,4**	**713,2**	**248,3**	**58**	**422**	**35,2**	**19,9**	**7**	**790,4**	**247,4**	**120**	**465,7**	**24,5**	**30,3**	**887,9**

<u>កំណត់សម្គាល់:</u>

- *FTC = គំរោងទោល*
- *ITC = គាំទ្រវិនិយោគមូលធន*
- *IPA = គំរោងមូលធន*
- *GBS = គាំទ្រថវិកា*
- *Food Aid = ស្បៀង*
- *Other = ផ្សេងៗ*
- *Total = សរុប*

ការផ្តល់ហិរញ្ញប្បទានសម្រាប់កិច្ចសហប្រតិបត្តិការបច្ចេកទេសឆ្នាំ២០០៧-២០០៨ បានផ្តោតការយកចិត្តទុកដាក់ជាពិសេសទៅលើការអភិវឌ្ឍន៍សមត្ថភាព ។ ការវិភាគក្នុងរបាយការណ៍ស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទាន

សហប្រតិបត្តិការឆ្នាំ២០០៧ ក៏បានពិចារណាអំពីតួនាទីនៃកិច្ចសហប្រតិបត្តិការបច្ចេកទេសសម្រាប់គាំទ្រកម្មវិធីកំណែទម្រង់នានា និងការគាំទ្រការអភិវឌ្ឍន៍សមត្ថភាពតាមរូបភាពផ្សេងៗ សម្រាប់រៀបចំគោលការណ៍ណែនាំស្តីពីតួនាទីនិងការគ្រប់គ្រងកិច្ចសហប្រតិបត្តិការបច្ចេកទេស ដែលជាផ្នែកមួយនៃគោលនយោបាយរួមស្តីពីការអភិវឌ្ឍន៍ធនធានមនុស្សនិងសមត្ថភាពរបស់ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ។ តាមការសង្កេតនៅក្នុងរបាយការណ៍កាលពីឆ្នាំមុន ដែល «កម្រិតជឿទុកចិត្តនៃរបាយការណ៍សិក្សានេះនៅតែជាបញ្ហាចោទមួយ» ដៃគូអភិវឌ្ឍន៍ជាច្រើន ពិសេសភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិសហរដ្ឋអាមេរិក ក៏បានពិនិត្យមើលឡើងវិញយ៉ាងហ្មត់ចត់ អំពីចំណាត់ថ្នាក់នៃការផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការរបស់ពួកគេ ។ ជាលទ្ធផល ធនធានសម្រាប់កិច្ចសហប្រតិបត្តិការបច្ចេកទេសដែលបានកត់ត្រាក្នុងឆ្នាំ២០០៦ ហើយដែលត្រូវបានរាយការណ៍នៅក្នុងរបាយការណ៍ឆ្នាំ២០០៧ ចំនួន ២៧៥លានដុល្លាអាមេរិក ស្មើនឹងប្រមាណពាក់កណ្តាលនៃការប្រើប្រាស់ហិរញ្ញប្បទានសរុប ត្រូវបានកែតំរូវមកត្រឹម ២៤៨លានដុល្លាអាមេរិកវិញ ។ តាមការកែតំរូវបរិមាណហិរញ្ញប្បទានសហប្រតិបត្តិការសរុប ចំនួន៧១៣លានដុល្លាអាមេរិក កិច្ចសហប្រតិបត្តិការបច្ចេកទេសក្នុងឆ្នាំ២០០៦ បានធ្លាក់ចុះមកត្រឹម៣៥% ហើយបានកើនឡើងបន្តិចវិញ ចំនួន៣៩%ក្នុងឆ្នាំ២០០៧ ។ រូបភាពទី៧បានបង្ហាញថា ៥០%នៃហិរញ្ញប្បទានសហប្រតិបត្តិការសរុបក្នុងឆ្នាំ ២០០៦-២០០៧ ត្រូវបានប្រើប្រាស់សម្រាប់គម្រោងវិនិយោគ ។ ព័ត៌មានលំអិតស្តីពីការផ្តល់ហិរញ្ញប្បទានសហ-ប្រតិបត្តិការរបស់ដៃគូអភិវឌ្ឍន៍នីមួយៗបានបង្ហាញក្នុងតារាងទី៨ ។

ភាពដែលអាចទស្សន៍ទាយជាមុន

ទន្ទឹមនឹងការតម្រឹមជាមួយនឹងបណ្តាអាទិភាពជាតិ ការប្រើប្រាស់ប្រព័ន្ធរបស់រដ្ឋ និងការផ្តល់ការគាំទ្រតាមរយៈការប្រើប្រាស់ទម្រង់សមស្របមួយ ភាពអាចទស្សន៍ទាយជាមុននៃហិរញ្ញប្បទានសហប្រតិបត្តិការ នឹងបង្កើនប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ ។ កិច្ចពិភាក្សាកម្រិតសកលមុនវេទិកាកំពូលនៅទីក្រុងអាក្រាបានកំណត់បញ្ហានេះជាបញ្ហាសំខាន់មួយ ។ នៅកម្ពុជា យើងសម្រេចបានវឌ្ឍនភាពជាដុំកំភួនក្នុងការបង្កើនភាពអាចទស្សន៍ទាយជាមុននៃធនធានបរទេសក្នុងរយៈពេលពីរឆ្នាំចុងក្រោយនេះ ។ ក្នុងបរិការណ៍នៃកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការរៀបចំប្រព័ន្ធគ្រប់គ្រងទិន្នន័យហិរញ្ញប្បទានសហប្រតិបត្តិការរបស់កម្ពុជា និងការផ្ទេរពីការប្រកាសផ្តល់ហិរញ្ញប្បទានផ្លូវការនៅក្នុងកិច្ចប្រជុំក្រុមពិគ្រោះយោបល់ ទៅជាការប្រកាសតួលេខណែនាំស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់ច្រើនឆ្នាំ នៅក្នុងវេទិកាសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា យើងបានផ្តោតការយកចិត្តទុកដាក់ជាច្រើនលើផែនកានីយកម្ម និងកម្មវិធីនីយកម្មនៃធនធានទាំងនេះ ។ ការអង្កេតស្តីពីការតាមដានការអនុវត្តន៍សេចក្តីថ្លែងការណ៍ទីក្រុងប៉ារីសដែលបានកត់ត្រាអំពីវឌ្ឍនភាពនេះ បានបង្ហាញពីភាពរលូនជាមួយគ្នា រវាងផែនការផ្តល់និងការប្រើប្រាស់ជាក់ស្តែងហិរញ្ញប្បទានសហប្រតិបត្តិការប្រចាំឆ្នាំនិមួយៗ (សូមមើលតារាងទី២) ។ សូចនាករសំខាន់ៗនៃភាពអាចទស្សន៍ទាយជាមុនគឺការប្រើប្រាស់តួលេខដែលបានផ្តល់ក្នុងក្របខ័ណ្ឌណែនាំស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការច្រើនឆ្នាំ ក្នុងវេទិកាសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី១ និងទិន្នន័យដែលបានកត់ត្រាក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ផ្លូវការកម្ពុជា ។ តារាងទី៩បានបង្ហាញថា ទោះបីភាពអាចទស្សន៍ទាយជាមុនក្នុងឆ្នាំ២០០៧មានកម្រិតខ្ពស់ចំនួន ៩៩% (ចំពោះតែដៃគូអភិវឌ្ឍន៍ដែលបានផ្តល់តួលេខទាន់ស្មានក្នុងវេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា នាខែមិថុនា ឆ្នាំ២០០៧) ក៏ដោយ ក៏មានភាពខុសគ្នាគួរឱ្យកត់សំគាល់រវាងដៃគូអភិវឌ្ឍន៍ផងដែរ ។ ការធ្វើ

វិភាគម្តងទៀតក្នុងឆ្នាំ២០០៨បានបង្ហាញពីគំលាតច្រើនជាងមុនសម្រាប់ដៃគូអភិវឌ្ឍន៍នីមួយៗ ហើយតួលេខប៉ាន់ស្មាននៃការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់ឆ្នាំ២០០៨
មានកម្រិតខ្ពស់ជាងតួលេខដែលបានប្រកាស ក្នុងវេទិកាសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី១ ។

តារាងទី៩ - ភាពអាចទស្សន៍ទាយជាមុននៃហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ឆ្នាំ ២០០៧-២០០៨

	២០០៧				២០០៨			
	ក្របខ័ណ្ឌណែនាំស្តីពីហិរញ្ញប្បទានច្រើនឆ្នាំ	តួលេខចុងក្រោយ (ប៉ាន់ស្មាន)	ដុល្លាអាមេរិកលំអៀង	% (=a/b)	ក្របខ័ណ្ឌណែនាំប្រើប្រាស់ហិរញ្ញប្បទានច្រើនឆ្នាំ	ប៉ាន់ស្មាន ប្រើប្រាស់ជាក់ស្តែង	ដុល្លាអាមេរិកលំអៀង	% (=a/b)
សាធារណរដ្ឋកូរ៉េ	12,3	31,4	19,1	255%	38,7	12,1	-26,7	31%
អាល្លឺម៉ង់	21,8	36,5	14,7	168%	19,3	33	13,7	171%
ហ្វាំងឡង់	3,3	5,2	1,9	155%	3	6,8	3,9	231%
ណូវែលហ្សេឡង់	2,5	3,8	1,3	153%	2,7	3,3	0,6	122%
បែលហ្ស៊ិក	6,5	8	1,5	123%	3,8	3,3	-0,5	87%
សហរដ្ឋអាមេរិក	48,8	58,1	9,3	119%	0	54,9	54,9	---
ជប៉ុន	112,3	122,1	9,8	109%	112,3	144,6	32,3	129%
សាធារណរដ្ឋប្រជាមានិតចិន	91,5	92,4	0,9	101%	105,1	127,9	22,8	122%
ចក្រភពអង់គ្លេស	24,7	23,7	-1	96%	28,5	37,8	9,3	133%
ធនាគារអភិវឌ្ឍន៍អាស៊ី	74,8	69,4	-5,4	93%	57	114	57	200%
សហភាពអឺរ៉ុប	50,5	44,9	-5,6	89%	35,2	52,1	16,9	148%
ស៊ុយអែត	19,7	17,3	-2,4	88%	23,8	17,9	-5,9	75%
បារាំង	25,1	21,8	-3,3	87%	36,2	33,3	-2,9	92%
អេស្ប៉ាញ	5	4,1	-0,9	83%	7	7,4	0,3	105%
ទីភ្នាក់ងារអង្គការសហប្រជាជាតិ	64,8	52,4	-12,4	81%	59,7	94,1	34,4	158%
អូស្ត្រាលី	37,6	29,6	-8	79%	41,9	23	-18,9	55%
ធនាគារពិភពលោក	62,6	47,6	-15	76%	86,7	57,1	-29,6	66%
កាណាដា	11,7	8,7	-3	74%	16,4	19,2	2,8	117%
ដាណឺម៉ាក	13,6	9,8	-3,8	72%	17,4	10,1	-7,3	58%
សរុប	**689,2**	**686,8**	**-2,4**	**99,70%**	**694,8**	**851,9**	**157,1**	**123%**

ក្របខ័ណ្ឌណែនាំហិរញ្ញប្បទានសហប្រតិបត្តិការច្រើនឆ្នាំ និងប្រព័ន្ធគ្រប់គ្រងទិន្នន័យហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ផ្លូវការដែលបានបង្កើតឡើងយ៉ាងរឹងមាំ គឺជាយន្តការសំខាន់សម្រាប់គាំទ្រការងារផែនការនីយកម្ម និងកម្មវិធីនីយកម្មនៃហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ ។ យើងត្រូវបន្តកិច្ចសហការនេះទៀត សម្រាប់បង្កើនប្រសិទ្ធភាពនៃការងារថវិកានីយកម្ម និងការគ្រប់គ្រងកម្មវិធី ។

សុខដុមនីយកម្ម និងភាពជាដៃគូ

> *«ក្រសួងជំនាញជាច្រើនបានពង្រឹងភាពជាម្ចាស់ក្នុងការអនុវត្តន៍សកម្មភាពស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការនៅកម្រិតវិស័យ ហើយបានបង្ហាញឆន្ទៈរួចជាស្រេចក្នុងការជម្រុញឱ្យដៃគូអភិវឌ្ឍន៍អនុវត្តបានពេញលេញនូវការប្តេជ្ញារបស់ពួកគេ ស្តីពីសុខដុមនីយកម្ម»*
>
> *ការពិនិត្យឯករាជ្យស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការនៅកម្ពុជា ឆ្នាំ២០០៨*

ទិសដៅអាទិភាពនៃសុខដុមនីយកម្មក្នុងផែនការសកម្មភាពស្តីពីសុខដុមនីយកម្ម ការតម្រឹម និងលទ្ធផល គឺការប្រើប្រាស់អភិក្រមគ្រប់គ្រងទូទាំងវិស័យនិងប្រតិភូកម្មកិច្ចសហប្រតិបត្តិការដែលជាវិធានការ សម្រាប់ជម្រុញប្រសិទ្ធភាពនៃការផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការ តាមរយៈការពង្រឹងភាពជាម្ចាស់ ការតម្រឹមជាមួយនឹងបណ្តាអាទិភាពជាតិ និងការជម្រុញឱ្យប្រើប្រាស់ប្រព័ន្ធជាតិ ។ ការអង្កេតស្តីពីការតាមដានការអនុវត្តន៍សេចក្តីថ្លែងការណ៍ទីក្រុងប៉ារីសឆ្នាំ២០០៨ បានបង្ហាញពីវឌ្ឍនភាពតិចតួចក្នុងការផ្តល់ធនធានសម្រាប់គាំទ្រអភិក្រមគ្រប់គ្រងទូទាំងវិស័យ ទោះបីជាមានកំណើនអំពីចំនួនក្នុងការអនុវត្តន៍អភិក្រមគ្រប់គ្រងទូទាំងវិស័យក៏ដោយ ។ ស្ថានភាពនេះអាចបង្ហាញអំពីការលំបាកក្នុងការជម្រុញឱ្យអនុវត្តអភិក្រមគ្រប់គ្រងទូទាំងវិស័យ ។ ដោយយល់ច្បាស់ពីចំណាយប្រតិបត្តិការសម្រាប់អនុវត្តទម្រង់ការថ្មីនេះ ដូចជាការរៀបចំផែនការរួមគ្នា ការចរចា និងការត្រួតពិនិត្យ យើងអាចជួបហានិភ័យដោយសារការផ្តល់ហិរញ្ញប្បទានស្របគ្នា ព្រោះអាចបណ្តាលឱ្យការអនុវត្តន៍អភិក្រមគ្រប់គ្រងទូទាំងវិស័យនៅតាមវិស័យទាំងនោះត្រូវជាប់គាំង ហើយចំណាយប្រតិបត្តិការត្រូវកើនខ្ពស់ជាប្រចាំ ។

នៅពេលដែលអភិក្រមគ្រប់គ្រងទូទាំងវិស័យកំពុងប្រឹងប្រែងសម្រាប់ទទួលយកទម្រង់ការនានា ក្នុងការផ្តល់ហិរញ្ញប្បទាន យើងត្រូវជម្រុញឱ្យមានការកែប្រែរបៀបរបបការងាររបស់ពួកគេ ដែលបច្ចុប្បន្ន បានសម្របសម្រួលគ្នាត្រឹមការរៀបចំផែនការប្រចាំឆ្នាំ និងការត្រួតពិនិត្យប៉ុណ្ណោះ ។ នៅក្នុងកម្រិតអប្បបរមា ការងារនេះក៏អាចជាមធ្យោបាយឆ្លុះបញ្ចាំងអំពីការគាំទ្រហិរញ្ញវត្ថុនិងសកម្មភាពទាំងអស់ នៅក្នុងផែនការសកម្មភាពប្រចាំឆ្នាំដែលជាមូលដ្ឋាននៃការរៀបចំកម្មវិធីនីយកម្មគ្រប់ជ្រុងជ្រោយ ការប្រើប្រាស់ប្រព័ន្ធជាតិឱ្យបានច្រើនឡើង និងវិធីសាស្ត្ររួមសម្រាប់ការតាមដាននិងត្រួតពិនិត្យ ។ ជាមួយនឹងវឌ្ឍនភាពថ្មីៗបច្ចុប្បន្ន និងការរៀបចំនានាតាមវិស័យមួយចំនួន ដើម្បីសម្របខ្លួនទៅនឹងអភិក្រមគ្រប់គ្រងទូទាំងវិស័យ យើងក៏ត្រូវមើលឱ្យឃើញអំពីបញ្ហាប្រឈមសំខាន់ៗ និងភាពស្មុគស្មាញជាច្រើនដែលបង្កើតឡើងដោយការផ្តល់មូលនិធិខ្សែបណ្តោយ និងប្រភពហិរញ្ញប្បទានអភិវឌ្ឍន៍ថ្មីៗដទៃទៀត។

ចំនួនប្រតិភូកម្មក្នុងកិច្ចសហប្រតិបត្តិការបានកើនឡើងតិចតួចក្នុងឆ្នាំ២០០៧ (មានគម្រោងចំនួន២៧បានអនុវត្តតាមទម្រង់សហហិរញ្ញប្បទាន) ហើយគម្រោងចំនួន៤១បានអនុវត្តការធ្វើប្រតិភូកម្មហិរញ្ញប្បទានឱ្យដៃគូអភិវឌ្ឍន៍ដទៃទៀត ។ បើពិនិត្យខាងទិដ្ឋភាពសុខដុមនីយកម្មវិញ ហិរញ្ញប្បទានដែលបានផ្តល់តាមទម្រង់ទាំង២នេះក៏មានទំហំធំល្មមដែរ ។ ក្នុងឆ្នាំ២០០៧ លំហូរនៃហិរញ្ញប្បទានតាមទម្រង់ទាំងនេះដែលបានបង្ហាញក្នុងតារាងទី១០ មានប្រមាណ៦៤លានដុល្លាអាមេរិក ស្មើនឹង៩%នៃសរុបធនធានសហប្រតិបត្តិការអភិវឌ្ឍន៍ ។ លទ្ធភាពនៃការធ្វើប្រតិភូកម្ម ឬកិច្ចសហប្រតិបត្តិការ បានឆ្លុះបញ្ចាំងក្នុងកម្មវិធីប្រតិបត្តិការសម្រាប់កាត់បន្ថយ

ភាពក្រីក្រនិងកំណើន និងការដាក់មូលនិធិរួមគ្នាសម្រាប់គាំទ្រវិស័យសុខាភិបាល គឺជាគំនិតផ្តួចផ្តើមដ៏សំខាន់ដែលបានអនុវត្តក្នុងឆ្នាំ២០០៨ ។

តារាងទី១០ - ទម្រង់ការនៃភាពជាដៃគូ ឆ្នាំ២០០៧

ដៃគូនាំមុខ - ចំនួនគម្រោង និងវិស័យ			ប្រតិភូកម្មដៃគូអភិវឌ្ឍន៍ ភ្នាក់ងារអនុវត្តន៍គម្រោង និងវិស័យ	
ADB	3	សុខាភិបាល បរិស្ថាននិងអភិរក្ស កសិកម្ម	EU/EC	UNDP – សុខមាលភាពសហគមន៍និងសង្គមកិច្ច អភិបាលកិច្ច និងរដ្ឋបាល UNICEF - សុខាភិបាល FAO - កសិកម្ម
World Bank	5	ថាមពលនិងអគ្គិសនី កិច្ចអភិវឌ្ឍន៍ជនបទ អភិបាលកិច្ច និងរដ្ឋបាល(២) ទឹកស្អាតនិងអនាម័យ	Finland	World Bank - អភិវឌ្ឍន៍ជនបទ
IFAD	2	កសិកម្ម (២)	France	ADB - កសិកម្ម អភិបាលកិច្ច និងរដ្ឋបាល
UNDP	5	អភិបាលកិច្ច និងរដ្ឋបាល (៤) អភិវឌ្ឍន៍ជនបទ	Germany	UNFPA - អភិបាលកិច្ច និងរដ្ឋបាល UNDP - អភិបាលកិច្ច និងរដ្ឋបាល
UNFPA	1	អភិបាលកិច្ច និងរដ្ឋបាល	Spain	UNDP - អភិបាលកិច្ច និងរដ្ឋបាល (២) អភិវឌ្ឍន៍ជនបទ WFP - ស្បៀងអាហារ
UNICEF	3	សុខុមាលភាពសហគមន៍និងសង្គមកិច្ច អប់រំ ទឹកស្អាត និងអនាម័យ	Sweden	UNDP - អភិបាលកិច្ច និងរដ្ឋបាល (២) UNICEF - អប់រំ
WFP	1	ស្បៀងអាហារ / សុខាភិបាល / ហ៊ីវ/អេដស៍ / ដឹកជញ្ជូន	UK	World Bank - អភិបាលកិច្ច និងរដ្ឋបាល (២), សុខាភិបាល UNDP - អភិបាលកិច្ច និងរដ្ឋបាល Denmark - ការអភិវឌ្ឍន៍ជនបទ US - សុខាភិបាល
Australia	1	សុខុមាលភាពសហគមន៍ និងសង្គមកិច្ច	Australia	World Bank - អភិបាលកិច្ច និងរដ្ឋបាល (៣) UNDP - អភិបាលកិច្ច និងរដ្ឋបាល (២), អភិវឌ្ឍន៍ជនបទ
Denmark	1	កសិកម្ម/អភិបាលកិច្ច និងរដ្ឋបាល/អភិវឌ្ឍន៍ជនបទ	Canada	UNDP - អភិបាលកិច្ច និងរដ្ឋបាល ការអភិវឌ្ឍន៍ជនបទ
France	1	បរិស្ថាន និងអភិរក្ស	New Zealand	UNDP - អភិបាលកិច្ច និងរដ្ឋបាល Denmark - ការអភិវឌ្ឍន៍ជនបទ

ការអនុវត្តន៍អភិក្រមគ្រប់គ្រងទូទាំងវិស័យ ត្រូវបានចាត់ទុកថាជាការឆ្លើយតបទៅនឹងការបែកខ្ញែកហិរញ្ញប្បទានសហប្រតិបត្តិការក្នុងកម្រិតខ្ពស់នៅកម្ពុជា ។ ការវិភាគដែលបានបង្ហាញក្នុងរបាយការណ៍ស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការឆ្នាំ២០០៧ ដែលបានបង្ហាញពីការខិតខំប្រឹងប្រែងជាច្រើនសម្រាប់កាត់បន្ថយការបែកខ្ញែកនៃហិរញ្ញប្បទានសហប្រតិបត្តិការ បានក្លាយទៅជាបញ្ហាប្រឈមគួរឱ្យកត់សំគាល់ ដោយសារកម្ពុជាមានដៃគូសំខាន់ៗជាច្រើន ទាំងដៃគូទ្វេភាគី ទាំងដៃគូពហុភាគី ។ របាយការណ៍នៃការសិក្សាកាលពីឆ្នាំ២០០៧ ទោះបីមិនចាំបាច់រៀបរាប់សាជាថ្មីម្តងទៀត ក៏សេចក្តីសន្និដ្ឋាននៃរបាយការណ៍ និងសំណើអនុវត្តសកម្មភាពអាទិភាពនៅតែមានភាពត្រឹមត្រូវដដែល ។

រូបភាពទី៨ : ភាពបែកខ្ញែកនៃហិរញ្ញប្បទានសហប្រតិបត្តិការ ឆ្នាំ២០០៧



របាយការណ៍នៃការសិក្សាបានលើកបញ្ហាប្រឈមមួយចំនួនបន្ថែមទៀត ពិសេស បានផ្តោតការយកចិត្តទុកដាក់ទៅលើចំនួនគម្រោងកំពុងអនុវត្តក្នុងឆ្នាំ២០០៧ និងចំណាយសម្រាប់គ្រប់គ្រងគម្រោងនិមួយៗ ។ រូបភាពទី៨ខាងលើបានបង្ហាញស្ថានភាពនៃការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការសរុប សម្រាប់គម្រោងទាំងអស់ដែលបានអនុវត្តនៅក្នុងឆ្នាំ២០០៧ ។ គម្រោងចំនួន៦២២ ក្នុងចំណោមគម្រោងទាំងអស់ចំនួន៧៥៩ ស្មើនឹងជាង ៨០%នៃចំនួនគម្រោងសរុប បានប្រើប្រាស់ហិរញ្ញប្បទានតិចជាង១លានដុល្លាអាមេរិកសម្រាប់គម្រោងនិមួយៗ ។ ធនធានហិរញ្ញប្បទានសរុបសម្រាប់គម្រោងទាំង៦២២ មានចំនួន១៤២លានដុល្លាអាមេរិក ពោលគឺជាមធ្យម ស្មើនឹង ២២៩.០០០ដុល្លាអាមេរិកសម្រាប់គម្រោងនិមួយៗ ។ ៨០%នៃគម្រោងកំពុងអនុវត្តនៅកម្ពុជាបានប្រើប្រាស់ត្រឹមតែ ២០%នៃហិរញ្ញប្បទានសហប្រតិបត្តិការសរុប ។ ប៉ុន្តែ ២០%នៃគម្រោងកំពុងអនុវត្ត បានប្រើប្រាស់ធនធានរហូតដល់៨០%នៃហិរញ្ញប្បទានសរុប ។

នៅពេលដែលទទួលយល់ព្រមទម្រង់ការផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការទាំងអស់ រាជរដ្ឋាភិបាលបានកត់សំគាល់អំពីការបែកខ្ញែកលើសលប់នៃហិរញ្ញប្បទាន ដែលបានបង្ហាញក្នុងសន្និសីទហ៊ីហ្វាន់ដាលឆ្នាំ២០០៧ ហើយក៏បានគូសបញ្ជាក់ពីភាពចាំបាច់ក្នុងការកាត់បន្ថយចំណាយសម្រាប់គ្រប់គ្រងគម្រោងផងដែរ ។ លើសពីនេះ ប្រសិនបើ «ដៃគូអភិវឌ្ឍន៍និមួយៗផ្តល់ហិរញ្ញប្បទានសម្រាប់គ្រប់ផ្នែកទាំងអស់» នោះ យើងមានការលំបាកក្នុងការឆ្លុះបញ្ចាំងធាតុចូលជាមួយនឹងលទ្ធផល ។ ប្រការនេះនឹងនាំឱ្យការតាមដានតាមវិស័យក្លាយជាការទទួលខុសត្រូវ

ជាសមូហភាពច្រើនជាងគណនេយ្យភាពទ្វេទិស ។ ក្រោយពីបានពិនិត្យសក្ខីភាពជាក់ស្តែងឡើងវិញ យើងគ្មានជម្រើសអ្វីក្រៅពីការពង្រឹងការអនុវត្តន៍អភិក្រមគ្រប់គ្រងទូទាំងវិស័យឡើយ ។ អនុវត្តដូចនេះ ទើបដៃគូអភិវឌ្ឍន៍អាចគោរពនិងអនុវត្តការសន្យារបស់ពួកគេស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទាន តាមរយៈការបង្កើនចំនួនប្រតិភូកម្មកិច្ចសហប្រតិបត្តិការ និងការចាប់ផ្តើមអនុវត្តអភិក្រមស្តីពី «ការបែងចែកពលកម្ម» ។

គំនិតផ្តួចផ្តើមចុងក្រោយនេះត្រូវបានពិភាក្សានៅកម្ពុជានាពេលថ្មីៗនេះ ក្នុងបរិបទនៃផែនទីចង្អុលផ្លូវរបស់សហភាពអឺរ៉ុប ។ ការសង្កេតក្នុងកម្រិតសកលបានបង្ហាញថា វឌ្ឍនភាពតិចតួចស្តីពីការប្រមូលផ្តុំហិរញ្ញប្បទានតាមវិស័យ មិនមែនជាការលើកទឹកចិត្តដល់ដៃគូអភិវឌ្ឍន៍ និងប្រទេសដៃគូឡើយ ។ នេះមានន័យថា ការបែកខ្ញែកនេះអាចនាំឱ្យមានការខ្វែងគំនិតគ្នា ដោយសារដៃគូអភិវឌ្ឍន៍មួយចំនួនប្រកាន់ខ្ជាប់នូវ «ឧត្តមភាពប្រៀបធៀប» របស់ប្រទេសខ្លួន[៩] ។ «ផែនការសកម្មភាពទីក្រុងអាក្រា» បានបញ្ជាក់សាឡើងវិញអំពីគោលការណ៍នៃសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីសថា ប្រទេសដៃគូត្រូវដឹកនាំដំណើរការនៃ «ការបែងចែកពលកម្ម» នេះ ។ ការយល់បែបនេះគឺជាការខុសឆ្គងមួយ ពិសេសចំពោះរាជរដ្ឋាភិបាលដែលពឹងផ្អែកខ្លាំងលើហិរញ្ញប្បទានសហប្រតិបត្តិការ ។ ជាក់ស្តែងនេះអាចបកស្រាយបានអំពីមូលហេតុដែល «ការបែងចែកពលកម្ម» នេះ ត្រូវបានរៀបចំជាច្រើនក្នុងកម្រិតសកល ហើយបែរជាអនុវត្តបានស្តួចស្តើងបំផុតនៅតាមប្រទេសដៃគូនិមួយៗ ។

ទោះជាយ៉ាងនេះក្តី យើងមានលទ្ធភាពបង្កើតគោលការណ៍ជាច្រើន ។ រាជរដ្ឋាភិបាលមានបំណងរៀបចំចក្ខុវិស័យរបស់ខ្លួន សម្រាប់អនុវត្តគោលការណ៍ស្តីពី «ការបែងចែកពលកម្ម» នេះ ហើយបានរៀបចំខ្លួនជាស្រេចសម្រាប់សម្របសម្រួលដំណើរការរវាងដៃគូដែលមានឆន្ទៈអនុវត្ត ។ ប៉ុន្តែ ក្រៅពីការចរចាស្តីពីយុទ្ធសាស្ត្រប្រទេស និងកិច្ចពិគ្រោះយោបល់ក្នុងអំឡុងពេលនៃការរៀបចំកម្មវិធីនីយកម្ម រាជរដ្ឋាភិបាលយល់អំពីបញ្ហាប្រឈមរបស់ខ្លួនក្នុងការណែនាំឱ្យដៃគូអភិវឌ្ឍន៍គាំទ្រវិស័យជាក់លាក់មួយចំនួន ។ ទោះជាយល់ច្បាស់ពីកម្រិតយ៉ាងនេះក៏ដោយ ក៏រាជរដ្ឋាភិបាលអាចលើកអំពីគោលការណ៍មួយចំនួន ដូចខាងក្រោម ÷

១- ការបំពេញបន្ថែមត្រូវពិនិត្យនៅកម្រិតជាតិ (ចំនួនដៃគូ និងការគាំទ្រតាមវិស័យ) និងក្នុងវិស័យនិមួយៗ (ចំនួនដៃគូ គម្រោង និងការបំពេញឱ្យគ្នារវាងបណ្តាទម្រង់ការផ្តល់ហិរញ្ញប្បទាន) ។

២- បញ្ហាប្រឈមគឺការគ្រប់គ្រងភាពបែកខ្ញែក ដែលមិនតម្រូវឱ្យមានការឯកភាព ។ ធ្វើបែបនេះ ទើបប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការអាចដើរស្របនឹងសមត្ថភាពបច្ចេកទេស (ដូចជាការប្រើប្រាស់អភិក្រមគ្រប់គ្រងទូទាំងវិស័យ ការដាក់មូលនិធិរួមគ្នាសម្រាប់កិច្ចសហប្រតិបត្តិការបច្ចេកទេស ប្រតិភូកម្មក្នុងកិច្ចសហប្រតិបត្តិការ)។

៣- ការធានាមិនឱ្យវិស័យណាមួយនៅឯកោ និងមិនបានទទួលហិរញ្ញប្បទានសហប្រតិបត្តិការ ព្រមទាំងត្រូវអនុវត្តតាមអភិក្រមស្តីពី «ពហុភាគី- ពហុវិស័យ» ដោយត្រូវប្រើប្រាស់ទិន្នន័យ និងសក្ខីភាពជាក់ស្តែងដែលពាក់ព័ន្ធនឹងវិសាលភាព និងទម្រង់ការនៃការផ្តល់ហិរញ្ញប្បទាន ។

៤- ផ្អែកលើលក្ខខ័ណ្ឌវិនិច្ឆ័យនេះ «ការបែងចែកពលកម្ម» ត្រូវយកចិត្តទុកដាក់លើ ÷

---

[៩] "ការពង្រឹងលទ្ធផលដោយអនុវត្តតាមសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីសនៅកំរិតវិស័យ" (២០០៨) ឯកសារស្តីពីលទ្ធផលនៃកិច្ចប្រជុំតុមូលទី៨ នៅវេទិកាកំពូលស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ នាទីក្រុងអាក្រា ។

ក- អាណត្តិរបស់ទីស្នាក់ការកណ្តាល និងការទទួលស្គាល់តួនាទីនៅតាមវិស័យ
ខ- បង្កើតជំនាញនៅតាមវិស័យ និងប្តេជ្ញាថែរក្សាកម្រិតបច្ចេកទេសដែលមាន
គ- ការសន្យាផ្តល់ហិរញ្ញប្បទានតាមវិស័យ និងភាពទស្សន៍ទាយទុកជាមុន
ឃ- ការធ្វើសង្គតិភាព និងការបំពេញបន្ថែមនៃកម្មវិធីប្រទេស
ង- បង្ហាញទំនុកចិត្ត និងទំនាក់ទំនងការងារជាមួយសមភាគីរបស់រាជរដ្ឋាភិបាល
ច- ប្តេជ្ញាចិត្តអនុវត្តគោលការណ៍ណែនាំស្តីពីតួនាទីរបស់ក្រុមការងារបច្ចេកទេស និងកិច្ចប្រតិបត្តិស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ
ឆ- សមត្ថភាពសម្រាប់ដឹកនាំ ឬតួនាទីសម្របសម្រួលដែលមានផលប្រយោជន៍សម្រាប់ទាំងអស់គ្នា
ជ- ស្ថានភាពតាមវិស័យ (ការផ្តល់ហិរញ្ញប្បទាន ចំនួនដៃគូ និងទំរង់ការផ្តល់ហិរញ្ញប្បទាន)

៥- តួនាទីរបស់ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ អង្គការសហប្រជាជាតិ និងមូលនិធិឯកទេសត្រូវប្រើប្រាស់គោលការណ៍នៃ «ការបែងចែកពលកម្ម» នៅតាមវិស័យដែលស្ថាប័នទាំងនោះមានសកម្មភាព (ដូចជាការប្រើប្រាស់ប្រតិភូកម្មកិច្ចសហប្រតិបត្តិការ)។

ស្របតាមគោលការណ៍ណែនាំស្តីពីតួនាទីក្រុមការងារបច្ចេកទេសចម្រុះ អ្នកសម្របសម្រួលរបស់ដៃគូអភិវឌ្ឍន៍តាមក្រុមការងារទាំងអស់ គឺជាមន្ត្រីជាន់ខ្ពស់ មានសមត្ថភាពជំនាញ និងសកម្មក្នុងការចែករំលែកព័ត៌មាន ព្រមទាំងមានលទ្ធភាពពង្រឹងក្រុមការងារបច្ចេកទេស និងលេខាធិការដ្ឋានរបស់ក្រុមការងារ ។ លើសពីនេះ រាជរដ្ឋាភិបាលមានសំណូមពរបន្ថែមមួយទៀតសម្រាប់អ្នកសម្របសម្រួលរបស់ដៃគូអភិវឌ្ឍន៍ ។ ការស្នើសុំឱ្យអ្នកសម្របសម្រួលតាមក្រុមការងារបច្ចេកទេសមានអាណត្តិការងារយ៉ាងតិច២ឆ្នាំ ក៏មានការលំបាកខ្លះដែរ ដោយសារអាណត្តិការងារខ្លីរបស់មន្ត្រីជាន់ខ្ពស់ខ្លះរបស់ដៃគូអភិវឌ្ឍន៍ ។ នៅពេលដែលគោលការណ៍នេះអាចផ្តល់នូវចំណុចចាប់ផ្តើម យើងក៏ត្រូវយល់អំពីភាពស្មុគស្មាញក្នុងកម្មវិធីនីយកម្មធនធានអភិវឌ្ឍន៍ ពិសេសការលំបាកក្នុងការកំណត់កិច្ចប្រតិបត្តិការរបស់ខ្លួននៅតាមវិស័យជាក់លាក់ ។ នេះមានន័យថា អភិក្រមនេះគ្រាន់តែជាចំណុចចាប់ផ្តើមប៉ុណ្ណោះ ហើយយើងត្រូវធ្វើពិចារណកម្ម ហើយត្រូវមានភាពទន់ភ្លន់ក្នុងពេលអនុវត្ត ។

សុខដុមនីយកម្មគឺជាដំណាក់កាល ដែលភាពហត់នឿយនៃប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការបានកើតឡើងយ៉ាងស្រួចស្រាវ ដោយសារដៃគូអភិវឌ្ឍន៍ត្រូវចំណាយពេលវេលាប្រជុំជាច្រើន សម្រាប់កំណត់អភិក្រមឯកភាព ។ គួរកត់សម្គាល់ផងដែរថា ការស្ទង់វាយតម្លៃរបស់ដៃគូអភិវឌ្ឍន៍ភាគច្រើនបានលើកឡើងអំពីកង្វះខាតចំណេះដឹងផ្ទៃក្នុង និងការលើកទឹកចិត្តសម្រាប់ពង្រឹងកិច្ចសហការរបស់ពួកគេបន្ថែមទៀត ។ ដៃគូអភិវឌ្ឍន៍ខ្លះទៀតបានយល់ថា តម្រូវការនៃការបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការពុំមែនជាអាទិភាពរបស់ខ្លួនឡើយ ។ ប៉ុន្តែ ចំពោះរាជរដ្ឋាភិបាល ទោះបីសមត្ថភាពនៅមានកម្រិតក៏ដោយ ក៏នេះគឺជាអាទិភាពពិតប្រាកដរបស់ខ្លួន ។ នៅពេលដែលសកម្មភាពទាំងនេះបានផ្តល់សារៈប្រយោជន៍ និងត្រូវបន្តអនុវត្តភាគីពាក់ព័ន្ធខ្លះទៀតយល់ថា «ប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ» គឺជាការងារឯកទេសមួយ ដែលគោលការណ៍របស់វាត្រូវអនុវត្តឱ្យកាន់តែជាក់ស្តែងឡើងៗ ពិសេសត្រូវអនុវត្តផ្ទាល់នៅកម្រិតវិស័យ ។ លើសពីនេះ

ក៏ត្រូវរកបញ្ហារាំងស្ទះ និងកំណត់សកម្មភាពរួមសម្រាប់ដោះស្រាយបញ្ហាទាំងនេះ ។ បញ្ហាប្រឈមគឺត្រូវយកកិច្ចការទាំងនេះទៅដោះស្រាយនៅកម្រិតវិស័យ ហើយត្រូវរិះរកដំណោះស្រាយស្របតាមវិស័យនោះ ។

ការគ្រប់គ្រងដោយផ្តោតលើលទ្ធផល

> *«ជីវភាពរស់នៅរបស់ប្រជាជនក្រីក្រគឺជាមូលដ្ឋានសម្រាប់វិនិច្ឆ័យលទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងរួមរបស់យើង»*
>
> *ផែនការសកម្មភាពអាក្រា ឆ្នាំ២០០៨*

លទ្ធភាពក្នុងការតាមដាន និងវាយតម្លៃគឺជាកត្តាសំខាន់សម្រាប់ការធ្វើសេចក្តីសម្រេចនានា ។ ការទទួលបានព័ត៌មានច្បាស់លាស់និងទាន់ពេលវេលាត្រូវបានចាត់ទុកជាផ្នែកមួយដ៏សំខាន់នៃដំណើរការធ្វើសេចក្តីសម្រេចកម្រិតគោលនយោបាយ និងការតាមដានការអនុវត្តន៍ ។ របាយការណ៍នេះគឺជាឧទាហរណ៍ជាក់ស្តែង សម្រាប់បង្ហាញអំពីការប្រមូលសក្ខីភាពជាក់ស្តែងនិងប្រើប្រាស់សក្ខីភាពទាំងនេះ ដើម្បីរៀបចំគោលនយោបាយ និងអនុវត្តសកម្មភាពអភិវឌ្ឍន៍ ។ ប៉ុន្តែ កិច្ចការដែលសំខាន់ជាងនេះ ហើយដែលបានអនុវត្តកន្លងមក គឺការត្រួតពិនិត្យពាក់កណ្តាលអាណត្តិនៃការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដែលបានស្នើឱ្យមានវឌ្ឍនភាពបន្ថែមទៀតនៅក្នុងវិស័យមួយចំនួន ដូចជាការលើកកំពស់វិស័យសុខាភិបាល និងកំណើនផលិតភាពក្នុងវិស័យកសិកម្ម ក៏ដូចជាវិស័យដទៃទៀតដែលភាគីពាក់ព័ន្ធបានពិភាក្សា ហើយស្នើឱ្យពង្រឹងសមិទ្ធផលបន្ថែមទៀត ។ ក្នុងន័យនេះដែរ ការត្រួតពិនិត្យឯករាជ្យ បានគូសបញ្ជាក់អំពីសារៈសំខាន់នៃការពង្រឹងក្របខ័ណ្ឌតាមដានភាពក្រីក្រនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ព្រមទាំងផ្សារភ្ជាប់នឹងប្រព័ន្ធគ្រប់គ្រងថ្នាក់ក្រោមជាតិ ។ នេះគឺជាបញ្ហាប្រឈមដ៏ស្រួចស្រាវបំផុតមួយសម្រាប់ការគ្រប់គ្រងការអភិវឌ្ឍន៍ដោយផ្អែកលើសក្ខីភាពជាក់ស្តែងនៅកម្ពុជា ។

លើសពីនេះ របាយការណ៍ស្វ័យវាយតម្លៃរបស់ក្រុមការងារបច្ចេកទេស ដែលជាផ្នែកមួយនៃការវាយតម្លៃប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ បានបង្ហាញថាប្រព័ន្ធតាមដាននៅកម្រិតវិស័យបានកែលំអឱ្យប្រសើរជាច្រើន បើទោះការកែលំអនេះមានភាពយឺតយ៉ាវជាងការរំពឹងទុកក៏ដោយ ។ ក្រុមការងារបច្ចេកទេសជាច្រើនបានរាយការណ៍អំពីបញ្ហាប្រឈមចម្បងថា លទ្ធផលដែលបានស្តែងចេញមិនប្រាកដជាមានទំនាក់ទំនងជាមួយនឹងធាតុចូលដែលក្រុមការងារបានទទួលឡើយ ។ បញ្ហានេះកើតមានឡើងជាញឹកញាប់ ដោយសារមិនមានភាពច្បាស់លាស់ក្នុងទំនាក់ទំនងរវាងផែនការ ថវិកា ការអនុវត្តន៍ និងការធ្វើរបាយការណ៍ ។ នេះបញ្ជាក់អំពីភាពចាំបាច់នៃការប្រើប្រាស់អភិក្រមគ្រប់ជ្រុងជ្រោយសម្រាប់ការតាមដាន និងការគ្រប់គ្រងដោយផ្តោតលើលទ្ធផល ព្រោះថាប្រសិនបើបុរេល័ក្ខខ័ណ្ឌស្តីពីទំនាក់ទំនងនេះពុំទាន់ត្រូវបានកំណត់ច្បាស់លាស់ទេ នោះការតាមដានមិនអាចអនុវត្តដោយសុក្រឹតបានឡើយ ។ ក្នុងន័យនេះ យើងមានវឌ្ឍនភាពគួរលើកទឹកចិត្ត ដែលវិស័យមួយចំនួនបានផ្តួចផ្តើមគំនិតបង្កើតឱ្យមានយន្តការសម្រាប់តាមដានគ្រប់ជ្រុងជ្រោយមួយ សម្រាប់ជាការឆ្លើយតបទៅនឹងការកត់សំគាល់របស់ការត្រួតពិនិត្យឯករាជ្យ ដែលបានលើកឡើងថា ការគាំទ្រដោយគ្មានការសម្របសម្រួលសម្រាប់ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ គឺជាប្រព័ន្ធចែកចាយព័ត៌មានដោយដុំៗ ។ កំណែទម្រង់ច្បាប់និងតុលាការគឺជាឧទាហរណ៍មួយ ដែលក្នុងដំណាក់កាលនីមួយៗនៃការគ្រប់គ្រង តែងតែគិតគូរដល់ការគ្រប់គ្រងដោយផ្តោតលើលទ្ធផល និងគោលការណ៍ដទៃទៀតនៃប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ ដើម្បីសម្រេចលទ្ធផលប្រកបដោយជោគជ័យ ។

នៅតាមវិស័យដទៃទៀត និងក្រុមការងារបច្ចេកទេសពាក់ព័ន្ធ ដូចជាការបោសសំអាតមីន និងវិស័យកសិកម្មនិងទឹក បានរាយការណ៍ពីវឌ្ឍនភាពក្នុងការបង្កើតអភិក្រមតាមវិស័យ ដែលបានបញ្ចូលផែនការតាមដានផងដែរ ។ លើសពីនេះ អភិក្រមគ្រប់គ្រងតាមវិស័យកំពុងដំណើរការល្អនៅក្នុងវិស័យសុខាភិបាល និងអប់រំ ។ ចំពោះវិស័យផ្សេងទៀតដែលទើបគិតគូរអភិក្រមនេះ ការសង្កេតជាសកលដែលថា «ការរង់ចាំឱ្យមានផែនការល្អឥតខ្ចោះគឺជាការស្រមើស្រមៃ និងធ្វើឱ្យមានភាពយឺតយ៉ាវដល់ការអនុវត្តន៍សកម្មភាព ។ ការផ្តោតទៅលើលទ្ធផលដែលត្រូវអនុវត្តឱ្យសម្រេច ការពិនិត្យហានិភ័យឱ្យបានហ្មត់ចត់ និងការតាមដានលទ្ធផលជាប្រចាំ» គឺជាកម្លាំងចលករសម្រាប់ជម្រុញវិស័យទាំងនេះ ។

គណនេយ្យភាពទ្វេទិស

> *«យើងទទួលខុសត្រូវចំពោះលទ្ធផលដែលបានឯកភាព ក្នុងក្របខ័ណ្ឌនៃគោលនយោបាយអភិវឌ្ឍន៍ និងគោលនយោបាយនៃហិរញ្ញប្បទានសហប្រតិបត្តិការ»*
>
> *ផែនការសកម្មភាពទីក្រុងអាក្រាឆ្នាំ២០០៨*

ការគ្រប់គ្រងដោយផ្តោតលើលទ្ធផលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយគណនេយ្យភាពទ្វេទិស ព្រោះរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ត្រូវទទួលខុសត្រូវចំពោះលទ្ធផលដែលសម្រេចបាន ។ បទពិសោធន៍រួមគ្នាបានបង្ហាញអំពីភាពចាំបាច់ក្នុងការកំណត់ភារកិច្ចទទួលខុសត្រូវ និងសកម្មភាពដែលត្រូវអនុវត្តរួមគ្នា ដូចក្នុងករណីនៃការអនុវត្តន៍សូចនាករតាមដានរួមគ្នា ដែលនឹងរៀបរាប់ក្នុងជំពូកទី ៤ ។ ជាទូទៅ ការចែករំលែកព័ត៌មានស្តីពីធនធានគឺជាការងារសំខាន់ ពីព្រោះនេះជាមូលដ្ឋានសម្រាប់ការធ្វើវិភាជន៍ និងគ្រប់គ្រងធនធានដែលមាន ព្រមទាំងសម្រាប់វាស់ស្ទង់លទ្ធផលផងដែរ ។ ទន្ទឹមនេះ ក៏ត្រូវបែងចែកឱ្យដាច់ស្រឡះរវាងការសន្យាផ្តល់ហិរញ្ញប្បទាននៅកម្រិតគោលនយោបាយ (សកម្មភាពដែលបានគ្រោង) និងលទ្ធផលជាក់ស្តែង (ការអនុវត្តន៍) ។ ទោះជាការចែករំលែកព័ត៌មាននៅតែជាបញ្ហាប្រឈមក្នុងកម្រិតសកលក៏ដោយ ក៏កម្ពុជាមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ដោយសារដៃគូអភិវឌ្ឍន៍បានប្រឹងប្រែងចែករំលែកព័ត៌មាន តាមរយៈការប្រើប្រាស់ប្រព័ន្ធទិន្នន័យព័ត៌មានរបស់រាជរដ្ឋាភិបាល ។ កិច្ចប្រឹងប្រែងទាំងនេះមិនត្រឹមតែជួយការគាំទ្រដល់ការរៀបចំផែនការនីយកម្ម និងការតាមដានហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលប៉ុណ្ណោះទេ ប៉ុន្តែ ការប្រឹងប្រែងនេះបានពង្រឹងតម្លាភាពតាមរយៈការផ្សព្វផ្សាយព័ត៌មានជាសាធារណៈ ។

ការប្រតិបត្តិល្អៗដទៃទៀតសម្រាប់ជម្រុញគណនេយ្យភាពទ្វេទិសរួមមាន ការវាយតម្លៃរួមគ្នា ឬការវាយតម្លៃឯករាជ្យលើភាពជាដៃគូសម្រាប់កិច្ចអភិវឌ្ឍន៍ ។ កម្ពុជាបានធ្វើការវាយតម្លៃឯករាជ្យ ដោយប្រើប្រាស់ល័ក្ខខ័ណ្ឌវិនិច្ឆ័យសកល ហើយបានប្រើប្រាស់របកគំហើញរបស់ការវាយតម្លៃឯករាជ្យ សម្រាប់ជាមូលដ្ឋានក្នុងការរៀបចំអនុសាសន៍កម្រិតគោលនយោបាយនៅក្នុងរបាយការណ៍នេះ ។ លើសពីនេះ របកគំហើញទាំងនេះនឹងក្លាយជាមូលដ្ឋាន សម្រាប់ពិភាក្សានៅក្នុងវេទិកាសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា ដែលនឹងរៀបចំនាពេលខាងមុខ និងសម្រាប់ក្រុមការងារបច្ចេកទេសផងដែរ ព្រោះគណនេយ្យភាពទ្វេទិសត្រូវអនុវត្តជាក់ស្តែងនៅកម្រិតក្រុមការងារបច្ចេកទេស ។ ការត្រួតពិនិត្យឯករាជ្យក៏បានគូសបញ្ជាក់អំពីភាពល្អប្រសើរជាងមុន ក្នុងការចែករំលែកព័ត៌មានស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការ ។ ទន្ទឹមនេះ ការត្រួតពិនិត្យឯករាជ្យក៏បានលើកបញ្ហាដែលត្រូវយក

ចិត្តទុកដាក់បន្ថែមទៀត ។ បញ្ហាស្ដីពីប្រព័ន្ធលើកទឹកចិត្តសម្រាប់ដៃគូអភិវឌ្ឍន៍ និងទស្សនៈដែលយល់ថា របៀបវារៈស្ដីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ មិនអាចអនុវត្តប្រកបដោយជោគជ័យ នៅតាមបណ្ដាប្រទេសជាដៃគូបានទេ ប្រសិនបើគ្មានការផ្លាស់ប្ដូរជាដុំកំភួន និងជាប្រព័ន្ធទៅលើរចនាសម្ព័ន្ធលើកទឹកចិត្ត ដើម្បីជម្រុញឱ្យមានឥរិយាបថត្រឹមត្រូវ ស្របតាមគោលការណ៍ស្ដីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ ។

និយមន័យនៃគណនេយ្យភាពទ្វេទិសក្នុងបរិបទសកលមានការវិវត្តន៍ ហើយផែនការសកម្មភាពទីក្រុងអាក្រាក៏បានបញ្ជាក់បន្ថែមអំពីការប្ដេជ្ញារបស់ប្រទេសដៃគូ ក្នុងការទទួលយកតួនាទីរបស់ស្ថាប័ននីតិប្បញ្ញត្តិដែលប្រសូត្រចេញពីការបោះឆ្នោត និងសង្គមស៊ីវិល ។ នេះគឺជាការពង្រីកការប្ដេជ្ញាចិត្តនៃសេចក្ដីថ្លែងការណ៍ទីក្រុងប៉ារីស បន្ថែមពីលើតួនាទីក្នុងការចែករំលែកព័ត៌មាន ។ ក្នុងបរិបទកម្ពុជា ក្រុមការងារបច្ចេកទេសបានបំពេញតួនាទីនេះបានយ៉ាងល្អប្រសើរ ដោយក្រុមការងារបច្ចេកទេសមួយចំនួនបានទទួលស្គាល់តួនាទីវិជ្ជមានរបស់សង្គមស៊ីវិល ក្នុងការងារដែលទាក់ទងនឹងបញ្ហាសេដ្ឋកិច្ច និងសង្គមកិច្ច (ទឹកស្អាតជនបទ ហ៊ីវ/អេដស៍) ។ ក្រុមការងារបច្ចេកទេសដទៃទៀត និងដៃគូអភិវឌ្ឍន៍ជាច្រើនបានមើលឃើញពីតួនាទីដោយឡែករបស់សង្គមស៊ីវិល ពិសេសសមត្ថភាពជំនាញតាមវិស័យ និងជាតំណាងឱ្យផលប្រយោជន៍ទូទៅ ។ ការត្រួតពិនិត្យឯករាជ្យក៏បានស្នើឱ្យពង្រីកតួនាទីរបស់រដ្ឋសភា ហើយក៏បានសង្កេតឃើញអំពីភាពចាស់ទុំច្រើនជាងមុនរបស់សង្គមស៊ីវិល ដោយសារពួកគេបានចូលរួមអនុវត្ត និងពង្រឹងគណនេយ្យភាពទ្វេទិស តាមរយៈការចែករំលែកព័ត៌មានស្ដីពីសកម្មភាពរបស់ពួកគេ ក៏ដូចជាការពង្រឹងតួនាទីរបស់ខ្លួនក្នុងយន្តការភាពជាដៃគូសម្រាប់កិច្ចអភិវឌ្ឍន៍ ។

ផែនការសកម្មភាពស្ដីពីសុខដុមនីយកម្ម ការតម្រឹម និងលទ្ធផល- ក្របខ័ណ្ឌការងារសម្រាប់ប្រសិទ្ធភាពនៃ ហិរញ្ញប្បទានសហប្រតិបត្តិការ

> *«កិច្ចប្រឹងប្រែងជាច្រើនបានផ្ដោតទៅលើការបង្កើតក្របខ័ណ្ឌ និងនីតិវិធី ដើម្បីបង្កើនប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ ប៉ុន្តែសកម្មភាពទាំងនេះពុំទាន់បានគ្រប់គ្រាន់នៅឡើយ ហើយនេះគឺជាការគ្រោះថ្នាក់មួយ ប្រសិនបើការត្រៀមរៀបចំអនុវត្តទាំងឡាយនេះត្រូវបានចាត់ទុកថាជាការអធ្យាស្រ័យសម្រាប់បកស្រាយមូលហេតុនៃសកម្មភាពតិចតួចដែលបានអនុវត្តកន្លងមក »។*
>
> *ការត្រួតពិនិត្យឯករាជ្យស្ដីពីហិរញ្ញប្បទានសហប្រតិបត្តិការនៅកម្ពុជា ឆ្នាំ២០០៨*

ផ្អែកតាមការវិភាគក្នុងរបាយការណ៍ពាក់កណ្ដាលអាណត្តិស្ដីពីការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ របាយការណ៍វាយតម្លៃប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ គួបផ្សំនឹងរបាយការណ៍ត្រួតពិនិត្យឯករាជ្យ និងរបាយការណ៍នៃការសិក្សាស្ដីពីកិច្ចសហប្រតិបត្តិការបច្ចេកទេស ព្រមទាំងទិន្នន័យជាក់ស្ដែងដែលបានរៀបចំសម្រាប់ការធ្វើអង្កេតការតាមដានការអនុវត្តន៍សេចក្ដីថ្លែងការណ៍ទីក្រុងប៉ារីស និងការរៀបចំរបាយការណ៍ស្ដីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការនេះ បានផ្ដល់សក្ខីភាពជាក់ស្ដែងសំខាន់ៗជាច្រើន ។ ទោះបីទិដ្ឋភាពរួមមានលក្ខណៈស្មុគស្មាញក៏ដោយ ក៏យើងអាចសន្និដ្ឋានអំពីវឌ្ឍនភាពក្នុងភាពជាដៃគូសម្រាប់កិច្ចអភិវឌ្ឍន៍ផងដែរ ។ ការគាំទ្រកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍បានកើនឡើង ហើយមានសង្គតិភាពជាមួយនឹងអាទិភាពនៃកិច្ច

អភិវឌ្ឍន៍កម្ពុជា ។ ទោះជាយ៉ាងនេះក្តី ក៏នៅមានបញ្ហាប្រឈមក្នុងការបង្កើនអត្ថប្រយោជន៍ឱ្យបានជាអតិបរមានូវធនធានទាំងអស់នេះ ។

១- ដូចរបាយការណ៍ត្រួតពិនិត្យឯករាជ្យបានបញ្ជាក់ យើងមានវឌ្ឍនភាពគួរឱ្យកត់សំគាល់ក្នុងការរៀបចំគោលនយោបាយ និងក្របខ័ណ្ឌការងារស្ថាប័ន ។ ប៉ុន្តែ ទិដ្ឋភាពទូទៅក្នុងការអនុវត្តន៍មានលក្ខណៈចម្រុះ ហើយកម្ពុជាមានស្ថានភាពប្រហាក់ប្រហែលនឹងបណ្តាប្រទេសដៃគូដទៃទៀតដែរ ។ លើសពីនេះ ប្រការដែលគួរឱ្យសោកស្តាយគឺ «ភាពនឿយណាយក្នុងកិច្ចប្រឹងប្រែងសម្រាប់បង្កើនប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ» ។ បញ្ហានេះតម្រូវឱ្យមានអន្តរាគមន៍ពីថ្នាក់ដឹកនាំជាន់ខ្ពស់ ដើម្បីជួយពង្រឹងកិច្ចដំណើរការឡើងវិញ ។ ទន្ទឹមនេះក៏ត្រូវពង្រឹងកិច្ចសម្របសម្រួលរវាងស្ថាប័នថ្នាក់កណ្តាល (ដូចរបាយការណ៍ត្រួតពិនិត្យពាក់កណ្តាលអាណត្តិស្តីពីការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិដែលរៀបចំដោយក្រសួងផែនការ) នឹងផ្តល់នូវចលនការសម្រាប់ជួយពង្រឹងកិច្ចការនៅកម្រិតវិស័យ។

២- ការងារពាក់ព័ន្ធនឹងប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ អាចក្លាយទៅជាកិច្ចដំណើរការដែលកិច្ចប្រតិបត្តិមានភាពស្មុគស្មាញ ហើយខុសប្លែកពីការងារដទៃទៀត ព្រមទាំងពិបាកឱ្យប្រតិបត្តិករគ្មានជំនាញយល់ដឹងអំពីគោលការណ៍ទាំងនេះ ។ ដូចនេះ ជំហានបន្ទាប់គឺការធ្វើឱ្យសាមញ្ញឡើងនូវកិច្ចដំណើរការ ការធ្វើអាទិភាវូបនីយកម្ម និងការកាត់បន្ថយការងារបច្ចេកទេសឱ្យបានតិចបំផុត ។

៣- ចីរភាពក្នុងការបង្កើតក្របខ័ណ្ឌគោលនយោបាយ និងការកសាងស្ថាបត្យកម្មនៃហិរញ្ញប្បទានសហប្រតិបត្តិការ ដែលរួមមាន ក្រុមការងារបច្ចេកទេសចម្រុះ គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ និងវេទិកាសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា មិនទាន់សម្រេចបាននូវលទ្ធផលតាមការរំពឹងទុក ស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ និងអត្ថប្រយោជន៍នៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍នៅឡើយ ។ ប្រសិនបើ «ផ្នែករឹង» ដំណើរការមិនល្អ នោះចាំបាច់ត្រូវពិចារណាលើ «ផ្នែកទន់» ហើយត្រូវចំណាយពេលវេលា និងកិច្ចខិតខំប្រឹងប្រែងជាច្រើនបន្ថែមទៀត ដើម្បីកសាងទំនាក់ទំនង ទំនុកចិត្ត និងសមត្ថកិច្ចចាំបាច់នានា ដើម្បីបំពេញការងារប្រកបដោយប្រសិទ្ធភាព ក្នុងបរិបទនៃភាពជាដៃគូ ។

៤- របាយការណ៍ត្រួតពិនិត្យពាក់កណ្តាលអាណត្តិស្តីពីការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បានថែងថា ការអភិវឌ្ឍន៍សមត្ថភាពគឺជាការងារសំខាន់ក្នុងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ។ ទស្សនៈនេះត្រូវបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងរបាយការណ៍នៃការសិក្សាស្តីពីកិច្ចសហប្រតិបត្តិការបច្ចេកទេស និងការត្រួតពិនិត្យឯករាជ្យ ដែលបានលើកឡើងថា «ការយល់ដឹងនិងការគោរពភាពជាម្ចាស់របស់រាជរដ្ឋាភិបាល មានសារៈសំខាន់បំផុត ដើម្បីអនុវត្តអភិក្រមនៃភាពជាដៃគូសម្រាប់ពង្រឹងសមត្ថភាព ពង្រឹងប្រព័ន្ធរបស់រាជរដ្ឋាភិបាល និងរៀបចំជាយថាហេតុនូវយុទ្ធសាស្ត្រចាកចេញសម្រាប់ហិរញ្ញប្បទានសហប្រតិបត្តិការ» ។ ទោះជាយ៉ាងនេះក្តី ក៏រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ នៅត្រូវការអភិក្រមថ្មីៗ និងសមត្ថកិច្ចសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍នេះដែរ ។

ជាទីបញ្ចប់ បញ្ហាប្រឈមសម្រាប់បង្កើនគណនេយ្យភាពទ្វេទិស គឺការជម្រុញឱ្យមានការចូលរួមយ៉ាងទូលំទូលាយពីភាគីពាក់ព័ន្ធទាំងឡាយក្នុងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ។ សេចក្តីផ្តើមនៃរបាយការណ៍នេះបានកត់សំគាល់ថា ទំនាក់ទំនងរវាងហិរញ្ញប្បទានសហប្រតិបត្តិការ និងលទ្ធផលត្រូវស្តែងចេញតាមរយៈគណនេយ្យភាព ទ្វេទិស ។

ប្រសិនបើសេចក្តីសន្និដ្ឋានសង្ខេបនេះបានរៀបរាប់ដោយសុក្រិតអំពីស្ថានភាពបច្ចុប្បន្ននៅកម្ពុជា នោះ យើងត្រូវប្រើប្រាស់សក្ខីភាពជាក់ស្តែងទាំងនេះ សម្រាប់ធ្វើជាមូលដ្ឋានក្នុងការស្នើអនុសាសន៍កម្រិតគោលនយោបាយ ។ អនុសាសន៍កម្រិតគោលនយោបាយនេះ គឺជាមូលដ្ឋានគ្រឹះសម្រាប់ពិភាក្សានិងឯកភាព ដើម្បីឈានទៅរៀបចំសូចនាករតាមដានរួមគ្នា ។

ឧបសម្ព័ន្ធ ៤

ការអនុវត្តន៍សូចនាករតាមដានរួមគ្នា

សូចនាករតាមដានរួមគ្នា មានគោលដៅផ្សារភ្ជាប់ការតាមដានការអនុវត្តន៍សកម្មភាពរបស់ស្ថាប័ននានានៃរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងក្រុមការងារបច្ចេកទេសចម្រុះ ទៅនឹងគោលដៅអាទិភាពមួយចំនួន ដែលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ ដោយសង្កត់ធ្ងន់លើចរិកលក្ខណៈនៃ «គណនេយ្យភាពទ្វេទិស» សូចនាករតាមដានរួមគ្នាគឺជាឧបករណ៍ដ៏សំខាន់បំផុត ក្នុងការបញ្ចូលគោលការណ៍នៃ «ការត្រួតពិនិត្យដោយផ្តោតលើលទ្ធផល និងគណនេយ្យភាពទ្វេទិស» ទៅក្នុងភាពជាដៃគូសម្រាប់កិច្ចអភិវឌ្ឍន៍ ។ លើសពីនេះ សូចនាករតាមដានរួមគ្នាទាំងនេះបានឆ្លុះបញ្ចាំងសកម្មភាពរួមគ្នា ដែលរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ត្រូវអនុវត្តរួមគ្នា ដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍ ។ សូចនាករតាមដានរួមគ្នាចំនួន២០ ដែលបានរៀបចំសម្រាប់គាំទ្រវិស័យអាទិភាពទាំងបួននៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិត្រូវបានអនុមតិក្នុងវេទិកាសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី១ នាខែមិថុនាកន្លងមក ។

គោលការណ៍នៃសូចនាករតាមដានរួមគ្នា

នៅក្នុងវេទិកាសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍លើកទី១នាឆ្នាំ២០០៧កន្លងមក យើងសង្កេតឃើញអំពីនិន្នាការក្នុងការប្រើប្រាស់សូចនាករតាមដានរួមគ្នា សម្រាប់ជាលក្ខខ័ណ្ឌ ឬក្របខ័ណ្ឌក្នុងការវាយតម្លៃវឌ្ឍនភាពរបស់រាជរដ្ឋាភិបាល ។ ទោះបីជានិន្នាការបែបនេះអាចមានលក្ខណៈសមស្របនិងចាំបាច់ ដើម្បីត្រួតពិនិត្យលទ្ធផលនៃការអនុវត្តន៍ការប្តេជ្ញារបស់រាជរដ្ឋាភិបាលក៏ដោយ ក៏យើងអាចពិនិត្យឃើញអំពីភាពទន់ខ្សោយនៃ «ចរិកទ្វេទិស» នៃសូចនាករតាមដានរួមគ្នា ដែលអាចធ្វើឱ្យមានអតុល្យភាពនៃទំនាក់ទំនងក្នុងការផ្តល់ហិរញ្ញប្បទាន ។ ដូចនេះគោលការណ៍សម្រាប់រក្សាឱ្យបាននូវ «ចរិតទ្វេទិស» នៃសូចនាករតាមដានរួមគ្នា ត្រូវបានគូសបញ្ជាក់ឡើងវិញ និងអាចសង្ខេបដូចខាងក្រោម ÷

១- សូចនាករតាមដានរួមគ្នាជាការព្រមព្រៀងរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ដែលផ្អែកលើគោលការណ៍នៃ «គណនេយ្យភាពទ្វេទិស» និងសកម្មភាពដែលត្រូវអនុវត្តរួមគ្នា ដើម្បីឈានទៅសម្រេចគោលដៅរបស់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។

២- សូចនាករតាមដានរួមគ្នាត្រូវផ្សារភ្ជាប់ទៅនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងកម្មវិធីកំណែទម្រង់របស់រាជរដ្ឋាភិបាល ដោយត្រូវកំណត់អំពីគោលដៅច្បាស់លាស់ ស្ថាប័នទទួលខុសត្រូវអនុវត្ត កាលបរិច្ឆេទ និងធនធានសម្រាប់អនុវត្ត ។

វឌ្ឍនភាពក្នុងការអនុវត្តន៍

ជារួម ការអនុវត្តន៍សូចនាករតាមដានរួមគ្នាទទួលបានលទ្ធផលគួរឱ្យកត់សំគាល់ បើទោះបីជាវឌ្ឍនភាពដែលសម្រេចបាន មានសន្ទុះនិងទំហំមិនដូចគ្នានៅតាមការដ្ឋានកំណែទម្រង់ និងតាមវិស័យនានាក៏ដោយ (សូម

មើលស្ថានភាពលំអិតក្នុងឧបសម្ព័ន្ធ) ។ ក្នុងពេលដែលផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបានប្រមូលផ្តុំអាទិភាពអភិវឌ្ឍន៍នៅកម្រិតថ្នាក់ជាតិ ជោគជ័យនៃការសម្រេចអាទិភាពទាំងនេះត្រូវពឹងផ្អែកលើការពង្រឹងភាពដឹកនាំរបស់បណ្តាស្ថាប័ននៃរាជរដ្ឋាភិបាលដែលទទួលបន្ទុកអនុវត្ត និងការគាំទ្រជាយុទ្ធសាស្ត្រ សម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិក្នុងក្របខ័ណ្ឌជវភាពនៃភាពជាដៃគូ ដែលជម្រុញឱ្យរាជរដ្ឋាភិបាលអនុវត្តភាពជាម្ចាស់លើកម្មវិធីនិងកិច្ចការអភិវឌ្ឍន៍ ។ ក្រុមការងារបច្ចេកទេសចម្រុះស្តីពីផែនការនិងការកាត់បន្ថយភាពក្រីក្រនឹងដើរតួនាទីដ៏សំខាន់សម្រាប់ពិភាក្សា និងឯកភាពលើជំហានការងារដែលពាក់ព័ន្ធនឹងការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិនេះ ។ ប៉ុន្តែ កន្លងមក ក្រុមការងារនេះបានរាយការណ៍អំពីវឌ្ឍនភាពជាច្រើន ដូចជាការរៀបចំបញ្ចប់នូវឯកសារផែនការយុទ្ធសាស្ត្រក្រសួងផែនការ (សូចនាករទី១) ដែលមានគោលដៅសម្រាប់ពង្រឹងសមត្ថភាពការងារផែនការនីយកម្ម និងតាមដាន និងសម្របសម្រួលការគាំទ្ររបស់ដៃគូអភិវឌ្ឍន៍ ។ អាទិភាពរបស់រាជរដ្ឋាភិបាលស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ គឺជាចំណុចគន្លឹះមួយសម្រាប់គ្រប់គ្រងការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (សូចនាករទី២) ។ ក្រុមការងារបច្ចេកទេសចម្រុះភាពជាដៃគូនិងសុខដុមនីយកម្មបានរាយការណ៍ថា ខ្លួនបានសម្រេចគោលដៅដែលស្ថិតក្រោមការទទួលខុសត្រូវ រួមមាន ÷ ការគ្រប់គ្រងព័ត៌មាន ការរៀបចំរបាយការណ៍ជាប្រចាំសម្រាប់កិច្ចប្រជុំរបស់គណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ និងការបញ្ចូលសូចនាករទៅក្នុងផែនការសកម្មភាពស្តីពីសុខដុមនីយកម្ម ការតម្រឹម និងលទ្ធផលជាដើម ។

អាទិភាពវិស័យសង្គមកិច្ច

ក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំ (សូចនាករទី៣) បានរាយការណ៍ពីកំណើនអត្រាចុះឈ្មោះចូលរៀនរបស់សិស្ស ដែលបានកើនឡើងពី៩២,៧% ក្នុងឆ្នាំសិក្សា២០០៦-២០០៧ ដល់៩៣,៣% ក្នុងឆ្នាំសិក្សា២០០៧-២០០៨ ។ ទន្ទឹមនឹងនេះ អត្រាចុះឈ្មោះរបស់សិស្សស្រីបានកើនឡើងពី៩១% ដល់ ៩៣,៣% ក្នុងឆ្នាំសិក្សា២០០៧-២០០៨ ។ អត្រាគង់វង្សរបស់សិស្សនៅកម្រិតបឋមសិក្សាបានកើនឡើងពីបណ្តាឆ្នាំមុន គឺពី ៤៩,៣% ដល់៥២,៥% ក្នុងឆ្នាំសិក្សា២០០៦-២០០៧ (សម្រាប់សិស្សស្រីកើនឡើងពី ៤៨,៩% ដល់ ៥៥,៤%) ។ ចំណែកឯវិស័យសុខាភិបាល (សូចនាករទី៤) ក៏សម្រេចបានជោគជ័យគួរឱ្យកត់សំគាល់ផងដែរ ។ ឆ្មបកម្រិតឧត្តមចំនួន១៨៨រូប និងកម្រិតមធ្យម៤០រូប ត្រូវបានជ្រើសរើសនិងដាក់ពង្រាយនៅតាមបណ្តាមណ្ឌលសុខភាព១៦៦ ដែលពីមុននេះ មានមណ្ឌលសុខភាព៦៦នៅមិនទាន់មានមន្ត្រីឆ្មបនៅឡើយ ។ ជាមួយគ្នានេះ ប្រាក់បៀវត្សសម្រាប់លើកទឹកចិត្តក៏ត្រូវបានផ្តល់ជូនផងដែរ ។ ក្រុមការងារបច្ចេកទេសចម្រុះប្រយុទ្ធប្រឆាំងនឹងជម្ងឺអេដស៍ (សូចនាករទី៥) ក៏បានរាយការណ៍ថា អត្រាឆ្លងមេរោគអេដស៍នៅក្នុងស្រទាប់យុវវ័យបានធ្លាក់ចុះមកត្រឹមកម្រិត០,៩% នាបច្ចុប្បន្ននេះ ។ រួមជាមួយវឌ្ឍនភាពនៅក្នុងវិស័យសង្គមកិច្ច ក្រុមការងារបច្ចេកទេសចម្រុះស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ និងក្រសួងផែនការបានគូសបញ្ជាក់ថា ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភត្រូវបានអនុមតិដោយក្រុមការងារបច្ចេកទេសចម្រុះស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ កាលពីដើមឆ្នាំ២០០៨កន្លងមក (សូចនាករទី៦) ។

អាទិភាពវិស័យសេដ្ឋកិច្ច

ក្នុងការរៀបចំ និងអនុវត្តន៍យុទ្ធសាស្ត្រវិស័យកសិកម្ម និងទឹក ស្ថាប័នរបស់រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ បានចុះហត្ថលេខាលើ« សេចក្តីប្រកាសស្តីពីគោលការណ៍ »សម្រាប់ជាក្របខ័ណ្ឌការងារណែនាំដល់ដៃគូអភិវឌ្ឍន៍ និងរាជរដ្ឋាភិបាលដែលប្រតិបត្តិការក្នុងវិស័យកសិកម្ម និងទឹក (សូចនាករទី៧) ។ ដើម្បីគាំទ្រដល់ការរៀបចំកម្មវិធីជាតិទាំង៥នៃយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មនិងទឹក ក្រុមគ្រប់គ្រងនិងគាំទ្រមួយត្រូវបានបង្កើតឡើងក្រោមការដឹកនាំរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងធនធានទឹក និងឧតុនិយម ដោយរំពឹងថានឹងជួយពន្លឿនការរៀបចំបញ្ចប់នូវកម្មវិធីជាតិចំនួន២នាពេលខាងមុខ ។ ការសម្របសម្រួលដំណើរការនេះក៏មានការជឿនលឿនទៅមុខផងដែរ តាមរយៈការប្រើប្រាស់នូវប្រព័ន្ធទិន្នន័យស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា ដែលដៃគូអភិវឌ្ឍន៍រមែងធ្វើបច្ចុប្បន្នភាពជាទៀងទាត់ ។

គោលនយោបាយស្តីពីការចុះបញ្ជី និងសិទ្ធិប្រើប្រាស់ដីរបស់ជនជាតិភាគតិច (សូចនាករទី៨) ត្រូវបានរៀបចំ និងអនុមតិដោយក្រុមប្រឹក្សាគោលនយោបាយដីធ្លី និងរង់ចាំការអនុមតិដោយរាជរដ្ឋាភិបាល ។ ដើម្បីគាំទ្រការអនុវត្តន៍គោលនយោបាយនេះ អនុក្រឹត្យដែលចែងលំអិតអំពីនីតិវិធីសម្រាប់ការចុះបញ្ជីដីធ្លីរបស់ជនជាតិដើមភាគតិច ត្រូវបានរៀបចំដោយក្រុមប្រឹក្សាគោលនយោបាយដីធ្លី ដែលនាពេលបច្ចុប្បន្ន កំពុងស្ថិតក្រោមការពិគ្រោះយោបល់ផ្ទៃក្នុងរវាងរាជរដ្ឋាភិបាលនិងភាគីពាក់ព័ន្ធដទៃទៀត ។ គោលដៅស្តីពីការលើកកំពស់ជីវភាពរស់នៅរបស់ប្រជាជនក្រីក្រ តាមរយៈការផ្តល់ដីសម្បទានសង្គមកិច្ចដល់ប្រជាជន៥០០គ្រួសារ និងដីបម្រុងទុកចំនួន១០.០០០ហិកតាសម្រាប់សម្បទានសង្គមកិច្ច ក៏សម្រេចបានវឌ្ឍនភាពផងដែរ បើទោះជាមិនបានទាំងស្រុងក៏ដោយ ។ ជាក់ស្តែង ប្រជាជនជិត១.០០០គ្រួសារត្រូវបានជ្រើសរើសរួចហើយសម្រាប់ផ្តល់ដីសម្បទានសង្គមកិច្ច ។ លើសពីនេះ បទបញ្ញត្តិដែលមានជាធរមានក្នុងអនុក្រឹត្យស្តីពីដីសម្បទានសេដ្ឋកិច្ច ត្រូវបានអនុវត្តយ៉ាងហ្មឹងម៉ាត់ (សូចនាករទី៩) ។ ជាមួយគ្នានេះដែរ ព័ត៌មានស្តីពីការផ្តល់ដីសម្បទានសេដ្ឋកិច្ចសម្រាប់ខេត្តក្រុងចំនួន៦ ត្រូវបានប្រមូលនិងផ្សព្វផ្សាយ ។ ដោយឡែក រាជរដ្ឋាភិបាលកំពុងបន្តត្រួតពិនិត្យដីសម្បទានសេដ្ឋកិច្ចដែលបានផ្តល់លើសពីទំហំ១០.០០០ហិកតាឡើងវិញ ។ ការកំណត់ព្រំប្រទល់តំបន់ការពារព្រៃឈើក៏មានវឌ្ឍនភាព ដោយក្នុងនោះតំបន់ព្រៃការពារចំនួន១៧ ត្រូវបានកំណត់ព្រំប្រទល់ និងគូសផែនទីរួចហើយ ។

ក្រុមប្រតិបត្តិសម្រាប់ការងារនេសាទ (សូចនាករទី១០) ត្រូវបានរៀបចំឡើង និងបានដាក់ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីពិនិត្យ និងអនុមតិ ។ នៅពេលក្រុមប្រតិបត្តិនេះត្រូវបានអនុមតិការគាំទ្រសម្រាប់វិស័យនឹងមានសុខដុមនីយកម្មប្រសើរជាងមុន និងតម្រឹមជាមួយនឹងអាទិភាពរបស់វិស័យ ។ ដូចគ្នានេះដែរ ក្នុងការបោសសំអាតមីន ក្របខ័ណ្ឌសម្រាប់រៀបចំផែនការយុទ្ធសាស្ត្រត្រូវបានពង្រឹង ។ ទន្ទឹមនេះយើងនៅមានបញ្ហាប្រឈមខ្លះ ។ នោះគឺការធ្វើសមាហរណកម្មឧបករណ៍ទាំងអស់នេះឱ្យមានសង្គតិភាព និងមានលក្ខណៈច្បាស់លាស់សម្រាប់គាំទ្រការបោសសំអាតមីន ។ ចុងបញ្ចប់ ចំពោះវិធានការសម្រាប់បង្កើតបរិស្ថានអំណោយផលសម្រាប់អភិវឌ្ឍវិស័យឯកជន ក្រសួងពាណិជ្ជកម្ម ក្រសួងសុខាភិបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រួមជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានសហការគ្នាអនុវត្តកិច្ចព្រមព្រៀងកម្រិតសេវា និងឯកភាពលើបញ្ជីនៃទំនិញហាមឃាត់ (សូចនាករទី១២) ។ ការបញ្ចូលបញ្ជី

ទាំងនេះទៅក្នុងប្រព័ន្ធស្វ័យប្រវត្តិកម្មការងារគយកំពុងត្រូវបានអនុវត្ត ។ រីឯកិច្ចការពាក់ព័ន្ធនឹងការពិនិត្យពីការផ្តល់អាជ្ញាប័ណ្ណដល់សហគ្រាសធុនតូច និងមធ្យមមិនសូវមានវឌ្ឍនភាពឡើយ ។

អាទិភាពវិស័យហេដ្ឋារចនាសម្ព័ន្ធ

ការថែទាំប្រព័ន្ធផ្លូវថ្នល់ជាអាទិភាពមួយរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន ។ ក្រសួងបានរៀបចំ និងដាក់ឱ្យអនុវត្តនូវសេចក្តីណែនាំសម្រាប់ការថែទាំផ្លូវថ្នល់ (សូចនាករទី១៣) ។ បញ្ហាប្រឈមគឺការអនុវត្តន៍សេចក្តីណែនាំដែលបានដាក់ចេញ ទន្ទឹមនឹងពេលដែលក្រសួងកំពុងរៀបចំយន្តការដើម្បីត្រួតពិនិត្យការដឹកលើសចំណុះ ។ ក្នុងការលើកកំពស់អនាម័យជនបទនិងការផ្គត់ផ្គង់ទឹកស្អាត ក្រសួងអភិវឌ្ឍន៍ជនបទបានរាយការណ៍ពីវឌ្ឍនភាពដែលសម្រេចបាន ក្នុងកិច្ចប្រឹងប្រែងដើម្បីបង្កើនការផ្គត់ផ្គង់ទឹកស្អាតដល់ប្រជាជន៥០% នៅជនបទ និងអនាម័យដល់ប្រជាជន៣០% ត្រឹមដំណាច់ឆ្នាំ២០១៥ ដែលនេះជាគោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជា និងបង្កើនការផ្គត់ផ្គង់ទឹកស្អាតឱ្យបានដល់ប្រជាជន៤០% នៅជនបទ និងអនាម័យឱ្យបានដល់ប្រជាជន២០% ត្រឹមដំណាច់ឆ្នាំ២០១១ (សូចនាករទី១៤) ។

វិស័យអភិបាលកិច្ច និងអាទិភាពពហុវិស័យ

ក្នុងកំណែទម្រង់រដ្ឋបាលសាធារណៈ (សូចនាករទី១៥) ការឈានទៅលុបបំបាត់ទម្លាប់ផ្តល់ប្រាក់ឧបត្ថម្ភដែលផ្តល់ដោយដៃគូអភិវឌ្ឍន៍ កំពុងបោះជំហានទៅមុខ តាមរយៈការដាក់ឱ្យអនុវត្តនូវយន្តការសំខាន់៣គឺ ÷ ភ្នាក់ងារប្រតិបត្តិការពិសេស កន្សោមអាទិភាព និងកម្មវិធីផ្តល់លាភការផ្អែកលើលទ្ធផលការងារ ។ សមាសធាតុស្នូលនៃគោលនយោបាយកែលំអប្រាក់បៀវត្សរ៍ត្រូវបានរៀបចំរួច និងកំពុងដាក់ឱ្យអនុវត្ត ដែលរួមមាន÷ការតម្លើងប្រាក់បៀវត្សរ៍២០% សម្រាប់មន្ត្រីរាជការ ការបន្តអនុវត្តន៍ប្រាក់បំណាច់មុខងារ (សម្រាប់ថ្នាក់គ្រប់គ្រងវិស័យអប់រំ និងសុខាភិបាល) យន្តការកន្សោមអាទិភាព និងកម្មវិធីផ្តល់លាភការផ្អែកលើលទ្ធផលការងារ ទំនើបកម្មប្រព័ន្ធសោធននិវត្តន៍ និងការធានារ៉ាប់រងសុខភាព ។ ជាជំហានមួយនៃគោលនយោបាយពង្រាយមន្ត្រីរាជការ ការសិក្សាមួយស្តីពីកិច្ចប្រតិបត្តិល្អៗកំពុងត្រូវបានអនុវត្ត ។ ការអនុវត្តន៍គោលនយោបាយកែលំអប្រាក់បៀវត្សរ៍ និងការដាក់ពង្រាយមន្ត្រី ត្រូវពឹងផ្អែកលើសង្គតិភាពនៃស្ថាប័ននានារបស់រាជរដ្ឋាភិបាល និងចីរភាពនៃចំណូលរដ្ឋផងដែរ ។

ក្នុងកំណែទម្រង់ច្បាប់និងប្រព័ន្ធតុលាការ ក្រៅពីការអនុមតិ និងការដាក់ឱ្យអនុវត្តក្រមនីតិវិធីព្រហ្មទណ្ឌ (សូចនាករទី១៦) វឌ្ឍនភាពក្នុងកំណែទម្រង់នេះនៅមានកម្រិតនៅឡើយ ។ ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណីត្រូវបានប្រកាសឱ្យអនុវត្ត ។ ប៉ុន្តែ បញ្ហាសង្គតិភាពរវាងច្បាប់មូលដ្ឋានទាំងនេះជាមួយនឹងការរៀបចំច្បាប់ថ្មីៗទៀតនៅតែជាបញ្ហាប្រឈមនៅឡើយ ។ ក្រមព្រហ្មទណ្ឌកំពុងត្រូវបានពិភាក្សានៅក្នុងគណៈកម្មាធិការអន្តរក្រសួង បើទោះបីជាច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់អង្គតុលាការ និងច្បាប់វិសោធនកម្មច្បាប់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មិនមានភាពជឿនលឿនក្នុងរយៈពេលនេះក៏ដោយ ។ ច្បាប់ស្តីពីការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ (សូចនាករទី១៧) នឹងចាប់ផ្តើមបន្ទាប់ពីការរៀបចំបញ្ចប់ក្រមព្រហ្មទណ្ឌ ។

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត- ក្រុង ស្រុក- ខណ្ឌ ត្រូវបានអនុមតិ និងប្រកាសឱ្យអនុវត្ត នៅខែឧសភា ឆ្នាំ២០០៨ (សូចនាករទី១៨) សម្រាប់ជាមូលដ្ឋាននៃការរៀបចំប្រព័ន្ធរដ្ឋបាលរបស់រដ្ឋ ។ ជាមួយគ្នានេះដែរ ការរៀបចំកម្មវិធីជាតិសម្រាប់គាំទ្រកិច្ចអភិវឌ្ឍន៍ប្រជាធិបតេយ្យនៅមូលដ្ឋានក៏បានចាប់ផ្តើមផងដែរ នាខែកញ្ញាឆ្នាំ២០០៨កន្លងមកនេះ ។ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ នឹងបំពេញឱ្យកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (សូចនាករទី១៩) ដែលកំពុងដំណើរការទៅមុខ ជាមួយនឹងការត្រៀមសម្រាប់អនុវត្តជំហានទី២របស់ខ្លួន ។ សូចនាករតាមដានរួមគ្នាចុងក្រោយបានសម្រេចលទ្ធផលគួរឱ្យកត់សំគាល់ ដូចជា÷ អនុក្រឹត្យស្តីពីការសម្រេចរដ្ឋបាលដើម្បីទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ដោយក្រសួងមហាផ្ទៃ និងច្បាប់ប្រយុទ្ធប្រឆាំងនឹងការជួញដូរស្ត្រីនិងកុមារ ដែលស្របតាមបទដ្ឋានពិធីសាររបស់សហប្រជាជាតិ ត្រូវបានអនុមតិរួចហើយ (សូចនាករទី២០) ។ ផែនការសកម្មភាពជាតិដើម្បីប្រឆាំងអំពើហិង្សាលើស្ត្រី ត្រូវបានរៀបចំ និងកំពុងពិភាក្សានៅទីស្តីការគណៈរដ្ឋមន្ត្រី មុននឹងបង្កើតក្រុមការងារមួយនៅក្រសួងមហាផ្ទៃ ។

សង្ខេបអំពីវឌ្ឍនភាពក្នុងការអនុវត្តន៍សូចនាករតាមដានរួមគ្នា

ផ្អែកតាមខ្លឹមសារដូចបានរៀបរាប់ខាងលើ តារាងខាងក្រោមបានសរុបអំពីវឌ្ឍនភាពនៃការអនុវត្តន៍សូចនាករតាមរួមគ្នាទាំង២០ ។

តារាងទី១១ - សង្ខេបអំពីវឌ្ឍនភាពនៃការអនុវត្តន៍សូចនាករតាមដានរួមគ្នា

គោលដៅ	សកម្មភាពចាំបាច់	វឌ្ឍនភាពជារួម
ការអនុវត្តន៍ និងការគ្រប់គ្រងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ		
១- អនុមតិផែនការយុទ្ធសាស្ត្រក្រសួងផែនការ	១- អនុមតិផែនការយុទ្ធសាស្ត្រក្រសួងផែនការ និងផ្តល់ការគាំទ្រមានការសម្របសម្រួល ២- ច្របាច់បញ្ចូលរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំស្តីពីផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងផ្នែកតម្រឹមនៃរបាយការណ៍ប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ	១- រៀបចំរួច- កំពុងបន្តពិភាក្សា ២- បញ្ចប់មួយផ្នែក- ការងារបន្ត
២- អនុវត្តអាទិភាពលើកកំពស់ប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ	១- ដៃគូអភិវឌ្ឍន៍ចែករំលែកព័ត៌មានគម្រោងថ្មីៗជាមួយក.អ.ក តាមរយៈប្រព័ន្ធទិន្នន័យហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា ២- រាយការណ៍ជូនគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ពីវឌ្ឍនភាពនៃការអនុវត្តន៍ផែនការសកម្មភាពសុខដុមនីយកម្ម ការតម្រឹម និងលទ្ធផល និងគោលការណ៍ណែនាំសម្រាប់ក្រុមការងារបច្ចេកទេស ៣- បញ្ចូលសូចនាករទៅក្នុងផែនការសកម្មភាពសុខដុមនីយកម្ម ការតម្រឹម និងលទ្ធផល	១- វឌ្ឍនភាពល្អ - ការងារបន្ត ២- សម្រេចគោលដៅ ៣- សម្រេចគោលដៅ
អាទិភាពក្នុងវិស័យសង្គមកិច្ចនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ		
៣- បង្កើនឱកាសចូលរៀននៅកម្រិតបឋមសិក្សា	១- បង្កើនអត្រាចូលរៀននៅកម្រិតបឋមសិក្សា (សរុប និងតាមភេទ) ២- បង្កើនអត្រាគង់វង្សរបស់សិស្សថ្នាក់ទី១ ដល់ទី៦	អត្រាចូលរៀន និងអត្រាគង់វង្សកើនឡើង
៤- បង្កើនអត្រាសម្រាលកូនដោយពេទ្យឆ្មប	១- ជ្រើសរើស និងពង្រាយបុគ្គលិកឆ្មបយ៉ាងតិច៦៨នាក់ ទៅមណ្ឌលសុខភាពដែលមិនទាន់មានឆ្មប ត្រឹមឆ្នាំ២០០៧ ២- ផ្តល់បៀវត្សរ៍លើកទឹកចិត្តដល់បុគ្គលិកឆ្មប	សម្រេចគោលដៅ
៥- ឆ្លើយតបនឹងការឆ្លងមេរោគអេដស៍	ពង្រីកវិសាលភាពការទប់ស្កាត់ ថែរក្សា និងគាំទ្រ និងកាត់បន្ថយផលប៉ះពាល់នៃជំងឺអេដស៍	សម្រេចគោលដៅ

៦- យុទ្ធសាស្ត្រសន្តិសុខស្បៀង និងអាហារូបត្ថម្ភ	រៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ និងអនុមតិដោយក្រសួង និងស្ថាប័នរបស់រាជរដ្ឋាភិបាល	យុទ្ធសាស្ត្ររៀបចំបញ្ចប់ កំពុងផ្សព្វផ្សាយ
អាទិភាពក្នុងវិស័យសេដ្ឋកិច្ចនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ		
៧- ភាពជាដៃគូក្នុងវិស័យកសិកម្ម និងទឹក	១- អនុវត្តយុទ្ធសាស្ត្រវិស័យកសិកម្ម និងទឹក ២- កែលំអការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍	១- នឹងបញ្ចប់ដំណាច់ឆ្នាំ២០០៨ ២- វឌ្ឍនភាព និងបន្តអនុវត្ត
៨- អនុវត្តច្បាប់ភូមិបាល	១- អនុមតិគោលនយោបាយស្តីពីការចុះបញ្ជី និងសិទ្ធិប្រើប្រាស់ដីរបស់សហគមន៍ជនជាតិភាគតិច និងអនុវត្តវិធានការការពារដីសហគមន៍ជនជាតិដើមភាគតិច ២- ប្រជាជន៥០០គ្រួសារតាំងទីលំនៅលើដីសម្បទានសង្គមកិច្ច ដោយមានការគាំទ្រខាងជីវភាពរស់នៅ និងដី១០.០០០ហិកតាត្រូវបម្រុងទុកសម្រាប់សម្បទានសង្គមកិច្ច	១- អនុវត្តបានមួយផ្នែក- កំពុងបន្ត ២- អនុវត្តបានមួយផ្នែក- កំពុងបន្ត
៩- អនុវត្តច្បាប់ព្រៃឈើ និងអនុក្រឹត្យដីសម្បទានសេដ្ឋកិច្ច	១- អនុវត្តអនុក្រឹត្យដីសម្បទានសេដ្ឋកិច្ច ៖ ផ្សព្វផ្សាយបញ្ជីពិនិត្យដីសម្បទានសេដ្ឋកិច្ចមានទំហំលើស១០.០០០ហិកតា ២- កំណត់ព្រំប្រទល់ព្រៃ តាមអនុក្រឹត្យលេខ៥៣ ចុះថ្ងៃទី១៥ ខែមេសា ឆ្នាំ២០០៥	១- អនុវត្តបានមួយផ្នែក ២- បោះបង្គោលបាន១៧តំបន់
១០- អនុវត្តអាទិភាពវិស័យជលផល	១- ពង្រាងក្រមប្រតិបត្តិការនេសាទដោយទទួលខុសត្រូវនៅកម្ពុជា ២- រដ្ឋបាលជលផលទទួលការគាំទ្រសមស្រប (មាត្រា១៤ច្បាប់ជលផល) ៣- ដៃគូអភិវឌ្ឍន៍ប្រើប្រាស់ប្រព័ន្ធផែនការ គណនេយ្យ និងតាមដានរបស់ជាតិ	១- បញ្ចប់ពង្រាង- កំពុងផ្សព្វផ្សាយ ២- មិនបានទទួលការគាំទ្រសមស្រប ៣- ដៃគូភាគតិចប្រើប្រព័ន្ធជាតិ
១១- បន្ថយករណីគ្រោះថ្នាក់ដោយសារមីន និងផ្ទៃដីដែលមានមីន	១- អនុវត្ត និងតាមដានការអនុវត្តន៍យុទ្ធសាស្ត្រ និងផែនការសកម្មភាពដែលមាន ២- ផ្តល់ និងប្រើប្រាស់ហិរញ្ញប្បទានរបស់រាជរដ្ឋាភិបាល និងដៃគូឱ្យទាន់ពេលវេលា ៣- បង្កើនតម្លាភាពនៃការប្រើប្រាស់ធនធាន	១- សម្រេចគោលដៅ ២- សម្រេចគោលដៅ ៣- សម្រេចគោលដៅ
១២- បរិយាកាសអំណោយផលដល់វិស័យឯកជន	១- ក្រសួងពាណិជ្ជកម្ម ក្រសួងសុខាភិបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះហត្ថលេខាការអនុវត្តន៍កិច្ចព្រមព្រៀងសេវាកម្មដោយភ្ជាប់នូវបញ្ជីទំនិញហាមឃាត់ ២- ពិនិត្យការអនុវត្តន៍ការគ្រប់គ្រងហានិភ័យ ដោយកាត់បន្ថយនៅត្រឹម៥០% ទាំងនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ៣- ផ្តល់អនុសាសន៍លើអាជ្ញាប័ណ្ណ២០ ដែលប៉ះពាល់ដល់សហគ្រាសធុនតូចនិងមធ្យម	១- ការងារបន្ត ២- សម្រេចមួយផ្នែក- ការងារបន្ត ៣- គ្មានវឌ្ឍនភាព
អាទិភាពក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ		
១៣- ចីរភាពនៃប្រព័ន្ធផ្លូវ	១- រៀបចំផែនការសកម្មភាពគ្រប់គ្រងថែទាំផ្លូវថ្នល់ ត្រឹមខែមិថុនា ឆ្នាំ២០០៨ ២- អនុវត្តសាកល្បងកិច្ចសន្យាថែទាំផ្លូវ៣ និងកម្មវិធីត្រួតពិនិត្យការផ្ទុកលើសចំណុះ	១- បានរៀបចំឯកសារណែនាំ ២- បន្តអនុវត្ត- វឌ្ឍនភាពយឺត
១៤- កែលំអទឹកស្អាត និងអនាម័យជនបទ	រៀបចំយុទ្ធសាស្ត្រស្តីពីការផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យជនបទ ព្រមទាំងថវិកា ដោយតម្រឹមជាមួយនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ	សម្រេចវឌ្ឍនភាព- ការងារបន្ត
អាទិភាពក្នុងវិស័យអភិបាលកិច្ច និងពហុវិស័យនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ		
១៥- កំណែទម្រង់រដ្ឋបាលសាធារណៈ	១- អនុវត្តយុទ្ធសាស្ត្ររួមស្តីពីការឈប់ជាបណ្តើរៗការផ្តល់ប្រាក់បៀវត្សរ៍បន្ថែម ២- កែលំអការផ្តល់ប្រាក់បៀវត្សរ៍និងល័ក្ខខ័ណ្ឌការងារ ៣- អនុវត្តគោលនយោបាយ និងផែនការសកម្មភាពការគ្រប់គ្រងធនធានមនុស្ស និងប្រព័ន្ធគ្រប់គ្រងព័ត៌មានធនធានមនុស្ស ៤- គោលនយោបាយយន្តការបញ្ចរតែមួយ និងផែនការសកម្មភាពដើម្បីអនុវត្ត	១- អនុក្រឹត្យលេខ២៩បានអនុមតិ ២- សមាសធាតុស្នូលត្រូវបានរៀបចំ ៣- រៀបចំរួចសម្រាប់ពិគ្រោះយោបល់ ៤- អនុវត្តបន្ត- ក្រសួងមហាផ្ទៃដឹកនាំ

១៦- កំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ	១- អនុមតិក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមព្រហ្មទណ្ឌ ក្រមរដ្ឋប្បវេណី ក្រមនីតិវិធីរដ្ឋប្បវេណី ច្បាប់លក្ខន្តិកៈចៅក្រម ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់តុលាការ ច្បាប់វិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ២- រៀបចំគោលការណ៍ណែនាំសម្រាប់ដំណើរការរៀបចំសេចក្តីព្រាងច្បាប់ ៣- បណ្តុះបណ្តាល និងជ្រើសរើសមន្ត្រីផ្នែកតុលាការ	១- ក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមនីតិវិធីរដ្ឋប្បវេណី ក្រមរដ្ឋប្បវេណីអនុមតិ ២- ផ្អាក ៣- ការងារអនុវត្តបន្ត
១៧- ប្រយុទ្ធប្រឆាំងអំពើពុករលួយ	១- រៀបចំបញ្ចប់ច្បាប់ប្រឆាំងអំពើពុករលួយ ២- រៀបចំផែនការគ្រប់គ្រងការអនុវត្តច្បាប់ប្រឆាំងអំពើពុករលួយ ៣- ផ្សព្វផ្សាយករណីអំពើពុករលួយ និងការផ្តន្ទាទោស ៤- រៀបចំក្របខ័ណ្ឌគោលនយោបាយស្តីពីសិទ្ធិទទួលព័ត៌មាន	១- នឹងចាប់ផ្តើមក្រោយបញ្ចប់សេចក្តីព្រាងក្រមព្រហ្មទណ្ឌ- ជាការងារអាទិភាពនៅក្នុងយុទ្ធសាស្ត្រចតុកោណ- ដំណាក់កាលទី២
១៨- កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ	១- បន្តរៀបចំបញ្ចប់ច្បាប់ស្តីពីការគ្រប់គ្រងរាជធានី ខេត្ត- ក្រុង ស្រុក- ខណ្ឌ ២- រៀបចំកម្មវិធីជាតិតាមទម្រង់ការឯកភាព និងធនធាន ៣- រៀបចំគោលការណ៍ចូលរួមសម្រាប់គាំទ្រកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ	១- សម្រេចគោលដៅ ២- ការងារបន្តក្នុងឆ្នាំ២០០៩ ៣- នឹងរៀបចំបន្ទាប់ពីកម្មវិធីជាតិ
១៩- បង្កើនទំនុកចិត្តលើថវិការដ្ឋ និងគណនេយ្យភាព	១- បន្តអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី១ ២- រៀបចំកម្មវិធីដំណាក់កាលទី២ និងផែនការសកម្មភាព រួមទាំងការផ្តល់អនុសាសន៍លើគំនិតផ្តួចផ្តើមស្តីពីតម្លាភាពក្នុងឧស្សាហកម្មរុករក ៣- បន្តត្រួតពិនិត្យវឌ្ឍនភាពតាមសូចនាករដែលបានឯកភាព	១- ដំណាក់កាលទី១បញ្ចប់ ២- ការងារអនុវត្តបន្ត ៣- ការងារអនុវត្តបន្ត
២០- អនុមតិ និងអនុវត្ត ច្បាប់និងផែនការសំដៅទប់ស្កាត់អំពើហិង្សាលើស្ត្រី និងការជួញដូរស្ត្រី និងកុមារ	១- សេចក្តីព្រាងអនុក្រឹត្យស្តីពីការសម្រេចចិត្តផ្នែករដ្ឋបាលស្តីពីអំពើហិង្សាក្នុងគ្រួសារ ២- អនុមតិច្បាប់ប្រឆាំងនឹងការជួញដូរមនុស្ស និងការជួញដូរផ្លូវភេទ ៣- អនុវត្តផែនការសកម្មភាពជាតិស្តីពីការលុបបំបាត់អំពើហិង្សាលើស្ត្រី ៤- ពិនិត្យឡើងវិញនូវបទបញ្ញត្តិ និងគោលនយោបាយស្តីពីអន្តោប្រវេសន៍	១- រង់ចាំការអនុមតិ ២- ច្បាប់ត្រូវបានអនុមតិ ៣- ទីស្តីការគណៈរដ្ឋមន្ត្រីពិភាក្សា ៤- បានពិនិត្យ

ជំពូក ៥

ទិសដៅកម្រិតគោលនយោបាយក្នុងការគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ

ជំពូកនេះបូកសរុបគោលគំនិតសំខាន់ៗទាំងអស់ ដែលបានបង្ហាញក្នុងជំពូកខាងដើមនៃរបាយការណ៍នេះ ដើម្បីលើកឡើងនូវអនុសាសន៍មួយចំនួន រួមទាំងសកម្មភាពអាទិភាពមួយចំនួនសម្រាប់រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍អនុវត្ត ។ ផ្អែកលើរបកគំហើញនៃការវាយតម្លៃស្តីពីប្រសិទ្ធភាពនៃការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការនិងការត្រួតពិនិត្យឯករាជ្យនាពេលថ្មីៗកន្លងមកនេះ ជំពូកនេះក៏នឹងលើកសកម្មភាពមួយចំនួន ក្នុងទម្រង់ជាសូចនាករតាមដានរួមគ្នាថ្មីមួយ ។

ដើម្បីរៀបចំអនុសាសន៍កម្រិតគោលនយោបាយ ចាំបាច់ត្រូវយកចិត្តទុកដាក់ដល់កត្តាមួយចំនួនដូចខាងក្រោម ÷

១- បច្ចុប្បន្ន រាជរដ្ឋាភិបាលបានឈានហួសចំណុចពាក់កណ្តាលនៃការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងផែនការសកម្មភាពស្តីពីសុខដុមនីយកម្ម ការតម្រឹម និងលទ្ធផល ។ បញ្ហាប្រឈមរបស់យើងគឺត្រូវកំណត់ឱ្យបានច្បាស់លាស់នូវអាទិភាពបន្ទាន់ ក្នុងក្របខ័ណ្ឌនៃប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការដែលមានស្រាប់ និងត្រូវផ្តោតទៅលើការប្រឹងប្រែងអនុវត្ត និងត្រួតពិនិត្យសកម្មភាពអាទិភាពបន្ទាន់មួយចំនួន ។

២- វេទិកាកំពូលនៅទីក្រុងអាក្រា បានផ្តល់នូវស្តង់ដារកម្រិតសកលសម្រាប់ជាមូលដ្ឋានក្នុងការអនុវត្តន៍របស់រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ។ ការចរចាគឺជាការងារចាំបាច់ ដើម្បីសម្រេចបាននូវមតិឯកភាពរួមមួយ ហើយផ្អែកលើនេះ រាល់អនុសាសន៍ថ្មីៗទាំងឡាយអាចនឹងអនុវត្តបាននៅក្នុងបរិបទកម្ពុជា ។ រីឯករណីខ្លះទៀត យើងត្រូវផ្តាច់ចេញពីរបៀបវារៈសកលទើបអាចអនុវត្តបានស្របនឹងស្ថានភាពកម្ពុជា ។

៣- យើងបានរៀបចំល័ក្ខខ័ណ្ឌបច្ចេកទេសសំខាន់ៗជាច្រើន ដូចជាគោលនយោបាយ ក្របខ័ណ្ឌស្ថាប័នយន្តការពិគ្រោះយោបល់ និងប្រភពធនធានជាដើម ។ ការវាយតម្លៃចុងក្រោយលើដំណើរការនៃការកំណត់អាទិភាពតម្រូវឱ្យមានការចូលរួមពីសំណាក់ថ្នាក់ដឹកនាំជាន់ខ្ពស់ និងអ្នករៀបចំគោលនយោបាយដើម្បីធានាឱ្យមានការគាំទ្ររឹងមាំសម្រាប់អនុវត្តសកម្មភាពសមស្របនានាឱ្យបានសម្រេច ។

៤-រីឯបញ្ហាប្រឈមដទៃទៀតពុំទាន់មានភាពចាំបាច់បន្ទាន់ សម្រាប់អនុវត្តគំនិតផ្តួចផ្តើមស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការឡើយ ។ ការពង្រឹងទំនាក់ទំនងរវាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិនិងថវិកា និងរវាងសមត្ថភាពនៃការផ្តល់សេវាសាធារណៈនិងការលើកទឹកចិត្ត និងតម្រូវការសេវាសាធារណៈ ទាមទារឱ្យបន្តអនុវត្តកម្មវិធីកំណែទម្រង់នានា ដោយបញ្ចូលការប្រតិបត្តិល្អស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទាន ពោលគឺបញ្ចូលបណ្តាអាទិភាពតាមវិស័យទៅក្នុងគោលដៅនៃប្រព័ន្ធទូលំទូលាយ ។

បរិបទនេះក៏បង្ហាញអំពីគោលការណ៍មួយចំនួន ដែលផ្អែកលើគោលគំនិតចម្បងចំនួន៥ដែលបានមកពីសក្ដីភាពជាក់ស្ដែងនិងការវិភាគនានា ដែលបានបង្ហាញនៅក្នុងជំពូកមុនៗនៃរបាយការណ៍ស្ដីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការនេះ ÷

១- សកម្មភាពអាទិភាពទាំងឡាយ ដែលស្ថិតនៅក្នុងក្របខ័ណ្ឌប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ ត្រូវធ្វើសមាហរណកម្មទៅក្នុងកម្មវិធីកំណែទម្រង់ និងត្រូវមានការគាំទ្រជាក់លាក់និងការប្ដេជ្ញាពីមន្ត្រីជាន់ខ្ពស់របស់រាជរដ្ឋាភិបាល និងពីភ្នាក់ងាររបស់ដៃគូអភិវឌ្ឍន៍ ។

២- កិច្ចប្រឹងប្រែងសម្រាប់ជម្រុញការអនុវត្តន៍បណ្ដាអាទិភាពនៃប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការដែលបានឯកភាពគ្នា តម្រូវឱ្យមានការខិតខំប្រឹងប្រែងសារជាថ្មីបន្ថែមទៀតសម្រាប់ពង្រឹងភាពជាដៃគូ បង្កើនជំនឿទុកចិត្ត និងការយោគយល់គ្នាទៅវិញទៅមក ព្រមទាំងមានសមត្ថកិច្ចសមស្របទៅនឹងការងារក្នុងក្របខ័ណ្ឌនៃភាពជាដៃគូសម្រាប់អភិវឌ្ឍសមត្ថភាព ។

៣- តម្រូវឱ្យបង្កើនកិច្ចសហការទាំងក្នុងស្ថាប័នថ្នាក់ជាតិនិងក្រសួង រវាងបណ្ដាស្ថាប័ននិងក្រសួងទាំងនេះ ។ ទន្ទឹមនេះ ក៏ត្រូវបង្កើនបណ្ដាញការងារអន្តរស្ថាប័នសម្រាប់រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលដែលចូលរួមការងារក្នុងវិស័យទាំងនេះផងដែរ ។

ការយល់ដឹងអំពីបរិបទបច្ចុប្បន្ន ការវិភាគលើសក្ដីភាពជាក់ស្ដែង និងការឯកភាពលើគោលការណ៍ទាំងនេះ បានផ្ដល់នូវអនុសាសន៍កម្រិតគោលនយោបាយដូចខាងក្រោម ÷

I - អនុសាសន៍កម្រិតគោលនយោបាយចំពោះរាជរដ្ឋាភិបាល

ក- ការកំណត់សកម្មភាពអាទិភាពសម្រាប់ប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ

១- ពង្រឹងទំនាក់ទំនងរវាងស្ថាប័នថ្នាក់ជាតិ (ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងផែនការ គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា) តាមរយៈការសម្របសម្រួលជាមួយឧត្ដមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ដើម្បីធានាឱ្យមានកិច្ចសហការអន្តរស្ថាប័នសម្រាប់រៀបចំទម្រង់នានា និងកាលបរិច្ឆេទ ព្រមទាំងទំនាក់ទំនងអន្តរស្ថាប័នរវាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិនិងកម្មវិធីនីយកម្មនៃថវិកា និងរវាងកម្មវិធីវិនិយោគសាធារណៈនិងក្របខ័ណ្ឌចំណាយសម្រាប់រយៈពេលមធ្យម ព្រមទាំងផ្សាភ្ជាប់កិច្ចការទាំងនេះជាមួយនឹងការគ្រប់គ្រងធនធានហិរញ្ញប្បទានសហប្រតិបត្តិការ ។

២- ថ្នាក់គ្រប់គ្រងនៅតាមក្រសួងនិងស្ថាប័នត្រូវបង្កើនវឌ្ឍនភាពថ្មីៗបន្ថែមទៀតតាមរយៈការកំណត់អាទិភាពសម្រាប់គ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ ដោយផ្អែកលើគោលដៅនិងផែនការតាមវិស័យ ។ រីឯតម្រូវការដោយឡែករបស់ដៃគូអភិវឌ្ឍន៍ រួមទាំងការប្រើប្រាស់កិច្ចសហប្រតិបត្តិការបច្ចេកទេស និងការប្រើប្រាស់ប្រព័ន្ធជាតិ នឹងត្រូវពិភាក្សាគ្នាយ៉ាងហ្មត់ចត់នៅក្នុងក្រុមការងារបច្ចេកទេសចម្រុះ និងគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ។

៣- សក្ដីភាពជាក់ស្ដែងនៃទំនាក់ទំនងជិតស្និទ្ធរវាងភាពដឹកនាំនិងការអភិវឌ្ឍន៍សមត្ថភាពបានគូសបញ្ជាក់អំពីការជម្រុញឱ្យមានគំរូគ្រប់គ្រង សម្រាប់អនុវត្តរបៀបវារៈនៃកម្មវិធីកំណែទម្រង់របស់រាជរដ្ឋាភិបាល ។ ផ្នត់គំនិតថ្មីនេះទាមទារថ្នាក់គ្រប់គ្រងតាមក្រសួងនិងស្ថាប័នផ្ដល់ទិសដៅច្បាស់លាស់ក្នុងការអភិវឌ្ឍន៍

សមត្ថភាពនៅពេលអនាគត និងផ្តល់ភារកិច្ចទទួលខុសត្រូវឱ្យកាន់តែច្រើនឡើងក្នុងការគ្រប់គ្រងគម្រោងនិងកម្មវិធីនានា ។ ក្នុងក្របខ័ណ្ឌនៃកម្មវិធីកំណែទម្រង់ ទាមទារឱ្យមានកិច្ចសហប្រតិបត្តិការរវាងក្រសួងនិងស្ថាប័ននៃរាជរដ្ឋាភិបាល ដើម្បីធានាសង្គតិភាពក្នុងការបកស្រាយ និងការអនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាលស្តីពីការអភិវឌ្ឍន៍សមត្ថភាព ការគ្រប់គ្រងធនធានមនុស្ស ការផ្តល់លាភការ និងការគ្រប់គ្រងការអនុវត្តន៍ ព្រមទាំងតួនាទីរបស់ដៃគូអភិវឌ្ឍន៍ក្នុងការគាំទ្រគោលដៅនៃកម្មវិធីកំណែទម្រង់នេះ ។

៤- គោលការណ៍ស្តីពីការបែងចែកពលកម្ម ត្រូវបានលើកឡើងក្នុងរបាយការណ៍នេះ ។ ដោយមានការគាំទ្របច្ចេកទេសពីគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា ថ្នាក់គ្រប់គ្រងនៃក្រសួងនិងស្ថាប័ននិមួយៗដែលកំពុងធ្វើការជាមួយនឹងដៃគូអភិវឌ្ឍន៍ ត្រូវបញ្ជាក់និងណែនាំអំពីរបៀបអនុវត្តគោលការណ៍ស្តីពីការបែងចែកពលកម្មនេះសម្រាប់វិស័យរបស់ខ្លួន តាមរយៈក្រុមការងារបច្ចេកទេសចម្រុះ ។

ខ- ការធ្វើសមាហរណកម្មអាទិភាពនៃប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ ជាមួយកម្មវិធីកំណែទម្រង់និងការងារតាមវិស័យ

១- គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា ដែលជាស្ថាប័នសម្របសម្រួលថ្នាក់ជាតិ មានតួនាទីសម្រួលដំណើរការការងាររបស់ក្រុមការងារបច្ចេកទេសចម្រុះ តាមរយៈការឧបត្ថម្ភគាំទ្រ ដូចជាការផ្តល់វគ្គបណ្តុះបណ្តាលនិងការគាំទ្រថវិកា ។ កម្មវិធីគាំទ្រនេះនឹងបន្តផ្តល់ដោយអនុវត្តតាមគោលការណ៍នៃតម្រូវការរបស់ក្រុមការងារបច្ចេកទេសចម្រុះ ។ សកម្មភាពនានានៃបណ្តាញក្រុមការងារបច្ចេកទេសចម្រុះរបស់រាជរដ្ឋាភិបាលនឹងត្រូវពង្រីកបន្ថែមដល់ប្រធានក្រុមការងារ និងមន្ត្រីជាន់ខ្ពស់របស់រាជរដ្ឋាភិបាល ។ ធ្វើដូចនេះ ទើបថ្នាក់គ្រប់គ្រងអាចផ្លាស់ប្តូរព័ត៌មាន និងជួយគាំទ្រគ្នាទៅវិញទៅមកបាន ។

២- រាល់សកម្មភាពដោយឡែកៗ ទោះបីនៅកម្រិតថ្នាក់ជាតិ ឬកម្រិតវិស័យក៏ដោយ ក៏ត្រូវបានបញ្ចូលទៅក្នុងអភិក្រមគ្រប់គ្រងទូទាំងវិស័យដែរ ដូចជាទំនាក់ទំនងរវាងផែនការនិងថវិកា ការធ្វើអាទិភាវូបនីយកម្មសមត្ថភាព វិធីសាស្ត្រអនុវត្តប្រកបដោយសុខដុមនីយកម្ម ការត្រួតពិនិត្យរួមគ្នា និងគណនេយ្យភាពទ្វេទិស ។ កម្មវិធីអភិក្រមគ្រប់គ្រងទូទាំងវិស័យដែលមានបច្ចុប្បន្ន ឬដែលកំពុងរៀបចំបង្កើត ត្រូវផ្តោតលើសកម្មភាពទាំងឡាយណាដែលពាក់ព័ន្ធ និងសមស្របប៉ុណ្ណោះ ។ កម្មវិធីនេះមិនត្រូវឱ្យធ្ងន់ធ្ងរសុទិដ្ឋិនិយម និងស្មុគស្មាញហួសហេតុពេកទេ ហើយភាពគ្រប់ជ្រុងជ្រោយនៃកម្មវិធី គឺជាការងារមានសារៈសំខាន់ទី២ បន្ទាប់ពីការចូលរួមរបស់ថ្នាក់ដឹកនាំកម្រិតនយោបាយ ។

៣- មន្ត្រីចូលរួមក្នុងក្រុមការងារបច្ចេកទេសចម្រុះត្រូវមានកម្រិតខ្ពស់ និងមានសមត្ថភាពក្នុងការងារនេះដើម្បីធានាការពិគ្រោះយោបល់មានប្រសិទ្ធភាព និងអាចសម្របសម្រួលការអនុវត្តន៍សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ។ លក្ខណៈសម្បត្តិខាងលើនេះគឺជាការចាំបាច់ ពិសេសសម្រាប់ចូលរួមក្នុងក្រុមការងារបច្ចេកទេសចម្រុះអន្តរវិស័យ ដែលទាមទារឱ្យការចូលរួមពីស្ថាប័នផ្សេងៗទៀតប្រកបដោយប្រសិទ្ធភាព ។ ក្នុងករណីពុំមានលទ្ធភាពចូលរួម គប្បីប្រើប្រាស់បណ្តាញទំនាក់ទំនងព័ត៌មានជាប្រចាំ ដើម្បីដោះស្រាយបញ្ហាក្នុងការគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ ។

៤- ក្នុងករណីគ្មានការគាំទ្រតាមរយៈកម្មវិធីសម្រាប់អនុវត្តអាទិភាពរបស់ប្រទេស និងបើគ្មានការបែងចែកពលកម្មប្រកបដោយប្រសិទ្ធភាពទេនោះ មន្ត្រីជាន់ខ្ពស់នៃក្រសួងនិងស្ថាប័នអាចស្វែងរកដៃគូអភិវឌ្ឍន៍សំខាន់ៗឱ្យជួយគាំទ្រ ដើម្បីជម្រុញការសម្របសម្រួលសកម្មភាពគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ ។ តារាងទី១០បង្ហាញថា ក្នុងវិស័យសំខាន់ទាំង៥ ដែលទទួលហិរញ្ញប្បទានច្រើនជាងគេក្នុងឆ្នាំ២០០៧នេះ ដៃគូអភិវឌ្ឍន៍សំខាន់ចំនួន៥បានផ្តល់ធនធានរហូតដល់៥០%នៃហិរញ្ញប្បទានដែលវិស័យទាំងនេះបានទទួល ។ ប្រសិនបើកិច្ចប្រឹងប្រែងបានផ្តោតខ្លាំងទៅលើការធានាប្រសិទ្ធភាព និងផលប្រយោជន៍នៃហិរញ្ញប្បទានសហប្រតិបត្តិការរបស់ដៃគូអភិវឌ្ឍន៍ នោះបញ្ហាប្រឈមក្នុងកិច្ចសម្របសម្រួលហិរញ្ញប្បទានសហប្រតិបត្តិការនឹងត្រូវបានដោះស្រាយបានមួយកម្រិត ។

តារាងទី១២- ការបែងចែកការគាំទ្រហិរញ្ញប្បទានសហប្រតិបត្តិការផ្តល់ដោយដៃគូអភិវឌ្ឍន៍ធំៗ ៥ ទៅលើវិស័យធំៗ ១០ ក្នុងឆ្នាំ២០០៧

សុខាភិបាល (រួមទាំង ហ៊ីវ/អេដស៍)		អភិបាលកិច្ច និងរដ្ឋបាល		ហេដ្ឋារចនាសម្ព័ន្ធ ដឹកជញ្ជូន		អប់រំ		អភិវឌ្ឍន៍ជនបទ	
USA	33,5	USA	16,7	China	42,3	ADB	15,3	Germany	13,8
Global Fund	21,1	China	14,8	Japan	37,9	Japan	13,1	Japan	10
UNFPA/WHO/UNICEF	13,6	Australia	11,1	ADB	8,5	Sweden	7,7	EC	7
United Kingdom	9,5	Japan	9,6	Republic of Korea	6,4	World Bank	7,3	ADB	6,3
Japan	7,4	Sweden	9,6	World Bank	1,6	EC	6,8	Australia	5,5
សរុប	85	សរុប	61,8	សរុប	96,7	សរុប	50,2	សរុប	42,6
សរុបតាមវិស័យ	152,1	សរុបតាមវិស័យ	109,9	សរុបតាមវិស័យ	99,2	សរុបតាមវិស័យ	88,2	សរុបតាមវិស័យ	71
ដៃគូធំជាងគេទាំង៥ (%)	**56%**	ដៃគូធំជាងគេទាំង៥ (%)	**56%**	ដៃគូធំជាងគេទាំង៥ (%)	**98%**	ដៃគូធំជាងគេទាំង៥ (%)	**57%**	ដៃគូធំជាងគេទាំង៥ (%)	**60%**
សហគមន៍		**កសិកម្ម**		**ព័ត៌មាន និងទូរគមនាគមន៍**		**ទឹក និងអនាម័យ**		**កម្មន្តសាល និងពាណិជ្ជកម្ម**	
China	26,2	Japan	10,3	Republic of Korea	16	ADB	5,8	EC	6
UN (UNICEF)	3,3	UN (IFAD/WFP)	8,1	China	8,8	France	4,6	USA	3,8
Australia	2,7	Australia	6,5	Japan	5,2	World Bank	3,5	Germany	2
EC	2,5	France	3,8	ADB	0,5	UN (UNICEF)	1,4	France	0,9
France	1,9	ADB	3,6	France	0,2	Japan	1	World Bank	0,8
សរុប	36,6	សរុប	32,2	សរុប	30,8	សរុប	16,4	សរុប	13,6
សរុបតាមវិស័យ	52,2	សរុបតាមវិស័យ	43,3	សរុបតាមវិស័យ	31,3	សរុបតាមវិស័យ	17,4	សរុបតាមវិស័យ	15,7
ដៃគូធំជាងគេទាំង៥ (%)	**70%**	ដៃគូធំជាងគេទាំង៥ (%)	**74%**	ដៃគូធំជាងគេទាំង៥ (%)	98%	ដៃគូធំជាងគេទាំង៥ (%)	94%	ដៃគូធំជាងគេទាំង៥ (%)	**87%**

គ- ការពង្រឹងសមត្ថភាពនៃភាពជាដៃគូ

១- អភិក្រមនៃកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ ដូចដែលបានគូសបញ្ជាក់ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ បានបញ្ជាក់ពីការផ្លាស់ប្តូរពីការគ្រប់គ្រងគម្រោងទោល ដែលជារបៀបគ្រប់គ្រងបែបបុរាណ មកការគាំទ្រដែលផ្តោតលើលទ្ធផលកម្រិតវិស័យទាំងមូលវិញ ។ ក្នុងស្មារតីនេះ តម្រូវការខាងការបណ្តុះបណ្តាលជំនាញត្រូវផ្អែកលើសមត្ថភាពគ្រប់គ្រងបច្ចេកទេសដែលមានស្រាប់ សម្រាប់កៀរគរដៃគូដទៃទៀតឱ្យចូលរួមអនុវត្តសកម្មភាពណាដែលឆ្លើយតបនឹងអាទិភាពនិងគោលដៅតាមវិស័យ ។

ភាពប៉ិនប្រសព្វក្នុងការពង្រឹងទំនុកចិត្ត ការបង្កើនការយល់ដឹងរួមគ្នា ការចូលរួមការចរចានិងពិគ្រោះយោបល់ក្នុងស្មារតីស្ថាបនា និងការបង្ហាញភាពដឹកនាំ និងភាពប៉ិនប្រសព្វក្នុងការផ្សព្វផ្សាយគោលនយោបាយជាតិប្រកបដោយប្រសិទ្ធភាព គឺជាកត្តាចម្បងសម្រាប់គ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ ដើម្បីឈានទៅសម្រេចលទ្ធផលដែលរំពឹងទុក ។ ទោះជាយ៉ាងនេះក៏ដោយ ក៏សកម្មភាពដូចបានរៀបរាប់ខាងលើនេះតម្រូវឱ្យមានការចូលរួមពីកម្រិតនយោបាយ ។

២- ក្នុងករណីដែលភាសាជាឧបសគ្គនៃប្រសិទ្ធភាពការងារ ឬធ្វើឱ្យទំនាក់ទំនងពុំបានគ្រប់ជ្រុងជ្រោយនោះ ត្រូវប្រើសេវាអ្នកបកប្រែផ្ទាល់មាត់និងការបកប្រែ ។ ចំណាយសម្រាប់ទូទាត់សេវាទាំងនេះ ត្រូវចរចាជាមួយអ្នកសម្របសម្រួលខាងដៃគូអភិវឌ្ឍន៍របស់ក្រុមការងារបច្ចេកទេសចម្រុះ ឬអាចប្រើប្រាស់ថវិកាជាកញ្ចប់របស់គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា ដែលជាជម្រើសចុងក្រោយ ។

II - អនុសាសន៍កម្រិតគោលនយោបាយសម្រាប់ដៃគូអភិវឌ្ឍន៍

ក- ការកំណត់សកម្មភាពអាទិភាពសម្រាប់ប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ

១- ស្ទាបស្ទង់អំពីការសន្យានិងអាទិភាពដោយឡែករបស់ដៃគូអភិវឌ្ឍន៍និមួយៗ សម្រាប់រៀបចំសកម្មភាពជាក់លាក់ (និងស្ថានភាពពិតប្រាកដក្នុងការអនុវត្តន៍គម្រោងរបស់ដៃគូអភិវឌ្ឍន៍) ។ ផ្អែកតាមការឆ្លើយតបរបស់ទីស្នាក់ការកណ្តាលរបស់ដៃគូអភិវឌ្ឍន៍ និងជំហរជាផ្លូវការដែលត្រូវប្រកាន់យកបន្ទាប់ពីវេទិកាកំពូលស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ ព្រមទាំងផែនការសកម្មភាពទីក្រុងអាក្រា ដៃគូអភិវឌ្ឍន៍និមួយៗនៅកម្ពុជាត្រូវបញ្ជាក់អំពីការប្តេជ្ញារបស់ទីស្នាក់ការកណ្តាលរៀងៗខ្លួន ព្រមទាំងសកម្មភាពចាំបាច់នានាសម្រាប់អនុវត្តនៅកម្ពុជា ។

២- ដៃគូអភិវឌ្ឍន៍ត្រូវបង្ហាញហេតុផលច្បាស់លាស់ អំពីការមិនអនុវត្តន៍តាមខ្លឹមសារនៃសេចក្តីថ្លែងការណ៍របស់កម្ពុជាស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការ និងការសន្យាជាសកលរបស់ខ្លួន ។ ដោយសារការប្រើប្រាស់ប្រព័ន្ធជាតិគឺជាជម្រើសទី១ នៃផែនការសកម្មភាពទីក្រុងអាក្រា ដៃគូអភិវឌ្ឍន៍ទាំងអស់ត្រូវបង្ហាញអំពីគោលជំហររួមរបស់ខ្លួន ក្នុងការវាយតម្លៃ និងការប្រើប្រាស់ប្រព័ន្ធជាតិ ទាំងកម្រិតថ្នាក់ជាតិ ទាំងកម្រិតវិស័យ ។ លើសពីនេះ ដៃគូអភិវឌ្ឍន៍ត្រូវជួយគាំទ្រដល់ការរៀបចំ និងការអនុវត្តន៍កម្មវិធីអភិវឌ្ឍន៍សមត្ថភាព ក្នុងករណីដែលត្រូវពង្រឹងប្រព័ន្ធជាតិបន្ថែមទៀត ។

៣- របាយការណ៍ស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ បានលើកឡើងអំពីគោលការណ៍ស្តីពីការបែងចែកពលកម្ម ឬការបំពេញឱ្យគ្នាទៅវិញទៅមក ។ ថ្នាក់គ្រប់គ្រងនៃស្ថាប័នដៃគូអភិវឌ្ឍន៍ត្រូវចូលរួម និងអនុវត្តគោលការណ៍ទាំងនេះ ក្នុងករណីដែលមន្ត្រីរបស់រាជរដ្ឋាភិបាលបានបញ្ជាក់អំពីគោលដៅថាពួកគេមានបំណងធ្វើសនិទានកម្ម និងកាត់បន្ថយភាពបែកខ្ញែកនៃការផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការក្នុងវិស័យរបស់ខ្លួន ។

ខ- ការធ្វើសមាហរណកម្មអាទិភាពប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ ជាមួយនឹងកម្មវិធីកំណែទម្រង់ និងការងារតាមវិស័យ

១- មន្ត្រីរបស់ដៃគូអភិវឌ្ឍន៍ត្រូវទទួលព័ត៌មានច្បាស់លាស់ពីថ្នាក់ដឹកនាំរបស់ខ្លួន អំពីបរិបទទូទៅ របៀបវារៈនៃកម្មវិធីកំណែទម្រង់របស់រាជរដ្ឋាភិបាល និងឥរិយាបទនៃការផ្តល់ការគាំទ្រដល់កម្មវិធីនៅកម្រិតថ្នាក់ជាតិ ឬកម្រិតវិស័យ ។ កិច្ចការទាំងនេះរួមមាន ÷ ការពង្រឹងប្រព័ន្ធជាតិ (ការគ្រប់គ្រងហិរញ្ញវត្ថុ លទ្ធកម្ម ការត្រួតពិនិត្យ។ល។) ការអភិវឌ្ឍន៍សមត្ថភាព (ផ្អែកតាមកម្មវិធីកំណែទម្រង់រដ្ឋបាលសារធារណៈ) ព្រមទាំងការគាំទ្រប្រព័ន្ធលាភការ ។

២- ដៃគូអភិវឌ្ឍន៍ដែលចូលរួមក្នុងក្រុមការងារបច្ចេកទេសចម្រុះ គឺជាមន្ត្រីជាន់ខ្ពស់ដែលមានសមត្ថភាពគ្រប់គ្រាន់ និងត្រូវទទួលយកភាពដឹកនាំរបស់រាជរដ្ឋាភិបាល ។ ទោះបីបានផ្តល់អនុសាសន៍នេះពីមុនហើយក៏ដោយ ក៏នៅតែមានភាពមិនទាន់យល់ច្បាស់លាស់អំពីតួនាទីរបស់ក្រុមការងារបច្ចេកទេសចម្រុះនៅឡើយ ។ តួនាទីទាំងនេះរួមមាន ÷ ការរៀបចំការពិគ្រោះយោបល់ ការផ្លាស់ប្តូរព័ត៌មានទៅវិញទៅមក ការបង្កើនជំនឿទុកចិត្តនិងការយល់ដឹងរួមគ្នា និងវេទិកាសម្រាប់រៀបចំសំណើសម្រាប់ការសម្រេចរបស់រាជរដ្ឋាភិបាល ។

៣- ក្នុងក្របខ័ណ្ឌនៃកំណែទម្រង់ គ្រប់គម្រោងនិងកម្មវិធីត្រូវរៀបចំក្នុងបរិបទនៃការគ្រប់គ្រងការផ្លាស់ប្តូរ ដែលមានភាពខុសផ្អែកពីរបៀបគ្រប់គ្រងគម្រោងទោល ដែលកន្លងមកបានផ្តោតតិចតួចទៅលើកម្មវិធីកំណែទម្រង់ថ្នាក់ជាតិ និងអាទិភាពនៃការអភិវឌ្ឍន៍សមត្ថភាពរបស់រាជរដ្ឋាភិបាល ។

គ- ការពង្រឹងសមត្ថភាពសម្រាប់ភាពជាដៃគូ

១- ស្ថាប័នដៃគូអភិវឌ្ឍន៍ត្រូវចែករំលែកព័ត៌មាន និងការប្រតិបត្តិល្អក្នុងការអនុវត្តន៍នីតិវិធីរបស់ខ្លួន សម្រាប់ពន្យល់ណែនាំដល់មន្ត្រីថ្មីរបស់ខ្លួន ។ ធ្វើដូចនេះទើបពួកគេអាចយល់ដឹងច្បាស់លាស់ពីគោលនយោបាយស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ និងការងារពាក់ព័ន្ធផ្សេងៗទៀតដែលត្រូវអនុវត្ត ។

២- ការផ្លាស់ប្តូរខាងគោលនយោបាយដែលបានចែងក្នុងផែនការសកម្មភាពទីក្រុងអាក្រា ដូចជា ការដាក់ល័ក្ខខ័ណ្ឌ និងការប្រើប្រាស់ប្រព័ន្ធជាតិ តម្រូវឱ្យដៃគូអភិវឌ្ឍន៍ពិនិត្យ និងកែសម្រួលគោលនយោបាយរបស់ខ្លួន ប្រសិនបើពួកគេមានឆន្ទៈពិតប្រាកដក្នុងការអនុវត្តន៍គោលការណ៍ទាំងនេះនៅកម្ពុជា ។ លើសពីនេះ ដៃគូអភិវឌ្ឍន៍ត្រូវមានមុខជំនាញចាំបាច់ច្បាស់លាស់ និងប្រព័ន្ធលើកទឹកចិត្តនានា ដូចជាមុខជំនាញសម្រាប់ការចរចាពហុភាគី ដែលជំនួសឱ្យល័ក្ខខ័ណ្ឌនៃគម្រោងទោល និងសម្រាប់គាំទ្រដល់កិច្ចប្រតិបត្តិការនានាស្តីពីការអភិវឌ្ឍន៍សមត្ថភាព ដែលជាលទ្ធផលនៃការសន្យាប្រើប្រាស់ប្រព័ន្ធជាតិ ។

៣- លើកទឹកចិត្តដៃគូអភិវឌ្ឍន៍ឱ្យឆ្លុះបញ្ចាំងប្រវត្តិសាស្ត្រ វប្បធម៌និងប្រពៃណីរបស់កម្ពុជា ដើម្បីឱ្យពួកគេអាចសម្របអភិក្រមការងារជាមួយនឹងសមភាគីរបស់ខ្លួន ។

III - ភារកិច្ចទទួលខុសត្រូវរួមគ្នា និងគណនេយ្យភាពទ្វេទិស

ក- ការកំណត់សកម្មភាពអាទិភាពសម្រាប់ប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ

១- អាទិភាពត្រូវកំណត់ដោយផ្អែកតាមក្របខ័ណ្ឌជាតិដែលបានឯកភាព ប៉ុន្តែ ក៏ត្រូវប្រើប្រាស់ស្របតាមល័ក្ខខ័ណ្ឌការអនុវត្តន៍ដែរ ។ ដើម្បីលើកកំពស់ភាពជាម្ចាស់របស់ប្រទេស អាទិភាពទាំងនោះត្រូវបង្ហាញ

ឱ្យច្បាស់លាស់ពីការគាំទ្រដល់ការរៀបចំប្រព័ន្ធជាតិនិងការពង្រឹងទំនាក់ទំនងរវាងការងារផែនកានីយកម្ម ការគ្រប់គ្រងហិរញ្ញវត្ថុ ការអនុវត្តន៍និងការត្រួតពិនិត្យ ។

២- នៅពេលរៀបចំបង្កើតផែនការ ឬយុទ្ធសាស្ត្រ ត្រូវយកចិត្តទុកដាក់ដល់សមត្ថភាពមន្ត្រី និងកម្រិតដឹកនាំខាងនយោបាយ ដើម្បីចៀសវាងស្ថានភាពមួយដែលសំណើដោះស្រាយមានភាពលំបាកស្មុគស្មាញ ហើយមានតែមន្ត្រីជំនាញបច្ចេកទេសមួយចំនួនតូចប៉ុណ្ណោះដែលអាចយល់ជ្រួតជ្រាបបាន ។

៣- ការកែលំអ"ការបែងចែកពលកម្ម" តម្រូវឱ្យមានសកម្មភាពរបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ។ មន្ត្រីរបស់រាជរដ្ឋាភិបាលតាមក្រសួងនិងស្ថាប័នត្រូវបញ្ជាក់ឱ្យច្បាស់អំពីបំណងរបស់ខ្លួន ក្នុងការអនុវត្តន៍ការងារនេះ ហើយអាចស្នើមកគណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជាឱ្យជួយសម្រួលការវិភាគ និងការអនុវត្តន៍គោលការណ៍ណែនាំ ប្រសិនបើចាំបាច់ ។

ខ- ការធ្វើសមាហរណកម្មអាទិភាពនៃប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការទៅក្នុងកម្មវិធីកំណែទម្រង់ និងការងារតាមវិស័យ

១- ប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការគឺជាការងារមួយផ្នែករបស់មន្ត្រីនៃរាជរដ្ឋាភិបាល និងមន្ត្រីរបស់ដៃគូអភិវឌ្ឍន៍ ហើយមិនត្រូវចាត់ទុកការងារនេះជាការងាររបស់មន្ត្រីជំនាញមួយចំនួនតូចឡើយ ។ រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍គួរសាកល្បងអនុវត្តគោលការណ៍ស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ ទាំងនៅកម្រិតសកល ទាំងនៅកម្រិតជាតិ ដើម្បីយល់ដឹងអំពីភាពសមស្របនៃគោលការណ៍ទាំងអស់នេះ ។

២- ក្នុងពេលអនុវត្តអភិក្រមគ្រប់គ្រងទូទាំងវិស័យ យើងត្រូវពិនិត្យឱ្យលើសពីការរៀបចំយន្តការរួមសម្រាប់ការងារផែនកានីយកម្ម ដែលការងារនេះគ្រាន់តែឆ្លុះបញ្ចាំងអំពីហិរញ្ញប្បទានគ្រប់ប្រភព ទាំងធនធានក្នុងស្រុក ទាំងធនធានបរទេសតែប៉ុណ្ណោះ ។ យើងត្រូវរៀបចំផែនការប្រតិបត្តិការប្រចាំឆ្នាំ ដែលជាផែនការគ្រប់ជ្រុងជ្រោយ ដោយត្រូវបញ្ចូលការអភិវឌ្ឍន៍សមត្ថភាពផងដែរ ។ អនុវត្តតាមរបៀបនេះ ទើបអាចបង្កើតមូលដ្ឋានរឹងមាំសម្រាប់បង្កើនការប្រើប្រាស់ប្រព័ន្ធជាតិនាពេលអនាគត ។

៣- រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ត្រូវដោះស្រាយអំពីកិច្ចដំណើរការមួយចំនួន ដូចជាយន្តការនៃកិច្ចពិគ្រោះយោបល់ ប្រព័ន្ធលាភការ ការកសាងសមត្ថភាពនិងបញ្ហាកំណែទម្រង់នានានៅកម្រិតថ្នាក់ដឹកនាំប្រសើរជាងដោះស្រាយនៅកម្រិតបច្ចេកទេស ។ ការបន្តដោះស្រាយតាមបែបបច្ចេកទេសទៅលើបញ្ហាដែលមិនមែនមានលក្ខណៈបច្ចេកទេស នឹងនាំឱ្យខ្ជះខ្ជាយធនធាន ព្រមទាំងបង្កើតការលំបាកក្នុងការរក្សាភាពជាដៃគូសម្រាប់កិច្ចសហប្រតិបត្តិការ ។

គ- ការពង្រឹងសមត្ថភាពនៃភាពជាដៃគូ

១- ជំនឿទុកចិត្ត ការយោគយល់គ្នា កិច្ចពិគ្រោះយោបល់ប្រកបដោយលទ្ធផល និងប្រសិទ្ធភាពនៃភាពជាដៃគូ មិនមែនជាការវិនិយោគតែម្តងនោះទេ ពិសេសនៅពេលដែលមានការផ្លាស់ប្តូរមន្ត្រីពាក់ព័ន្ធញឹកញាប់ ។ ទាំងរាជរដ្ឋាភិបាល ទាំងដៃគូអភិវឌ្ឍន៍ចាំបាច់ត្រូវបន្តវិនិយោគសម្រាប់កសាងទំនុកចិត្ត ការយោគយល់គ្នា ដើម្បីឈានទៅសម្រេចឱ្យបានលទ្ធផលដែលរំពឹងទុក ។ ផ្អែកតាមហេតុផលខាងលើនេះ

នៅឆ្នាំ២០០៩ បណ្តាញក្រុមការងារបច្ចេកទេសចម្រុះនឹងពង្រីកបន្ថែមទៀត សម្រាប់ផ្តល់ការគាំទ្រដល់ប្រធានក្រុមការងារបច្ចេកទេសចម្រុះ និងអ្នកសម្របសម្រួលខាងដៃគូអភិវឌ្ឍន៍ ព្រមទាំងសម្រាប់ជួយពង្រឹងយន្តការនៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ។

២- របាយការណ៍នៃការត្រួតពិនិត្យឯករាជ្យស្តីពីការវាយតម្លៃប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ និងរបាយការណ៍ការសិក្សាស្តីពីកិច្ចសហប្រតិបត្តិការបច្ចេកទេសបានបញ្ជាក់ថា ភាពដឹកនាំដ៏រឹងមាំរបស់រាជរដ្ឋាភិបាល គឺជាមូលដ្ឋានសម្រាប់រៀបចំអភិក្រមនៃកិច្ចអភិវឌ្ឍន៍សមត្ថភាពមួយ ដែលឆ្លើយតបនឹងគោលជំហររបស់រាជរដ្ឋាភិបាល ។ កិច្ចសហប្រតិបត្តិការក្នុងការងារដែលបានឯកភាពនឹងក្លាយជាមូលដ្ឋានគ្រឹះសម្រាប់ពិគ្រោះយោបល់ ហើយនេះជាកាតាលីករសម្រាប់ជម្រុញវឌ្ឍនភាពនៅក្នុងវិស័យដទៃទៀត ។

៣- ការងារបន្តរបស់ក្រុមការងារបច្ចេកទេសចម្រុះ និងគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ គឺការកំណត់ទស្សនទានមួយសម្រាប់កំណត់និងឯកភាពសូចនាករតាមដានរួមគ្នា ព្រមទាំងត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តន៍សូចនាករទាំងនេះ ។ បច្ចុប្បន្ននេះ យើងមានសូចនាករតាមដានរួមគ្នាដែលមានលក្ខណៈចម្រុះគ្នា ដោយមានសូចនាករខ្លះបានរំលេចអំពីលទ្ធផលរំពឹងទុក និងសូចនាករខ្លះទៀតរំលេចអំពីកិច្ចដំណើរការ ។ ប្រការនេះបានធ្វើឱ្យមានការលំបាកក្នុងការវាយតម្លៃអំពីទំនាក់ទំនងរវាងសកម្មភាពដែលត្រូវអនុវត្ត ជាមួយនឹងលទ្ធផលដែលរំពឹងទុក ។

ការរួមគ្នាត្រួតពិនិត្យការអនុវត្តន៍គោលនយោបាយ

ការគ្រប់គ្រងនិងត្រួតពិនិត្យការអនុវត្តន៍ផែនការសកម្មភាពស្តីពីសុខដុមនីយកម្ម ការតម្រឹមនិងលទ្ធផល និងសូចនាករសម្រាប់តាមដានរួមគ្នា ត្រូវបានធ្វើជាប្រចាំតាមរយៈយន្តការនៃគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ហើយអនុសាសន៍ទាំងឡាយក្នុងរបាយការណ៍នេះក៏បានក្លាយជាសូចនាករសម្រាប់តាមដានរួមគ្នាផងដែរ ។ អនុសាសន៍សំខាន់ទាំងនេះ ទោះបីជាមានលក្ខណៈទូទៅនៅឡើយក៏ដោយ ក៏ត្រូវចាត់ទុកថាជាជំហានចាំបាច់ចំពោះមុខដើម្បីឈានទៅកំណត់សកម្មភាពជាក់លាក់សម្រាប់វិស័យនិមួយៗ ។ សូចនាករសម្រាប់តាមដានរួមគ្នាដែលបានលើកឡើងនេះ មានដូចតទៅ ៖

១- ផ្អែកតាមយុទ្ធសាស្ត្រចតុកោណ- ដំណាក់កាលទី២ របាយការណ៍ពាក់កណ្តាលអាណត្តិនៃការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ផែនការសកម្មភាពស្តីពីសុខដុមនីយកម្ម ការតម្រឹមនិងលទ្ធផល សេចក្តីថ្លែងការណ៍កម្ពុជាស្តីពីការបង្កើនប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ ការវាយតម្លៃប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ ដែលរួមមានការស្វ័យវាយតម្លៃរបស់ដៃគូអភិវឌ្ឍន៍ និងក្រុមការងារបច្ចេកទេសចម្រុះ និងរបាយការណ៍ត្រួតពិនិត្យឯករាជ្យ អនុសាសន៍លើរបាយការណ៍ស្តីពីការបង្កើនប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការឆ្នាំ២០០៨ និងការពិភាក្សាក្នុងវេទិកាសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា ព្រមទាំងផែនការសកម្មភាពទីក្រុងអាក្រា រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍បានសន្យារួមគ្នាដូចតទៅ ៖

ក- រាជរដ្ឋាភិបាលនឹងពិភាក្សាផ្ទៃក្នុងកម្រិតខ្ពស់ ដើម្បីកំណត់សកម្មភាពជាក់ស្តែង ដែលអាចសម្រេចបាននិងអាចត្រួតពិនិត្យបាន ទាំងកម្រិតជាតិ ទាំងកម្រិតវិស័យ ដើម្បីជម្រុញឱ្យមានវឌ្ឍនភាពក្នុងការអនុវត្តន៍អាទិភាព និងការប្តេជ្ញាបង្កើនប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ ។

ខ- ដៃគូអភិវឌ្ឍន៍ត្រូវពិភាក្សាផ្ទៃក្នុង និងត្រូវពិភាក្សាជាមួយនឹងទីស្នាក់ការកណ្តាលរៀងៗខ្លួន (ឈរលើស្មារតីនៃវេទិកាកំពូលស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ) និងជាមួយដៃគូអភិវឌ្ឍន៍ផ្សេងទៀត ដើម្បីកំណត់សកម្មភាពជាក់ស្តែងដែលអាចសម្រេចបាន និងអាចត្រួតពិនិត្យបាន ដើម្បីជម្រុញឱ្យមានវឌ្ឍនភាពក្នុងការអនុវត្តន៍អាទិភាព និងការប្តេជ្ញាបង្កើនប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ ។

គ- រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ត្រូវចូលប្រជុំរួមគ្នានាត្រីមាសទី១ឆ្នាំ២០០៩ ដើម្បីពិភាក្សានិងកំណត់សកម្មភាពមួយចំនួនសម្រាប់អនុវត្ត ។ សកម្មភាពទាំងនេះត្រូវមានភាពជាក់ស្តែង អាចវាស់វែង និងអាចតាមដានបាន ដោយផ្អែកតាមផែនការសកម្មភាពស្តីពីសុខដុមនីយកម្ម ការតម្រឹម និងលទ្ធផល ព្រមទាំងការប្តេជ្ញានានាដែលបានឯកភាពក្នុងសេចក្តីថ្លែងការណ៍កម្ពុជា ។

២- គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (គ.ជ.ន/ក.អ.ក) ក្នុងតួនាទីជាចំណុចប្រមូលផ្តុំរបស់រាជរដ្ឋាភិបាល នឹងសម្របសម្រួលដំណើរការនេះ ដោយសហការជាមួយនឹងក្រុមការងារបច្ចេកទេសចម្រុះស្តីពីភាពជាដៃគូនិងសុខដុមនីយកម្ម ។ សកម្មភាពអាទិភាពដែលបានឯកភាពគ្នានេះ នឹងត្រូវបង្ហាញក្នុងកិច្ចប្រជុំនៃគណៈកម្មាធិការសម្របសម្រួលរវាងរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ហើយសកម្មភាពដែលបានឯកភាពទាំងនេះនឹងត្រូវបញ្ចូលទៅក្នុងតារាងសូចនាករសម្រាប់តាមដានរួមគ្នាឆ្នាំ២០០៩-២០១០ ដោយចាត់ទុកសកម្មភាពទាំងនេះគឺជាការប្តេជ្ញារួមគ្នា សម្រាប់អនុវត្តផែនការសកម្មភាពស្តីពីសុខដុមនីយកម្ម ការតម្រឹមនិងលទ្ធផល និងការប្តេជ្ញាដែលបានចែងក្នុងសេចក្តីថ្លែងការណ៍កម្ពុជាស្តីពីការបង្កើនប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ ។

- - - - - - - -

ជំពូក ៦

សេចក្ដីសន្និដ្ឋាន

របាយការណ៍ស្ដីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រត្តិបត្តិការនៅកម្ពុជាឆ្នាំ២០០៨ ពុំមានគោលដៅដើម្បីបង្ហាញពីទ្រឹស្ដីដើម្បីកែលំអការគ្រប់គ្រង និងការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការនោះទេ ។ ផ្ទុយមកវិញ របាយការណ៍នេះបានបង្ហាញអំពីសក្ខីភាពជាក់ស្ដែង ទាំងខាងបរិមាណ ទាំងខាងគុណភាព សម្រាប់បង្ហាញអំពីកត្តាជោគជ័យនានា និងបណ្ដាបញ្ហាប្រឈមដែលនៅសេសសល់ បន្ទាប់ពីវេទិកាសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី១មក ។ របាយកាណ៍នេះបានផ្ដែកលើទស្សនៈដ៏រឹងមាំ ។ ការស្រាវជ្រាវ និងការវិភាគនានាត្រូវបានផ្សារភ្ជាប់ទៅនឹងទិដ្ឋភាពខាងផ្នែកគោលនយោបាយសម្រាប់ស្វែងរកដំណោះស្រាយ ។ កិច្ចប្រឹងប្រែងក្នុងការផ្សារភ្ជាប់ទំនាក់ទំនងរវាងប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការនិងកិច្ចអភិវឌ្ឍន៍ដោយផ្ដោតលើលទ្ធផលតម្រូវឱ្យរាជរដ្ឋាភិបាលប្រើប្រាស់សក្ខីភាពជាក់ស្ដែងសម្រាប់បង្ហាញអំពីសារជាតិនៃទំនាក់ទំនងនេះ ហើយបន្ទាប់មកប្រែក្លាយទំនាក់ទំនងនេះឱ្យក្លាយជាសកម្មភាពជាក់ស្ដែងនិងសមស្រប នៅកម្រិតគោលនយោបាយ ដែលអាចឆ្លុះបញ្ចាំងអំពីលទ្ធផលបាន ។ ប៉ុន្ដែ បណ្ដាសកម្មភាពទាំងនេះមិនត្រូវអនុវត្ត ដោយកាត់ផ្ដាច់ចេញពីបរិការណ៍កម្ពុជាឡើយ ។ អនុសាសន៍ភាគច្រើននៃរបាយការណ៍នេះមានលក្ខណៈទូទៅប៉ុណ្ណោះ ។ ក្នុងស្មារតីនេះ សូចនាករតាមដានរួមគ្នាដែលបានស្នើឡើងសម្រាប់អនុវត្តអនុសាសន៍ទាំងនេះ នឹងក្លាយជាមូលដ្ឋានសម្រាប់កំណត់សកម្មភាពជាក់ស្ដែងតាមវិស័យនិមួយៗ និងសម្រាប់ត្រួតពិនិត្យតាមដានដើម្បីធានាថា សកម្មភាពដែលបានដាក់ឱ្យអនុវត្តទាំងនេះ មានភាពត្រឹមត្រូវ មានខ្លឹមសារគ្រប់គ្រាន់ និងមានសារៈប្រយោជន៍ ។

«យើងត្រូវពន្លឿនល្បឿនអនុវត្តបន្ថែមទៀត» គឺជាទស្សនៈដែលប្រសូត្រចេញមកពីវេទិកាកំពូលនៅទីក្រុងអាក្រានាពេលថ្មីៗកន្លងមកនេះ ។ ទោះបីបញ្ហាប្រឈមអាចមានសភាពខុសប្លែកពីប្រទេសមួយទៅប្រទេសមួយក៏ដោយ ក៏បញ្ហានេះមានភាពត្រឹមត្រូវក្នុងបរិការណ៍កម្ពុជា ។ ធាតុពិត «យើងត្រូវពន្លឿនល្បឿនអនុវត្តបន្ថែមទៀត» នេះ ក៏ជាប្រធានបទគោលនៃរបាយការណ៍ស្ដីពីហិរញ្ញប្បទានសហប្រតិបត្តិការឆ្នាំ២០០៧កន្លងមកផងដែរ ។ ការទាមទារឱ្យមានកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀតនេះ តម្រូវឱ្យយើងត្រួតពិនិត្យមើលឱ្យបានល្អិតល្អន់ជាមុនសិនដើម្បីធានាអំពីភាពត្រឹមត្រូវនិងសមស្របនូវបណ្ដាសកម្មភាពជាក់ស្ដែងដែលត្រូវដាក់ឱ្យអនុវត្ត ។ តើនេះគ្រាន់តែតម្រូវឱ្យយើងបន្ដខិតខំប្រឹងប្រែងបន្ថែមទ្វេដងឬ? ។ នេះមានន័យថា យើងមិនបានដកស្រង់បទពិសោធន៍កម្រិតគោលនយោបាយកន្លងមកឡើយ ។ ការសម្របតាមក្របខ័ណ្ឌសកលលោក ហើយប្រកាន់យកសេណារីយ៉ូបន្ថែមបន្ទាប់ពីសេចក្ដីថ្លែងការណ៍ទីក្រុងប៉ារីសក្នុងបរិការណ៍កម្ពុជា ព្រមទាំងប្រើប្រាស់សក្ខីភាពជាក់ស្ដែង មិនមែនមាន

ន័យថា យើងអាចគ្រប់គ្រងកិច្ចការមានប្រសិទ្ធភាពជាងមុនបានឡើយ ។ ចុងបញ្ចប់ យើងក៏មិនអាចពិចារណាអំពីជម្រើសក្នុងការបង្កើត និងកំណត់គោលដៅថ្មីសម្រាប់គ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ ដើម្បីអនុវត្តសេណារីយ៉ូក្រោយសេចក្តីថ្លែងការណ៍ទីក្រុងប៉ារីស ដោយច្រានចោលសញ្ញាណនៃប្រសិទ្ធភាព និងភាពជាដៃគូនោះបានឡើយ ។

សក្ខីភាពជាក់ស្តែង និងអនុសាសន៍កម្រិតគោលនយោបាយដែលបានបង្ហាញក្នុងរបាយការណ៍នេះ បានបញ្ជាក់ថា មាតិកណ្តាលគឺជាមាតិកាដ៏ត្រឹមត្រូវមួយ ។«យុទ្ធសាស្ត្រចតុកោណ- ដំណាក់កាលទី២» ក៏បានបញ្ជាក់រួចហើយថា រាជរដ្ឋាភិបាលបានប្តេជ្ញាអនុវត្ត «ផែនការសកម្មភាពទីក្រុងអាក្រា» ដែលឆ្លុះបញ្ចាំងអំពីការឯកភាពគ្នាដ៏រឹងមាំក្នុងការបន្តអនុវត្តន៍អភិក្រមស្តីពីភាពជាដៃគូ ។ ការអនុវត្តន៍នូវការប្តេជ្ញានេះតម្រូវឱ្យ ÷

ក- ផ្តោតការយកចិត្តទុកដាក់ជាសំខាន់លើភាពដឹកនាំ ។

ខ- អនុវត្តសាកល្បង ដើម្បីយល់ច្បាស់អំពីភាពសមស្របនៃគោលការណ៍មួយចំនួនស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ ។

គ- ធ្វើសមាហរណកម្មគោលការណ៍ស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ ទៅក្នុងតួនាទីរបស់ក្រសួងនិងស្ថាប័នរបស់រាជរដ្ឋាភិបាល ។

នេះមានន័យថា ការពិភាក្សាជុំវិញបញ្ហាដែលទាក់ទងនឹងរបៀបវារៈស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ ត្រូវផ្តោតការចិត្តទុកដាក់ទៅលើ ÷

១- លាភការនិងការកសាងសមត្ថភាពក្នុងក្របខ័ណ្ឌនៃកំណែទម្រង់រដ្ឋបាលសាធារណៈ ។

២- ផែនការនីយកម្ម និងការកត់ត្រាឱ្យច្បាស់លាស់អំពីបរិមាណផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការ គឺជាភារកិច្ចស្នូលរបស់ក្រសួងផែនការ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

៣- ការអនុវត្តន៍អភិក្រមគ្រប់គ្រងទូទាំងវិស័យឱ្យស្របតាមបរិការណ៍ និងស្ថានភាពជាក់ស្តែងរបស់វិស័យ ។

លើសពីនេះ ក៏តម្រូវឱ្យអនុវត្តអភិក្រមផ្សេងទៀតសម្រាប់បង្កើនប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការក្នុងការដ្ឋានកំណែទម្រង់អន្តរវិស័យ ដែលមិនមែនជាការដោះស្រាយចង្អោមបញ្ហាតូចចង្អៀតមួយចំនួននោះឡើយ ។ នេះមានន័យថា ក្នុងកម្មវិធីកំណែទម្រង់ទាំងអស់ យើងត្រូវយល់ដឹង និងគិតគូរឱ្យច្បាស់អំពីជវភាពភាពស្មុគស្មាញ ហានិភ័យ និងការប្រែប្រួលនៃបណ្តាបញ្ហាប្រឈមឱ្យបានច្បាស់លាស់ មុនពេលកំណត់សកម្មភាពចាំបាច់ និងគោលដៅដែលត្រូវអនុវត្តឱ្យបានសម្រេច ។

នាពេលអនាគត អភិក្រមនេះទាមទារឱ្យមានការយល់ដឹងយ៉ាងពេញលេញ ហើយដំណោះស្រាយក្នុងកម្រិតបច្ចេកទេស អាចជួយឱ្យសម្រេចគោលដៅសម្រាប់ប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការបានមួយផ្នែកតែប៉ុណ្ណោះ ។ ដំណោះស្រាយក្នុងកម្រិតបច្ចេកទេសនេះ មិនអាចជួយឱ្យសម្រេចបានពេញលេញនូវគោលដៅនៃកិច្ចអភិវឌ្ឍន៍ដោយផ្តោតលើលទ្ធផលបានឡើយ ។ របាយការណ៍ត្រួតពិនិត្យឯករាជ្យបានរំលេចឱ្យឃើញថា កត្តានយោបាយ និងភាពដឹកនាំនៃកិច្ចអភិវឌ្ឍន៍ដោយផ្តោតលើភាពជាដៃគូ គឺជាកត្តាមានសារៈសំខាន់កាន់តែធំធេងឡើងៗ ។ ផ្អែកតាមស្មារតីនេះ គោលដៅចម្បងនៃអនុសាសន៍ដែលបានលើកឡើងក្នុងរបាយការណ៍នេះ ហើយដែល

បានផ្តោតទៅលើការកែលំអទំនាក់ទំនងនៃការផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការ គឺការកំណត់ជំហានបន្ទាប់ដែលត្រូវអនុវត្តរួមគ្នា ។

ក្នុងខណៈពេលដែលរបៀបវារៈស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការនៅតែជាបញ្ហាប្រឈមនៅឡើយ ការវិភាគជាច្រើនបានបង្ហាញថា បរិស្ថានកម្ពុជាបានផ្តល់លក្ខណៈអនុគ្រោះជាច្រើនដល់ការពន្លឿនល្បឿននៃការអនុវត្តន៍សកម្មភាព ដើម្បីពង្រឹងការគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការនៅកម្ពុជាឱ្យកាន់តែប្រសើរឡើង ។ ដោយវេទិកាកំពូលនៅទីក្រុងអាក្រាបានកត់សំគាល់ឃើញអំពីកង្វះកាលានុវត្តភាពនៅកម្រិតសកល ដៃគូអភិវឌ្ឍន៍ត្រូវប្រឹងប្រែងបន្ថែមទៀត ក្នុងការប្រែក្លាយការប្តេជ្ញារបស់ខ្លួនឱ្យទៅជាសកម្មភាពជាក់ស្តែងឱ្យបានច្រើនជាងរាជរដ្ឋាភិបាល ។ សេចក្តីសន្និដ្ឋាននៃរបាយការណ៍ត្រួតពិនិត្យឯករាជ្យ ដែលជាផ្នែកមួយនៃការវាយតម្លៃប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ បានបង្ហាញថា កម្ពុជាអាចបង្កើនវឌ្ឍនភាពបន្ថែមទៀត ហើយអាចបង្ហាញអំពីភាពដឹកនាំរបស់រាជរដ្ឋាភិបាល ក្នុងកំណែទម្រង់ហិរញ្ញប្បទានសហប្រតិបត្តិការលើទិដ្ឋភាពជាច្រើននៅលើឆាកអន្តរជាតិ ។ បណ្តាស្នាដៃដែលសម្រេចបានកន្លងមកនៅកម្ពុជា គឺជាវិញ្ញាសារសាកល្បងសម្រាប់ជម្រុញឱ្យដៃគូអភិវឌ្ឍន៍កែប្រែទម្លាប់អនុវត្តសកម្មភាពរបស់ខ្លួន ដើម្បីរួមចំណែកដល់កិច្ចអភិវឌ្ឍន៍ដោយផ្តោតលើលទ្ធផល ។

\- - - - - - - -

សុក្រិត្យភាពនៃទិន្នន័យ

ការសំអាត និងការធ្វើសុពលភាពទិន្នន័យ

ទិន្នន័យដែលបានប្រើប្រាស់សម្រាប់ធ្វើការវិភាគនៅក្នុងរបាយការណ៍ស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការឆ្នាំ២០០៨នេះ មានគុណភាពប្រសើរជាងឆ្នាំ២០០៧ ។ ការបើកវគ្គបណ្តុះបណ្តាល និងការពិគ្រោះយោបល់ជាមួយនឹងមន្ត្រីនៃរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ បានពង្រឹងសមត្ថភាពសម្រាប់រៀបចំរបាយការណ៍នេះ ។ មន្ត្រីរបស់ ក.អ.ក/គ.ជ.នា បានទទួលការបណ្តុះបណ្តាលច្បាស់លាស់អំពីវិធីសាស្ត្រធ្វើសុពលភាពទិន្នន័យ ដែលអាចជួយពង្រឹងសមត្ថភាពរបស់ខ្លួនក្នុងការគ្រប់គ្រងព័ត៌មានបានមួយកម្រិតបន្ថែមទៀត ។ ទិន្នន័យដែលត្រូវបានប្រើប្រាស់ក្នុងរបាយការណ៍នេះ ត្រូវបានធ្វើសុពលភាពក្នុងពេលដំណើរការនៃការធ្វើអង្កេតការស្តីពីការអនុវត្តន៍សេចក្តីថ្លែងការណ៍ទីក្រុងប៉ារីសឆ្នាំ២០០៨ ហើយក៏បានធ្វើសុពលភាពម្តងទៀតនៅពេលរៀបចំរបាយការណ៍នេះ ដែលអាចចាត់ទុកទិន្នន័យនេះមានគុណភាពល្អប្រសើរ ។

រចនាសម្ព័ន្ធនៃប្រព័ន្ធទិន្នន័យស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការនៅកម្ពុជា

ប្រព័ន្ធទិន្នន័យស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការនៅកម្ពុជា ជាប្រព័ន្ធមួយដែលត្រូវបានបង្កើតឡើងដោយអ្នកឯកទេសជាតិ ។ រចនាសម្ព័ន្ធនៃប្រព័ន្ធទិន្នន័យត្រូវបានកែសម្រួលឡើងវិញ ស្របតាមតម្រូវការរបស់រាជរដ្ឋាភិបាល និងអ្នកប្រើប្រាស់ដទៃទៀត ។ បន្ទាប់ពីរៀបចំរបាយការណ៍ស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការនាឆ្នាំ២០០៧មក ក.អ.ក/គ.ជ.នា បានកែលំអរចនាសម្ព័ន្ធនៃប្រព័ន្ធព័ត៌មាន ដូចជា : ការផ្តល់លេខរៀងសម្រាប់បណ្តាគម្រោងនៃកម្មវិធីវិនិយោគសាធារណៈ ការចងក្រងគម្រោងដែលផ្តល់ការគាំទ្រតាមទម្រង់សហហិរញ្ញប្បទាន និងការកែលំអទម្រង់ធ្វើរបាយការណ៍ស្តីពីវឌ្ឍនភាពជាដើម ។

កំណត់សំគាល់អំពីទិន្នន័យ និងការប្រមូលទិន្នន័យ

តួលេខសម្រាប់ឆ្នាំ២០០៦ត្រូវបានកែសម្រួលយ៉ាងច្រើន ដោយសារការបញ្ចូលធនធានដែលបានមកពីការលុបបំណុលរបស់អង្គការមូលនិធិរូបិយវត្ថុអន្តរជាតិ និងការកែសម្រួលនិយមន័យនៃធនធានដែលមិនទាន់បែងចែកឱ្យវិស័យណាមួយច្បាស់លាស់ ។ ចំពោះទិដ្ឋភាពអវិជ្ជមានវិញ ដៃគូអភិវឌ្ឍន៍មួយចំនួនមិនបានផ្តល់ទិន្នន័យ ដែលនាំឱ្យធនធានសរុបមាននិន្នាការថយចុះ ដូចជា ប្រទេសន័រវេស អៀកឡង់ ឥណ្ឌា ថៃ ស្ថាប័ន GAVI និង OPEC ។ លើសពីនេះ ដៃគូអភិវឌ្ឍន៍មួយចំនួនទៀតមិនបានផ្តល់ព័ត៌មានស្តីពីធនធានរបស់ខ្លួនសម្រាប់អនុវត្តគម្រោងកម្រិតតំបន់ ឬធនធានដែលផ្តល់ត្រង់ពីទីស្នាក់ការកណ្តាលទៅឱ្យអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិនៅឡើយ ។ តួលេខនៃការផ្តល់ហិរញ្ញប្បទានដែលបានកត់ត្រានៅក្នុងប្រព័ន្ធទិន្នន័យកម្ពុជា គឺជាតួលេខស្តីពីការផ្ទេរមូលនិធិទៅកាន់គណនីរបស់គម្រោង ។ ក្នុងស្មារតីនេះ តួលេខដែលបានកត់ត្រាក្នុងប្រព័ន្ធទិន្នន័យកម្ពុជា មិនត្រូវចាត់ទុកថាជាធនធានដែលបានប្រើប្រាស់ជាក់ស្តែងប្រចាំឆ្នាំរាយការណ៍និមួយៗឡើយ ។

ការប្រៀបធៀបនឹងទិន្នន័យក្នុងប្រព័ន្ធរាយការណ៍ពីឥណទានរបស់អង្គការសម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និង អភិវឌ្ឍន៍

ព័ត៌មានដែលមាននៅក្នុងប្រព័ន្ធទិន្នន័យស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការនៅកម្ពុជា បានបញ្ចូលតួលេខស្តីពីធនធានផ្ទាល់របស់អង្គការក្រៅរដ្ឋាភិបាល ដែលធនធាននេះមិនត្រូវបានចាត់ទុកថាជាហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ឡើយ (ប្រមាណ៥០លានដុល្លាក្នុងឆ្នាំ២០០៦) ។ ព័ត៌មានដែលមាននៅក្នុងប្រព័ន្ធទិន្នន័យស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការនៅកម្ពុជា មានភាពលំអិតជាងព័ត៌មាន ដែលមាននៅក្នុងប្រព័ន្ធទិន្នន័យរបស់អង្គការដើម្បីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងអភិវឌ្ឍន៍

ដែលកត់ត្រាតែធនធានផ្តល់ដោយប្រទេសនិងស្ថាប័នដែលជាសមាជិកគណៈកម្មាធិការហិរញ្ញប្បទានសហប្រតិបត្តិការ និង ដៃគូមួយចំនួនតូចថែមទៀតតែប៉ុណ្ណោះ ។ អង្គការដើម្បីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងអភិវឌ្ឍន៍បានកត់ត្រាធនធានប្រមាណ ៤១៣លានដុល្លានៅក្នុងឆ្នាំ២០០៦ ធៀបនឹងធនធាន៦៦៣លានដុល្លា ដែលបានកត់ត្រាក្នុងប្រព័ន្ធទិន្នន័យស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការកម្ពុជា (មិនរាប់បញ្ចូលតួលេខរបស់អង្គការក្រៅរដ្ឋាភិបាល) ។

ភាពខុសគ្នារវាងទិន្នន័យហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ផ្លូវការរបស់កម្ពុជានិងទិន្នន័យ របស់អង្គការដើម្បីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងអភិវឌ្ឍន៍

	២០០៦ (DAC CRS)	ទិន្នន័យកម្ពុជា ២០០៦ (ទិន្នន័យឆ្នាំ២០០៧)	ទិន្នន័យកម្ពុជា ២០០៦ (ទិន្នន័យឆ្នាំ២០០៨)	ទិន្នន័យ DAC - ទិន្នន័យកម្ពុជា	ទិន្នន័យកម្ពុជា (ទិន្នន័យឆ្នាំ២០០៨សំរាប់ឆ្នាំ២០០៦) - ទិន្នន័យកម្ពុជា (ទិន្នន័យឆ្នាំ២០០៧ សំរាប់ឆ្នាំ២០០៦)
ទីភ្នាក់ងារអង្គការសហប្រជាជាតិ	5,17	47,90	54,00	-48,83	6,1
ធនាគារពិភពលោក	..	26,6	24,5	-24,50	-2,1
មូលនិធិរូបិយវត្ថុអន្តរជាតិ				-83,50	83,3
ធនាគារអភិវឌ្ឍន៍អាស៊ី	..	62	67,5	-67,50	5,5
មូលនិធិសកលប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍ របេង និងគ្រុនចាញ់	22,18	22,2	21,9	0,28	-0,3
អូទ្រីស	0,02	0	0	0,02	0
បែលហ្សិក	11,96	7,3	7,3	4,66	0
ដាណឺម៉ាក	23,00	6,1	4,1	18,90	-2
ហ្វាំងឡង់	3,11	3,5	4,5	-1,39	1
បារាំង	28,47	22	21,8	6,67	-0,2
អាល្លឺម៉ង់	27,64	30,5	32,4	-4,76	1,9
អៀកឡង់	4,19	0	0	4,19	0
លុចហ្សំបួរ	0,20	0	0	0,20	0
ហូល្លង់	2,02	0,1	0,1	1,92	0
ព័រទុយហ្គាល់	0,02	0	0	0,02	0
អេស្ប៉ាញ	1,97	0	2,8	-0,83	2,8
ស៊ុយអែត	16,86	16,1	16	0,86	-0,1
ចក្រភពអង់គ្លេស	22,48	20	20,7	1,78	0,7
សហភាពអឺរ៉ុប	28,77	35,2	46,5	-17,73	11,3
អូស្ត្រាលី	33,10	17,3	22,5	10,60	5,2
កាណាដា	6,90	5,7	7,9	-1,00	2,2
ជប៉ុន	107,09	100,5	103,7	3,39	3,2
ណូវែលហ្សេឡង់	3,14	1,5	1,7	1,44	0,2
ន័រវេស	3,21	0	0	3,21	0
ស្វីស	2,90	2,5	2,4	0,50	-0,1
សហរដ្ឋអាមេរិក	59,50	51	51	8,50	0
សរុប	**413,92**	**478,00**	**513,30**	-182,88	118,6

កំណត់សំគាល់ : ទិន្នន័យខាងលើនេះបានដកស្រង់ចេញពីប្រព័ន្ធរាយការណ៍ពីឥណទានរបស់អង្គការសម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ នាថ្ងៃទី១០ ខែតុលា

តារាងខាងលើបានបង្ហាញអំពីភាពខុសគ្នារវាងទិន្នន័យរបស់គណៈកម្មាធិការហិរញ្ញប្បទានសហប្រតិបត្តិការ និង ទិន្នន័យរបស់កម្ពុជា សម្រាប់ឆ្នាំ២០០៦ និងឆ្នាំ២០០៧ ដែលត្រូវបានកែសម្រួលក្នុងឆ្នាំ២០០៨នេះ ។ យើងអាចសន្និដ្ឋានបានថា

តួលេខដែលបានកត់ត្រាក្នុងប្រព័ន្ធទិន្នន័យស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការកម្ពុជាសម្រាប់ឆ្នាំ២០០៧ មានគុណភាពប្រសើរជាងមុន និងមានលក្ខណៈគ្រប់គ្រាន់សម្រាប់ជាមូលដ្ឋានក្នុងការធ្វើវិភាគនៅក្នុងរបាយការណ៍នេះ ដោយគួបផ្សំជាមួយនឹងសក្ខីភាពជាក់ស្តែងដទៃទៀត ។ តួលេខសម្រាប់ឆ្នាំ២០០៨គឺជាតួលេខបណ្តោះអាសន្ន ។ ចំណែកឯតួលេខប៉ាន់ស្មានសម្រាប់ឆ្នាំ២០០៩ និង២០១០ បានបញ្ជាក់អំពីវឌ្ឍនភាព និងកិច្ចខិតខំប្រឹងប្រែងរបស់ដៃគូអភិវឌ្ឍន៍ ក្នុងការគាំទ្រដំណើការរៀបចំផែនការ និងថវិការជ្ជ ។

\- - - - - - - -

ឧបសម្ព័ន្ធ

ទិន្នន័យបន្ថែមស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការ

២.១ ប៉ាន់ស្មានការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការតាមប្រភពដៃគូអភិវឌ្ឍន៍ និងវិស័យ ឆ្នាំ២០០៧ (ពាន់ដុល្លាអាមេរិក)

Development partner	Term	Health	Education	Agric.	Man. Ming Trade	Rural Dev.	Banking & Biz	Urban Plan. & Mana.	Inf. & Com.	Energy, Power & Elec	Trans.	Water & Sanitation	Comm. & Social	Culture & Art	Enviro. & Conser.	Gender	HIV/ AIDS	Gov. & Adm.	Tourism	Budget & BoP	Emer. & Food Aid	Other	TOTAL
UN Programs Delivered : Total	Grant	11.251	10.515	3.428	489	8.527	120				666	1.419	5.854	1.801	2.350	1.101	5.383	21.366	97			16.455	90.825
	Loan			4.624																		988	5.612
UN own resources disbursed	Grant	8.194	5.763	3.428	466	4.402	120				666	1.361	3.311	1.801	2.350	1.101	5.377	7.278	97			2.103	47.820
	Loan			4.624																			4.624
World Bank	Grant	2.378	4.265		848	38				126		260			275			1.929		15.495			25.613
	Loan	2.671	3.009			2.986				1.371	1.569	3.285			73			7.072					22.036
International Monetary Fund	Grant						525											393					919
Asian Development Bank	Grant	1.339	1.513	498	509	578	940		539	245	382	2.994	1.086		302	379		1.305					12.608
២៨- ច្បាប់អាជីវកម្មនេសាទរបស់កម្ពុជាត្រូវបានរៀបចំឡើង ដោយផ្អែកលើច្បាប់របស់អង្គការស្បៀង អាហារនិងកសិកម្ម មានគោលដៅផ្តល់គោលការណ៍ និងការណែនាំមួយចំនួនដល់គ្រប់កម្រិតនៃស្ថាប័នពាក់ព័ន្ធ របស់រាជរដ្ឋាភិបាល សង្គមស៊ីវិល និងវិស័យឯកជន ស្តីពីអភិក្រម និងយុទ្ធសាស្ត្រមួយចំនួន ដែលអាចអនុវត្ត ក្នុងការអភិវឌ្ឍន៍ អភិរក្ស និងការគ្រប់គ្រងនៅក្នុងវិស័យនេះ ។ យើងបានរៀបចំសេចក្តីព្រាងច្បាប់នេះរួចហើយ ហើយបច្ចុប្បន្ន រដ្ឋបាលជលផលបាននិងកំពុងពិភាក្សាច្បាប់នេះនៅផ្ទៃក្នុងរបស់ខ្លួន ។ សេចក្តីព្រាងច្បាប់នេះ នឹងត្រូវពិភាក្សាយ៉ាងទូលំទូលាយជាមួយភាគីពាក់ព័ន្ធដទៃទៀត រួមមានដៃគូអភិវឌ្ឍន៍ អង្គការក្រៅរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល) មុនពេលដាក់ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីសុំ ការអនុមតិជាចុងក្រោយ ។

<u>សកម្មភាពចាំបាច់</u> : ពិភាក្សាជាមួយនឹងក្រសួងស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ដើម្បីធានាឱ្យរដ្ឋបាលជលផលមានហិរញ្ញប្បទានគ្រប់គ្រាន់ (គិតទាំងចំណូលដែលបានមកពីវិស័យនេះ) សម្រាប់អនុវត្ត ភាតព្វកិច្ចរបស់ខ្លួនស្របតាមមាត្រាទី ១៤ នៃច្បាប់ជលផល

២៩- តាមរយៈក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋបាលនេសាទបានស្នើសុំមូលនិធិ ដើម្បីអនុវត្ត ភារកិច្ចរបស់ខ្លួន ឱ្យស្របការកំណត់នៅក្នុងច្បាប់នេសាទ ។ ថវិកាដែលទទួលបានពីរាជរដ្ឋាភិបាល មិនទាន់ គ្រប់គ្រាន់តាមតម្រូវការឡើយ ហើយយើងទទួលបានមូលនិធិពីដៃគូអភិវឌ្ឍន៍មួយចំនួនតូចតែប៉ុណ្ណោះ ។ ជាទូទៅ មូលនិធិទាំងនេះពុំមានលក្ខណៈសុខដុមនីយកម្ម ជាមួយគ្នានៅឡើយ ។

<u>សកម្មភាពចាំបាច់</u> : ដៃគូអភិវឌ្ឍន៍ប្រើប្រាស់ប្រព័ន្ធផែនការ គណនេយ្យ និងត្រួតពិនិត្យរបស់រដ្ឋបាលជលផល ស្របតាមក្របខ័ណ្ឌចំណាយរយៈពេលមធ្យម និងប្រព័ន្ធប្រាក់បៀវត្សរ៍ស្របតាមប្រសិទ្ធភាពការងារ នាចុងឆ្នាំ២០០៧

៣០- ប្រព័ន្ធរៀបចំផែនការកម្ម ថវិកានីយកម្ម និងរបាយការណ៍ ត្រូវបានបង្កើតឡើង ក្នុងគោលបំណង តម្រង់ទិសឆ្ពោះទៅការប្រើប្រាស់អភិក្រមគ្រប់គ្រងទូទាំងវិស័យនៅក្នុងរដ្ឋបាលជលផល ។ ប្រព័ន្ធនេះត្រូវបាន រៀបចំស្របតាមក្របខ័ណ្ឌយុទ្ធសាស្ត្រថវិការបស់ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ។ បន្ថែមលើនេះ ប្រព័ន្ធទិន្នន័យផែនការ សៀវភៅបញ្ជីគណនេយ្យ និងអង្គភាពតាមដាន និងវាយតម្លៃត្រូវបានបង្កើតឡើង និង ដំណើរការ ដើម្បីគាំទ្រការអនុវត្តន៍ប្រព័ន្ធនេះ ។ ប៉ុន្តែមានតែដៃគូអភិវឌ្ឍន៍មួយចំនួនតូចប៉ុណ្ណោះ ដែលបាន និង កំពុងប្រើប្រាស់ប្រព័ន្ធនេះ ។

គោលដៅទី ១១: បន្តកាត់បន្ថយគ្រោះថ្នាក់ដោយសារមីននិងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះចំនួន៧០-៨០និងកាត់បន្ថយ ឱ្យបាន ៥-១០% នៃដីដែលមានមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ

<u>សកម្មភាពចាំបាច់</u> : អនុវត្តការត្រួតពិនិត្យតាមដាន និងវាយតម្លៃអំពីការអនុវត្តន៍សកម្មភាពនានា ដែលបាន ចែងក្នុងគោលនយោបាយយុទ្ធសាស្ត្រ និងផែនការសកម្មភាពស្តីពីមីននិងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ

៣១- ចាប់តាំងពីខែកក្កដា ឆ្នាំ២០០៧ ដល់ខែមិថុនា ឆ្នាំ២០០៨ យើងបានទទួលជោគជ័យគួរឱ្យកត់ សំគាល់សម្រាប់សកម្មភាពមីន ដូចដែលបានបញ្ជាក់ក្នុងការអង្កេតកិរិត១ ។ យើងបានពង្រឹងក្របខ័ណ្ឌផែនការ យុទ្ធសាស្ត្រ ។ យុទ្ធសាស្ត្រជាតិស្តីពីយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះដែលបានបន្សល់ក្រោយសង្គ្រាម (២០០៦-២០១៥) ត្រូវ បានអនុមតិជាផ្លូវការនៅក្នុងសន្និសិទ្ធជាតិស្តីអំពីសកម្មភាពមីន នាខែវិច្ឆិកា ឆ្នាំ២០០៧ ។ បន្ទាប់មក យើងបានធ្វើ បច្ចុប្បន្នភាពក្នុងខែកុម្ភៈ ឆ្នាំ២០០៨ ។ ផែនទីបង្ហាញផ្លូវរបស់អាជ្ញាធរសកម្មភាពមីននៅកម្ពុជាសម្រាប់ឆ្នាំ២០០៨ ត្រូវបានពិភាក្សា និងអនុមតិដោយក្រុមការងារបច្ចេកទេសចំរុះសកម្មភាពមីន ក្នុងខែកុម្ភៈ ឆ្នាំ២០០៨ ។ យើងបាន បញ្ចប់ការសិក្សារៀបចំមួយស្តីពីការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិថ្មីសម្រាប់សកម្មភាពមីនក្នុងខែសីហា ឆ្នាំ២០០៨ ដោយមានការគាំទ្រពីមជ្ឈមណ្ឌលអន្តរជាតិកំចាត់មីនដើម្បីមនុស្សជាតិរបស់ហ្សឺណែវ ។ យុទ្ធសាស្ត្រជាតិថ្មីនេះ បានបង្ហាញទិដ្ឋភាពមួយចំនួននៃក្របខ័ណ្ឌផែនការបច្ចុប្បន្ន ដែលកំពុងអនុវត្តដោយអាជ្ញាធរសកម្មភាពមីននៅ កម្ពុជា និងដោយមានការចូលរួមពីភាគីពាក់ព័ន្ធដទៃទៀតនៅក្នុងវិស័យនេះ ។ កិច្ចខិតខំប្រឹងប្រែងបន្តទៀត គឺត្រូវធ្វើសមាហរណកម្មនូវរាល់ដំណើរការទាំងអស់ប្រកបដោយភាពរលូនទៅក្នុងយុទ្ធសាស្ត្រមួយ ដោយផ្អែកលើមូលដ្ឋាននៃប្រត្យក្សភាពសម្រាប់វិស័យសកម្មភាពមីននាពេលអនាគត ។

<u>សកម្មភាពចាំបាច់</u> : ធានាការផ្តល់ និងការប្រើប្រាស់ហិរញ្ញប្បទានរបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ឱ្យបាន ទាន់ពេលវេលា

៣២- ផ្អែកតាមរបាយការណ៍ មូលនិធិរបស់រាជរដ្ឋាភិបាលបានកើនឡើងច្រើន បើប្រៀបធៀបនឹងបណ្តា ឆ្នាំកន្លងទៅ ។ លើសពីនេះ វិស័យនេះក៏បានទទួលមូលនិធិជាច្រើននិងទាន់ពេលវេលាផងដែរ។ យើងនឹងបន្ត ប្រឹងប្រែង ដើម្បីពង្រឹងវឌ្ឍនភាព

បន្ថែមទៀត ។ ទោះជាយ៉ាងណាក៏ដោយ យើងបានចំណាយពេលវេលាដ៏ច្រើន នៅក្នុងដំណើរការនៃការដកមូលនិធិសម្រាប់ប្រើប្រាស់ ដោយសារការិយាល័យធិបតេយ្យនៅមានការិតខ្ពស់ នៅ ឡើយ ។ ពាក់ព័ន្ធនឹងបញ្ហានេះដែរ មូលនិធិរបស់ដៃគូអភិវឌ្ឍន៍តែងបានផ្តល់ដោយផ្ទាល់ទៅប្រតិបត្តិករដោះមីន ដោយមិនបានផ្តល់របាយការណ៍ឱ្យក្រុមការងារបច្ចេកទេសចម្រុះវិស័យមីន ឬអាជ្ញាធរមីនបានដឹងឡើយ ។ ក្រៅពី គំរោង"លទ្ធផលនៃការដោះមីន " Clearing for Result" (ជាកម្មវិធីពហុមូលនិធិដែលគ្រប់គ្រងដោយកម្មវិធី អភិវឌ្ឍន៍សហប្រជាជាតិ) រាល់ការផ្តល់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ជាច្រើនមានលក្ខណៈបែកខ្ញែក និង/ ឬក៏មិនរាយការណ៍ជាលក្ខណៈប្រមូលផ្តុំតាមទម្រង់ជាក់លាក់ ដែលនេះជាមូលដ្ឋានសម្រាប់ក្រុមការងារបច្ចេកទេស ចម្រុះសកម្មភាពមីនមានលទ្ធភាពរៀបចំកម្មវិធីវិនិយោគសាធារណៈ ឬរៀបចំផែនការកម្ម និងធ្វើរបាយការណ៍ ប្រកបដោយប្រសិទ្ធភាពបានឡើយ ។

<u>សកម្មភាពចាំបាច់</u> : កែលំអយន្តការសម្រាប់ត្រួតពិនិត្យការប្រើប្រាស់ធនធាន ឱ្យមានតម្លាភាព និងប្រសិទ្ធភាព

៣៣- សមត្ថភាពតាមដាន និងត្រួតពិនិត្យសម្រាប់វិស័យមីនត្រូវបានពង្រឹងគួរឱ្យកត់សំគាល់ ។ សមត្ថភាពរបស់អាជ្ញាធរមីនកម្ពុជាបានបង្កើនទ្វេដង ដើម្បីពង្រឹងគុណភាពក្នុងប្រតិបត្តិការដោះមីន ដោយបាន ពង្រីកក្រុមត្រួតពិនិត្យគុណភាពពីចំនួន ២ ទៅ៤ ក្រុម និងបានដាក់ពង្រាយនៅតាមខេត្ត ព្រមទាំងបានត្រួតពិនិត្យ ជាប្រចាំលើកិច្ចប្រតិបត្តិការបោសសំអាតមីននៅតាមការដ្ឋាន ដើម្បីសម្រេចឱ្យបានតាមស្តង់ដារគុណភាព/ សុវត្ថិភាពជាតិឬលើសពីនេះ ។ ទន្ទឹមនេះដែរ នាយកដ្ឋានសេដ្ឋកិច្ច-សង្គមនៃអាជ្ញាធរមីនកម្ពុជាមានក្រុមត្រួត ពិនិត្យការគ្រប់គ្រងដីក្រោយពេលដោះមីនរួចចំនួនពីរក្រុម ដើម្បីធានាដំណើរការចាត់ថ្នាក់អាទិភាពចំការមីន ។ អាជ្ញាធរមីនកម្ពុជាបានតម្រង់គោលដៅនៃការប្រើប្រាស់ធនធាន សម្រាប់សកម្មភាពមីនឆ្ពោះទៅរកតំបន់មាន សក្តានុពលផ្នែកសេដ្ឋកិច្ច-សង្គម ដល់ប្រជាជនសហគមន៍ដែលរងផលប៉ះពាល់ដោយសារមីន និងយុទ្ធភ័ណ្ឌសេសសល់ពីសង្គ្រាម ។ ក្នុងឆ្នាំ២០០៨ នេះ ក្រុមសេដ្ឋកិច្ច-សង្គម បានត្រួតពិនិត្យដីដែលដោះមីនរួចចំនួនប្រមាណជា ២០០កន្លែង ។ បញ្ហាប្រឈមនាអនាគត គឺការធ្វើវិមជ្ឈការភារកិច្ចទៅឱ្យអាជ្ញាធរខេត្ត- ក្រុង ។

គោលដៅទី ១២: បង្កើតបរិយាកាសអំណោយផលសម្រាប់កិច្ចអភិវឌ្ឍន៍វិស័យឯកជន

<u>សកម្មភាពចាំបាច់</u> : ស្ថាប័នពាក់ព័ន្ធ ដូចជាក្រសួងពាណិជ្ជកម្ម សុខាភិបាល កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឧស្សាហកម្ម រ៉ែ និងថាមពល សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចុះហត្ថលេខា និងអនុវត្តកិច្ចព្រមព្រៀងស្តីពីសេវាកម្មដោយ ភ្ជាប់ជាមួយនូវបញ្ជីទំនិញហាមឃាត់រវាងស្ថាប័នទាំងនេះ ។

៣៤- រាជរដ្ឋាភិបាលកម្ពុជាចាត់ទុកវិស័យឯកជនជាក្បាលម៉ាស៊ីននៃកំណើន ។ អាស្រ័យហេតុនេះ ការ បង្កើតបរិយាកាសអំណោយផលដល់ការអភិវឌ្ឍន៍វិស័យឯកជនគឺជាកិច្ចការអាទិភាព ។ យើងបានសម្រេច វឌ្ឍនភាពជាច្រើនគួរឱ្យកត់សំគាល់ ។ ជាក់ស្តែង អត្រាកំណើនសេដ្ឋកិច្ចដែលមានតួលេខពីរខ្ទង់ក្នុងទសវត្សរ៍ កន្លងមក ការកើនឡើងនូវវិនិយោគផ្ទាល់ពីបរទេស និងការកើនឡើងនូវចំនួនក្រុមហ៊ុនដែលបានចុះបញ្ជី ។ ទោះជាយ៉ាងណាក៏ដោយ ក៏យើងត្រូវតែខិតខំបន្ថែមទៀតដើម្បីពង្រឹងសមិទ្ធផលទាំងនេះ ។ ការបន្តប្រឹងប្រែង របស់រាជរដ្ឋាភិបាលនៅតែមានសារៈសំខាន់ ក្នុងការរក្សាល្បឿននៃកំណើនបែបនេះ នៅក្នុងបរិស្ថានសាកល និង ថ្នាក់ជាតិនាពេលបច្ចុប្បន្ន រួមទាំងកង្វល់នានាស្តីពីការរក្សាឱ្យបាននូវស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច ។

៣៥- កិច្ចសហប្រតិបត្តិការបានដំណើរការល្អរវាងបណ្តាក្រសួងពាក់ព័ន្ធក្នុងការអនុវត្តន៍កិច្ចព្រមព្រៀង ស្តីពីសេវាកម្ម ។ វឌ្ឍនភាពនេះរួមមាន ការព្រមព្រៀងគ្នានូវបញ្ជីទំនិញហាមឃាត់ ។ រាជរដ្ឋាភិបាលកំពុងអនុវត្ត ការងារនេះបន្តដោយដាក់បញ្ជីទំនិញហាមឃាត់នេះ ទៅក្នុងប្រព័ន្ធ ASYCUDA ។

សកម្មភាពចាំបាច់ : ពិនិត្យការអនុវត្តន៍ការគ្រប់គ្រងហានីភ័យ និងកាត់បន្ថយអត្រាអធិការកិច្ចឱ្យមកត្រឹម ៥០% រួមទាំងតំបន់សេដ្ឋកិច្ចពិសេសផងដែរ ។ ការត្រួតពិនិត្យនេះនឹងអនុវត្តដោយអនុគណៈកម្មការស្តីពីការអភិវឌ្ឍន៍ ពាណិជ្ជកម្ម

៣៦- រាជរដ្ឋាភិបាលបានបង្កើតសមាសធាតុជាច្រើន សម្រាប់ក្របខ័ណ្ឌស្តីពីការគ្រប់គ្រងហានីភ័យ ដូចជា ការិយាល័យគ្រប់គ្រងហានីភ័យរបស់នាយកដ្ឋានគយនិងរដ្ឋាករ ប្រព័ន្ធពាណិជ្ជកម្មដែលជឿទុកចិត្តបាន កិច្ចព្រមព្រៀងអំពីបញ្ជីទំនិញហាមឃាត់ កិច្ចព្រមព្រៀងសេវាកម្ម និងប្រព័ន្ធស្វ័យប្រវត្តិសំរាប់ទិន្នន័យគយនៅ កំពង់ផែព្រះសីហនុ ។ យើងរំពឹងថា នៅពេលដែលប្រព័ន្ធនេះបានដំណើរការពេញលេញ ក៏រិតនៃអធិការកិច្ច
នឹងត្រូវថយចុះ ។

សកម្មភាពចាំបាច់ : លើកអនុសាសន៍ជាក់ស្តែងលើអាជ្ញាប័ណ្ណអាទិភាព ដើម្បីធានាភាពសមស្រប និងប្រសិទ្ធភាព

៣៧- ពាក់ព័ន្ធទៅនឹងសហគ្រាសធុនតូចនិងមធ្យម យើងឃើញមិនទាន់មានវឌ្ឍនភាព បញ្ហានៃការវាយ តម្លៃផលប៉ះពាលអំពីភាពសមស្រប និងប្រសិទ្ធភាពនៃការផ្តល់អាជ្ញាប័ណ្ណនៅឡើយ ។ ករណីនេះគឺជាបញ្ហា ប្រឈមចំបងសម្រាប់វិស័យឯកជន ។

អាទិភាពក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ

គោលដៅទី ១៣: ចីរភាពនៃបណ្តាញផ្លូវជាតិនិងផ្លូវជនបទ

សកម្មភាពចាំបាច់ : រៀបចំផែនការសកម្មភាពសម្រាប់បង្កើតប្រព័ន្ធគ្រប់គ្រងការថែទាំបណ្តាញផ្លូវ នាខែ មិថុនា ឆ្នាំ ២០០៨

៣៨- រាជរដ្ឋាភិបាលបានចាត់ទុកថា ការថែទាំផ្លូវជាតិនៅកម្ពុជាគឺជាអាទិភាពមួយដ៏សំខាន់ ។ ក្រសួង សាធារណៈការនិងដឹកជញ្ជូនបានចេញគោលការណ៍ណែនាំជាច្រើនស្តីពីការថែទាំផ្លូវ ។ បញ្ហាប្រឈមចំពោះមុខ គឺ ត្រូវធានាឱ្យបាននូវការអនុវត្តន៍គោលការណ៍ណែនាំទាំងនេះ។ យើងរំពឹងថា គំរោងគ្រប់គ្រងផ្លូវថ្នល់ដែលនឹងត្រូវ ដាក់ឱ្យអនុវត្តក្នុងឆ្នាំ២០០៨-២០១៣ នឹងជួយពង្រឹងប្រព័ន្ធគ្រប់គ្រងថែទាំគុណភាពផ្លូវថ្នល់។ ទោះបីរាជរដ្ឋាភិបាល បានចាត់ទុកថា ការថែទាំផ្លូវជាអាទិភាពសំខាន់ក៏ដោយ ក៏អវត្តមាននៃសារាចរណែនាំស្តីពីបញ្ហានេះ បានធ្វើឱ្យជួប ប្រទះការលំបាកក្នុងការប្រែក្លាយចក្ខុវិស័យស្តីពីការថែទាំផ្លូវថ្នល់ឱ្យទៅជាសកម្មភាពជាក់ស្តែង ។

សកម្មភាពចាំបាច់ : ការពារផ្លូវថ្នល់ដោយ ÷ ១- អនុវត្តសាកល្បង និងត្រួតពិនិត្យឡើងវិញនូវកិច្ចសន្យាថែទាំផ្លូវថ្នល់តាមរដូវកាលចំនួន ៣ (ខែមិថុនា ឆ្នាំ ២០០៨) និង២- កែលំអ និងរៀបចំកម្មវិធីត្រួតពិនិត្យការផ្ទុក ហួសចំណុះ (ខែមិថុនា ឆ្នាំ ២០០៨)

៣៩- ការផ្តល់មូលនិធិតាមរយៈគំរោងប្រតិបត្តិការសម្រាប់កាត់បន្ថយភាពក្រីក្រ និងកំណើនរបស់ធនាគារពិភពលោក ត្រូវបានផ្តល់សម្រាប់គាំទ្រដល់គម្រោងសាកល្បងនៃការប្រើប្រាស់ប្រភពពីខាងក្រៅ សម្រាប់ថែទាំ ផ្លូវថ្នល់ ។ យើងកំពុងដំណើរការរៀបចំឯកសារដេញថ្លៃ ដើម្បីធានាសង្គតិភាពជាមួយនឹងបទបញ្ញត្តិលទ្ធកម្ម របស់រាជរដ្ឋាភិបាល ។ ព្រមពេលជាមួយគ្នានេះដែរ ក្រសួងសាធារណៈការនិងដឹកជញ្ជូនកំពុងរៀបចំការសិក្សា ដើម្បីពិនិត្យអំពីយុទ្ធសាស្ត្រ និងផលប៉ះពាល់ ព្រមទាំងដំណើរការសម្រាប់ការផ្ទេរការងារនេះឱ្យវិស័យឯកជន ។

៤០- ក្រសួងសាធារណៈការនិងដឹកជញ្ជូនកំពុងខិតខំប្រឹងប្រែងរៀបចំយន្តការនិងដាក់ចេញនូវវិធានការ យ៉ាងហ្មឺងម៉ាត់ ដើម្បីត្រួតពិនិត្យការដឹកជញ្ជូនលើសទម្ងន់ ។ រាជរដ្ឋាភិបាលបានបង្កើតគណៈកម្មាធិការមួយដែល មានបីថ្នាក់ ដើម្បីដោះស្រាយបញ្ហានេះ ។ ប៉ុន្តែ សកម្មភាពរបស់គណៈកម្មាធិការទាំងបីថ្នាក់នេះនៅមានកម្រិត នៅឡើយ ។ បន្ថែមពីលើនេះ ការខ្វះទិន្នន័យស្តីពីការផ្ទុកទម្ងន់ (ចាប់តាំងពីដើមឆ្នាំ២០០៨) រួមនឹងការខ្វះទំនាក់ ទំនងរវាងក្រសួងសាធារណៈការនិងដឹកជញ្ជូនជាមួយនឹងថ្នាក់ខេត្ត បានធ្វើឱ្យការងារត្រួតពិនិត្យការដឹកជញ្ជូន លើសទម្ងន់ក្លាយជាបញ្ហាប្រឈមនៅទូទាំងប្រទេស ។

៤១- យើងត្រូវបង្កើតស្ថានីយថ្លឹងទម្ងន់ចំនួន ៧ និងមានជញ្ជីងថ្លឹងទម្ងន់ចល័ត ដែលនឹងត្រូវដាក់ឱ្យ ដំណើរការក្នុងឆ្នាំ២០០៩ នេះ ដើម្បីជម្រុញការអនុវត្តន៍ច្បាប់និងបទដ្ឋានស្តីពីការដឹកជញ្ជូនលើសទម្ងន់ ហើយនេះជា វិធានការបន្ទាន់មួយ ។ ប៉ុន្តែ យើងនៅមានការងារជាច្រើនដែលត្រូវអនុវត្ត រួមមានការបង្កើតនីតិវិធីសម្រាប់ ការត្រួតពិនិត្យការដឹកជញ្ជូនលើសទម្ងន់ ស្ថានីយថ្លឹងទម្ងន់ ជញ្ជីងថ្លឹងទម្ងន់ចល័ត និងការផ្តល់ការគាំទ្រថវិកា ឱ្យបានគ្រប់គ្រាន់សម្រាប់ជម្រុញការអនុវត្តន៍ច្បាប់ស្តីពីការដឹកជញ្ជូនលើសទម្ងន់នេះ ។

គោលដៅទី ១៤: បង្កើនការប្រើប្រាស់ទឹកស្អាត និងអនាម័យ ពិសេសនៅតំបន់ជនបទ

<u>សកម្មភាពចាំបាច់</u> : រៀបចំ និងអនុវត្តយុទ្ធសាស្រ្តស្តីពីការផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យនៅជនបទ ព្រមទាំងថវិកា ដែលផ្អែកលើគោលនយោបាយស្តីពីការផ្គត់ផ្គង់ទឹក ស្អាតនិងអនាម័យនៅជនបទ ដោយត្រូវតម្រឹមជាមួយនឹង ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ

៤២- សកម្មភាពគន្លឹះពីរ ត្រូវបានចាត់ទុកថាជាល័ក្ខខ័ណ្ឌវិនិច្ឆ័យក្នុងការវាស់វែងវឌ្ឍនភាពធៀបនឹង គោលដៅរបស់សូចនាករតាមដានរួមគ្នា ក្រោយពីការបង្កើតក្រុមការងារបច្ចេកទេសចម្រុះស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទមក ។ សកម្មភាពទាំងពីរនេះគឺ÷១- បង្កើនសេវាផ្គត់ផ្គង់ទឹកស្អាតដល់ប្រជាជននៅតំបន់ ជនបទឱ្យបាន ៥០% និងសេវាអនាម័យឱ្យបាន ៣០% នៅដំណាច់ឆ្នាំ២០១៥ ដែលគោលដៅនេះត្រូវបានកំណត់ នៅក្នុងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា និង ២- បង្កើនសេវាផ្គត់ផ្គង់ទឹកស្អាតដល់ប្រជាជននៅតំបន់ជនបទ ឱ្យបាន ៤០% និងសេវាអនាម័យឱ្យបាន ២០% នៅដំណាច់ឆ្នាំ ២០១១ ដែលគោលដៅនេះត្រូវបានកំណត់នៅក្នុង ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ។

៤៣- ដោយមានការគាំទ្រយ៉ាងសកម្មពីសំណាក់ដៃគូអភិវឌ្ឍន៍ ក្រសួងអភិវឌ្ឍន៍ជនបទទទួលបាន ជោគជ័យជាច្រើនក្នុងការចូលរួមចំណែកផ្គត់ផ្គង់ទឹកស្អាត និងបរិក្ខាអនាម័យគ្រប់គ្រាន់ ដូចជា ១- ការជីក អណ្តូងទឹកស្អាតប្រមាណ៤.២០០អណ្តូង ។ ២- ការសាងសង់បង្គន់អនាម័យសាធារណៈប្រមាណ ២.០០០ ពិសេស ក្នុងសាលាតាមទីជនបទ ។ ៣- គ្រួសារចំនួន ៥៥.៣០៨ បានទទួលធនធានសម្រាប់សង់បង្គន់អនាម័យតាមផ្ទះ ។ ៤- ភូមិចំនួន២០០ ក្នុងខេត្តទាំង ៩ បានចូលរួមក្នុងទស្សនវិស័យថ្មីប្រឌិត «អនាម័យរួមដឹកនាំដោយសហគមន៍ » (Community Led Total Sanitation) និង៥- ភូមិចំនួន៧០ បានទទួលជោគជ័យក្នុងសហគមន៍ ដោយបាន សង់បង្គន់សាមញ្ញ និងតំលៃសមរម្យ និងដោយគ្មានបំពេញខាតលើតម្លៃសំភារៈសាងសង់ឡើយ ។

៤៤- រាជរដ្ឋាភិបាលកំពុងអនុវត្ត «ស្តង់ដាទឹកស្អាតកម្រិតជាតិ» ដែលត្រូវបានបង្កើតក្នុងឆ្នាំ ២០០៤ ដោយ សហការជាមួយក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងអង្គការសុខភាពពិភពលោក។ នេះជាឯកសារណែនាំសម្រាប់វាយតម្លៃគុណភាពទឹកស្អាត ទាំងនៅតំបន់ទីក្រុង និងជនបទ ។ រាជរដ្ឋាភិបាលក៏ បានបង្កើតយុទ្ធសាស្រ្តស្តីពីការផ្លាស់ប្តូរឥរិយាបទ និងការទំនាក់ទំនងសម្រាប់វិស័យ ផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ និងបានដាក់ឱ្យអនុវត្តនៅតាមសហគមន៍ជនបទ។ ដើម្បីពង្រឹងការអភិវឌ្ឍន៍សមត្ថភាពសម្រាប់ការគ្រប់គ្រងកម្មវិធីផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យជនបទនៅតាមកម្រិតសហគមន៍

ដែលផ្តោតលើការគ្រប់គ្រងកិច្ចប្រតិបត្តិការ និងការថែទាំប្រកបដោយចីរភាព ក្រសួងអភិវឌ្ឍន៍ជនបទបានដាក់ចេញឯកសារណែនាំ សម្រាប់បង្កើត «ក្រុម អ្នកប្រើប្រាស់ទឹកស្អាតនិងអនាម័យ» (Water and Sanitation User Groups) នៅតាមកម្រិតភូមិ ។ រាជ រដ្ឋាភិបាលបានជម្រុញ «បំលាស់ប្តូរប្រព័ន្ធអនាម័យដែលមានការចូលរួម» (Participatory Hygiene and Sanitation Transformation) និង «អនាម័យដឹកនាំរួមដោយសហគមន៍» ដើម្បីបង្កើនប្រសិទ្ធភាពនៃសកម្មភាព ខាងអនាម័យនៅតាមជនបទ។

៤៥- ទោះជាមានវឌ្ឍនភាពដូចបានរៀបរាប់ខាងលើក៏ដោយ ក៏របាយការណ៍វឌ្ឍនភាពស្តីពី «គោលដៅ អភិវឌ្ឍន៍សហស្សវត្សរ៍របស់កម្ពុជា» នាខែឧសភា ឆ្នាំ២០០៧ ដែលរៀបចំដោយក្រសួងផែនការ បានបង្ហាញថា មាន ប្រជាជនប្រមាណតែ ៤២% ប៉ុណ្ណោះ ដែលទទួលបានការផ្គត់ផ្គង់ទឹកស្អាត និងប្រជាជនប្រមាណ១៤% ប៉ុណ្ណោះ ដែលបានទទួលបរិក្ខារអនាម័យគ្រប់គ្រាន់ ។ កង្វះព័ត៌មានដែលអាចជឿទុកចិត្តបានអំពីបរិមាណនៃការផ្គត់ផ្គង់ ទឹកស្អាតនិងអនាម័យជនបទ គឺជាបញ្ហាប្រឈមដ៏សំខាន់ក្នុងការវាយតម្លៃការអនុវត្តន៍ការងារនៅតាមវិស័យ ។ តួលេខនេះមានភាពខុសគ្នាយ៉ាងខ្លាំង ដោយសារប្រើប្រាស់ប្រភពព័ត៌មាន និងសូចនាករនៅក្នុងប្រព័ន្ធវាយតម្លៃ និងការអង្កេតផ្សេងៗពីគ្នា ។ ក្នុងយុទ្ធសាស្ត្រជាតិស្តីពីការផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យជនបទ សកម្មភាពអាទិភាព រួមមាន÷ការបង្កើនប្រសិទ្ធភាពគ្រប់គ្រងទិន្នន័យ និងប្រព័ន្ធព័ត៌មាននៃការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ យន្តការត្រួតពិនិត្យគុណភាពទឹក និងចីរភាពនៃការផ្គត់ផ្គង់ទឹកស្អាតនិងបរិក្ខារអនាម័យដែលបានសង់រួច ។

៤៦- សេចក្តីសំរេចថ្មីៗនេះរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងការកៀរគរមូលនិធិមួយផ្នែកពីអង្គការ មូលនិធិរូបិយវត្ថុអន្តរជាតិ សម្រាប់ការផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យជនបទ គឺជាការប្តេជ្ញាចិត្តគួរជាទីកត់សំគាល់ របស់រដ្ឋាភិបាលក្នុងការយកចិត្តទុកដាក់ចំពោះវិស័យនេះ ។ ប៉ុន្តែ កង្វះខាតយុទ្ធសាស្ត្រថ្នាក់ជាតិដ៏ច្បាស់លាស់មួយ គឺជាបញ្ហាចំបងក្នុងការអភិវឌ្ឍន៍ការផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យជនបទប្រកបដោយចីរភាព ។ ក្រោមការដឹកនាំ របស់ក្រសួងអភិវឌ្ឍន៍ជនបទ ដៃគូអភិវឌ្ឍន៍បាននិងកំពុងផ្តល់ការគាំទ្រ ប្រកបដោយភាពសុខដុមនីយកម្ម ក្នុង ការរៀបចំយុទ្ធសាស្ត្រជាតិរួមមួយស្តីពីការផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យជនបទ ។ ប៉ុន្តែ ទន្ទឹមនេះ វឌ្ឍនភាពនៃ ការរៀបចំយុទ្ធសាស្ត្រនេះក៏នៅមានកម្រិតនៅឡើយ ។

អាទិភាពក្នុងវិស័យអភិបាលកិច្ច និងពហុវិស័យនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ

គោលដៅទី១៥: បន្តពង្រឹងរដ្ឋបាលសាធារណៈដើម្បីបំរើផលប្រយោជន៍ប្រជាជន និងក្លាយជាដៃគូសម្រាប់ កិច្ចអភិវឌ្ឍន៍ ។

សកម្មភាពចាំបាច់ : អនុវត្តយុទ្ធសាស្ត្ររួមរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ស្តីពីការឈប់អនុវត្តជាជំហានៗ នូវការផ្តល់ប្រាក់បៀវត្សរ៍បន្ថែមដោយ÷

ក- អនុវត្តផែនការសកម្មភាពតាមវិស័យដែលបានឯកភាព និង

ខ- បង្កើតកន្សោមអាទិភាព (PMGs) និងអនុវត្តប្រព័ន្ធលាភការផ្អែកតាមលទ្ធផលការងារ (MBPIs) នៅក្នុងក្រសួងសុខាភិបាល និងយ៉ាងតិចបំផុតនៅក្រសួង/ស្ថាប័នមួយចំនួនទៀត

៤៧- កិច្ចប្រតិបត្តិស្តីពីការផ្តល់ប្រាក់បៀវត្សរ៍បន្ថែមត្រូវបានកាត់បន្ថយជាបណ្តើរៗនៅតាមកម្រិតវិស័យ តាមរយៈយន្តការមួយចំនួន ÷ ភ្នាក់ងារប្រតិបត្តិការពិសេស កន្សោមអាទិភាព ប្រព័ន្ធលាភការតាមលទ្ធផល ការងារ ។ ក្រសួងសុខាភិបាលបានរៀបចំអនុវត្តប្រព័ន្ធលាភការផ្អែកតាមលទ្ធផលការងារ នាដើមឆ្នាំ២០០៩ ហើយ ក្រសួងដទៃទៀត ដូចជាក្រសួងមហាផ្ទៃ និងក្រសួងសាធារណៈការនិងដឹកជញ្ជូន កំពុងពិភាក្សាជាមួយនឹងក្រុម ប្រឹក្សាកំណែទម្រង់រដ្ឋបាល សម្រាប់ចាប់ផ្តើមអនុវត្តប្រព័ន្ធលាភការនេះ ។

<u>សកម្មភាពចាំបាច់</u> : កែលំអការផ្ដល់ប្រាក់បៀវត្សរ៍និងលក្ខខ័ណ្ឌការងាររបស់មន្ត្រីរាជការ តាមរយៈ

ក- រៀបចំយុទ្ធសាស្ត្រនិងផែនការរយៈពេលមធ្យមសម្រាប់កែលំអបៀវត្សរ៍និង

ខ- រៀបចំគោលនយោបាយ និងផែនការសកម្មភាពស្ដីពីការពង្រាយមន្ត្រីរាជការ

៤៨- សមាសភាគសំខាន់នៃយុទ្ធសាស្ត្រស្ដីពីប្រព័ន្ធលាភការត្រូវបានរៀបចំ ហើយកំពុងដាក់ឱ្យអនុវត្ត ដូចជាការតម្លើងប្រាក់បៀវត្សរ៍មូលដ្ឋាន ២០% ការបន្តអនុវត្តន៍ប្រាក់ឧបត្ថម្ភតាមមុខងារ (ថ្នាក់គ្រប់គ្រង វិស័យ អប់រំ និងសុខាភិបាល) ការអនុវត្តន៍កន្សោមអាទិភាពនិងប្រព័ន្ធលាភការតាមលទ្ធផលការងារ ការធ្វើទំនើបកម្ម ប្រព័ន្ធប្រាក់សោធននិវត្តន៍ និងប្រព័ន្ធធានារ៉ាប់រងសុខភាព ។ ជំហានបន្ទាប់សម្រាប់អនុវត្តគោលនយោបាយស្ដីពី ការពង្រាយមន្ត្រីរាជការ គឺការសិក្សាអំពីកិច្ចប្រតិបត្តិល្អៗដែលទើបនឹងបញ្ចប់ក្នុងពេលថ្មីៗនេះ ។ ការពិភាក្សាលើ របកគំហើញបានដំណើរការ ក្នុងគោលដៅស្វែងរកជំនួយបច្ចេកទេស សម្រាប់ជួយរៀបចំសេចក្ដីព្រាងគោល នយោបាយ និងយន្តការនានា សម្រាប់អនុវត្តគោលនយោបាយពង្រាយមន្ត្រីនេះ ។ ការអនុវត្តន៍គោលនយោបាយ ស្ដីពីប្រព័ន្ធលាភការ និងការពង្រាយមន្ត្រីនេះ ត្រូវពឹងអាស្រ័យទៅលើសង្គតិភាពនៃប្រព័ន្ធស្ថាប័ន និងចីរភាពនៃ ធនធានហិរញ្ញវត្ថុផងដែរ ។

<u>សកម្មភាពចាំបាច់</u> : រៀបចំ និងអនុវត្តគោលនយោបាយ និងផែនការសកម្មភាពស្ដីពីការគ្រប់គ្រងធនធានមនុស្ស ដោយប្រើប្រាស់មគ្គុទេសក៍ស្ដីពីការគ្រប់គ្រងធនធានមនុស្ស និងប្រព័ន្ធគ្រប់គ្រងព័ត៌មានធនធានមនុស្សសម្រាប់ មន្ត្រីរាជការ

៤៩- សេចក្ដីថ្លែងការណ៍កម្រិតគោលនយោបាយស្ដីពីការគ្រប់គ្រងធនធានមនុស្ស និងផែនការសកម្មភាព ត្រូវបានរៀបចំរួច ហើយបច្ចុប្បន្ន កំពុងពិភាក្សាជាមួយនឹងដៃគូអភិវឌ្ឍន៍ ។ កិច្ចការនេះកំពុងដំណើរការ ដើម្បី ឈានទៅបញ្ចប់ការពិគ្រោះយោបល់សម្រាប់អនុមតិគោលនយោបាយនេះ និងការអនុវត្តន៍ផែនការសកម្មភាព ។ យើងបានទទួលគម្រោងមួយ សម្រាប់គាំទ្រដល់ការរៀបចំប្រព័ន្ធព័ត៌មានសម្រាប់គ្រប់គ្រងធនធានមនុស្ស ។

<u>សកម្មភាពចាំបាច់</u> : កែលំអការផ្ដល់សេវា តាមរយៈការបង្កើតយន្តការបញ្ជរតែមួយ និងពង្រឹងក្របខ័ណ្ឌច្បាប់ ដោយបង្កើតបញ្ជរតែមួយ យ៉ាងតិចបំផុតឱ្យបាន៥កន្លែងទៀតនៅទូទាំងប្រទេស

៥០- សេចក្ដីថ្លែងការណ៍កម្រិតគោលនយោបាយ និងអនុក្រឹត្យស្ដីពីបញ្ជរតែមួយ ត្រូវបានពិភាក្សានៅ ទីស្ដីការគណៈរដ្ឋមន្ត្រី ។ អង្គពិភាក្សានោះបានឯកភាពប្រគល់កិច្ចការនេះទៅឱ្យក្រសួងមហាផ្ទៃ សម្រាប់បន្តគាំទ្រ ការអនុវត្តន៍កំណែទម្រង់ស្ដីពីវិមជ្ឈការ និងវិសហមជ្ឈការ ។ ក្រសួងមហាផ្ទៃបានអនុវត្តកិច្ចការនេះបន្ត ដោយ ចាត់ទុកថា កិច្ចការនេះជាផ្នែកមួយនៃយុទ្ធសាស្ត្រសម្រាប់បង្ខិតសេវាសាធារណៈឱ្យកៀកជាប់នឹងប្រជាជន ។ ទស្សនទានស្ដីពីភ្នាក់ងារប្រតិបត្តិការពិសេសរបស់រាជរដ្ឋាភិបាល គឺការលើកកំពស់គុណភាពក្នុងការផ្ដល់សេវា សាធារណៈ ។ ទន្ទឹមនេះ ភ្នាក់ងារប្រតិបត្តិការពិសេសកំពុងដាក់ឱ្យអនុវត្តសម្រាប់បង្កើនគណនេយ្យភាពក្នុងការ ផ្ដល់សេវាសាធារណៈផងដែរ ។

គោលដៅទី ១៦ : រៀបចំប្រព័ន្ធច្បាប់និងតុលាការឱ្យដំណើរការល្អប្រកបដោយគណនេយ្យភាព និង តម្លាភាព ដែលការពារសិទ្ធិបុគ្គលដូចមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ

<u>សកម្មភាពចាំបាច់</u> : គោលដៅទី២ នៃយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ : បញ្ចប់ការរៀបចំសេចក្ដីព្រាង ច្បាប់ និងអនុមតិច្បាប់សំខាន់ៗដែលនៅសេសសល់ (ក្រមស្ដីពីនីតិវិធីរដ្ឋប្បវេណី ក្រមរដ្ឋប្បវេណី ក្រម ព្រហ្មទណ្ឌ ច្បាប់ស្ដីពីលក្ខន្តិកៈ

ចៅក្រមច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់តុលាការ និងច្បាប់ស្តីពី ការធ្វើវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម) ។

៥១- នៅឆ្នាំ២០០៧នេះ រាជរដ្ឋាភិបាលបានអនុមតិនិងប្រកាសឱ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌ ។ រាជ រដ្ឋាភិបាលបានចាប់ផ្តើមផ្សព្វផ្សាយនិងបណ្តុះបណ្តាលក្រមនេះដល់មន្ត្រីពាក់ព័ន្ធរួចរាល់ហើយ ប៉ុន្តែទាមទារឱ្យ អោយមានការខិតខំប្រឹងប្រែងបន្ថែមទៀតដើម្បីអនុវត្តក្រមនេះឱ្យបានពេញលេញ ។ ទន្ទឹមនេះ ក៏បានរៀបចំបញ្ចប់ ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណីនិងប្រកាសឱ្យប្រើក្រមទាំងពីរនេះនៅក្នុងពេលឆាប់ៗនេះ ។ ប៉ុន្តែ យើងនៅមានបញ្ហាមួយចំនួន ដែលត្រូវដោះស្រាយពាក់ព័ន្ធនឹងសង្គតិភាពរវាងក្រមទាំងពីរនេះជាមួយនឹងច្បាប់ ក្នុងវិស័យផ្សេងៗទៀត ។ យើងមានទំនុកចិត្តថា នឹងអាចដោះស្រាយបញ្ហាទាំងនេះ ។ ក្រមទាំងពីរនេះកំពុងដាក់ ឱ្យអនុវត្ត ។

៥២- រាជរដ្ឋាភិបាលបានចំណាយពេលយ៉ាងច្រើន មុននឹងក្រមព្រហ្មទណ្ឌត្រូវដាក់ឱ្យពិគ្រោះយោបល់ ដោយក្រុមប្រឹក្សាអ្នកច្បាប់ ។ បច្ចុប្បន្ននេះ ក្រមនេះកំពុងស្ថិតនៅក្នុងការពិភាក្សារបស់កិច្ចប្រជុំអន្តរក្រសួង ។ ការងារបច្ចេកទេសទាំងអស់ទាក់ទងនឹងក្រមព្រហ្មទណ្ឌត្រូវបានដោះស្រាយចប់សព្វគ្រប់ ហើយយើងរំពឹងថា នឹង មិនត្រូវចំណាយពេលច្រើនទៀតទេសម្រាប់នីតិវិធីដែលនៅសេសសល់ក្នុងការអនុមតិក្រមនេះឡើយ ។ ការអនុមតិ ច្បាប់នេះមានសារៈសំខាន់ណាស់ ដើម្បីឈានទៅអនុមតិច្បាប់ពាក់ព័ន្ធដទៃៗទៀត ។

៥៣- ទន្ទឹមនេះ ក៏ពិនិត្យអំពីវឌ្ឍនភាពតិចតួចចំពោះច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម ច្បាប់ស្តីពីការរៀបចំនិង ប្រព្រឹត្តទៅរបស់តុលាការ និងច្បាប់ស្តីពីការធ្វើវិសោធនកម្មនៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តម ក្រុមប្រឹក្សានៃអង្គចៅក្រម ។ វិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រពឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មានការយឺតយ៉ាវដោយសារការខ្វែងគំនិតគ្នារវាងអ្នកធ្វើគោលនយោបាយនានា ហើយបញ្ហានេះត្រូវទាមទារឱ្យ មានដំណោះស្រាយជាបន្ទាន់ ។ ការយឺតយ៉ាវក្នុងការអនុមតិច្បាប់នេះបានបង្កើតបញ្ហាដល់ការអនុវត្តន៍កំណែ ទម្រង់តុលាការ ពិសេស បានបង្អាក់ដំណើរការធ្វើផែនការ និងអនុវត្តគម្រោង «តុលាការគំរូ» ក៏ដូចជាការរៀបចំ ដំណើរការរដ្ឋបាលរបស់តុលាការផងដែរ ។

<u>សកម្មភាពចាំបាច់</u> : គោលបំណងទី ២និងទី ៧ នៃយុទ្ធសាស្ត្រប្រព័ន្ធច្បាប់និងតុលាការ : ពិនិត្យឡើងវិញនិងបញ្ចប់ គោលការណ៍ណែនាំ សម្រាប់ដំណើរការព្រាងច្បាប់ ដោយផ្អែកលើបទពិសោធ៍កន្លងមក ។ គោលការណ៍ណែនាំនេះនឹងលើកអំពីតម្រូវការខាងកិច្ចសហប្រតិបត្តិការបច្ចេកទេសសម្រាប់ការកសាងសមត្ថភាព និងសម្រាប់ពង្រឹង ភាពជាម្ចាស់របស់អង្គភាពរៀបចំច្បាប់នៃក្រសួងពាក់ព័ន្ធ ។

៥៤- បន្ទាប់ពីពុំសូវមានវឌ្ឍនភាពក្នុងការរៀបចំគោលការណ៍ណែនាំនេះអស់មួយរយៈពេលមក យើង បានខិតខំប្រឹងប្រែងក្នុងពេលថ្មីៗនេះ ដើម្បីបញ្ចប់ការងារនេះ ។ ក្រុមការងារដែលទទួលបន្ទុកកិច្ចការនេះបាន កំណត់ថា ក្រុមប្រឹក្សាអ្នកច្បាប់ត្រូវបញ្ចប់ការរៀបចំគោលការណ៍ណែនាំនេះឱ្យបានមុនការបោះឆ្នោតសាកល ហើយបន្ទាប់មក នឹងត្រូវអនុមតិ និងដាក់ឱ្យអនុវត្តភ្លាម ។ ប៉ុន្តែ យើងត្រូវរង់ចាំអស់រយៈពេលយូរក្នុងការអនុមតិ គោលការណ៍ណែនាំ ដែលមានសារៈសំខាន់សម្រាប់ធានាឱ្យមានសង្គតិភាពនៅក្នុងដំណើរការរៀបចំសេចក្តីព្រាង ច្បាប់ ។ យើងមានការសង្ឃឹមថា ការអនុមតិគោលការណ៍ណែនាំនេះគឺជាអាទិភាពមួយរបស់រាជរដ្ឋាភិបាល សម្រាប់នីតិកាលទី៤នេះ ។

<u>សកម្មភាពចាំបាច់</u> : គោលបំណងទី ៧និងទី៤ នៃយុទ្ធសាស្ត្រប្រព័ន្ធច្បាប់និងតុលាការ : ការបណ្តុះបណ្តាលនិង ការជ្រើសរើស ប្រកបដោយតម្លាភាពនូវមន្ត្រីបំរើឱ្យផ្នែកតុលាការនិងច្បាប់ដើម្បីកែលំអនូវការផ្តល់សេវា តុលាការ និងដំណើរការរបស់តុលាការ

៥៥- ការបន្តបណ្តុះបណ្តាលមន្ត្រីយុត្តិធម៌ ពិសេសលើច្បាប់ថ្មីៗ ដែលកំពុងត្រូវអនុវត្តនេះ បានជួយ បង្កើនចំណេះដឹងនូវនីតិវិធីថ្មីៗ ។ ក៏ប៉ុន្តែ យើងពុំទាន់អាចមើលឃើញជាក់ស្តែងនូវលទ្ធផលនៃការបណ្តុះបណ្តាល នេះទៅលើមុខងាររបស់តុលាការនៅឡើយ ។

៥៦- យើងនៅមានកង្វល់មួយចំនួនពាក់ព័ន្ធនឹងការប្រលងជ្រើសរើសចៅក្រម ដោយសារចៅក្រមស្ត្រី ដែលបានប្រឡងជាប់មានចំនួនតិចតួច ។ ការបង្កើតសាលាបណ្តុះបណ្តាលវិជ្ជាជីវៈសារការី និងអាជ្ញាសាលា ជាសញ្ញាណជីវិជ្ជមានមួយ ដែលនឹងរួមចំណែកក្នុងការបណ្តុះបណ្តាលវិជ្ជាជីវៈតុលាការ ហើយនឹងក្លាយជា មជ្ឈមណ្ឌលសម្រាប់វគ្គបណ្តុះបណ្តាលនានាទាក់ទងនឹងការគ្រប់គ្រងរឿងក្តី ។

គោលដៅ១៧: ប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ

<u>សកម្មភាពចាំបាច់</u> :១- រៀបចំបញ្ចប់ និងអនុមតិសេចក្តីព្រាងច្បាប់ស្តីពីការប្រឆាំងនឹងអំពើពុករលួយ ស្រប តាមបទដ្ឋានជាអន្តរជាតិ ។ ២- រៀបចំផែនការសម្រាប់គ្រប់គ្រងការអនុវត្តន៍ច្បាប់ស្តីពីការប្រឆាំងនឹងអំពើ ពុករលួយ ។ ៣-ផ្សព្វផ្សាយជាទៀងទាត់ ៦ ខែម្តងនូវព័ត៌មានស្តីពីករណីអំពើពុករលួយ និងការផ្តន្ទាទោស ។ ៤- រៀបចំក្របខ័ណ្ឌគោលនយោបាយច្បាស់លាស់ស្តីពីសិទ្ធិទទួលព័ត៌មាន។

៥៧- សេចក្តីព្រាងច្បាប់ស្តីពីការប្រឆាំងនឹងអំពើពុករលួយនឹងត្រូវបញ្ចប់ បន្ទាប់ពីការអនុមតិសេចក្តី ព្រាងក្រមព្រហ្មទណ្ឌ។ ចំណុចនេះត្រូវបានគូសបញ្ជាក់ឡើងវិញនៅក្នុងយុទ្ធសាស្ត្រចតុកោណ- ដំណាក់កាលទី ២ ។ ការអនុវត្តន៍តាមដំណាក់កាលបែបនេះ គឺដើម្បីធានានូវសង្គតិភាពរវាងច្បាប់ផ្សេងៗ និងការអនុវត្តន៍ច្បាប់ប្រកប ដោយប្រសិទ្ធភាព។

គោលដៅទី១៨: រៀបចំសម្រាប់អនុវត្តឱ្យបានពេញលេញនូវក្របខ័ណ្ឌយុទ្ធសាស្ត្រជាតិស្តីពីកំណែទំរង់វិមជ្ឈការ និងវិសហមជ្ឈការ ។

<u>សកម្មភាពចាំបាច់</u> : បន្តរៀបចំសេចក្តីព្រាងច្បាប់អង្គការស្តីពីកិច្ចអភិវឌ្ឍន៍មូលដ្ឋាននៅថ្នាក់ក្រោមជាតិ និង ផ្តួចផ្តើមការពិគ្រោះយោបល់ទូលាយ ជាមួយភាគីពាក់ព័ន្ធ (ត្រីមាសទី៤ ឆ្នាំ២០០៧)។

៥៨- រាជរដ្ឋាភិបាលបានប្រកាសឱ្យប្រើច្បាប់ស្តីពី "ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត- ក្រុង ស្រុក- និងខណ្ឌ " កាលពីខែឧសភា ឆ្នាំ២០០៨ ។ ច្បាប់នេះបានផ្តល់ជាមូលដ្ឋានសម្រាប់ក្រុមប្រឹក្សានានាដែលត្រូវបាន ជ្រើសតាំង និងរដ្ឋបាលឯកភាព» នៅថ្នាក់ខេត្តនិងស្រុក ។ ច្បាប់នេះបំពេញឱ្យច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល ឃុំ- សង្កាត់នាឆ្នាំ២០០១ ។ ជាមួយគ្នានេះដែររដ្ឋាភិបាលក៏បានប្រកាសឱ្យអនុវត្ត" ច្បាប់ស្តីពីការបោះឆ្នោតក្រុម ប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខណ្ឌ " ។ ច្បាប់នេះបាន លើកឡើងថាសមាជិកនៃក្រុមប្រឹក្សាខេត្ត និងស្រុក ត្រូវបានជ្រើសរើសដោយផ្អែកលើសមាមាត្រនៃតំណាងរបស់ គណបក្សក្នុងបញ្ជីឈ្មោះ ។

៥៩- ការរៀបចំបោះឆ្នោតសម្រាប់ក្រុមប្រឹក្សាស្រុក និងខេត្ត ដែលត្រូវធ្វើឡើងក្នុងអំឡុងពេល១២ខែ បាននិងកំពុងដំណើរការ ដោយរាប់បញ្ចូលទាំងការរៀបចំលិខិតគតិយុត្តិ សម្រាប់កំណត់រចនាសម្ព័ន្ធរដ្ឋបាលរបស់ ក្រុមប្រឹក្សា និងនីតិវិធី ។

៦០- ការអនុមតិច្បាប់គ្រប់គ្រងរដ្ឋបាលមូលដ្ឋាន បានផ្តល់នូវមូលដ្ឋានសម្រាប់ដំណើរការត្រួតពិនិត្យ និងចាត់ចែងឡើងវិញនូវតួនាទីមុខងារសំខាន់ៗរបស់ក្រសួងនិងស្ថាប័ននៃថ្នាក់ក្រោមជាតិ ។ ដំណើរការនេះនឹង ជួបការពិបាកនិងស្មុគស្មាញ ដែលអាចអូសបន្លាយពេលវេលាយូរជាងការរំពឹងទុក ព្រោះមានការទាក់ទងទៅនឹង ការចាត់ចែងឡើងវិញនៃផែនការ ថវិកា ការគ្រប់គ្រងបុគ្គលិក និងទ្រព្យសម្បត្តិនានា ។ ដើម្បីត្រួតពិនិត្យ ដំណើរការនេះ យើងនឹងប្រើប្រាស់គណៈកម្មាធិការជាតិសម្រាប់ពង្រឹងលទ្ធិប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

សម្រង់សុន្ទរកថារបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃ
ព្រះរាជាណាចក្រកម្ពុជាស្តីពីយុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ដំណាក់កាលទី២

ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយនៅតែជារបៀបវារៈអាទិភាពមួយដ៏សំខាន់នៃបញ្ជីរបៀបវារៈរបស់រាជរដ្ឋាភិបាល នីតិកាលទី៤នៃរដ្ឋសភានេះ ។ រាជរដ្ឋាភិបាលយល់ច្បាស់ថាច្បាប់ស្តីពីការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ គឺជា មូលដ្ឋាន គតិយុត្តិគន្លឹះមួយមិនអាចខ្វះបានសម្រាប់ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយប្រកបដោយប្រសិទ្ធភាព ។ ក្នុង ស្មារតីនេះ រាជរដ្ឋាភិបាលនៅតែប្តេជ្ញាចិត្តមោះមុតឥតរាថយ ក្នុងការរៀបចំ និងជម្រុញអនុម័តច្បាប់នេះ ដោយបន្តកិច្ចសហការ ពិគ្រោះយោបល់យ៉ាងជិតស្និទ្ធជាមួយនឹងគ្រប់ភាគីពាក់ព័ន្ធ ដោយផ្អែកលើច្បាប់គោលដទៃទៀតជាមូលដ្ឋាន ដែលត្រូវ អនុម័តជាមុនសិន ។ ដំណើរការតាមលំដាប់លំដោយបែបនេះ ទើបធានាបាននូវសង្គតិភាពនិងភាពរលូន រវាងច្បាប់ ដែលពាក់ព័ន្ធ ជាពិសេស ធានាបាននូវប្រសិទ្ធភាពក្នុងការអនុវត្តន៍ ។ រាជរដ្ឋាភិបាលនីតិកាលទី៤ នឹងបន្ត អនុវត្តវិធានការមុតស្រួចជាយុទ្ធសាស្ត្រជាក់ស្តែងដែលអាចដោះស្រាយបញ្ហាអំពើពុករលួយប្រកបដោយប្រសិទ្ធភាពតាម រយៈវិធានការប្រទាក់ក្រឡាគ្នាដូចខាងក្រោម :

១- ការបង្ការទប់ស្កាត់ជាមុនៈ រាជរដ្ឋាភិបាលបន្តជំរុញសកម្មភាពលើកកំពស់ការយល់ដឹងរាល់ទិដ្ឋភាពស្តីពី អំពើពុក រលួយ រួមមាន មូលហេតុ ឥទ្ធិពល និងផលលំបាកដ៏គ្រោះថ្នាក់ទាំងឡាយនៃអំពើពុករលួយនេះ ដើម្បីបន្តលើកទឹកចិត្ត សាធារណជនឱ្យចូលរួម ក្នុងការទប់ស្កាត់ប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ។ រាជរដ្ឋាភិបាលបន្តអនុវត្តវិធានការ ជាក់ស្តែងដើម្បីលើកទឹកចិត្តមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ឱ្យប្រកាន់ខ្ជាប់នូវសេចក្តីថ្លៃថ្នូរ សីលធម៌ស្មារតស្មី និងអនុវត្ត ការងារប្រកបដោយមនសិការវិជ្ជាជីវៈ និងស្មារតីទទួលខុសត្រូវខ្ពស់។

២- ការពង្រឹងគណនេយ្យភាពនិងពង្រឹងសមត្ថភាពស្ថាប័នៈ រាជរដ្ឋាភិបាលយកចិត្តទុកដាក់អនុវត្តឱ្យមានប្រសិទ្ធភាព នូវគោលការណ៍បញ្ចៀសទំនាស់ផលប្រយោជន៍រវាងឯកជន និងសាធារណៈ ដោយអនុវត្តគោលការណ៍វិសមិតភាព មុខងារ ជាពិសេស វិសមិតភាពរវាងមុខងារនយោបាយ និងមុខងារសាធារណៈ និងរវាងមុខងារនយោបាយ ឬមុខងារ សាធារណៈជាមួយនឹងសកម្មភាពខាងវិជ្ជាជីវៈធុរកិច្ច ព្រមទាំងកាត់បន្ថយនិងលុបបំបាត់ចោលនូវការប្រើតួនាទី ឥទ្ធិពល សិទ្ធិអំណាចដែលធ្វើឱ្យមានភាពមិនច្បាស់លាស់ ឬមានភាពលំអៀង ក្នុងការធ្វើសេចក្តីសម្រេច ។

៣- ការគាំទ្រ និងការចូលរួមពីសាធារណជន : នេះគឺជាលក្ខខ័ណ្ឌមិនអាចខ្វះបានក្នុងការទប់ស្កាត់ កាត់បន្ថយនិងប្រយុទ្ធ ប្រឆាំងនឹងអំពើពុករលួយឱ្យមានប្រសិទ្ធភាព។ ជាមួយគ្នានេះដែរ រាជរដ្ឋាភិបាលនឹងបន្តជំរុញលើកកំពស់ថែមទៀត នូវការការពារសេរីភាពនៃការស្វែងរកទទួលនិងផ្សព្វផ្សាយក្នុងបណ្តាញព័ត៌មាននូវករណីពាក់ព័ន្ធនឹងអំពើពុករលួយ ។ ប៉ុន្តែ ការអនុវត្តន៍កិច្ចការទាំងអស់នេះ ត្រូវតែមានលក្ខណៈជឿទុកចិត្តបាន និងមានការទទួលខុសត្រូវ ដោយត្រូវគោរព សិទ្ធិកិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ប្រជាជន ព្រមទាំងការពារបាននូវសន្តិសុខជាតិ និងសណ្តាប់ធ្នាប់សាធារណៈ។

៤- ការចូលរួមពីវិស័យឯកជន : រាជរដ្ឋាភិបាលបន្តរៀបចំ និងជំរុញអនុវត្តគោលនយោបាយ បទដ្ឋានគតិយុត្តិ និងនីតិវិធី សម្រាប់ការពារភាពសុចរិតនៃវិស័យឯកជនដើម្បីបញ្ចៀសការឃុបឃិត និងធានាឱ្យបាននូវការប្រកួតប្រជែងដោយ ស្មោះត្រង់ រវាងក្រុមហ៊ុន សហគ្រាសឯកជនដោយធានាអោយបាននូវការប្រព្រឹត្តល្អត្រឹមត្រូវប្រកបដោយកិត្តិយស សេចក្តីថ្លៃថ្នូ ក្នុងសកម្មភាពធុរកិច្ច ។ រាជរដ្ឋាភិបាលនឹងធានាតុល្យភាពរវាងសិទ្ធិនិងផលប្រយោជន៍ទាំងឡាយ ដែល មានចែងក្នុងកិច្ចសន្យារវាងភាគីរដ្ឋ និងវិស័យឯកជន។

៥-ការពង្រឹងការអនុវត្តន៍ច្បាប់ៈ រាជរដ្ឋាភិបាលនឹងចាត់វិធានការតឹងរ៉ឹងសំដៅបំបាត់វប្បធម៌និទណ្ឌភាព កាត់បន្ថយអំពើ ពុករលួយនិងបង្កើនភាពទំនុកចិត្តរបស់សាធារណជនចំពោះរាជរដ្ឋាភិបាល ។

ជំនួសឱ្យគណៈកម្មាធិការជាតិដឹកនាំការងារកំណែទំរង់វិមជ្ឈការ និងវិសហមជ្ឈការ ដែលជាស្ថាប័នគ្រប់គ្រង វិមជ្ឈការក្នុងពេលបច្ចុប្បន្ននេះ ។ គណៈកម្មាធិការថ្មីនេះត្រូវមានតំណាងពីបណ្តាក្រសួងពាក់ព័ន្ធទាំងអស់ ។ សេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ច្បាប់នេះ មានសារៈសំខាន់ណាស់ ប្រសិនបើមុខងារសំខាន់ៗ ត្រូវបានផ្ទេរទៅឱ្យក្រុមប្រឹក្សានានានៅថ្នាក់ក្រោមជាតិ។

៦១- ការចូលរួមយ៉ាងទូលំទូលាយពីសំណាក់ភាគីពាក់ព័ន្ធ តាមរយៈដំណើរការនៃការរៀបចំលិខិត គតិយុត្តិ និងនីតិវិធីសំខាន់ៗ សម្រាប់អនុវត្តច្បាប់គ្រប់គ្រងរដ្ឋបាលមូលដ្ឋាន និងក្នុងដំណើរការត្រួតពិនិត្យមុខងារគឺជាកិច្ចការដែលមានសារៈសំខាន់ណាស់ ។

__សកម្មភាពចាំបាច់__ : បន្តរៀបចំកម្មវិធីជាតិ ទម្រង់ការ និងការធានាធនធានសម្រាប់ចាប់ផ្តើមអនុវត្ត (ត្រីមាសទី២ ឆ្នាំ២០០៨)

៦២- បន្ទាប់ពីការពន្យារពេលមួយរយៈ យើងបានបញ្ចប់ការរៀបចំកិច្ចសន្យាសម្រាប់ក្រុមប្រឹក្សាយោបល់ ដើម្បីជាជំនួយដល់ក្រុមរៀបចំកម្មវិធីជាតិរបស់គណៈកម្មការជាតិដឹកនាំការងារកំណែទំរង់វិមជ្ឈការ និងវិសហ- មជ្ឈការ តាមរយៈការបង្កើត កម្មវិធីជាតិមួយសំរាប់ពង្រឹងលទ្ធិប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ។ ការងារនេះ ត្រូវបានចាប់ផ្តើមនៅដើមខែកញ្ញា ឆ្នាំ២០០៨ ដោយរំពឹងថាដំណើរការនេះនឹងត្រូវប្រើរយៈពេល៩ខែ ។ ដំណើរការ នេះត្រូវអនុវត្តបន្តទៀត ដោយត្រូវវាយតម្លៃរួមគ្នាជាមួយនឹងដៃគូអភិវឌ្ឍន៍ និងការរៀបចំឱ្យមានការគាំទ្រប្រកប ដោយសុខដុមនីយកម្ម សម្រាប់គាំទ្រដល់ការអនុវត្តន៍បណ្តាអាទិភាពនៃកម្មវិធីជាតិ ។

៦៣- ពេលវេលាហាក់មានភាពចង្អៀត ប្រសិនបើកម្មវិធីពហុដៃគូអភិវឌ្ឍន៍ថ្មីមួយមិនអាចរៀបចំចប់ សព្វគ្រប់ និងត្រូវអនុមតិនាខែមករា ឆ្នាំ២០១០ ។ ដើម្បីធានាភាពជាម្ចាស់របស់រាជរដ្ឋាភិបាល យើងត្រូវគ្រប់គ្រង ដោយប្រុងប្រយ័ត្នចំពោះហានិភ័យនៃការកំណត់ពេលវេលាសម្រាប់ចាប់ផ្តើមអនុវត្តគម្រោងរបស់ដៃគូអភិវឌ្ឍន៍។

៦៤- ជោគជ័យនៃការរៀបចំខាងលើនឹងត្រូវពឹងផ្អែកទាំងស្រុងលើដំណើរការពិភាក្សាដ៏ល្អិតល្អន់ ដោយឈរលើភាពដឹកនាំរបស់រដ្ឋាភិបាល និងការពិភាក្សាឱ្យបានទូលំទូលាយជាមួយនឹងភាគីពាក់ព័ន្ធដទៃទៀត (ក្រសួង ពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល)។ ដំណើរការពិភាក្សានេះគឺជាការងារអាទិភាព ក្នុងបណ្តាអាទិភាពដទៃ ទៀត ដូចជាការបោះឆ្នោតថ្នាក់ស្រុកនិងខេត្តក្នុងឆ្នាំ២០០៩ ។ ទន្ទឹមនឹងនេះ យើងក៏ទទួលស្គាល់ថា ការតាមដាន និងការធ្វើរបាយការណ៍នូវគំរោងកំពុងដំណើរការ ក៏ជាបន្ទុកបន្ថែមសម្រាប់រាជរដ្ឋាភិបាលផងដែរ។

__សកម្មភាពចាំបាច់__ : រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍បានរៀបចំគោលការណ៍ដើម្បីគាំទ្រដល់កំណែទំរង់ វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា

៦៥- គោលការណ៍ទាំងនោះនឹងត្រូវដាក់បញ្ចូលទៅក្នុងដំណើរការនៃការរៀបចំកម្មវិធីថ្នាក់ជាតិ។

គោលដៅទី១៩ : បង្កើនជំនឿទុកចិត្តលើថវិការដ្ឋនិងបង្កើនគណនេយ្យភាពក្នុងកិច្ចការហិរញ្ញវត្ថុ

__សកម្មភាពចាំបាច់__ : បន្តអនុវត្តសកម្មភាពនិងរៀបចំបញ្ចប់សកម្មភាពគន្លឹះដែលនៅសេសសល់សម្រាប់ ដំណាក់កាលទី១

៦៦- រាជរដ្ឋាភិបាលបាននិងកំពុងយកចិត្តទុកដាក់លើផ្នែក៤ដើម្បីបន្តធានាសមិទ្ធផលនានាដែលសម្រេច បាន ក្នុងដំណាក់កាលទី ១ ។ វិស័យទាំងនេះសុទ្ធសឹងតែមានវឌ្ឍនភាពនៅក្នុងអំឡុងពេលនៃវេទិកាលើកទី១ ប៉ុន្តែ តម្រូវឱ្យមានការពង្រឹងនិងការយកចិត្តទុកដាក់ឱ្យកាន់តែស៊ីជំរៅបន្ថែមទៀត ។ រាជរដ្ឋាភិបាលនឹងបន្តការ តាមដានសមិទ្ធផលរបស់ផ្នែកទាំងនេះ ដើម្បីធានាឱ្យបាននូវចិរភាព និងវឌ្ឍនភាពបន្តទៅទៀត ។ សកម្មភាព សម្រាប់វិស័យទាំងនេះរួមមាន ៖

៦៧- *បន្តការកែលំអគោលនយោបាយនិងការគ្រប់គ្រងចំណូល* ៖ បន្តពង្រឹងបន្ថែមទៀតគោលនយោបាយ ចំណូល ។ ក្នុងន័យនេះ ត្រូវបន្តការយកចិត្តទុកដាក់លើគោលនយោបាយចំណូលរយៈពេលមធ្យម ដូចជាចំណូល ដែលបានមកពីប្រេងឆៅ ហ្គាស រ៉ែ បង្កើនការយកពន្ធគយ ចំណូលពន្ធនិងចំណូលមិនមែនពន្ធ ហើយបន្តកែលំអ ក្នុងការព្យាករណ៍ម៉ាក្រូសេដ្ឋកិច្ចនិងគិតចំណូល ។ ដូច្នេះ រាជរដ្ឋាភិបាលបានរៀបចំគោលនយោបាយបង្កើន ចំណូលដែលជាគោលនយោបាយរយៈពេលមធ្យម ដោយរាប់បញ្ចូលទាំងចំណូលដែលបានមកពីប្រេងឆៅ និង ហ្គាសផងដែរ ។ លើសពីនេះ នៅក្នុងឆ្នាំ២០០៧ ចំណូលដែលទទួលបានមាន២២.៥% លើសគោលដៅ បើធៀប នឹងថវិកាជាតិសរុបឆ្នាំ២០០៧ ហើយចំណូលក្នុងស្រុកមាន ១២% នៃផលិតផលក្នុងស្រុកសរុប ។ តាមការប៉ាន់ស្មាន ប្រាក់ចំណូលមានប្រហែល ១២% នៃផលិតផលក្នុងស្រុកសរុបសម្រាប់ឆ្នាំ២០០៨ ។

៦៨- *បន្តការកែលំអការគ្រប់គ្រងបំណុល* ៖ ដើម្បីកែលំអការគ្រប់គ្រងបំណុល រាជរដ្ឋាភិបាលបានបន្ត ត្រួតពិនិត្យលើសកម្មភាពមួយចំនួន ដូចជា ក្របខ័ណ្ឌស្ថាប័ននិងច្បាប់ តួនាទីនិងការទទួលខុសត្រូវក្នុងការគ្រប់គ្រង ឥណទាន ការកែលំអនិងការអនុវត្តន៍យុទ្ធសាស្ត្រគ្រប់គ្រងបំណុល និងពង្រីកការប្រើប្រាស់ប្រព័ន្ធទិន្នន័យស្តីពី កម្ចី ។ ជាលទ្ធផល យើងសម្រេចបាននូវសមិទ្ធផលមួយចំនួនដូចខាងក្រោម ៖

- ការតម្លើងប្រព័ន្ធទិន្នន័យស្តីពីការគ្រប់គ្រងកម្ចីនៅនាយកដ្ឋានវិនិយោគនិងកិច្ចសហប្រតិបត្តិការ ហើយ យើងកំពុងយកចិត្តទុកដាក់លើការកត់ត្រាស្តីពីការចំណាយទៅលើសេវាឥណទាននានា ។
- ការធ្វើសុពលភាពប្រព័ន្ធគ្រប់គ្រងបំណុល និងវិភាគហិរញ្ញវត្ថុដើម្បីឆ្លើយតបនឹងរបាយការណ៍របស់ ម្ចាស់ឥណទាន ។
- ការធ្វើរបាយការណ៍ប្រព័ន្ធគ្រប់គ្រងបំណុលនិងវិភាគហិរញ្ញវត្ថុប្រចាំខែស្តីពីបំណុល ការធ្វើរបាយ- ការណ៍ស្តីពីការផ្តល់ឥណទាន និងជំនួយឥតសំណងបន្តទៅឱ្យអង្គភាពនិងស្ថាប័នដទៃ ហើយបញ្ជូន របាយការណ៍នេះទៅរតនាគាជាតិ ធនាគារជាតិនៃកម្ពុជា និងអង្គភាពគ្រប់គ្រងសាច់ប្រាក់ ។
- ការបើកវគ្គបណ្តុះបណ្តាលស្តីពីការវិភាគបំណុលដល់មន្ត្រីនាយកដ្ឋានវិនិយោគនិងកិច្ចសហប្រតិបត្តិការ និងមន្ត្រីរបស់នាយកដ្ឋានពាក់ព័ន្ធដទៃទៀត ។
- ការរៀបចំនិងពិគ្រោះយោបល់លើឯកសារស្តីពីយុទ្ធសាស្ត្រគ្រប់គ្រងបំណុល និងការរៀបចំច្បាប់និង ស្ថាប័នសម្រាប់ការគ្រប់គ្រងបំណុល។

៦៩- *បន្តកែលំអការគ្រប់គ្រងសាច់ប្រាក់និងគណនីធនាគារ* ៖ រាជរដ្ឋាភិបាលបានពង្រឹងការគ្រប់គ្រង សាច់ប្រាក់ និងគណនីធនាគារដោយផ្តោតការយកចិត្តទុកដាក់លើគណនីរួមរបស់រដ្ឋាភិបាល និងឥណទានទោល របស់រតនាគារជាតិ ពង្រីកការប្រើប្រាស់ប្រព័ន្ធធនាគារសម្រាប់ប្រតិបត្តិការចំណូលនិងចំណាយនានារបស់រាជ រដ្ឋាភិបាល ។ លើសពីនេះ រដ្ឋាភិបាលបានពង្រឹងនិងកែលំអផែនការសាច់ប្រាក់និងការតាមដានបំណុល ដែលមិន ទាន់សងនិងហួសកាលកំណត់ ។ ជាលទ្ធផល យើងសម្រេចបាននូវវឌ្ឍនភាពដូចខាងក្រោម ៖

- ពុំមានការកើនឡើងនូវបំណុលដែលមិនទាន់សងនិងហួសកាលកំណត់ថ្មី ។

- រាល់ការចំណាយទៅលើបំណុលទាំងនោះ (រយៈពេលមួយខែ បន្ទាប់ពីទទួលបាននូវវិក័យប័ត្រ សម្រាប់ ទូទាត់ពីរតនាគារជាតិ) ត្រូវបានកាត់ចេញទាំងស្រុងឱ្យនៅកម្រិត 0% ។

- ការបង្កើតនូវកម្មវិធីទិន្នន័យកុំព្យូទ័រសម្រាប់កត់ត្រាបំណុលដែលមិនទាន់សងនិងហួសកាលកំនត់តាម រយៈប្រព័ន្ធគណនេយ្យកុំព្យូទ័រនៃបញ្ជីគណនីថ្មីៗដែលបានអនុវត្តនៅក្នុងឆ្នាំ២០០៧ ។

- បន្តការពង្រឹងនូវគណនីរបស់រដ្ឋាភិបាល និងបានបិទគណនីទាំង១០១ របស់រាជរដ្ឋាភិបាលបន្ថែមទៀត លើកលែងតែគណនីប្រាក់បៀវត្សរ៍ប៉ុណ្ណោះ ។

- ការបើកប្រាក់បៀវត្សរ៍របស់មន្ត្រីរាជការតាមប្រព័ន្ធធនាគារត្រូវបានអនុវត្តនៅថ្នាក់កណ្តាល និងបាន ពង្រីកបន្ថែមនៅថ្នាក់ខេត្តនិងក្រុង (ភ្នំពេញ ខេត្តសៀមរាប និងក្រុងព្រះសីហនុ)។ គិតមកដល់ ពាក់កណ្តាលឆ្នាំ២០០៨ គណនីសរុបចំនួន៣៧៧២ នៃក្រសួងនិងស្ថាប័នចំនួន២៦ ត្រូវបានបើកនៅ ធនាគារអេអិនហ្សែត (ANZ)។

- អង្គភាពគ្រប់គ្រងលំហូរសាច់ប្រាក់ត្រូវបានបង្កើតឡើងនៅក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បី ត្រួតពិនិត្យការអនុវត្តន៍ថវិកា និងការគ្រប់គ្រងសាច់ប្រាក់ ។

- បុគ្គលិកនៃអង្គភាពគ្រប់គ្រងលំហូរសាច់ប្រាក់កំពុងត្រូវបានជ្រើសរើស ហើយវគ្គបណ្តុះបណ្តាលត្រូវ បានរៀបចំ ។

- គំរូសម្រាប់ទស្សន៍ទាយសាច់ប្រាក់ត្រូវបានរៀបចំ ។

- អង្គភាពគ្រប់គ្រងលំហូរសាច់ប្រាក់បានបង្កើតឯកសារ សម្រាប់ការប៉ាន់ស្មានសាច់ប្រាក់ និងការបង្វែរសាច់ប្រាក់សម្រាប់គណនីរដ្ឋាភិបាលទាំងមូល។

- អង្គការមូលនិធិរូបិយប័ណ្ណអន្តរជាតិបានផ្តល់ជំនួយបច្ចេកទេស ដើម្បីគាំទ្រអង្គភាពគ្រប់គ្រងលំហូរ សាច់ប្រាក់និងរតនាគារជាតិ ក្នុងការធ្វើសុខដុមនីយកម្មផែនការសកម្មភាពនាយកដ្ឋាន ពង្រឹងគណនី ទោលរបស់រតនាគារ និងរៀបចំគំរោងសាកល្បងប្រើប្រាស់ធនគារពាណិជ្ជកម្មដើម្បីប្រមូលថវិកា។

៧០- *បន្តកែលំអប្រព័ន្ធលទ្ធកម្មសាធារណៈ* : នីតិវិធីលទ្ធកម្មសាធារណៈត្រូវបានកែលំអ តាមរយៈការ បង្កើនលក្ខណៈគតិយុត្តិនៃច្បាប់ ការអនុវត្តន៍អនុក្រឹត្យថ្មីស្តីពីលទ្ធកម្ម និងការអនុវត្តន៍បទដ្ឋាននិងបទបញ្ជានានា ការពង្រឹងសមត្ថភាពរបស់ស្ថាប័នលទ្ធកម្មនៅថ្នាក់ជាតិ និងខេត្ត-ក្រុង ការពង្រឹងសមត្ថភាពត្រួតពិនិត្យ និងវាយតម្លៃ ការបង្កើនការប្រកួតប្រជែង និងតម្លាភាពក្នុងនីតិវិធីលទ្ធកម្ម និងការបញ្ជាក់ពីខ្សែគណនេយ្យភាពក្នុងនីតិវិធី លទ្ធកម្ម ។ វឌ្ឍនភាពមានដូចខាងក្រោមៈ

- លទ្ធកម្មសាធារណៈត្រូវបានផ្ទេរការទទួលខុសត្រូវផ្ទាល់ទៅឱ្យក្រសួង/ស្ថាប័នពាក់ព័ន្ធ ក្នុងកម្រិត ថវិកាមួយកំណត់ ។

- បែបបទនិងនីតិវិធីលទ្ធកម្ម និងផែនការលទ្ធកម្មត្រូវបានអនុវត្តនិងកែលំអ ។

- ការជ្រើសរើសទីប្រឹក្សាសំរាប់អភិវឌ្ឍន៍គេហទំព័រលទ្ធកម្មកំពុងត្រូវបានដំណើរការ ហើយលក្ខខ័ណ្ឌយោង របស់ទីប្រឹក្សាដើម្បីធ្វើសេចក្តីព្រាងច្បាប់លទ្ធកម្មត្រូវបានរៀបចំ និងផ្ញើជូនធនាគារពិភពលោក សម្រាប់កែលំអ ។

<u>សកម្មភាពចាំបាច់</u> : រៀបចំផែនការសកម្មភាពសំរាប់ជំហានទី២នៃដំណាក់កាលទី២ រួមទាំងផ្តល់អនុសាសន៍ សំរាប់ជាមូលដ្ឋានក្នុងការអនុមតិគំនិតផ្តួចផ្តើមស្តីពីតម្លាភាពក្នុងវិស័យឧស្សាហកម្មរុករក

៧១- ផែនការសកម្មភាព ដែលជាឯកសារមូលដ្ឋានសំរាប់កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ សាធារណៈជំហានទី២ ដំណាក់កាលទី២ ត្រូវបានរៀបចំឡើង ហើយនឹងត្រូវបញ្ចប់ក្នុងពេលឆាប់ៗនេះ សម្រាប់បោះ ពុម្ពផ្សាយ។ ក្នុងអំឡុងពេលរៀបចំឯកសារនេះ រាជរដ្ឋាភិបាលបានទទួលមតិកែលំអនានា ពិសេសពីដៃគូអភិវឌ្ឍន៍ និងបានពិចារណាមតិកែលំអទាំងនោះយ៉ាងមធ្យ័ត

ដើម្បីធានាថា ផែនការសកម្មភាពនេះត្រូវបានបញ្ចប់និងមាន វិសាលភាព ដើម្បីសម្រេចបាននូវគណនេយ្យភាពហិរញ្ញវត្ថុ ។ លើសពីនេះ ដើម្បីអនុវត្តសកម្មភាព និងកម្មវត្ថុ ដែលបានកំណត់ក្នុងផែនការសកម្មភាពនេះ ចាំបាច់ត្រូវមានផែនការសកម្មភាពពិស្តារ២បន្ថែមទៀត គឺៈ ផែនការសកម្មភាពរបស់នាយកដ្ឋាននានា និងផែនការសកម្មភាពរបស់ក្រសួង ។ ផែនការសកម្មភាពរបស់ នាយកដ្ឋានត្រូវរៀបចំ និងធ្វើបច្ចុប្បន្នភាពយ៉ាងទៀងទាត់ ។ ប៉ុន្តែ ផែនការសកម្មភាពកំពុងត្រូវបានរៀបចំ ដោយក្រសួងពាក់ព័ន្ធ ក្រោមការគាំទ្រពីលេខាធិការដ្ឋាននៃគណៈកម្មាធិការអចិន្ត្រៃយ៍កំណែទម្រង់ហិរញ្ញវត្ថុ សាធារណៈ ។ សេចក្តីព្រាងទី១នៃផែនការសកម្មភាពក្រសួងនឹងត្រូវលេចជារូបរាងឡើងនាចុងខែតុលាឆ្នាំ២០០៨ ។

៧២- ផែនការសកម្មភាពទាំងនេះមានទំនាក់ទំនងគ្នា ហើយត្រូវផ្សាភ្ជាប់គ្នាយ៉ាងជិតស្និទ្ធ ។ ផែនការ ទាំងនេះអាចប្រែប្រួល និងផ្លាស់ប្តូរតាមពេលវេលា និងតាមកាលៈទេសៈ។ ផែនការទាំងនេះនឹងត្រូវបោះពុម្ពផ្សាយឱ្យបានមុនខែធ្នូ ឆ្នាំ២០០៨នេះ ។

<u>សកម្មភាពចាំបាច់</u> : បន្តត្រួតពិនិត្យសកម្មភាពនៃការអនុវត្តន៍សូចនាករដែលបានឯកភាពក្នុងកំណែទម្រង់ការ គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

៧៣- ដូចដែលមានចែងក្នុងជំហាន២ ដំណាក់កាលទី២ រាជរដ្ឋាភិបាលកម្ពុជានឹងត្រួតពិនិត្យជាប្រចាំ នូវវឌ្ឍនភាពនៃសូចនាករទាំងឡាយ ។ ការត្រួតពិនិត្យនេះនឹងត្រូវដំណើរការជា៣កម្រិត ÷

- កម្រិត១: នាយកដ្ឋាននានានឹងធ្វើរបាយការណ៍ប្រចាំត្រីមាស ជូនគណៈកម្មាធិការកំណែទម្រង់ អំពី លទ្ធផលដែលសម្រេចបានធៀបនឹងគោលដៅដែលបានកំណត់ក្នុងផែនការសកម្មភាព ។ លើសពីនេះ ក៏ត្រូវត្រួត ពិនិត្យវឌ្ឍនភាពប្រចាំឆ្នាំផងដែរ ។
- កម្រិត២: ការបន្តត្រួតពិនិត្យជារៀងរាល់ត្រីមាសនូវគោលដៅសំខាន់ៗទាក់ទងនឹងសកម្មភាព សម្រាប់ ជំហាន ១ ដើម្បីរក្សាឱ្យបាននូវលទ្ធផលនៃកំណែទម្រង់ដំណាក់កាលទី១ និងកែលំអបន្ថែមទៀត ។
- កម្រិត៣: ការត្រួតពិនិត្យវឌ្ឍនភាពប្រចាំឆមាសនៃសូចនាករសំខាន់នានាក្នុងជំហាន២ ដើម្បីសម្រេចឱ្យ បាននូវគោលដៅនៃជំហាន២ ។ គោលបំណងនៃការត្រួតពិនិត្យនេះគឺ ដើម្បីពិនិត្យឡើងវិញអំពីវឌ្ឍនភាពនានា ដើម្បីឈានទៅសម្រេចបានគោលដៅនៃជំហាន២ ។

គោលដៅទី២០: អនុមតិច្បាប់ អនុក្រឹត្យនិងលិខិតបទដ្ឋានពាក់ព័ន្ធ ព្រមទាំងអនុវត្តផែនការប្រឆាំងនឹងអំពើ ហិង្សាគ្រប់ប្រភេទ ព្រមទាំងការជួញដូរស្ត្រី និងកុមារស្របតាមបទដ្ឋានអន្តរជាតិ ។

<u>សកម្មភាពចាំបាច់</u> : អនុមតិសេចក្តីព្រាងអនុក្រឹត្យស្តីពីការសំរេចចិត្តផ្នែករដ្ឋបាលស្តីពីអំពើហិង្សាក្នុងគ្រួសារ

៧៤- សេចក្តីព្រាងអនុក្រឹត្យនេះត្រូវបានរៀបចំដោយក្រសួងមហាផ្ទៃ ហើយបច្ចុប្បន្ន ត្រូវបានដាក់ជូនរាជ រដ្ឋាភិបាលដើម្បីអនុមតិ ។

<u>សកម្មភាពចាំបាច់</u> : អនុមតិសេចក្តីពាងច្បាប់ស្តីពីការលុបបំបាត់ការជួញដូរមនុស្ស និងការជួញដូរផ្លូវភេទ ស្រប តាមពិធីសារអង្គការសហប្រជាជាតិស្តីពីការជួញដូរមនុស្ស និងការជួញដូរផ្លូវភេទ និងសន្និសញ្ញាអង្គការសហ- ប្រជាជាតិស្តីពីឧក្រិដ្ឋកម្មឆ្លងដែន និងសេចក្តីព្រាងក្រមព្រហ្មទណ្ឌ

៧៥- ច្បាប់ស្តីការលុបបំបាត់ការជួញដូរមនុស្ស ស្របតាមពិធីសារអង្គការសហប្រជាជាតិស្តីពីការជួញដូរ មនុស្សត្រូវបានអនុមតិនាឆ្នាំ២០០៧ ។ លើសពីនេះ គោលការណ៍ណែនាំត្រូវបានរៀបចំដើម្បីគាំទ្រការអនុវត្តន៍ ច្បាប់នេះ ។ ប៉ុន្តែ

មានបញ្ហាប្រឈមមួយចំនួនក្នុងការអនុវត្តន៍ ។ ឧបសគ្គក្នុងការអនុវត្តន៍ច្បាប់នេះ មានលក្ខណៈ ស្មុគស្មាញ ។ ទោះបីជាគោលការណ៍ណែនាំក្នុងការអនុវត្តន៍ច្បាប់ត្រូវបានរៀបចំឡើង ប៉ុន្តែពុំទាន់មានផែនការ សកម្មភាពសម្រាប់អនុវត្តនៅឡើយ ។ ម្យ៉ាងទៀតដៃគូអភិវឌ្ឍន៍ក៏ពុំទាន់មានទស្សនៈឯកភាពគ្នាក្នុងការអនុវត្តន៍ ច្បាប់នេះទេ ។ នាពេលបច្ចុប្បន្ន ចំណាប់អារម្មណ៍បន្ទាន់គឺការរៀបចំក្របខណ្ឌគតិយុត្តិ សម្រាប់ករណី «រៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេស» ដែលបានក្លាយទៅជាការងារអាទិភាពថ្មីបន្ថែមទៀត ។

<u>សកម្មភាពចាំបាច់</u> : អនុវត្តផែនការសកម្មភាពជាតិស្តីពីការលុបបំបាត់អំពើហិង្សាលើស្ត្រី។ គោលដៅជាក់លាក់ សម្រាប់ឆ្នាំ២០០៧នេះគឺការបង្កើតក្រុមការងារនៅក្រសួងមហាផ្ទៃ សម្រាប់រៀបចំឯកសារបណ្តុះបណ្តាលនានា ដើម្បីអនុវត្តអនុក្រឹត្យនេះ

៧៦- ផែនការសកម្មភាពជាតិត្រូវបានរៀបចំ ហើយបច្ចុប្បន្ននេះ កំពុងពិភាក្សានៅទីស្តីការគណៈរដ្ឋមន្ត្រី ។ ទោះបីជាក្រុមការងារពុំទាន់បានបង្កើតជាផ្លូវការ ក៏វគ្គបណ្តុះបណ្តាលត្រូវបានរៀបចំ ដូចជាវគ្គស្តីពីការតស៊ូមតិ យុទ្ធនាការបង្កើនការយល់ដឹង និងការបណ្តុះបណ្តាលមន្ត្រីតុលាការ និងនគរបាលជាដើម ។

<u>សកម្មភាពចាំបាច់</u>: ពិនិត្យឡើងវិញអំពីគោលនយោបាយនិងបទបញ្ញត្តិស្តីពីអន្តោប្រវេសន៍ ។ គោលដៅជាក់លាក់ សម្រាប់ឆ្នាំ២០០៧ រួមមាន÷ ការអនុមតិឯកសារយុទ្ធសាស្ត្រស្តីពីអន្តោប្រវេសន៍ ដោយភ្ជាប់ការងារអន្តោប្រវេសន៍ ជាមួយនឹងការជួញដូរ ការរត់ពន្ធ និងច្បាប់ការងារ ព្រមទាំងកំណែទម្រង់ច្បាប់ និងបំពេញបន្ថែមការខ្វះចន្លោះ ខាងទិដ្ឋភាពច្បាប់ ដើម្បីការពារជនអន្តោប្រវេសន៍ ។

៧៧- ការត្រួតពិនិត្យលើកដំបូងត្រូវបានអនុវត្តចំពោះបញ្ហាអន្តោប្រវេសន៍ ។ ប៉ុន្តែ បញ្ហាប្រឈមគឺ យើងមិនទាន់មានគោលនយោបាយនិងយុទ្ធសាស្ត្រស្តីពីអន្តោប្រវេសន៍ និងកង្វះសមត្ថភាពនៃមន្ត្រីក្នុងក្រសួង កិច្ចការនារីចំពោះបញ្ហានេះ ។ នៅពេលដែលគោលនយោបាយអន្តោប្រវេសន៍ត្រូវបានរៀបចំ ការអនុវត្តន៍ ច្បាប់អន្តោប្រវេសន៍ក៏នឹងត្រូវចាប់ផ្តើមដែរ ។

\- - - - - - - -

Glossary of Aid Management Terms

វាក្យស័ព្ទប្រើប្រាស់ក្នុងការគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍

English definition	Khmer translation
General terms	**វាក្យស័ព្ទទូទៅ**
Country Analytic Work (CAW) Country analytic work (CAW) encompasses the analysis and advice necessary to strengthen policy dialogue, develop and implement country strategies in support of sound development assistance. Good analytic work is essential for well-focused development policy and programmes. It should include major pieces of analytical work such as: Diagnostic reviews (e.g. Country Procurement Assessment Report, Country Financial Accountability Assessments etc.). Country or sector studies and strategies. Country or sector evaluations. Cross-cutting analytical work such as gender assessments. ***Coordinated Country Analytic Work*** Coordinated country analytic work is: (i) CAW undertaken by one or more donor jointly; (ii) CAW undertaken by one donor on behalf of another donor (including work undertaken by one and/or used by another when it is co financed and formally acknowledged in official documentation); (iii) CAW undertaken with substantive involvement from government.	***ការសិក្សាវិភាគរបស់ដៃគូអភិវឌ្ឍន៍*** ការសិក្សាវិភាគរបស់ដៃគូអភិវឌ្ឍន៍រួមមាន ការវិភាគ និងការផ្តល់អនុសាសន៍ដែលចាំបាច់ ដើម្បីពង្រឹងការពិភាក្សាកម្រិតគោលនយោបាយ ការតាក់តែង និងអនុវត្តយុទ្ធសាស្ត្រប្រទេស ដោយមានការគាំទ្រហិរញ្ញប្បទានសហប្រតិបត្តិការ ។ ការសិក្សាវិភាគដែលមានលក្ខណៈត្រឹមត្រូវមានសារៈសំខាន់ សម្រាប់ការរៀបចំគោលនយោបាយ និងកម្មវិធីអភិវឌ្ឍន៍ឱ្យចំទិសដៅ ។ ការសិក្សាវិភាគរួមបញ្ចូលការពិនិត្យវិនិច្ឆ័យពីបញ្ហា (ដូចជារបាយការណ៍វាយតម្លៃប្រព័ន្ធលទ្ធកម្មរបស់ប្រទេស ការវាយតម្លៃគណនេយ្យភាពហិរញ្ញវត្ថុជាដើម) ។ យុទ្ធសាស្ត្រ និងការសិក្សាកម្រិតប្រទេស ឬកម្រិតវិស័យ ការវាយតម្លៃកម្រិតប្រទេស ឬកម្រិតវិស័យ និងការសិក្សាវិភាគពីបញ្ហាដែលមានចរិតអន្តរវិស័យ ដូចជាការវាយតម្លៃផ្នែកយេនឌ័រជាដើម) ។ ***ការសិក្សាវិភាគរបស់ដៃគូអភិវឌ្ឍន៍ដោយមានការសម្របសម្រួល*** គឺជាការសិក្សាដែល (១) បានធ្វើឡើងរួមគ្នាដោយដៃគូអភិវឌ្ឍន៍មួយ ជាមួយដៃគូអភិវឌ្ឍន៍ផ្សេងទៀត ឬ (២) បានធ្វើឡើងដោយដៃគូអភិវឌ្ឍន៍មួយ ក្នុងនាមដៃគូអភិវឌ្ឍន៍ផ្សេងទៀត (រាប់បញ្ចូលទាំងការសិក្សាដែលធ្វើឡើងដោយដៃគូអភិវឌ្ឍន៍មួយ និងត្រូវបានប្រើប្រាស់ដោយដៃគូអភិវឌ្ឍន៍ផ្សេងទៀត ក្នុងខណៈដែលដៃគូអភិវឌ្ឍន៍បានផ្តល់ហិរញ្ញប្បទានរួមគ្នាសម្រាប់រៀបចំការសិក្សានេះ និងបានទទួលស្គាល់ជាផ្លូវការ) (៣) ត្រូវបានធ្វើឡើងដោយមានការចូលរួមសម្របសម្រួលពីរាជរដ្ឋាភិបាល ។
Donor / Development Partner The funding agency or country making a financial commitment to the project from its core funds. Agencies who receive funds from others as part of a co-funded project are not donors (or are donors only for that portion of funding that they have contributed from their own core funds). Donors can be multilateral, bilateral and/or NGOs.	***ប្រទេសផ្តល់ហិរញ្ញប្បទាន- ដៃគូអភិវឌ្ឍន៍*** ជាភ្នាក់ងារឬប្រទេសដែលសន្យាផ្តល់ធនធានហិរញ្ញវត្ថុផ្ទាល់សម្រាប់គាំទ្រគម្រោង ។ ភាគីដែលទទួលហិរញ្ញប្បទានពីភាគីដទៃទៀត ក្រោមទម្រង់សហហិរញ្ញប្បទាន មិនមែនជាប្រទេសផ្តល់ហិរញ្ញប្បទានទេ (ឬគឺជាប្រទេសផ្តល់ហិរញ្ញប្បទានចំពោះតែចំណែកហិរញ្ញប្បទានដែលខ្លួនបានផ្តល់ផ្ទាល់ប៉ុណ្ណោះ) ។ ដៃគូអភិវឌ្ឍន៍អាចជាស្ថាប័នពហុភាគី ឬទ្វេភាគី និងអង្គការមិនមែនរដ្ឋាភិបាល ។
Implementing Partner The partner who receives funds from the donor. Implementing partners cannot commit or disburse funds (unless they are own core resources) according to the	***ភ្នាក់ងារអនុវត្តន៍*** ជាភាគីដែលទទួលហិរញ្ញប្បទានពីប្រទេសឬស្ថាប័នផ្តល់ហិរញ្ញប្បទាន ។ ភ្នាក់ងារអនុវត្តន៍មិនអាចធ្វើការសន្យា ឬប្រើប្រាស់ហិរញ្ញប្បទានបានឡើយ (លើកលែងតែធនធានផ្ទាល់)

English definition	Khmer translation
terminology used in the ODA Database. Disbursements from other sources should be recorded as such in Section IV.	យោងតាមវាក្យស័ព្ទដែលប្រើនៅក្នុងប្រព័ន្ធទិន្នន័យហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា ។ ហិរញ្ញប្បទានដែលបានមកពីប្រភពផ្សេងគួរតែកត់ត្រាចូលទៅក្នុងផ្នែកទី៤ ។
Paris Declaration on Aid Effectiveness An agreement brokered by the OECD/DAC and signed by over 100 donor and partner countries in 2005, designed to increase the impact and effectiveness of aid. The agreement is associated with 12 indicators of effectiveness, some of which are monitored locally. The agreement can be accessed on www.oecd.org.	***សេចក្តីថ្លែងការណ៍ក្រុងប៉ារីសស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ*** កិច្ចព្រមព្រៀង ដែលផ្តួចផ្តើមដោយអង្គការដើម្បីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងអភិវឌ្ឍន៍ និងបានចុះហត្ថលេខាដោយប្រទេសជាដៃគូ និងដៃគូអភិវឌ្ឍន៍ជាង១០០ប្រទេស និងស្ថាប័ននាឆ្នាំ២០០៥ មានគោលបំណងបង្កើនប្រសិទ្ធភាពនៃហិរញ្ញប្បទានសហ-ប្រតិបត្តិការ ។ នៅក្នុងកិច្ចព្រមព្រៀងមានសូចនាករ ១២ ដែលសូចនាករខ្លះត្រូវតាមដានក្នុងកម្រិតប្រទេសជាដៃគូ ។ សេចក្តីថ្លែងការណ៍ក្រុងប៉ារីសមាននៅក្នុងគេហទំព័រ www.oecd.org ។
Programme-Based Approach (PBA) Programme-based approaches (PBA) are a way of engaging in development cooperation based on the principles of coordinated support for a locally owned programme of development, such as a national development strategy, a sector programme, a thematic programme or a programme of a specific organisation. Programme based approaches share the following features: Leadership by the host country or organisation. A single comprehensive programme and budget framework. A formalised process for donor coordination and harmonisation of donor procedures for reporting, budgeting, financial management and procurement. Efforts to increase the use of local systems for programme design and implementation, financial management, monitoring and evaluation. Donors can support and implement programme-based approaches in different ways and across a range of aid modalities including budget support, sector budget support, project support, pooled arrangements and trust funds. In order to qualify as a PBA for purposes of the monitoring survey it is suggested that all 4 of the following criteria should be met: Criterion 1 Is the host country or organisation exercising leadership over the programme supported by donors? (Y/N) Criterion 2 Is a single comprehensive programme	***អភិក្រមគ្រប់គ្រងតាមកម្មវិធី*** អភិក្រមគ្រប់គ្រងតាមកម្មវិធីជារបៀបមួយដើម្បីចូលរួមក្នុងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ឈរលើគោលការណ៍សម្របសម្រួលការគាំទ្រដល់កម្មវិធីអភិវឌ្ឍន៍ ដែលផ្តួចផ្តើម និងដឹកនាំដោយប្រទេសជាដៃគូ ដូចជាយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ កម្មវិធីតាមវិស័យ ឬតាមប្រធានបទ និងកម្មវិធីរបស់ស្ថាប័ន ។ អភិក្រមគ្រប់គ្រងតាមកម្មវិធីមានចរិតលក្ខណៈរួមដូចតទៅ ÷ ភាពជាអ្នកដឹកនាំនៃប្រទេសជាដៃគូ ឬស្ថាប័ន កម្មវិធីអភិឌ្ឍន៍គ្រប់ជ្រុងជ្រោយ និងក្របខ័ណ្ឌថវិការួមមួយ យន្តការសម្របសម្រួលផ្លូវការ និងសុខដុមនីយកម្មនៃនីតិវិធីរបស់ដៃគូអភិវឌ្ឍន៍ ដូចជាការរៀបចំរបាយការណ៍ ថវិកាកម្ម ការគ្រប់គ្រងហិរញ្ញវត្ថុ និងលទ្ធកម្ម ។ ក្រៅពីនេះ ក៏មានកិច្ចប្រឹងប្រែងដើម្បីបង្កើនការប្រើប្រាស់ប្រព័ន្ធរបស់ជាតិ សម្រាប់រៀបចំកម្មវិធី ការអនុវត្តន៍ ការគ្រប់គ្រងហិរញ្ញវត្ថុ ការត្រួតពិនិត្យ និងវាយតម្លៃគម្រោង ។ ដៃគូអភិវឌ្ឍន៍អាចគាំទ្រ និងអនុវត្តអភិក្រមគ្រប់គ្រងតាមកម្មវិធី និងទម្រង់ការផ្សេងៗគ្នា ដូចជាការគាំទ្រថវិកា ការគាំទ្រថវិកាសម្រាប់វិស័យ ការគាំទ្រតាមគម្រោង ការបញ្ចូលធនធាន និងមូលនិធិរួមគ្នា ។ ក្នុងការធ្វើអង្កេតស្តីពីការអនុវត្តន៍សេចក្តីថ្លែងការណ៍ក្រុងប៉ារីសឆ្នាំ២០០៨ ដើម្បីចាត់ទុកថាជាអភិក្រមគ្រប់គ្រងតាមកម្មវិធី ត្រូវបំពេញល័ក្ខខ័ណ្ឌបួន ÷ ១- ភាពជាម្ចាស់របស់ប្រទេសជាដៃគូ ឬស្ថាប័នលើកម្មវិធីដែលគាំទ្រដោយដៃគូអភិវឌ្ឍន៍ ។ ២- មានកម្មវិធីគ្រប់ជ្រុងជ្រោយ និងក្របខ័ណ្ឌថវិការួមមួយ ។ ៣- មានយន្តការផ្លូវការដើម្បីសម្របសម្រួលរវាងដៃគូអភិវឌ្ឍន៍ និងការធ្វើសុខដុមនីយកម្ម

English definition	Khmer translation
and budget framework used? (Y/N) Criterion 3 Is there a formal process for donor coordination and harmonisation of donor procedures for reporting budgeting, financial management and procurement? (Y/N) Criterion 4 Does your support to the programme use at least two of the following local systems: (i) programme design, (ii) programme implementation, (iii) financial management and (iv) monitoring and evaluation? (Y/N) Donors are invited to review their portfolio of activities with a view to determining which of them meet all four of the above criteria (activities that meet less than four criteria do not qualify as ODA provided in support PBAs). For the purpose of the 2008 PD survey, direct budget support provided in support of PBAs is tracked separately from other PBA modality: Direct budget support provided in support of PBAs. Other assistance in support of programme-based approaches.	នីតិវិធីរបស់ដៃគូអភិវឌ្ឍន៍ ក្នុងការរៀបចំរបាយការណ៍ ការប្រើប្រាស់ថវិកា ការគ្រប់គ្រងហិរញ្ញវត្ថុ និងលទ្ធកម្ម ។ ៤- ដៃគូអភិវឌ្ឍន៍ប្រើប្រាស់នូវប្រព័ន្ធជាតិយ៉ាងតិច២ ក្នុងចំណោមប្រព័ន្ធខាងក្រោម ៖ ការរៀបចំកម្មវិធី ការអនុវត្តន៍កម្មវិធី ការគ្រប់គ្រងហិរញ្ញវត្ថុ ការត្រួតពិនិត្យនិងវាយតម្លៃ ។ ដៃគូអភិវឌ្ឍន៍គួរតែពិនិត្យសកម្មភាពក្នុងកញ្ចប់ហិរញ្ញប្បទានរបស់ខ្លួន ដើម្បីកំណត់ថាបានបំពេញលក្ខខ័ណ្ឌទាំង៤ខាងលើឬទេ (សកម្មភាពដែលបានបំពេញលក្ខខ័ណ្ឌតិចជាង ៤ ខាងលើមិនអាចចាត់ទុកថាជាហិរញ្ញប្បទានសហប្រតិបត្តិការដែលគាំទ្រដល់អភិក្រមគ្រប់គ្រងតាមកម្មវិធីឡើយ) ។ សម្រាប់ការធ្វើអង្កេតសេចក្តីថ្លែងការណ៍ក្រុងប៉ារីសឆ្នាំ ២០០៨ នេះដែរ ការគាំទ្រថវិកាដោយផ្ទាល់ដល់អភិក្រមគ្រប់គ្រងទូទាំងវិស័យ ត្រូវបានកត់ត្រាដាច់ដោយឡែកពីទម្រង់ការផ្សេងទៀតនៃអភិក្រមគ្រប់គ្រងតាមកម្មវិធី ដូចជាការផ្តល់ហិរញ្ញប្បទានក្នុងទម្រង់ការផ្សេងៗដើម្បីគាំទ្រដល់អភិក្រមគ្រប់គ្រងតាមកម្មវិធីណាមួយ ។
Project Implementation Unit When providing development assistance in a country some donors establish Project Implementation Units (They are also commonly referred to as project management units, project management consultants, project management offices, project coordination offices etc.). These are dedicated management units designed to support the implementation and administration of projects or programmes. PIUs typically share the following key features: PIUs are TYPICALLY required to perform subsidiary (rather than principal) tasks with regard to the implementation of a project or programme: monitoring and reporting on technical and/or financial progress, accounting, procurement of works, goods and services, drawing-up of terms of reference, contract supervision, detailed design or equipment specification. PIUs are often established at the request of a donor following the inception of a project or programme. The staff of PIUs vary considerably in size and composition. Staff size can vary from 1 to as many as 200 but most count less than 10 professional staff. Although a significant number	***អង្គភាពអនុវត្តន៍គម្រោង*** ក្នុងការផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការដល់ប្រទេសមួយ ដៃគូអភិវឌ្ឍន៍មួយចំនួនបង្កើតអង្គភាពអនុវត្តន៍គម្រោង (ឬហៅថា អង្គភាពគ្រប់គ្រងគម្រោង ទីប្រឹក្សាគ្រប់គ្រងគម្រោង ការិយាល័យគ្រប់គ្រងគម្រោង ការិយាល័យសម្របសម្រួលគម្រោង) ។ អង្គភាពទាំងនេះត្រូវបង្កើតឡើងដើម្បីគាំទ្រការអនុវត្តន៍ និងគ្រប់គ្រងកម្មវិធី ឬគម្រោង។ អង្គភាពអនុវត្តន៍គម្រោង មានចំណុចរួមដូចខាងក្រោម ៖ អង្គភាពត្រូវបានតម្រូវឱ្យអនុវត្តមុខងារបន្ទាប់បន្សំទាក់ទងនឹងការអនុវត្តន៍គម្រោងឬកម្មវិធី ដូចជាការត្រួតពិនិត្យ និងធ្វើរបាយការណ៍ស្តីពីវឌ្ឍនភាពផ្នែកបច្ចេកទេស ឬផ្នែកហិរញ្ញវត្ថុ កិច្ចការគណនេយ្យ លទ្ធកម្មសេវា ការរៀបចំលក្ខខ័ណ្ឌការងារ គ្រប់គ្រងកិច្ចសន្យានិងការរៀបចំចុះបញ្ជីសារពើភ័ណ្ឌ ។ អង្គភាពអនុវត្តន៍គម្រោងបង្កើតឡើងតាមសំណើរបស់ដៃគូអភិវឌ្ឍន៍ បន្ទាប់ពីបានចាប់ផ្តើមគម្រោង ឬកម្មវិធី ។ អង្គភាពអនុវត្តន៍គម្រោងនីមួយៗមានចំនួនបុគ្គលិក និងសមាសភាពខុសៗគ្នា ។ ចំនួនបុគ្គលិកអាចមានចាប់ពី ១ រហូតដល់ ២០០ ។ ប៉ុន្តែ ជាទូទៅ មានបុគ្គលិកគម្រោងតិចជាង ១០ នាក់ ។ ថ្វីត្បិតអង្គភាពអនុវត្តន៍គម្រោងជាច្រើនដំណើរការដោយមន្ត្រីរបស់រាជរដ្ឋាភិបាល អង្គភាពអនុវត្តន៍គម្រោងភាគច្រើនជួលបុគ្គលិកពីខាងក្រៅ (ដូចជាទីប្រឹក្សាក្នុងប្រទេសសម្រាប់រយៈពេលវែង) ។ អង្គភាពអនុវត្តន៍គម្រោង ខុសពីការផ្តល់ប្រឹក្សាបច្ចេកទេសដោយផ្ទាល់សម្រាប់រដ្ឋបាលថ្នាក់ជាតិ ។

English definition	Khmer translation
of PIUs make use of government staff, most PIUs are externally recruited (e.g. long-term local consultants). A distinction is made here between a PIU and technical advice provided directly to national administrations. ***Parallel PIU*** A PIU is parallel when it is created and operates outside existing country institutional and administrative structures at the behest of a donor. In practice, there is a continuum between parallel and integrated PIUs. The criteria below have been designed to help donors and partner authorities draw a line within this continuum and identify with greater certainty parallel PIUs. For the purpose of the 2008 PD survey, PIUs are said to be parallel when they meet at least three out of the four criteria set out below (anything less counts as integrated): Criterion 1: Are the PIUs accountable to the external funding agencies/donors rather than to the country implementing agencies (ministries, departments, agencies etc)? (Y/N) Criterion 2: Are the terms of reference for externally appointed staff determined by the donor (rather than by the country implementing agencies)? (Y/N) Criterion 3: Is most of the professional staff appointed by the donor (rather than the country implementing agencies)? (Y/N) Criterion 4: Is the salary structure of national staff (including benefits) higher than those of civil service personnel? (Y/N)	***អង្គភាពអនុវត្តន៍គម្រោងដាច់ដោយឡែក*** អង្គភាពអនុវត្តន៍គម្រោងដាច់ដោយឡែក ត្រូវបានបង្កើតឡើង និងដំណើរការខាងក្រៅរចនាសម្ព័ន្ធស្ថាប័ន និងរដ្ឋបាលដែលមានស្រាប់របស់រដ្ឋ ក្រោមការគ្រប់គ្រងរបស់ដៃគូអភិវឌ្ឍន៍ ។ តាមការអនុវត្តន៍ជាក់ស្តែង មានភាពខុសគ្នារវាងអង្គភាពអនុវត្តន៍គម្រោងដាច់ដោយឡែក ជាមួយនិងអង្គភាពអនុវត្តន៍គម្រោងដែលបានធ្វើសមាហរណកម្មជាមួយស្ថាប័នរដ្ឋ ។ លក្ខខណ្ឌខាងក្រោមជាជំនួយសម្រាប់ញែកឱ្យដាច់ពីគ្នានូវប្រភេទនានានៃអង្គភាពអនុវត្តន៍គម្រោង ពិសេសកំណត់អង្គភាពអនុវត្តគម្រោងដាច់ដោយឡែក ។ ក្នុងការធ្វើអង្កេតសេចក្តីថ្លែងការណ៍ក្រុងប៉ារីសឆ្នាំ២០០៨ អង្គភាពអនុវត្តន៍គម្រោង ត្រូវបានចាត់ទុកថាមានលក្ខណៈដាច់ដោយឡែក នៅពេលដែលបំពេញលក្ខខណ្ឌយ៉ាងតិចចំនួន ៣ នៃលក្ខខណ្ឌ ៤ ខាងក្រោម ។ ទី១- អង្គភាពអនុវត្តន៍គម្រោងទទួលខុសត្រូវ ចំពោះដៃគូអភិវឌ្ឍន៍ ឬភ្នាក់ងារផ្តល់មូលនិធិ ជាជាងទទួលខុសត្រូវចំពោះក្រសួង នាយកដ្ឋាន ឬភ្នាក់ងារនៃប្រទេសដៃគូ ។ ទី២- លក្ខខណ្ឌការងារនៃបុគ្គលិក ដែលបានជួលមកពីក្រៅត្រូវបានកំណត់ដោយដៃគូអភិវឌ្ឍន៍ជាជាងដោយស្ថាប័នប្រទេសដៃគូ ។ ទី៣- បុគ្គលិកភាគច្រើនត្រូវបានតែងតាំងដោយដៃគូអភិវឌ្ឍន៍ ជាជាងដោយស្ថាប័នប្រទេសដៃគូ ។ ទី៤- រចនាសម្ព័ន្ធ និងប្រាក់ខែរបស់បុគ្គលិកគម្រោង (រាប់បញ្ចូលទាំងផលលាភ) ខ្ពស់ជាងប្រាក់ខែរបស់មន្ត្រីរាជការ ។
Sector Sectoral classifications organize projects according to their spheres of societal endeavor. For example, "productive" sectors create economic value by generating and distributing goods and services. "Infrastructure" sectors provide the basic installations and facilities on which communities depend. "Social" sectors provide for the mental, physical, and spiritual well-being of individuals and their communities. "Environmental" sectors sustain the earth's physical and biological assets. "Governance" sectors guide and	***វិស័យ*** ការរៀបចំចំណាត់ថ្នាក់តាមវិស័យ គឺសម្រាប់បែងចែងគម្រោងទៅតាមគោលដៅដែលចង់ឱ្យគម្រោងសម្រេច ។ ឧទាហរណ៍ វិស័យផលិតកម្មបង្កើតតម្លៃសេដ្ឋកិច្ច តាមរយៈការផលិត និងការបែងចែកទំនិញ និងសេវាកម្ម ។ វិស័យហេដ្ឋារចនាសម្ព័ន្ធផ្តល់នូវមធ្យោបាយ និងឧបករណ៍គ្រឹះសម្រាប់ប្រើប្រាស់ក្នុងសហគមន៍ ។ វិស័យសង្គមកិច្ចផ្តល់សុខុមាលភាពផ្នែកចិត្តគំនិត កាយសម្បទា ព្រមទាំងស្មារតីដល់បុគ្គល និងសហគមន៍ទាំងមូល ។ វិស័យបរិស្ថានជួយរក្សាផែនដី ទាំងផ្នែករូបសាស្រ្ត និងជីវសាស្រ្តឱ្យបានគង់វង្ស ។ វិស័យអភិបាលកិច្ចជួយណែនាំ និងរៀបចំការងាររដ្ឋបាលរបស់ប្រទេស សហគមន៍ អង្គការ ឬសមាគមផ្សេងៗ ។ ការបែងចែកគម្រោងទៅតាម

English definition	Khmer translation
administer the affairs of a state, community, organization or association. Sectoral classifications help provide the social and economic benchmarks used to measure a programme or project's impact.	វិស័យ ជួយផ្តល់នូវលក្ខខ័ណ្ឌវិនិច្ឆ័យសង្គមនិងសេដ្ឋកិច្ច សម្រាប់ប្រើប្រាស់ក្នុងការវាយតម្លៃផលប៉ះពាល់នៃគម្រោង ឬកម្មវិធី ។
Missions Donor missions to the field are defined as missions that meet all of the following criteria: The mission is undertaken by, or on behalf of, a donor, including by consultants commissioned by a donor. The mission involved international travel typically, but not exclusively, from donor headquarters. The mission made a request to meet with government officials including local government. This definition should exclude missions undertaken by donors to attend events (workshops, conferences, etc.) that do not involve request to meet with government officials. ***Coordinated missions*** are: (i) missions undertaken by one or more donor jointly, or (ii) missions undertaken by one donor on behalf of another donor (delegated co-operation).	***បេសកកម្ម*** ដើម្បីកំណត់ជាបេសកកម្មដែលបញ្ជូនដោយដៃគូអភិវឌ្ឍន៍ ត្រូវគោរពលក្ខខ័ណ្ឌទាំងអស់ខាងក្រោម ។ បេសកកម្មធ្វើឡើងដោយ ឬក្នុងនាមដៃគូអភិវឌ្ឍន៍ រាប់បញ្ចូលទាំងជំនាញការដែលដៃគូអភិវឌ្ឍន៍ប្រគល់ការងារឱ្យធ្វើ ។ បេសកកម្ម ជាទូទៅ ពាក់ព័ន្ធនឹងការធ្វើដំណើរឆ្លងប្រទេស ដូចជាមកពីស្នាក់ការកណ្តាលរបស់ដៃគូអភិវឌ្ឍន៍ ។ បេសកកម្មស្នើសុំឱ្យមានកិច្ចប្រជុំជាមួយមន្ត្រីរាជរដ្ឋាភិបាល ដោយរួមទាំងនៅថ្នាក់មូលដ្ឋាន ។ និយមន័យនៃពាក្យបេសកកម្មនេះ មិនរាប់បញ្ចូលដំណើររបស់ដៃគូអភិវឌ្ឍន៍ក្នុងការចូលរួមសិក្ខាសាលា ឬសន្និសីទ ហើយពុំបានស្នើសុំជួបជាមួយមន្ត្រីរាជរដ្ឋាភិបាលឡើយ ។ ***បេសកកម្មដោយមានការសម្របសម្រួល*** គឺជា ÷ ១- បេសកកម្មដែលធ្វើឡើងដោយដៃគូអភិវឌ្ឍន៍មួយ ឬច្រើនរួមគ្នា ឬក៏ជា ២- បេសកកម្មធ្វើដោយដៃគូអភិវឌ្ឍន៍មួយ ក្នុងនាមដៃគូអភិវឌ្ឍន៍ផ្សេងទៀត
Official Development Assistance (ODA) Grants or Loans to countries and territories on Part I of the DAC List of Aid Recipients (developing countries) which are: (a) undertaken by the official sector; (b) with promotion of economic development and welfare as the main objective; (c) at concessional financial terms [if a loan, having a Grant Element of at least 25 per cent]. In addition to financial flows, Technical Co-operation is included in aid. Grants, Loans and credits for military purposes are excluded.	***ហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ផ្លូវការ*** ជាហិរញ្ញប្បទានឥតសំណង ឬជាកម្ចីសម្បទាន ដែលផ្តល់ដល់ប្រទេសទាំងឡាយដែលមានឈ្មោះនៅក្នុងផ្នែកទី ១ នៃបញ្ជីឈ្មោះប្រទេសទទួលជំនួយរបស់គណៈកម្មាធិការជំនួយអភិវឌ្ឍន៍ (ប្រទេសកំពុងអភិវឌ្ឍន៍) និងដែល ÷ ក- ផ្តល់ឱ្យវិស័យផ្លូវការ ។ ខ- មានគោលដៅចម្បងគឺការអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសុខុមាលភាពសង្គម ។ គ- ហិរញ្ញប្បទានមានលក្ខណៈសម្បទាន (ប្រសិនបើជាកម្ចី ត្រូវរួមមានសមាសធាតុឥតសំណងយ៉ាងតិចបំផុតស្មើ ២៥% នៃកម្ចី) ។ ក្រៅពីលំហូរហិរញ្ញប្បទាន កិច្ចសហប្រតិបត្តិការបច្ចេកទេសក៏ត្រូវរាប់បញ្ចូលជាហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ដែរ ។ ហិរញ្ញប្បទាន ទាំងឥតសំណង និងកម្ចីសម្រាប់គោលដៅយោធា មិនត្រូវបានរាប់បញ្ចូលជាហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ឡើយ ។
Project/program completion date Actual, if already completed, or planned completion date of the project/program.	***កាលបរិច្ឆេទបញ្ចប់គម្រោង/កម្មវិធី*** គឺជាកាលបរិច្ឆេទបញ្ចប់ជាក់ស្តែងនៃគម្រោង/កម្មវិធី ឬកាលបរិច្ឆេទដែលបានគ្រោងសម្រាប់បញ្ចប់គម្រោង/កម្មវិធី ។

English definition	Khmer translation
Project/program start date The actual start date of the implementation of the project/program. Sometimes the same as the project signature/commitment date although usually a few months after signing.	***កាលបរិច្ឆេទចាប់ផ្ដើមគម្រោង/កម្មវិធី*** ជាកាលបរិច្ឆេទជាក់ស្ដែងនៃការចាប់ផ្ដើមអនុវត្តគម្រោង/កម្មវិធី ។ នៅពេលខ្លះកាលបរិច្ឆេទចាប់ផ្ដើមអនុវត្តគម្រោង/កម្មវិធី ជាកាលបរិច្ឆេទនៃការចុះហត្ថលេខាលើគម្រោង បើទោះការអនុវត្តន៍ចាប់ផ្ដើមក្រោយកាលបរិច្ឆេទបន្តិចក៏ដោយ ។
Public Financial Management terms	**ពាក្យទាក់ទងនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**
Annual Budget The expenditure programme originally approved by the legislature.	***ថវិកាប្រចាំឆ្នាំ*** ជាកម្មវិធីចំណាយដែលអនុម័តដោយសភា ។
Commitment A firm written agreement by the donor to provide funds for a particular project or to a Trust Fund. The Commitment Date is the date of that written agreement. Commitments are usually multi-year – i.e., they are designed to fund expenditures for several years – but the total commitment is recorded in the year that the agreement is signed (even though disbursements may be projected to take place over a longer period).	***ការសន្យាផ្ដល់ហិរញ្ញប្បទាន*** ជាកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរជាក់លាក់មួយរបស់ដៃគូអភិវឌ្ឍន៍ ដោយសន្យាថានឹងផ្ដល់ហិរញ្ញប្បទានដល់គម្រោង ឬបញ្ចូលធនធានទៅក្នុងមូលនិធិរក្សាទុកណាមួយ ។ កាលបរិច្ឆេទនៃការសន្យាផ្ដល់ហិរញ្ញប្បទានជាកាលបរិច្ឆេទដែលបានធ្វើកិច្ចព្រមព្រៀង ។ ជាទូទៅ ក្នុងការសន្យាផ្ដល់ហិរញ្ញប្បទាន ការសន្យាធ្វើសម្រាប់រយៈពេលច្រើនឆ្នាំ មានន័យថាជាកម្មវិធីចំណាយរយៈពេលច្រើនឆ្នាំ ប៉ុន្តែ «ការសន្យាផ្ដល់ហិរញ្ញប្បទាន» សរុបត្រូវបានកត់ត្រានៅក្នុងឆ្នាំដែលកិច្ចព្រមព្រៀងបានចុះហត្ថលេខា (ទោះបីជាហិរញ្ញប្បទានអាចគ្រោងសម្រាប់ប្រើប្រាស់ក្នុងកំឡុងពេលវែងក៏ដោយ) ។
Concessional Loan The provision of funds by a donor as a loan which consists of a minimum 25 percent grant element, thus qualifying it as an ODA transaction. It is also commonly referred to as a "soft" loan.	***កម្ចីសម្បទាន*** ការផ្ដល់ហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ ក្នុងទម្រង់ជាកម្ចី ដែលក្នុងនោះ ហិរញ្ញប្បទានឥតសំណងយ៉ាងតិចស្មើនឹង២៥% ។ កម្ចីសម្បទានក៏ជាហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ផ្លូវការដែរ ។ កម្ចីសម្បទានអាចកំណត់ថាជាកម្ចី«ទន់» ផងដែរ ។
Disbursement The release of funds to, or the purchase of goods or services for, a recipient; by extension, the amount thus spent. Disbursements record the actual international transfer of financial resources, or of goods or services valued at the cost of the donor. The Disbursement Date is the date at which those funds were made available – usually this involves the transfer of funds into the implementer's bank account or the draw down by the implementer of funds held in an account by the donor.	***ការប្រើប្រាស់ហិរញ្ញប្បទាន*** ជាការបញ្ចេញហិរញ្ញប្បទាន ឬការទិញទំនិញ ឬសេវាផ្ដល់ឱ្យប្រទេសទទួលហិរញ្ញប្បទាន ។ ដៃគូអភិវឌ្ឍន៍ជាអ្នកទទួលខុសត្រូវក្នុងការផ្ទេរធនធានហិរញ្ញវត្ថុ ឬទំនិញ ឬសេវាកម្ម ។ កាលបរិច្ឆេទនៃការប្រើប្រាស់ហិរញ្ញប្បទាន គឺជាពេលដែលប្រទេសទទួលហិរញ្ញប្បទានទទួលបានហិរញ្ញប្បទានទាំងនោះ (ជាទូទៅ ជាពេលដែលហិរញ្ញប្បទានត្រូវបានផ្ទេរចូលក្នុងគណនីធនាគាររបស់អ្នកអនុវត្តន៍គម្រោង/កម្មវិធី ឬនៅពេលដែលអ្នកអនុវត្តន៍គម្រោងដកហិរញ្ញប្បទានចេញពីគណនីរបស់ដៃគូអភិវឌ្ឍន៍ ។
Fiscal Year Is the fiscal year of the country receiving ODA. The 12 months that covers a single budget cycle.	***ឆ្នាំសារពើពន្ធ*** គឺជាឆ្នាំសារពើពន្ធនៃប្រទេសដែលទទួលហិរញ្ញប្បទានអភិវឌ្ឍន៍ផ្លូវការ ដែលមានរយៈពេល១២ខែ ដែលគ្របដណ្ដប់មួយវដ្តនៃដំណើរការថវិកា ។

English definition	Khmer translation
Grant Transfers made in cash, goods or services for which no repayment is required	***ហិរញ្ញប្បទានឥតសំណង*** ការផ្ទេរហិរញ្ញប្បទានជាសាច់ប្រាក់ ទំនិញ ឬសេវាកម្ម ដោយពុំមានការទាមទារឱ្យសងវិញឡើយ ។
Grant Element Reflects the financial terms of a commitment: interest rate, MATURITY (q.v.) and grace period (interval to first repayment of capital). It measures the concessionality of a loan, in the form of the present value of an interest rate below the market rate over the life of a loan. Conventionally the market rate is taken as 10 per cent in DAC statistics. Thus, the grant element is nil for a loan carrying an interest rate of 10 percent; it is 100 per cent for a grant; and it lies between these two limits for a soft loan. If the face value of a loan is multiplied by its grant element, the result is referred to as the grant equivalent of that loan.	***សមាសធាតុឥតសំណង*** ឆ្លុះបញ្ចាំងពីល័ក្ខខ័ណ្ឌនៃហិរញ្ញប្បទាន ដូចជា អត្រាការប្រាក់ កាលកំណត់ត្រូវសង និងរយៈពេលអនុគ្រោះ (ចន្លោះពេលរហូតដល់ថ្ងៃកំណត់សងលើកដំបូង) ។ សមាសធាតុឥតសំណងត្រូវបានប្រើប្រាស់សម្រាប់វាយតម្លៃពីកម្រិតសម្បទាននៃកម្ចី ក្នុងរូបភាពជាតម្លៃបច្ចុប្បន្ននៃអត្រាការប្រាក់របស់កម្ចី ដែលត្រូវតែមានកម្រិតទាបជាងអត្រាការប្រាក់នៅលើទីផ្សារ ។ នៅក្នុងស្ថិតិរបស់ OECD/DAC អត្រាការប្រាក់ទីផ្សារត្រូវបានសន្មតស្មើនឹង ១0% ។ ដូចនេះ សមាសធាតុឥតសំណងមានតម្លៃស្មើសូន្យចំពោះកម្ចីដែលមានអត្រាការប្រាក់ ១0% និងស្មើ ១00% ចំពោះហិរញ្ញប្បទានឥតសំណង ។ សមាសធាតុឥតសំណងត្រូវស្ថិតនៅចន្លោះពី 0 ទៅ ១00% ។ ផលគុណនៃតម្លៃបច្ចុប្បន្នរបស់កម្ចីនិងអត្រាសមាសធាតុឥតសំណង គឺជាឥណទានដែលចាត់ជាហិរញ្ញប្បទានឥតសំណង ។
Loans (Credits) The provision of resources, excluding food or other bulk commodities, for relief or development purposes, including import procurement programmes, which must be repaid according to conditions established at the time of the loan agreement or as subsequently agreed.	***កម្ចី (ឥណទាន)*** ជាការផ្តល់ធនធានទាំងឡាយ (ដោយមិនរាប់បញ្ចូលម្ហូបអាហារ និងឧបករណ៍ប្រើប្រាស់ផ្សេងៗ) ក្នុងគោលបំណងជួយសង្គ្រោះ ឬសម្រាប់គោលដៅអភិវឌ្ឍន៍ ដោយរួមបញ្ចូលទាំងកម្មវិធីលទ្ធកម្មដែលត្រូវតែសងវិញទៅតាមល័ក្ខខ័ណ្ឌនៃកិច្ចព្រមព្រៀងកម្ចី ឬតាមការព្រមព្រៀងណាមួយក្រោយទៀត ។
National Auditing Procedures Donors rely on the audit opinions, issued by the country's supreme audit institution, on the government's normal financial reports/statements as defined above. The use of national auditing procedures means that donors do not make additional requirements on governments for auditing. For the purpose of the 2008 PD survey, national auditing mechanisms are used when the donor responds “Yes” to BOTH criteria below: 1. Are your funds subject to audit carried out under the responsibility of the Supreme Audit Institution? (Y/N) 2. You do NOT under normal circumstances request additional audit arrangements? (Yes, donors do	***នីតិវិធីសវនកម្មជាតិ*** ដៃគូអភិវឌ្ឍន៍ផ្អែកទៅលើជម្រើសអំពីសវនកម្មដែលផ្តល់ដោយស្ថាប័នសវនកម្មជាន់ខ្ពស់របស់ប្រទេស ឬរបាយការណ៍ហិរញ្ញវត្ថុរបស់រដ្ឋាភិបាល ។ ការប្រើប្រាស់ប្រព័ន្ធសវនកម្មជាតិ មានន័យថា ដៃគូអភិវឌ្ឍន៍មិនតម្រូវឱ្យរាជរដ្ឋាភិបាលធ្វើសវនកម្មមួយបន្ថែមទៀតឡើយ ។ ក្នុងការធ្វើអង្កេតសេចក្តីថ្លែងការណ៍ក្រុងប៉ារីសឆ្នាំ២00៨ ដៃគូអភិវឌ្ឍន៍ប្រើប្រាស់យន្តការសវនកម្មជាតិ នៅពេលដែលដៃគូអភិវឌ្ឍន៍ឆ្លើយតបវិជ្ជមានលើចំណុច (១) និង (២) និងឆ្លើយតបវិជ្ជមានយ៉ាងហោចណាស់មួយលើចំណុច (៣) និង (៤) ដូចខាង ក្រោម÷ ១- តើហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ស្ថិតក្រោមសវនកម្មរបស់ស្ថាប័នសវនកម្មជាន់ខ្ពស់របស់ជាតិឬទេ ? ២- តើក្នុងកាលៈទេសៈធម្មតា ដៃគូអភិវឌ្ឍន៍មិនតម្រូវឱ្យមានសវនកម្មបន្ថែមឡើយ?

English definition	Khmer translation
not require additional audits/No, donors do require additional audits) AND “Yes” to at least one of the criteria below: 3. You do NOT require audit standards different from those adopted by the Supreme Audit Institution? (Yes, donors do not require different audit standards/No, donors do require different audit standards) 4. You do NOT require the SAI to change its audit cycle to audit your funds? (Yes, donors do not require to change the audit cycle/No, donors do require change to the audit cycle)	៣- ដៃគូអភិវឌ្ឍន៍មិនតម្រូវឱ្យមានស្តង់ដារសវនកម្ម ដែលខុសគ្នាពីស្តង់ដារដែលកំណត់ដោយស្ថាប័នសវនកម្មជាន់ខ្ពស់ជាតិ ? និង ៤- ដៃគូអភិវឌ្ឍន៍មិនតម្រូវឱ្យស្ថាប័នសវនកម្មជាន់ខ្ពស់ជាតិ ផ្លាស់ប្តូរកាលបរិច្ឆេទទូទៅរបស់ស្ថាប័ន ដើម្បីតម្រូវជាមួយនឹងកាលបរិច្ឆេទសវនកម្មមូលនិធិរបស់ដៃគូអភិវឌ្ឍន៍ឡើយ ?
National Budget Execution Procedures Donors use national budget execution procedures when the funds they provide are managed according to the national budgeting procedures established in the general legislation and implemented by government. This means that programmes supported by donors are subject to normal country budgetary execution procedures namely procedures for authorisation, approval and payment. For the purpose of the 2008 PD survey, national budget execution procedures are used when answers yes to three out of the four criteria below (anything less does not qualify):1. Are your funds included in the annual budget approved by country legislature? (Y/N) 2. Are your funds subject to established country budget execution procedures? (Y/N) 3. Are your funds processed (e.g. deposited & disbursed) through the established country treasury system? (Y/N) 4. You do NOT require the opening of separate bank accounts for your funds? (Y/N)	***នីតិវិធីសម្រាប់ការគ្រប់គ្រងថវិការដ្ឋ*** ដៃគូអភិវឌ្ឍន៍ប្រើប្រាស់នីតិវិធីរដ្ឋសម្រាប់គ្រប់គ្រងថវិការដ្ឋ នៅពេលដែលហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ ត្រូវបានចាត់ចែងតាមនីតិវិធីគ្រប់គ្រងថវិការដ្ឋ ដែលមានកំណត់នៅក្នុងច្បាប់ និងអនុវត្តដោយរាជរដ្ឋាភិបាល ។ នេះមានន័យថាកម្មវិធីដែលគាំទ្រដោយដៃគូអភិវឌ្ឍន៍ ត្រូវគោរពតាមនីតិវិធីគ្រប់គ្រងថវិការដ្ឋរបស់រាជរដ្ឋាភិបាល ដូចជាការអនុញ្ញាតចំណាយ ការអនុម័ត និងចំណាយនានា ។ ក្នុងការធ្វើអង្កេតសេចក្តីថ្លែងការណ៍ក្រុងប៉ារីសឆ្នាំ២០០៨ យើងសន្មតថាដៃគូអភិវឌ្ឍន៍ប្រើប្រាស់នីតិវិធីគ្រប់គ្រងថវិការដ្ឋ ប្រសិនបើបានឆ្លើយជាវិជ្ជមានចំពោះល័ក្ខខ័ណ្ឌបីក្នុងចំណោមល័ក្ខខ័ណ្ឌទាំង ៤ គឺ (១) ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ត្រូវបានបញ្ចូលទៅក្នុងថវិការដ្ឋដែលបានអនុមតិដោយរដ្ឋសភា (២) មូលនិធិរបស់ដៃគូអភិវឌ្ឍន៍គោរពតាមនីតិវិធីគ្រប់គ្រងថវិការដ្ឋ (៣) មូលនិធិរបស់ដៃគូអភិវឌ្ឍន៍ត្រូវបានដំណើរការ (ដូចជាការតំកល់ និងការប្រើប្រាស់) តាមរយៈប្រព័ន្ធរតនាគារជាតិ និង (៤) ដៃគូអភិវឌ្ឍន៍មិនតម្រូវឱ្យបើកគណនីធនាគារដោយឡែកសម្រាប់ហិរញ្ញប្បទានឡើយ ។
National Financial Reporting Procedures Legislative frameworks normally provide for specific types of financial reports to be produced as well as periodicity of such reporting. The use of national financial reporting means that donors do not impose additional requirements on governments for financial reporting. In particular donors do NOT require: maintenance of a separate	***នីតិវិធីជាតិសម្រាប់រៀបចំរបាយការណ៍ហិរញ្ញវត្ថុ*** ជាធម្មតា ក្របខ័ណ្ឌច្បាប់ហិរញ្ញវត្ថុតម្រូវឱ្យរៀបចំរបាយការណ៍ហិរញ្ញវត្ថុជាច្រើនប្រភេទរាប់បញ្ចូលទាំងរបាយការណ៍ក្នុងពេលកំណត់ណាមួយ ។ ការប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុរដ្ឋមានន័យថា ដៃគូអភិវឌ្ឍន៍មិនតម្រូវឱ្យរាជរដ្ឋាភិបាលរៀបចំរបាយការណ៍ហិរញ្ញវត្ថុបន្ថែមទៀតទេ ។ ពិសេស ដៃគូអភិវឌ្ឍន៍មិនតម្រូវឱ្យរក្សាប្រព័ន្ធគណនេយ្យ ឬប្លង់គណនេយ្យដាច់ដោយឡែក ដើម្បីកត់ត្រាការប្រើប្រាស់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ ។

English definition	Khmer translation
accounting system to satisfy donor reporting requirements. Creation of a separate chart of account to record the use of donor funds. For the purpose of the 2008 PD survey, national financial reporting mechanisms are used when the donor responds "Yes" to both criteria below (anything less does not qualify):1. You do NOT require maintenance of a separate accounting system to satisfy your own reporting requirements? (Yes, you do not require a separate accounting system/No, you do require a separate accounting system)2. You ONLY require financial reports prepared using country's established financial reporting arrangements? (Y/N)	ក្នុងការធ្វើអង្កេតសេចក្តីថ្លែងការណ៍ក្រុងប៉ារីសឆ្នាំ២០០៨ ដៃគូអភិវឌ្ឍន៍ចាត់ទុកថា បានប្រើប្រាស់យន្តការនៃការធ្វើរបាយការណ៍ហិរញ្ញវត្ថុរដ្ឋ នៅពេលដែលបំពេញល័ក្ខខ័ណ្ឌដាច់ខាតទាំង២ គឺ (១)មិនតម្រូវឱ្យរក្សាប្រព័ន្ធគណនេយ្យមួយដាច់ដោយឡែក តាមតម្រូវការនៃនីតិវិធីរបស់ខ្លួន និង (២) តម្រូវឱ្យមានការរៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយប្រើនូវនីតិវិធីរៀបចំរបាយការណ៍ហិរញ្ញវត្ថុរដ្ឋ ។
National PFM procedures Disbursements of ODA for the government sector that use all three components of a country's national public financial management procedures, i.e.: (i) national budget execution procedures; (ii) national financial reporting procedures and (iii) national auditing procedures.	***នីតិវិធីជាតិសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ*** គឺជាការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការផ្លូវការ តាមវិស័យនានារបស់រាជរដ្ឋាភិបាល ដែលប្រើប្រាស់សមាសធាតុទាំងបីនៃនីតិវិធីគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺ (១) នីតិវិធីនៃការគ្រប់គ្រងថវិការដ្ឋ (២) នីតិវិធីរៀបចំរបាយការណ៍ហិរញ្ញវត្ថុរដ្ឋ និង (៣) នីតិវិធីសវនកម្មជាតិ ។
National Procurement Procedures Donors use national procurement procedures when the funds they provide for the implementation of projects and programmes are managed according to the national procurement procedures as they were established in the general legislation and implemented by government. The use of national procurement procedures means that donors do not make additional, or special, requirements on governments for the procurement of works, goods and services. (Where weaknesses in national procurement systems have been identified, donors may work with partner countries in order to improve the efficiency, economy, and transparency of their implementation).	***នីតិវិធីជាតិសម្រាប់លទ្ធកម្ម*** ដៃគូអភិវឌ្ឍន៍ប្រើប្រាស់ប្រព័ន្ធលទ្ធកម្មជាតិ នៅពេលដែលហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ សម្រាប់អនុវត្តគម្រោងនិងកម្មវិធី ត្រូវបានគ្រប់គ្រងតាមនីតិវិធីនៃប្រព័ន្ធលទ្ធកម្មជាតិ ដែលត្រូវបានអនុមតិដោយរដ្ឋសភា និងអនុវត្តដោយរាជរដ្ឋាភិបាល ។ ការប្រើប្រាស់ប្រព័ន្ធលទ្ធកម្មជាតិមានន័យថា ដៃគូអភិវឌ្ឍន៍មិនតម្រូវឱ្យរាជរដ្ឋាភិបាលប្រើប្រាស់ប្រព័ន្ធលទ្ធកម្មផ្សេងទៀតឡើយ ក្នុងការងារលទ្ធកម្មទំនិញ ឬសេវានានា(នៅពេលដែលប្រព័ន្ធលទ្ធកម្មជាតិនៅខ្សោយនៅឡើយ ដៃគូអភិវឌ្ឍន៍អាចធ្វើការជាមួយនឹងប្រទេសដៃគូ ដើម្បីបង្កើនប្រសិទ្ធភាពសេដ្ឋកិច្ច និងតម្លាភាពនៃការប្រើប្រាស់ប្រព័ន្ធទាំងនោះ) ។
Pledge The grant or loan resources indicated in a non-binding (often verbal) manner by a donor over one year or a fixed number of years. Often these sums are not associated with any particular project, which must be designed at a later time. A pledge is not	***ការប្រកាសផ្តល់ហិរញ្ញប្បទាន*** ជាការប្រកាសផ្តល់ធនធាន សម្រាប់រយៈពេលមួយឆ្នាំ ឬច្រើនឆ្នាំ ដែលជាទូទៅមិនភ្ជាប់កាតព្វកិច្ចរបស់ដៃគូអភិវឌ្ឍន៍ (ភាគច្រើនដោយផ្ទាល់មាត់) ។ ការប្រកាសផ្តល់គ្រាន់តែជាការផ្តល់ព័ត៌មាន និងពុំមានលក្ខណៈចាប់បង្ខំទេ ។ ហិរញ្ញប្បទានទាំងនេះមិនផ្តោត

English definition	Khmer translation
equivalent to a commitment and is treated as purely indicative.	លើគម្រោងជាក់លាក់ណាមួយនោះទេ ។ គម្រោងទាំងនោះចាំបាច់ត្រូវរៀបចំនៅពេលក្រោយមកទៀត ។ ការប្រកាសហិរញ្ញប្បទានពុំមានន័យដូចនឹងការសន្យាផ្តល់ហិរញ្ញប្បទានឡើយ ព្រោះនេះគ្រាន់តែជាការបង្ហាញតួលេខណែនាំប៉ុណ្ណោះ ។
Project/program budget The total resources committed to the project/program from all sources.	***ថវិការបស់គម្រោង និងកម្មវិធី*** ធនធានសរុបរបស់គម្រោង ឬកម្មវិធីដែលបានមកពីគ្រប់ប្រភពទាំងអស់ ។
Project/Program Status On-going – once the project document is signed and the project is operationally open. Completed – the project is operationally closed (financial closure is not necessary) Suspended – the activities of the project have been officially suspended at the request of one of the signatory parties. Pipeline - donor is identified and a concept paper or project document is being/has been drafted, with funding identified (but not committed).	***ស្ថានភាពគម្រោង/កម្មវិធី*** គម្រោងកំពុងដំណើរការ : នៅពេលដែលឯកសារគម្រោងត្រូវបានចុះហត្ថលេខា ហើយគម្រោងត្រូវបានចាប់ផ្តើមអនុវត្ត ។ គម្រោងត្រូវបានបញ្ចប់ : កិច្ចប្រតិបត្តិការរបស់គម្រោងត្រូវបានបញ្ឈប់ (ទោះបីជាមិនទាន់បិទបញ្ជីហិរញ្ញវត្ថុក៏ដោយ) ។ គម្រោងបង្អាក : សកម្មភាពនានារបស់គម្រោងត្រូវបានបង្អាកជាផ្លូវការ តាមសំណើរបស់ភាគីហត្ថលេខីណាមួយ ។ គម្រោងអាទិភាពខ្ពស់ : កំណត់ដៃគូអភិវឌ្ឍន៍សម្រាប់គាំទ្រ ហើយឯកសារទស្សនទាន ឬឯកសារគម្រោងត្រូវបានព្រាង ដោយមានការកំណត់ហិរញ្ញប្បទានច្បាស់លាស់ (ប៉ុន្តែពុំមានការសន្យាផ្តល់ហិរញ្ញប្បទាននៅឡើយ) ។
Types of ODA	***ប្រភេទហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ផ្លូវការ***
Technical Cooperation Includes both (a) grants to nationals of aid recipient countries receiving education or training at home or abroad, and (b) payments to consultants, advisers and similar personnel as well as teachers and administrators serving in recipient countries, (including the cost of associated equipment). Assistance of this kind provided specifically to facilitate the implementation of a capital project is included indistinguishably among bilateral project and programme expenditures, and not separately identified as technical co-operation in statistics of aggregate flows. ***Coordinated Technical Cooperation*** Coordinated technical cooperation means free standing and embedded technical cooperation that respects the following principles: Ownership -- Partner countries exercise effective leadership over their capacity	***កិច្ចសហប្រតិបត្តិការបច្ចេកទេស*** រួមមាន ÷ (ក) ហិរញ្ញប្បទានឥតសំណងដល់ប្រជាជននៃបណ្តា «ប្រទេសទទួលហិរញ្ញប្បទាន» ដូចជាការអប់រំ ឬការបណ្តុះបណ្តាលក្នុងប្រទេសនិងក្រៅប្រទេស និង (ខ) ចំណាយសម្រាប់ទីប្រឹក្សា ជំនាញការ និងបុគ្គលិកប្រហាក់ប្រហែលដទៃទៀត ព្រមទាំងគ្រូបង្រៀន បុគ្គលិករដ្ឋបាលដែលបម្រើការនៅក្នុងប្រទេសទទួលហិរញ្ញប្បទាន (ក្នុងនោះរួមមានការចំណាយលើសំភារៈបរិក្ខារផងដែរ) ។ ហិរញ្ញប្បទានប្រភេទនេះ ត្រូវបានផ្តល់ដើម្បីសម្រួលដល់ការអនុវត្តន៍គម្រោងវិនិយោគ និងត្រូវបានចាត់ទុកជាថវិកាចំណាយរបស់គម្រោង ឬកម្មវិធីរបស់ដៃគូអភិវឌ្ឍន៍ទ្វេភាគី ហើយមិនត្រូវចាត់ជាកិច្ចសហប្រតិ-បត្តិការបច្ចេកទេសនៅក្នុងស្ថិតិអំពីលំហូរធនធានទាំងមូលរបស់គម្រោងឡើយ ។ ***កិច្ចសហប្រតិបត្តិការបច្ចេកទេសដោយមានការសម្របសម្រួល*** ជាកិច្ចសហប្រតិបត្តិការបច្ចេកទេសសុទ្ធសាធ និងកិច្ចសហប្រតិបត្តិការបច្ចេកទេសដោយភ្ជាប់នឹងគម្រោងវិនិយោគ ដែលគោរពលក្ខខ័ណ្ឌដូចតទៅ÷ភាពជាម្ចាស់(ប្រទេសដៃគូជាអ្នកដឹកនាំលើកម្មវិធីអភិវឌ្ឍន៍សមត្ថភាព) ការតម្រឹម (កិច្ចសហប្រតិបត្តិការបច្ចេ

English definition	Khmer translation
development programmes. Alignment – Technical co-operation in support of capacity development is aligned with countries' development objectives and strategies. Harmonisation – Where more than one donor is involved in supporting partner-led capacity development, donors coordinate their activities and contributions. For the purpose of the 2008 PD survey, technical cooperation is coordinated when it meets: BOTH criteria below: Criterion 1: Have relevant country authorities (government or non-government) communicated clear capacity development objectives as part of broader national or sector strategies? (Y/N) Criterion 2 Is the technical cooperation aligned with the countries' capacity development objectives? (Y/N)AND at least one the criteria below: Criterion 3 Do relevant country authorities (government or non-government) have control over the Technical Cooperation? (Y/N) Criterion 4 If more than one donor is involved in supporting country programmes, are there arrangements involving the country authorities in place for coordinating the technical cooperation provided by different donors? (Y/N).	កទេសសម្រាប់គាំទ្រការអភិវឌ្ឍន៍សមត្ថភាព ត្រូវបានតម្រឹមជាមួយនឹងគោលដៅ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់ប្រទេស) សុខដុមនីយកម្ម (នៅពេលដែលមានដៃគូអភិវឌ្ឍន៍ច្រើនចូលរួមគាំទ្រការអភិវឌ្ឍន៍សមត្ថភាព ដៃគូអភិវឌ្ឍន៍ត្រូវសម្របសម្រួលសកម្មភាព និងធនធាន) ។ ក្នុងការធ្វើអង្កេតសេចក្តីថ្លែងការណ៍ក្រុងប៉ារីសឆ្នាំ២០០៨ ត្រូវចាត់ទុកជាកិច្ចសហ-ប្រតិបត្តិការបច្ចេកទេសដោយមានការសម្របសម្រួល នៅពេលដែលបំពេញល័ក្ខខ័ណ្ឌទី១ និងទី២ និងយ៉ាងហោចណាស់ល័ក្ខខ័ណ្ឌមួយនៃល័ក្ខខ័ណ្ឌទី៣ ឬទី៤ ។ ១- តើស្ថាប័នពាក់ព័ន្ធ (ទាំងរាជរដ្ឋាភិបាល និងក្រៅរដ្ឋាភិបាល) បានគូសបញ្ជាក់ច្បាស់លាស់អំពីគោលដៅនៃការអភិវឌ្ឍន៍សមត្ថភាពនៅក្នុងយុទ្ធសាស្ត្រជាតិ ឬវិស័យឬទេ ? ២- តើកិច្ចសហប្រតិបត្តិការបច្ចេកទេសត្រូវបានតម្រឹមជាមួយនឹងគោលដៅនៃការអភិវឌ្ឍន៍សមត្ថភាពរបស់រាជរដ្ឋាភិបាល ឬទេ ? ៣- តើស្ថាប័នពាក់ព័ន្ធ (ទាំងរាជរដ្ឋាភិបាល និងក្រៅរដ្ឋាភិបាល) ជាអ្នកគ្រប់គ្រងកិច្ចសហប្រតិបត្តិការបច្ចេកទេស ឬទេ ? ៤- ប្រសិនបើមានដៃគូអភិវឌ្ឍន៍ច្រើនចូលរួមគាំទ្រកម្មវិធី តើមានយន្តការសម្រាប់ស្ថាប័នរបស់រាជរដ្ឋាភិបាលសម្រាប់សម្របសម្រួលធនធានរបស់ដៃគូអភិវឌ្ឍន៍ ឬទេ ?
Free-standing Technical Cooperation The provision of resources aimed at the transfer of technical and managerial skills and know-how or of technology for the purpose of building up national capacity to undertake development activities, without reference to the implementation of any specific investment project(s). FTC includes pre-investment activities, such as feasibility studies, when the investment itself has not yet been approved or funding not yet secured.	***កិច្ចសហប្រតិបត្តិការបច្ចេកទេសសុទ្ធសាធ*** ជាការផ្តល់ប្រភពធនធានដែលមានគោលដៅផ្ទេរនូវបច្ចេកទេស បច្ចេកវិទ្យា និងជំនាញខាងការគ្រប់គ្រង និងចំណេះដឹង សំដៅអភិវឌ្ឍសមត្ថភាពជាតិ សម្រាប់ជម្រុញកិច្ចអភិវឌ្ឍន៍ ដោយពុំផ្តោតទៅលើការអនុវត្តន៍គម្រោងវិនិយោគជាក់លាក់ណាមួយឡើយ ។ កិច្ចសហប្រតិបត្តិការបច្ចេកទេសសុទ្ធសាធរួមបញ្ចូលបណ្តាសកម្មភាពមុនពេលវិនិយោគ ដូចជាការសិក្សាសមិទ្ធិលទ្ធភាពទាំងឡាយដែលត្រូវធ្វើមុនពេលអនុមតិគម្រោងវិនិយោគ ឬមុនពេលអនុមតិហិរញ្ញប្បទាន ។
Investment-related Technical Cooperation The provision of resources, as a separately identifiable activity, directly aimed at strengthening the capacity to execute specific investment projects (i.e. those that are associated with some material/tangible output). Included under ITC would be pre-	***កិច្ចសហប្រតិបត្តិការបច្ចេកទេសភ្ជាប់ជាមួយការវិនិយោគ*** ជាការផ្តល់ធនធានសំដៅពង្រឹងសមត្ថភាពដើម្បីអនុវត្តគម្រោងវិនិយោគជាក់លាក់ (ដូចជាធនធានសម្រាប់សម្រេចឱ្យបាននូវធាតុចេញជាក់ស្តែង) ។ កិច្ចសហប្រតិបត្តិការបច្ចេកទេសភ្ជាប់ជាមួយការវិនិយោគ ក៏រួមបញ្ចូលផងដែរនូវបណ្តាសកម្មភាពដែលត្រូវអនុវត្តមុនពេលចាប់ផ្តើមគម្រោងវិនិយោគ ។

English definition	Khmer translation
investment-type activities directly related to the implementation of an approved investment project.	
Investment Project/Programme Assistance The provision of financing, in cash or in kind, for specific capital investment projects, i.e., projects that create productive capital which can generate new goods or services. Also known as capital assistance. Investment project assistance may have a technical co-operation component.	***ហិរញ្ញប្បទានសម្រាប់គម្រោង/កម្មវិធីវិនិយោគ*** ជាការផ្តល់ហិរញ្ញប្បទានជាសាច់ប្រាក់ ឬជាវត្ថុសម្រាប់គម្រោងវិនិយោគមូលធន (គឺជាគម្រោងដែលបង្កើតមូលធនផលិតកម្មដែលអាចបង្កើតទំនិញ ឬសេវាកម្មថ្មី) ។ ជួនកាលគេហៅ«ហិរញ្ញប្បទានសម្រាប់គម្រោង/ កម្មវិធីវិនិយោគ» ថាជាហិរញ្ញប្បទានមូលធន ។ ហិរញ្ញប្បទាននេះអាចមានសមាសធាតុនៃកិច្ចសហប្រតិបត្តិការបច្ចេកទេសផងដែរ ។
Budget Support or Balance-of-Payments Support The provision of assistance which is not cast in terms of specific investment or technical co-operation projects but which is instead provided in the context of broader development programme and macro-economic objectives and/or which is provided for the specific purpose of supporting the recipient's balance-of-payments position and making available foreign exchange. This category includes non-food commodity input assistance in kind and financial grants and loans to pay for commodity inputs. It also includes resources ascribed to debt relief.	***ការគាំទ្រថវិកា ឬការគាំទ្រជញ្ជីងទូទាត់*** ជាការផ្តល់ហិរញ្ញប្បទាន ដែលមិនស្ថិតក្នុងបរិការណ៍នៃគម្រោងសហប្រតិបត្តិការបច្ចេកទេស ឬវិនិយោគណាមួយជាក់លាក់ ។ ប៉ុន្តែ គឺជាការផ្តល់ហិរញ្ញប្បទាន ក្នុងបរិការណ៍នៃកម្មវិធីអភិវឌ្ឍន៍ដ៏ទូលំទូលាយ និងមានគោលដៅម៉ាក្រូសេដ្ឋកិច្ច ឬក៏ផ្តល់សម្រាប់គោលដៅជាក់លាក់នៃការគាំទ្រដល់ជញ្ជីងទូទាត់នៃប្រទេសទទួលហិរញ្ញប្បទានព្រមទាំងធានាស្ថេរភាពនៃអត្រាប្តូរប្រាក់ ។ ហិរញ្ញប្បទានប្រភេទនេះរួមមានហិរញ្ញប្បទានដែលមិនមែនជាស្បៀងអាហារ តែជាវត្ថុ ឬជាសាច់ប្រាក់ និងកម្ចីដើម្បីទូទាត់ថ្លៃទំនិញ ។ ហិរញ្ញប្បទាននេះក៏រួមមានការលុបចោលបំណុលផងដែរ ។
Sector Budget Support For the purposes of the 2008 PD survey, sector budget support is a sub-category of direct budget support. Sector budget support means that dialogue between donors and partner governments focuses on sector-specific concerns rather than on overall policy and budget priorities.	***ការគាំទ្រថវិកាតាមវិស័យ*** ក្នុងការធ្វើអង្កេតសេចក្តីថ្លែងការណ៍ក្រុងប៉ារីសឆ្នាំ២០០៨ ការគាំទ្រថវិកាតាមវិស័យជាប្រភេទមួយនៃការគាំទ្រថវិកាផ្ទាល់ ។ ការគាំទ្រថវិកាតាមវិស័យមានន័យថា កិច្ចពិភាក្សារវាងដៃគូអភិវឌ្ឍន៍និងរាជរដ្ឋាភិបាលផ្តោតលើការគាំទ្រវិស័យជាក់លាក់ ជាជាងការគាំទ្រគោលនយោបាយទូទៅ និងអាទិភាពនៃថវិការដ្ឋ ។
Tied Aid ODA where procurement of the goods or services involved is limited to the donor country or to a group of countries which does not include substantially all developing countries. Tied Aid Credits are	***ហិរញ្ញប្បទានសហប្រតិបត្តិការភ្ជាប់ចំណង*** ជាហិរញ្ញប្បទាន ដែលការធ្វើលទ្ធកម្មទំនិញ ឬសេវាកម្ម ត្រូវដាក់កំហិតឱ្យទិញ ឬប្រើសេវាកម្មពីប្រទេសដៃគូអភិវឌ្ឍន៍ ឬក្រុមហ៊ុននៃប្រទេសមួយចំនួនប៉ុណ្ណោះ លើកលែង

English definition	Khmer translation
subject to certain disciplines concerning their concessionality levels, the countries to which they may be directed, and their developmental relevance so as to avoid using aid funds on projects that would be commercially viable with private finance, and to ensure that recipient countries receive good value. ***Untied Aid*** Official Development Assistance for which the associated goods and services may be fully and freely procured in substantially all countries. ***Partially Tied Aid*** Official Development Assistance (or Official Aid) for which the associated goods and services must be procured in the donor country or among a restricted group of other countries, which must however include substantially all developing countries.	ប្រទេសកំពុងអភិវឌ្ឍន៍ ។ ឥណទាននៃ «ហិរញ្ញប្បទានសហប្រតិបត្តិការភ្ជាប់លក្ខខ័ណ្ឌ» ត្រូវមានល័ក្ខខ័ណ្ឌមួយចំនួនពាក់ព័ន្ធនឹងកម្រិតនៃសម្បទាន ប្រទេសដែលត្រូវទិញ ឬប្រើសេវាកម្ម និងការអភិវឌ្ឍន៍ ។ លក្ខខ័ណ្ឌទាំងនេះគឺដើម្បីចៀសវាងការប្រើប្រាស់ហិរញ្ញប្បទានលក្ខណៈពាណិជ្ជកម្ម និងដើម្បីធានាថាប្រទេសទទួលហិរញ្ញប្បទាននឹងទទួលបានផលប្រយោជន៍ខ្ពស់ពីឥណទាននេះ ។ ***ហិរញ្ញប្បទានសហប្រតិបត្តិការគ្មានភ្ជាប់ចំណង*** ជាហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ផ្លូវការ ដែលក្នុងនោះ ទំនិញនិងសេវាកម្មអាចធ្វើលទ្ធកម្មដោយសេរី និងពេញលេញពីប្រទេសណាក៏បាន ។ ***ហិរញ្ញប្បទានសហប្រតិបត្តិការភ្ជាប់ល័ក្ខខ័ណ្ឌខ្លះ*** ជាហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ផ្លូវការ (ឬហិរញ្ញប្បទានសហប្រតិបត្តិការផ្លូវការ) ដែលក្នុងនោះ ទំនិញ និងសេវាកម្ម ត្រូវតែធ្វើលទ្ធកម្មនៅក្នុងប្រទេសដៃគូអភិវឌ្ឍន៍ ឬក្នុងចំណោមក្រុមប្រទេសកំណត់ ប៉ុន្តែ ក៏បានរាប់បញ្ចូលប្រទេសកំពុងអភិវឌ្ឍន៍ទាំងអស់ផងដែរ ។
Emergency and Relief Assistance The provision of resources aimed at immediately relieving distress and improving the well-being of populations affected by natural or man-made disasters. Food aid for humanitarian and emergency purposes is included in this category. Emergency and relief assistance is usually not related to national development efforts or to enhancing national capacity but is still included in the definition of ODA, although it is sometimes omitted from a narrower definition that relates to "core ODA".	***ជំនួយមនុស្សធម៌ និងសង្គ្រោះបន្ទាន់*** ជាការផ្តល់ហិរញ្ញប្បទាន ក្នុងគោលបំណងសម្រួលការលំបាក និងកែលំអសុខុមាលភាពរបស់ប្រជាពលរដ្ឋដែលទទួលរងគ្រោះពីគ្រោះធម្មជាតិ ឬគ្រោះមហន្តរាយដែលបង្កដោយមនុស្ស ។ ការផ្តល់ស្បៀងអាហារសម្រាប់មនុស្សធម៌ និងសង្គ្រោះបន្ទាន់ ក៏ត្រូវបានរាប់បញ្ចូលក្នុងហិរញ្ញប្បទានប្រភេទនេះដែរ ។ ជាទូទៅ ហិរញ្ញប្បទានសង្គ្រោះបន្ទាន់និងមនុស្សធម៌មិនពាក់ព័ន្ធទៅនឹងកិច្ចអភិវឌ្ឍន៍ជាតិ ឬការពង្រឹងសមត្ថភាពជាតិឡើយ ។ ទោះបីជាហិរញ្ញប្បទានប្រភេទនេះត្រូវកត់ត្រាថាជាហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍ផ្លូវការក៏ដោយ ក៏ហិរញ្ញប្បទាននេះផ្តោតតែលើគោលដៅមនុស្សធម៌ប៉ុណ្ណោះ គឺពុំបានផ្តោតទៅលើកិច្ចសហប្រតិបត្តិការដើម្បីអភិវឌ្ឍន៍ឡើយ ។
Food Aid (for Development purposes) The provision of food for human consumption for developmental purposes, including grants and loans for the purchase of food. Associated costs such as transport, storage, distribution, etc., are also included in this category, as well as donor-supplied, food-related items such as animal food and agricultural inputs related to food production, when these are part of a food aid programme.	***ហិរញ្ញប្បទានជាស្បៀងអាហារ*** ជាការផ្តល់ស្បៀងអាហារសម្រាប់ការប្រើប្រាស់របស់ប្រជាជន សំដៅបម្រើការអភិវឌ្ឍន៍ប្រទេស ។ ហិរញ្ញប្បទាននេះមាន ហិរញ្ញប្បទានឥតសំណង និងកម្ចីសម្រាប់ទិញស្បៀងអាហារ ។ ចំណាយរួមផ្សំដូចជាការដឹកជញ្ជូន ថ្លៃស្តុកទុក ការចែកចាយ ក៏រាប់បញ្ចូលក្នុងប្រភេទហិរញ្ញប្បទាននេះដែរ ។ ការឧបត្ថម្ភផ្សេងៗ ដូចជាចំណីសត្វ និងឧបករណ៍កសិកម្មសម្រាប់ផលិតស្បៀង ក៏ត្រូវរាប់បញ្ចូលក្នុងហិរញ្ញប្បទានប្រភេទនេះដែរ ប្រសិនបើកម្មវិធីផ្តល់ហិរញ្ញប្បទានគឺជាផ្នែកមួយនៃកម្មវិធីហិរញ្ញប្បទានស្បៀងអាហារ ។